# ដាក់គំនាប់ស្នេហ៍ ប្រពន្ធក្នុងនាម


សំបុត្រអាពាហ៍ពិពាហ៍ចងគេជាប់នឹងនាង តែមិនមែនជាស្នេហា...
ក្នុងខ្សែភ្នែករបស់មនុស្សគ្រប់គ្នា រួមទាំងគេ នាងជាស្រីទន់ជ្រាយ
ពិការជើងដែលត្រូវអង្គុយលើកៅអីរុញមួយជីវិត ទើបនាងគ្មានតម្លៃឲ្យគេយកភ្នែកមើល
ត្រូវលេបទឹកភ្នែកតែម្នាក់ឯង។
រហូតដល់ម្ដាយធ្លាក់ខ្លួនឈឺ និងត្រូវការឲ្យនាងរៀបការ
ហើយគេគឺជាបុរសដែលម្ដាយឃើញថាសក្តិសមនឹងនាង។
សម្រាប់ ម៉ាទិនេស ម៉ាឡេសាសស្វ ក្មេងស្រីក្បែរផ្ទះ
ដែលមានខ្លួនប្រាណស្រមេកស្រមកមិនធ្លាប់នៅក្នុងខ្សែភ្នែករបស់គេ
រហូតដល់ពេលវេលានាំមកឲ្យជួបគ្នាម្ដងទៀត ទោះនាងអង្គុយលើកៅអីរុញដដែល
ប៉ុន្តែបេះដូងរបស់គេបានធ្លាក់ទៅនៅនឹងចុងជើងរបស់នាងទៅហើយ។

"ហេតុអីក៏បន្លំធ្វើជាពិការជើង ?"
"វាជារឿងផ្ទាល់ខ្លួនរបស់ខ្ញុំ"
"វាក៏ជារឿងរបស់បង ព្រោះបងជាប្ដីរបស់អូន"
"គ្រាន់តែជាប្ដីក្នុងនាម"
"ដែលបងមិនធ្វើស្អីអូន ព្រោះឃើញអូនមិនរឹងមាំ តែចាប់ពីវិនាទីនេះទៅ
អូនត្រៀមខ្លួនទទួលយកភាពឆ្កួតកាមរបស់បងទៅ!"





Come to join us
www.facebook.com/yuveakvey
Tel:010687767


ឈុតបិសាចនៃម៉ាឡេសាសស្វ (អ៊ីតាលី)


រក្សាសិទ្ធ ហាមថតចំលងគ្រប់រូបភាព


ដាក់គំនាប់ស្នេហ៍ ប្រពន្ធក្នុងនាម

Ls521

S@rIkA




Scanned with CamScanner

# ១

"អ៊ាៗ...សាស្ត្រា...សាស្ត្រាចារ្យ...ម៉ាត...ម៉ោ...ម៉ោខាងណោះហើយ... អ៊ាៗៗ"

ឲ្យតែ ម៉ាទិនេស ម៉ាឡេសាសសូ បង្ហាញខ្លួនក្នុងមហាវិទ្យាល័យដែលខ្លួនជាម្ចាស់ផង ជាសាស្ត្រាចារ្យផង សំឡេងស្រែកបែបនេះរបស់ស្រីៗ ក៏បន្លឺឡើងជាប្រចាំ ឡើងគេស៊ាំទៅហើយ ទើបតែងញញឹមដាក់ពួកនាង និងដើរសំដៅបន្ទប់ធ្វើការ។

"សង្ហា សង្ហា..."

និសិត្សស្រីៗនាំគ្នាសរសើរចេញមុខចេញមាត់ពីសម្រស់សង្ហា ហាក់ដូចទេវបុត្ររបស់សាស្ត្រាចារ្យ។

"មែនហើយ...សង្ហាណាស់ ខ្ញុំមករៀននៅទីនេះ ព្រោះចង់នៅជិតគាត់"

"ដូចខ្ញុំដែរ មិនអីចឹងមិនម៉ោរៀនទីនេះទេ ថ្លៃសាលាថ្លៃ"

និសិត្សស្រីៗនាំគ្នានិយាយឆ្ការដៃឆ្ការជើង ហើយរហ័សលើកដៃបិទមាត់ទប់សំឡេងស្រែកក្រិត ពេលឃើញសាស្ត្រាចារ្យស្រីស្អាត ដែលមានដីក្រេជាអតីតនិសិត្សបរទេសដើរកាត់ល្មម។

"ពួកនាងមកឈរធ្វើស្អីនៅមុំនេះ មិនរៀនទេឬ?"

ជីយ៉ន បាញ់ភ្នែកដែលគួសដោយអាយឡៃនន័រដាក់និសិត្សស្រី ដោយការមិនពេញចិត្ត។

"ហើយជូតទឹកមាត់នៅតាមចង្កេកមាត់ចេញផង"



"សាស្ត្រាចារ្យ គីម...ពួកខ្ញុំគ្រាន់តែមកលួចមើលសាស្ត្រាចារ្យ ម៉ាត ប៉ុណ្ណោះ" និសិត្សស្រីម្នាក់អធិប្បាយ។

"មកលួចមើលធ្វើអី មិនដឹងឬយ៉ាងម៉េចថាសាស្ត្រាចារ្យ ម៉ាត របស់ពួកនាង ជិតរៀបការមិនប៉ុន្មានថ្ងៃនេះទៀត"

សំឡេងរបស់ ជីយ៉ន កាចប្លែកខុសពីធម្មតា។

"ខ្ញុំដឹងហើយ ពត៌មានល្បីសឹងអី"

"ដឹងហើយ កុំម៉ោរញ៉េរញ៉ៃនឹងសាស្ត្រាចារ្យ ម៉ាត ទៀត"

"ចាំ សាស្ត្រាចារ្យ គីម"

"ចាំ នាំគ្នាទៅៗ"

និសិត្សស្រីទាំងឡាយបណ្ដើរគ្នាចេញពីមុខអគារសាកលវិទ្យាធិការ។

"អាសទាំងក្មេងពួកនាងនេះ"

ជីយ៉ន រអ៊ូរទាំតាមពីក្រោយនិសិត្ស ដោយការមួម៉ៅ ហើយងាកទៅមើលអគារ សម្របទឹកមុខឲ្យធម្មតា ទើបដើរចេញទៅ។

"លោកនាយកមានបង្រៀនឬ?"

ពេលដើរចូលមក ហើយជួប ម៉ាទិនេស នៅតាមផ្លូវ ជីយ៉ន រាក់ទាក់ដោយសំឡេងពីរោះពិសា។

"បាទ"

"អីយ៉ា ស្មានថានៅផ្ទះ ត្រៀមខ្លួនធ្វើជាកូនកំលោះតើ"

ម៉ាទិនេស សើចញឹមៗ។

"កូនកំលោះដូចខ្ញុំមិនចាំបាច់ត្រៀមអីច្រើនទេ មានតែកូនក្រមុំប៉ុណ្ណោះដែលត្រូវត្រៀមច្រើន"



"មែនហ្នឹង ឮថាពិការផងមែនទេ" និយាយហើយ ជីយ៉ន ក៏លើកដៃបិទ

មាត់ ហើយក៏បួញមាត់បួញ.កកែពាក្យខ្លួនឯង "អុំ! ខ្ញុំសុំទោស ភ្លេចខ្លួន"

"បាទ មិនអីទេ ជារឿងពិត កូនក្រមុំរបស់ខ្ញុំអង្គុយលើកៅអីរុញ" ទឹកមុខរបស់ ម៉ាទិនេស នៅតែរាបស្មើ "ខ្ញុំសុំទៅសិនហើយ សាស្ត្រាចារ្យ គីម ត្រូវទៅត្រៀមខ្លួនចូលបង្រៀន"

គេដើរចេញទៅ តែត្រូវ ជីយ៉ន ស្រវាចាប់ដៃ ទើបអ្នកកំលោះមើលដៃសខ្ចី និងងើយមើលមុខរបស់នាង ទើប ជីយ៉ន ដឹងខ្លួន រហ័សដកដៃមកវិញ។

"សុំទោស"

ម៉ាទិនេស សើចញឹមៗ ប្រាប់ឲ្យដឹងថាមិនបានប្រកាន់។

"សាស្ត្រាចារ្យ គីម មានការអីនឹងខ្ញុំទៀតឬអត់ ?"

"ខ្ញុំចង់ដឹងរឿងខ្លះ តែមិនដឹងថាសួរទៅល្អឬអត់" នាងបង្ហាញឲ្យឃើញទឹកមុខលំបាកចិត្ត។

"សួរមកចុះ បើខ្ញុំឆ្លើយបាន ខ្ញុំនឹងឆ្លើយ"

នាងខ្ទឹបមាត់បន្តិច ហើយសួរ៖

"ហេតុអីលោកនាយក សម្រេចចិត្ត...រៀបការជាមួយកូនក្រមុំពិការជើង ទាំងដែលមានមនុស្សល្អគ្រប់ដប់ រង់ចាំឲ្យលោកនាយកជ្រើសរើស ?"

ពន្លឺភ្នែករបស់ ម៉ាទិនេស រាបស្មើ មើលមិនដឹងថាកំពុងមានអារម្មណ៍អី ប៉ុន្តែមុខមាត់នៅតែមានស្នាមញញឹមលម្អ។

"ព្រោះខ្ញុំចង់មើលថែគេ"

"ចង់មើលថែស្រីពិការ ដែលមួយថ្ងៃៗគិតតែអង្គុយលើកៅអីរុញ ?"

"បាទ ខ្ញុំចង់មើលថែគេ"

"តែខ្ញុំថា គេមិនសក្តិសមនឹងលោកនាយកអីបន្តិច" នាងបញ្ចេញគំនិតផ្ទាល់ខ្លួនដោយមានចេតនា "មនុស្សល្អឥតខ្ចោះដូចលោកនាយក គួរតែបានមនុស្សស្រីដែលល្អជាងនេះ..."



មុខមាត់របស់ ម៉ាទិនេស នៅតែមានស្នាមញញឹម សម្តីសម្តៅនៅតែសុភាពរាបសារទន់ភ្លន់។

"មនុស្សយើងមើលឃើញភាពល្អឥតខ្ចោះខុសគ្នា"

"យ៉ាងម៉េចដែរ ?"

"សម្រាប់ខ្ញុំ...យ្យូលី ល្អឥតខ្ចោះសម្រាប់ខ្ញុំ ហើយជាមនុស្សស្រីតែម្នាក់ដែលខ្ញុំត្រូវការមើលថែអស់មួយជីវិត"

ជីយ៉ន ស្ទើរតែមិនចង់ជឿអ្វីដែលបានឮ។

"ខ្ញុំថាលោកនាយកជំទាស់ចាស់ទុំមិនបានច្រើនជាង"

"ខ្ញុំមានគោលជំហររបស់ខ្លួនជានិច្ច ហើយបើមិនចូលចិត្ត ខ្ញុំមិនព្រមធ្វើជាដាច់ខាត"

"តែខ្ញុំថា..."

"ខ្ញុំសុំទៅសិនហើយ ត្រូវទៅបង្រៀន"

"អី...ចាំ"

ជីយ៉ន តាមមើល ម៉ាទិនេស ដោយខ្សែភ្នែកពោរពេញសោកស្តាយ។

"មីខ្វិននោះវាសក្តិសមត្រង់ណា ខ្ញុំទៅវិញទេដែលសក្តិសមនឹងគ្រប់គ្រងលោក លោកនាយក ម៉ាឡេសាសសូ"

នាងនិយាយខ្សឹបៗ ឯដៃទាំងពីរដែលដាក់ស្របដងខ្លួនក៏ក្តាប់ណែន ខ្សែភ្នែកមានតែភាពច្រណែនឫស្យា។



"អ្នកនាងរង់ចាំនៅក្នុងឡានទៅ ចាំខ្ញុំទៅប្រាប់លោក ម៉ាត ថាអ្នកនាងមករក"



Scanned with CamScanner

ហុងស៊ីល ស្រីបម្រើជំនិតអង្វរករចៅហ្វាយស្រី ដែលអង្គុយក្នុងឡានពណ៌ស។

"អត់ទេ ខ្ញុំចុះទៅរកបង ម៉ាត ដោយខ្លួនឯង"

"តែ..."

"ទៅយករទេះម៉ោ ខ្ញុំទៅរកបង ម៉ាត"

ការពិតនាងមិនចង់ជួបមុខគេទេ ប៉ុន្តែព្រោះត្រូវយកគំរូជំនូនសម្រាប់ជូនភ្ញៀវឲ្យ ម៉ាទិនេស ជ្រើសរើស ទើបមិនអាចបញ្ចៀសការប្រឈមមុខបាន។

"ក៏បាន"

ហុងស៊ីល គ្មានជម្រើស ទើបត្រូវធ្វើតាមបញ្ជារបស់ចៅហ្វាយស្រី ដោយមានអ្នកឡានជួយគ្រាហ៍ យ៉ូលី មកដាក់លើរទេះរុញ។ ពេលគ្រប់យ៉ាងរួចរាល់នាងក៏ងាកទៅបញ្ជាមនុស្សរបស់ខ្លួន។

"អ៊ំដើរលេងម្តុំនេះសិនទៅ បន្តិចទៀតខ្ញុំមកវិញ"

"ឲ្យខ្ញុំជួយរុញទៅទេអ្នកនាង?"

"មិនបាច់ទេ មាន បងហុងស៊ីល ម្នាក់បានហើយ អ៊ំទៅដើងលេងចុះ"

នាងញញឹមដាក់អ្នកបើកបរ ហើយងាកមករកអ្នកមើលថែ។

"ជួយយកថង់ដាក់អំណោយជូនភ្ញៀវមកផង នៅលើកៅអីដែលខ្ញុំអង្គុយ"

"ចាំ អ្នកនាង" ហុងស៊ីល ឱនទៅក្នុងឡាន យកថង់ក្រដាសពណ៌ "បានហើយអ្នកនាង"

"ហុចម៉ោ ខ្ញុំកាន់ខ្លួនឯង"

ហុងស៊ីល ហុចថង់ក្រដាសឲ្យចៅហ្វាយ ហើយរុញរទេះចូលក្នុងអគាររបស់មហាវិទ្យាល័យធំល្វឹងល្វើយនៅចំពោះមុខ ដែលជាជំនួញមួយទៀតរបស់



ក្រកូលមហាសេដ្ឋី ម៉ាឡេសាសស៊ូ។

"អ្នកនាងទាក់ទងលោក ម៉ាត បានហើយឬនៅ?"

ហុងស៊ីល សួរដោយចិត្តខ្វល់ខ្វាយ ព្រោះតាំងពីនៅលើឡាន ដែល យ៉ូលី ទាក់ទង ម៉ាទិនេស មិនបាន។

"នៅទេ តេរប៉ុន្មានដងក៏មិនលើក"

"ប្រហែលជាប់បង្រៀនទេដឹងអ្នកនាង"

នាងក្រមុំងក់ក្បាលជាការយល់ស្រប។

"អ៊ីចឹងនាំខ្ញុំទៅចាំបង ម៉ាត នៅបន្ទប់ធ្វើការរបស់គាត់ក៏បាន"

"ចាំ ប៉ុន្តែបន្ទប់ធ្វើការរបស់លោក ម៉ាត នៅឯណា?" ហុងស៊ីល ងាកឆ្វេងងាកស្តាំ។

"មែនហើយ ខ្ញុំក៏មិនដែលមកដែរ នេះជាលើកដំបូង"

តាមធម្មតានាងតែងតែគេចមុខពី ម៉ាទិនេស មានតែម្តងនេះប៉ុណ្ណោះដែលគេចមិនបាន ព្រោះជាបញ្ជារបស់ម្តាយ។

"អ៊ីចឹងអ្នកនាងរង់ចាំត្រង់នេះហើយ ចាំខ្ញុំទៅសួរនិសិត្សមួយក្រុមនោះ"

ហុងស៊ីល រុញរទេះដែលចៅហ្វាយស្រីអង្គុយ មកក្រោមដើមឈើធំដែលនៅជិតនោះមានបង់ថ្មជាងដប់។

"អឺម អរគុណ"

យ៉ូលី សើចញឹមៗ មើលអ្នកមើលថៃវ័យជាងសាបសិបឆ្នាំជាង ដែលដើរសម្តៅទៅនិសិត្សមួយក្រុម។ ហុងស៊ីល មើលថែនាងតាំងពីជួបឧបទ្ទវហេតុថ្មីៗ រហូតមកដល់ពេលនេះជិតដប់ឆ្នាំទៅហើយ ដែលធ្វើឲ្យនាង និង ហុងស៊ីល ស្និទ្ធស្នាលគ្នា។ ហុងស៊ីល មើលថែនាងបានល្អណាស់ មិនធ្លាប់មានអ្វីខ្វះចន្លោះ ដែលធ្វើឲ្យនាងស្រឡាញ់ ហុងស៊ីល ដូចបងស្រីម្នាក់។



"នេះនាងមកទើសទែងស្អីនៅត្រង់នេះ ?"

សំឡេងស្រួចរលែមរបស់ស្រីម្នាក់ ដែលមើលទៅមិនរួសរាយ បន្លឺឡើងនៅក្បែរខ្លួន ទើប យុ្យលី ដកខ្សែភ្នែកពីអ្នកមើលថៃ ដែលដើរទៅឆ្ងាយហើយ ផ្ទែង.កមើលអ្នកដែលសួរខ្លួន ទើបឃើញថាជាស្រីស្អាតម្នាក់ តែថាត់មុខក្រាស់ ដែលឈរសម្លក់សម្លឹងនាង។

"ខ្ញុំមានការនឹងអ្នកនៅទីនេះ ?"

ជីយ៉ន ជ្រឹមភ្នែកមើលស្រីស្អាតហាក់ដូចទេធីតា តែគួរឲ្យស្ដាយ ដែលខ្វិនជើង។

"និងអ្នកណា !"

យុ្យលី ខ្ទឹបបបូរមាត់ ប្រឹងទប់អារម្មណ៍ មិនឲ្យឆេះឆួលជាងនេះ។

"មិនពាក់ព័ន្ធនិងអ្នកនាងទេដឹង"

"នេះនាង !" ជីយ៉ន សម្លឹងនាង ហាក់ដូចចង់ស៊ីសាច់ហុតឈាម "ប្រាប់ម៉ោថាមកទីនេះធ្វើស្អី មករកអ្នកណា ?"

"ខ្ញុំប្រាប់ហើយថា មិនពាក់ព័ន្ធនិងអ្នកនាង"

ជីយ៉ន មើលអ្នកដែលអង្គុយលើរទេះរុញ ដោយការរករឿង បន្ទាប់មកក៏មើលថង់ក្រដាសនៅលើភ្លៅរបស់ស្រីពិការ ហើយញញឹមចំអក។

"កុំប្រាប់ណាថានាងគឺ..." ជីយ៉ន ស្ទើរទប់សំណើចមិនជាប់ "កូនក្រមុំខ្វិនរបស់លោកនាយក ម៉ាឡេសាសសូ"

យុ្យលី រាប់មួយដល់មួយរយនៅក្នុងចិត្ត មិនអីចឹងមុខជាមានរឿងនឹងស្រីស្អាតតែសម្បកក្រៅមិនខាន។

"បើមែន តើយ៉ាងម៉េច ?"

"មិនយ៉ាងម៉េចទេ" ជីយ៉ន សម្លឹងមើល យុ្យលី តាំងពីក្បាលដល់ចុងជើង



ដោយការប្រមាថ "ខ្វិនៗបែបនេះ ធ្វើស្អីបាន"

"នាងនិយាយបែបនេះ ចង់មានន័យយ៉ាងម៉េច ?"

"គឺមានន័យ..." ជីយ៉ន ញញឹមបានគួរឲ្យទះផ្កាប់មុខ "គឺយប់ផ្សំដំណេកកូនកំលោះប្រហែលមិនប៉ះពាល់ទេដឹង"

សម្ដីរបស់ស្រីនៅចំពោះ លើសកាំបិតចាក់ចំបេះដូងឲ្យឈឺទៅទៀត យុ្យលី ឈឺ ប៉ុន្តែព្យាយាមលាក់ទឹកមុខ ហើយស្រីនៅចំពោះមុខគិតតែញញឹម។

"ប៉ះពាល់ឬមិនប៉ះពាល់ អ្ននាងមិនចាំបាច់ច្រណែនទេ ព្រោះយ៉ាងណាក៏អ្នកនាងគ្មានថ្ងៃទទួលបានសិទ្ធិនេះដែរ បង ម៉ាត ជ្រើសរើសខ្ញុំជាកូនក្រមុំយើងនឹងរស់នៅជាមួយគ្នាមួយជីវិត"

ជីយ៉ន ញ័រខ្លួនដូចខ្មោចចូលដោយភាពឫស្យា តែមិនព្រមឈប់ត្រឹមហ្នឹង។

"គ្មានប្រុសណាគេជ្រើសរើសនៅជាមួយស្រីខ្វិនទេ បើមិនត្រូវបង្ខំ"

យុ្យលី ភាំងនិយាយមិនចេញ ព្រោះសម្ដីរបស់ស្រីនៅចំពោះ វាចាក់ត្រូវចំណុចខ្លាំងណាស់ ដែលវាជាមន្ទិលជាប់នៅក្នុងបេះដូងរបស់នាង។

"វាមិនមែនជារឿងរបស់នាង"

ជីយ៉ន មកមើលដោយខ្សែភ្នែកវេទនា។

"ទោះស្អាតដូចទេធីតាយ៉ាងណា បើខ្វិនជើង ត្រូវមើលថែមួយជីវិតដូចនាង មិនលើសពីបីខែ ខ្ញុំនឹងបានដំណឹងលែងលះរបស់នាង និងលោកនាយកម៉ាឡេសាសសូ មិនខាន"

"គ្មានផ្លូវទេ"

"ខ្ញុំនឹងរង់ចាំមើល អូ្ន...ភ្លេចប្រាប់ ទីនេះលោកនាយក ម៉ាឡេសាសសូ



"ខ្ញុំនឹងរង់ចាំមើល... ប្រយ័ត្ន ល្បីណាស់ ស្រីៗ ទាំងមានប្ដី ទាំងនៅទំនេរសុទ្ធតែប៉ងលោកនាយក ប្រយ័ត្ន

ប្ដីឲ្យបានល្អទៅ"

យូលី ស្ទើរតែទប់ទោសៈលែងជាប់ទៅហើយ នាងក្ដាប់ដៃណែន ធ្វើឲ្យថង់ក្រដាសនៅក្នុងដៃចង់រហែក។

"រួមទាំងនាងដែរមែនទេ ?"

ជីយ៉ន ញាក់ស្មាបន្តិច ព្រមទាំងញញឹមបេះបួយ ហើយឆ្លើយដោយមិនញញើត។

"ប្រាកដហើយ សង្ហានិងជាអ្នកមានដូចលោកនាយក ម៉ាឡេសាសស្រីណាមើលរំលង មានតែភ្លើសុទ្ធ"

អ្នកស្ដាប់មានតែកំហឹង ទឹកភ្នែករកកល់ចង់រលីងរលោង ចង់មកបកអាក្រាតការខូចចិត្តរបស់ខ្លួនឲ្យបាន សំណាងល្អដែល ហុងស៊ីល រត់មកដល់ល្មម។

"មានរឿងអីឬអ្នកនាង ?"

"គ្មានអីទេ គ្រាន់តែជាឆ្កែព្រុសមួយក្បាល"

"នាងថាអ្នកណា មីកូនក្រមុំខ្ទិន ?" ជីយ៉ន សួរដោយការរករឿង។

"ហើយនាងគិតថាខ្ញុំថាឲ្យអ្នកណា ?"

"នេះនាង..."

"កុំចូលម៉ោ មិនអីចិងស៊ីកំផ្លៀងមិនខាន !"

ហុងស៊ីល ចូលមកពាំង ពេលឃើញ ជីយ៉ន ប្រុងធ្វើបាបថៅហ្វាយរបស់ខ្លួន។

"ថៅហ្វាយឲ្យដៃ កញ្ចះឡើងចាង ចាំមើលគូទឆ្នាំងមិនទាន់ខ្មៅផងក៏ត្រូវប្ដីទាត់ចោល ជឿខ្ញុំទៅ"

ជីយ៉ន សើចដោយការពេញចិត្តហើយ ក៏ធ្វើឆើយ ដើរចេញទៅ។



ហុងស៊ីល អង្គុញជើងក្បែរថៅហ្វាយ ដោយការព្រួយបារម្ភ៖

"អ្នកនាងកុំទៅស្ដាប់ស្រីមាត់ក្រហមនោះប៉ប៉ោច យើងចូលទៅរកលោក ម៉ាត ទៅ ខ្ញុំដឹងហើយថាបន្ទប់ធ្វើការរបស់លោក ម៉ាត នៅឯណា"

"ខ្ញុំចង់ទៅវិញហើយ"

"ហេតុអីអ្នកនាង ?" អ្នកមើលថែបើកភ្នែកធំៗ។

"ខ្ញុំគ្មានអារម្មណ៍ទេ ចង់ទៅផ្ទះវិញ"

ការខូចចិត្ត ដោយសារសម្ដីប្រមាថមើលងាយរបស់មនុស្សស្រីមិនស្គាល់ឈ្មោះម្នាក់នោះ ធ្វើឲ្យនាងឈឺចាប់។ នាងអាចដៅបានថា ម៉ាទិនេស គួរតែស្គាល់មនុស្សស្រីម្នាក់នោះច្បាស់ មិនអីចឹងនាងមិនហ៊ានតមាត់ត.កនឹងនាងបែបនេះទេ។

"តែលោកស្រីបញ្ជាថា ត្រូវឲ្យលោក ម៉ាត ជួយសម្រេចចិត្តរឿងនេះ"

"ប្រាប់ម៉ាក់ទៅថា បង ម៉ាត រើសរួចហើយ"

"តែ..."

"ខ្ញុំទទួលខុសត្រូវរឿងនេះ បងគ្រាន់តែនាំខ្ញុំទៅផ្ទះវិញទៅបានហើយ"

ទោះមានអារម្មណ៍ថា ការងារដែលបញ្ជាមិនទាន់រួចរាល់ ប៉ុន្តែពេលឃើញទឹកមុខសោកសៅរបស់ យូលី ហើយ ហុងស៊ីល ក៏អត់មិនបាននឹងអាណិត ទើបត្រូវធ្វើតាមចិត្តថៅហ្វាយ។

"អឹម"

ហើយ យូលី ក៏ស្ងាត់មាត់រហូត នៅតាមផ្លូវក៏ថាត្រូវបបួលងាកមើលនេះមើលនោះ ក៏នាងមិនចាប់អារម្មណ៍។

ព្រោះតែបែបនេះហ្នឹងអី ទើបនាងជឿថា ម៉ាទិនេស ព្រមរៀបការជាមួយនាង ព្រោះតែក្ដីស្រឡាញ់ មែនហើយ...វាគ្មានផ្លូវជាក្ដីស្រឡាញ់បាន ក្នុងពេល



ដែលនាងគ្មានអ្វីសក្តិសមនឹងបុរសល្អឥតខ្ចោះដូចគេ គ្មានអីបន្តិច។

ទឹកភ្នែកហូរម្តងទៀត ដោយមិនអាចទប់បាន។ នាងគួរតែបដិសេធមង្គលការនេះ បដិសេធសំណូមពររបស់ម្តាយ ដែលកំពុងធ្លាក់ខ្លួនឈឺ តែនាងមិនអាចធ្វើបាន។ នាងលង់ស្នេហ៍ ម៉ាទិនេស យូរមកហើយ យូរដល់ថ្នាក់ចាំមិនបានថាតាំងពីពេលណា តែងតែលួចមើលគេ តែងតែព្រួយបារម្ភគេពីចម្ងាយ... មែនហើយ បានត្រឹមតែធ្វើពីចម្ងាយប៉ុណ្ណោះ ព្រោះនាងពិការជើង។

កាលពីជិតដប់ឆ្នាំមុន នាង និងឪពុករបស់នាងទៅស្ទូចត្រីនៅបឹងទន្លេសាបមួយនៅប្រទេសអ៊ីតាលី ដែលជាកន្លែងឪពុកចូលចិត្តទៅខ្លាំង ថ្ងៃនោះម្តាយរវល់ជាប់ទៅជប់លៀងជាមួយម្តាយរបស់ ម៉ាទិនេស ទើបនាងត្រូវទៅជាមួយឪពុកតែពីរនាក់។ គ្រប់យ៉ាងរលូន រហូតដល់ពេលត្រឡប់មកវិញ ភ្លៀងធ្លាក់ខ្លាំង ហើយក៏ធ្វើឲ្យកើតសោកនាកម្មដ៏សាហាវបំផុតនៅក្នុងជីវិតរបស់នាង។

ឪពុករបស់នាងស្លាប់នៅក្នុងរថយន្ត ខណៈដែលនាងសន្លប់សន្លិនមិនដឹងខ្លួន ពេលភ្ញាក់ដឹងខ្លួន ក៏នាំយកភាពពិការ ដែលនរកបញ្ជូនមកឲ្យ ប៉ុន្តែប៉ុណ្ណឹងមិនស្មើនឹងការដែលត្រូវបាត់បង់បុរស ដែលស្រឡាញ់នាងខ្លាំងបំផុតនៅក្នុងលោកនេះ។

កន្លងផុតទៅយូរមកហើយនិងការឈឺចាប់ ដែលទទួលបាន ហើយវាក៏ធ្វើឲ្យនាង ត្រូវចេញពីសាលារៀនធម្មតា មករៀននៅផ្ទះតែម្នាក់ឯងជាមួយគ្រូដែលជួលមក។ ជាច្រើនដង ដែលនាងចង់លាចាកពិភពលោកនេះ ជាច្រើនដងដែលចង់ឈប់ដកដង្ហើម ប៉ុន្តែព្រោះមានម្តាយ ម្តាយដែលខូចចិត្តនឹងការចាកចេញទៅរបស់ឪពុកយ៉ាងទាន់ហន់ ម្តាយដែលប្រហែលជាស្លុតដល់ថ្នាក់ដាច់ខ្យល់ស្លាប់ បើត្រូវបាត់បង់នាងម្នាក់ទៀត ដូច្នេះហើយទើបនាងសុខចិត្តមានខ្យល់ដង្ហើមរស់នៅបន្តមកដល់សព្វថ្ងៃនេះ ក្នុងសភាពជាស្រីពិការរស់នៅ



ជាមួយរទេះរុញគ្រប់ពេលវេលា។

ទឹកភ្នែកស្រក់លើថង់ក្រដាស ដែលដាក់គំរូអំណោយជូនពេលទទួលភ្ញៀវ ទើបនាងរហ័សបន្លប់ដោយទឹកមុខរាបស្មើ ដើម្បីកុំឲ្យមានអ្នកណាដឹង។ គ្មានអ្នកណាដឹងថានាងមានអារម្មណ៍យ៉ាងណា ក្រៅពី ហុងស៊ុល អ្នកមើលថែជំនិត។

"កុំទៅស្តាប់សម្តីរបស់ស្រីប៉ិនប្រណែនម្នាក់នេះ យ៉ាងណាក៏លោក ម៉ាត សម្រេចចិត្តជ្រើសរើសអ្នកនាងរួចទៅហើយ"

យ៉ូលី ញញឹមឡកឡឺយខ្លួនឯង ទឹកមុខទទេស្អាត គ្មានអារម្មណ៍អី។

"បងក៏ដឹង ដូចដែលខ្ញុំដឹងមិនអីចឹង..." នាងងាកមកមើលអ្នកមើលថែ "ថាហេតុអីបានជាបង ម៉ាត ព្រមរៀបការជាមួយខ្ញុំ"

"ព្រោះលោក ម៉ាត អាណិតស្រឡាញ់អ្នកនាងហ្នឹងអី"

នាងក៏ចង់គិតអីចឹង ចង់គិតថា ម៉ាទិនេស ព្រមរៀបការនឹងនាង ព្រោះតែក្តីស្រឡាញ់ ប៉ុន្តែវាមិនដូចការប្រាថ្នារបស់នាង ព្រោះការពិតទៅ ម៉ាទិនេស ព្រមរៀបការជាមួយនាង ព្រោះមិនអាចជំទាស់បញ្ជារបស់ក្រុមគ្រួសារបាន។

"ព្រោះបង ម៉ាត ជំទាស់បញ្ជារបស់អ៊ំស្រីមិនបានទៅវិញទេ"

"ខ្ញុំថាមិនមែនទេ ព្រោះខ្សែភ្នែករបស់លោក ម៉ាត ដែលមើលមកអ្នកនាងរបស់ខ្ញុំ មានតែការព្រួយបារម្ភ"

អ្នកដែលមានកំណួចនៅក្នុងចិត្ត នៅតែញញឹមចំអកខ្លួនឯង។

"គ្រាន់តែព្រួយបារម្ភជើងពិការរបស់ខ្ញុំ"

"តែតាមដែលខ្ញុំដឹង លោក ម៉ាត ជាបុរសមឺសៗ ស្ងៀមៗក៏ពិតមែន ប៉ុន្តែមានចរិតមិនព្រមបុះញ៉មអ្នកណា អ្វីដែលមិនចូលចិត្តគឺបដិសេធ គ្មានផ្លូវព្រមធ្វើតាមអ្នកណា ហើយរឿងមង្គលការនេះ គឺជារឿងធំនៅក្នុងជីវិត លោក ម៉ាត



ប្រហែលមានចិត្តចំពោះអ្នកនាង"

"បើអ៊ីចឹងប្រហែលមានចិត្តអាណិតជើងពិការរបស់ខ្ញុំ"

"អ្នកនាង...កុំគិតបែបហ្នឹង"

យ្យូលី បង្ខំចិត្តញញឹម។

"ខ្ញុំឈឺភ្នែកហើយ សុំដេកមួយស្រទ្បេត ពេលដល់ហើយដាស់ផង"

ហុងស៊ុល មើលចៅហ្វាយស្រី ដោយក្ដីអាណិត។ នាងដឹងច្បាស់ថា យ្យូលី ស្រឡាញ់ ម៉ាទិនេស លួចស្រឡាញ់យូរមកហើយ ប៉ុន្តែកំណួចដ៏ធំនៅក្នុងចិត្តរបស់ចៅហ្វាយ គឺគិតថា ម៉ាទិនេស គ្រាន់តែអាណិតខ្លួនប៉ុណ្ណោះ។

ម៉ាទិនេស ដឹងថា យ្យូលី ទៅរកដល់មហាវិទ្យាល័យ តែមិនបានជួបខ្លួន ទើបគេមករកនាងវិញដល់ផ្ទះ។

"សួស្តី អ្នកមីង"

អ្នកកំលោះរាក់ទាក់ម្ដាយរបស់ យ្យូលី ហើយរកមើលនាងក្រមុំ។

"យ្យូលី កំពុងងូតទឹក បន្តិចទៀតចុះមកហើយ អង្គុយចុះសិនម៉ោ ម៉ាត" ឌ្យូងហ៊ុ ញញឹមដាក់អនាគតកូនប្រសា "ហើយនេះមកពីណាមកពីណី មកព្រលប់តែម្ដងណាំ"

"ខ្ញុំទើបតែដឹងថា លីលី ទៅរកខ្ញុំដល់មហាវិទ្យាល័យ តែមិនជួប ទើបខ្ញុំមករកដល់ទីនេះ"

ឌ្យូងហ៊ុ ចងចិញ្ចើម។

"ហ៎ា! មិនជួបគ្នាទេឬ ចុះម៉េចក៏ លីលី ប្រាប់មីងថាជួបគ្នាហើយ ហើយម៉ាត ក៏រើសអំណោយដែលទុកជូនភ្ញៀវហើយ"

អ្នកកំលោះគ្រវីក្បាល។



"គួរតែយល់ច្រឡំ ខ្ញុំគួរតែជាប់បង្រៀន ហើយពេល លីលី តេរទៅក៏មិនបានទទួល"

ឌ្យូងហ៊ុ ដកដង្ហើមធំ។

"គិតអីចេះខុស មុខមាត់កូនស្រីរបស់មីងសោកសៅប្លែកៗ តែមីងឆ្ងល់ថា ហេតុអីក៏កុហកថាបានជួបក្មួយហើយ"

អ្នកកំលោះដកដង្ហើមធំ ដោយអារម្មណ៍តានតឹង។

"យ្យូលី ប្រហែលមិនចង់ជួបខ្ញុំប៉ុន្មាន..."

"មិនមែនទេ ម៉ាត នាងច្រមក់នោះ ធ្វើជាសម្ដីហាំបែបហ្នឹងហើយ ឃើញពេលចេញទៅមុខឲ្យពព្រាយ ញញឹមរីកមុខដូចបានហោះ ពេលមិនបានជួប ទើបសោកសៅ ត្រឡប់មកវិញ"

ម៉ាទិនេស មិនបាននិយាយអីទៀត ក្រៅពីអង្គុយញញឹម និងយកថង់ជំនូនជូនភ្ញៀវ មកបើកមើលម្ដងមួយៗ។

"រើសមើលទៅថាចូលចិត្តបែបណា"

"ខ្ញុំតាមចិត្ត លីលី"

"សាករើសមើលសិនទៅ ក្រែងលោមានចិត្តត្រូវគ្នា"

ឌ្យូងហ៊ុ បញ្ចុះបញ្ចូលដោយទឹកមុខញញឹម ស្ទើរតែមិននៅសល់ស្លាកស្នាមនៃការឈឺចាប់ឲ្យឃើញ។

"បាទ"

ម៉ាទិនេស រើសមិនយូរប៉ុន្មាន ក៏យករូបតុក្កតាគូស្នេហ៍មកមើល ដោយទឹកមុខញឹមៗ ទើបអនាគតម្ដាយក្មេកសួរ។



"ចូលចិត្តឬ ?"

"បាទ គួរឲ្យស្រឡាញ់ ប្រុសចាស់ស្រីចាស់" អ្នកកំលោះងក់ក្បាល។



Scanned with CamScanner

"ដឹងន័យរបស់វាឬអត់?"

គេគ្រវីក្បាលតិចៗ ហើយក៏រហ័សនិយាយ៖

"ខ្ញុំមិនច្បាស់ពីន័យរបស់វាទេ ប៉ុន្តែបើឲ្យដៅ វាគួរតែបញ្ជាក់ពីក្ដីស្រឡាញ់ដែលមានឲ្យគ្នារហូតដល់ចាស់សក់ស្កូវ"

"ត្រឹមត្រូវហើយ" ខ្សងហ៊ី ញញឹមពព្រាយ "សរុបទៅចូលចិត្តមួយនេះមែនទេ?"

ម៉ាទិនេស ញញឹមដាក់តុក្កតាគូស្នេហ៍នៅក្នុងដៃម្ដងទៀត ហើយឆ្លើយតបសំណួររបស់អនាគតម្ដាយក្មេកម្ដងទៀត៖

"បាទ"

"ដឹងទេថាមានចិត្តដូច លីលី ណាស់ នាងច្រមក់នោះក៏ជ្រើសរើសយកមួយនេះដែរ" ខ្សងហ៊ី នៅតែញញឹមបិទមាត់មិនជិត "គូព្រេងគឺបែបនេះហើយ ចូលចិត្តស្រដៀងៗគ្នា"

ម៉ាទិនេស សើចញឹមៗ ប៉ុន្តែមិនទាន់បាននិយាយអីផង សំឡេងរបស់ ឃ្យូលី ក៏បន្លឺឡើង ទើបអ្នកកំលោះរហ័សងាកទៅមើល។

"យើងមិនមែនជាគូព្រេងនឹងគ្នាទេម៉ាក់"

"លីលី ងូតទឹកហើយឬកូន"

ខ្សងហ៊ី ងាកទៅសួរ និងមើលមុខជូរផ្អែមរបស់កូនស្រី ដោយការរអាចិត្តជួបមុខ ម៉ាទិនេស ពេលណា មិនដែលឃើញលាស់ទឹកមុខហ្នឹងចេញសោះ។

"ចាំ"

"បើអីចឹងមកអង្គុយនិយាយជាមួយបង ម៉ាត ត្រង់នេះម៉ោ"

ឃ្យូលី ប្រសព្វភ្នែកនឹង ម៉ាទិនេស ដោយអចេតនា។ គេសង្ហា ធ្វើឲ្យនាងមានអារម្មណ៍ថា មិនអាចប៉ះពាល់បាន តើហៀកត៏រហូតដល់មនុស្សស្រី



អង្វរករសុំឲ្យបាននៅជិត។ បេះដូងរបស់នាងលោតញាប់ជានិច្ច ពេលនៅជិតគេ ខ្យល់ដង្ហើមរបស់នាង ស្រដៀងនឹងហួតអស់ពីសួត ត្រឹមតែរភ្នែកមុតស្រួចនោះមើលមក។ នាងលង់ស្នេហ៍គេស្ទើរឆ្កួតទៅហើយ សុខចិត្តធ្វើជាខ្ញុំន ប្រើសិទ្ធិក្នុងការចាប់ផ្ដើម ដើម្បីបានគ្រប់គ្រងគេ ទោះបានត្រឹមសិទ្ធិពីសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ។

មានមោទនៈភាព...អត់ទេ នាងគ្មានអារម្មណ៍បែបនោះអីបន្តិច...

នាងក្រមុំស្រក់ទឹកភ្នែកនៅក្នុងចិត្ត ហើយក៏រហ័សបន្លប់អារម្មណ៍ ដោយភាពសោះកក្រោះនៅក្នុងខ្លួន។

"ខ្ញុំមិនទំនេរ"

"បងប្រុសខំមករកហើយ កុំគ្មានមារយាទ លីលី"

"ខ្ញុំមិនចង់ជួបមុខគេ"

នាងងាកមុខចេញ និងបង្វែរកង់រទេះ ទើប ម៉ាទិនេស សម្រេចចិត្តដើរទៅពាំងមុខ។

"បងទើបតែដឹងថា អូនទៅរកបងនៅមហាវិទ្យាល័យ"

សម្ដីប្រមាថមើលងាយរបស់ស្រីបបូរមាត់ក្រហម ហាក់ដូចទើបតែផឹកឈាមស្រស់ម្នាក់នោះ នៅតែចាក់ដើមទ្រូងរបស់នាង។

"ទៅឲ្យឆ្ងាយ"

"បងគួរតែជាប់បង្រៀន"

"ចាំ" នាងតបដោយសំឡេងរឹងកំព្រើស "ចៀសចេញ ខ្ញុំទៅសួន"

ម៉ាទិនេស មិនព្រម គេដើររាំងទៅក្រោយរទេះ។

"បងនាំទៅ"

"មិនបាច់ ខ្ញុំទៅខ្លួនឯងបាន"



នាងឡូឡា ប៉ុន្តែគ្មាននរណាចាប់អារម្មណ៍ ព្រោះសូម្បីម្ដាយ ក៏អង្គុយធ្វើមិនដឹងមិនឮ ដែលឃើញនាងត្រូវរុញចេញទៅ។

"បានហើយ ទុកខ្ញុំចោលទីនេះហើយ"

ម៉ាទិនេស ដើរវាងមកឈរទល់មុខ ពេលរុញនាងចេញមកសួន តាមដែលនាងត្រូវការ ដោយអង្គុយចោងហោង មើលមុខនាងមិនដាក់ភ្នែក។

"ម៉េចក៏មួម៉ៅ មុខរបស់បងមានអាហារជូរផ្អែមឬអត់ ?"

នាងក្រមុំសម្លឹងមុខសម្លក់គេ ខណៈដែលខ្ចីបបបូរមាត់ ទើប ម៉ាទិនេស ហាមប្រាម។

"កុំខាំមាត់បែបនេះ ជាំអស់ហើយ"

"មាត់របស់ខ្ញុំ"

កាន់តែគេហាម នាងកាន់តែធ្វើ ដូច្នេះហើយទើប ម៉ាទិនេស ឱនមកថើបបបូរមាត់ត្រជាក់នោះភ្លាម ធ្វើឲ្យអ្នកដែលអង្គុយលើរទេះ បើកភ្នែកធំៗ ប៉ុន្តែត្រូវគេចាប់កញ្ចឹង.កជាប់ សង្កត់ក្បាលរបស់នាងឲ្យនៅមួយកន្លែង និងព្រមឲ្យគេថើបតាមអំពើចិត្ត ដោយមិនអាចគេចវេះបាន។

នាងក្រមុំបិទភ្នែកយឺតៗ ផ្ចិតយកភាពទន់ភ្លន់ លាយឡំនឹងភាពរឹងកំព្រឹស ពីបបូរមាត់របស់ ម៉ាទិនេស។ វាស្នាមថើបដំបូងរបស់នាង ហើយនាងក៏រីករាយខ្លាំងណាស់ ដែលឲ្យវាទៅបុរសដែលខ្លួនលួចស្រឡាញ់។

យូរតែម្ដង ស្ទើរតែរលាយហាក់ដូចកំពុងរាំរបាំក្នុងវាលផ្កាលើឋានសួគ៌ ស្លាបមេអំបៅរាប់លានទទះនៅក្នុងពោះ ដៃដែលរុញច្រាន ពេលនាងដាក់លើស្មាធំទូលាយ ហើយឱប.ករឹងមាំរបស់គេ។

ការថើបដ៏ទន់ភ្លន់ ទៅជាក្ដៅទៅៗ ពេល ម៉ាទិនេស គ្រប់គ្រងអារម្មណ៍របស់ខ្លួនឯងមិនបាន ទើបគេសង្កត់បបូរមាត់កាន់តែខ្លាំង ញាក់ញីរហូតដល់



បបូរមាត់របស់នាងជាំ ហើយជ្រែកអណ្ដាតចូលទៅក្នុង ធ្វើឲ្យនាងបើកភ្នែកធំ ប៉ុន្តែក៏ទោរទន់តាមនៅវិនាទីបន្ទាប់ ធ្វើឲ្យការថើបផ្អែមល្ហែមកើតឡើងយ៉ាងយូរ ទាល់តែ ម៉ាទិនេស ងើបចេញ និងដកដង្ហើមធំ។

"កុំខាំមាត់ទៀត"

មុខរបស់នាងក្រហម ស្មារតីក៏ត្រឡប់មកវិញ នោះហើយដែលធ្វើឲ្យនាងអាម៉ាស់ ស្ទើរតែមិនចង់ទុកមុខលម្អនៅលើស្មារទៀត ហើយមើលគេដោយការស្អប់ខ្ពើម ទឹកភ្នែកក៏រកកល់ចង់ស្រក់។

"បង ម៉ាត គ្មានសិទ្ធិធ្វើបែបនេះដាក់ខ្ញុំទេ"

នាងតវ៉ាគេ ប៉ុន្តែបេះដូងនៅតែលោតដុកដាក់ រាងកាយនៅតែរីកដូចផ្កាត្រូវទឹក កម្ដៅនៅតែរត់ឲ្យរសើបពេញខ្លួន។

"បងសុំទោស ប៉ុន្តែបើមាត់របស់អូនជាំ គួរឲ្យជាំព្រោះត្រូវបងថើប មិនមែនព្រោះតែអូនគិតតែខាំមាត់របស់ខ្លួនឯង"

នាងក្រមុំភាំង ពើងទ្រូងដាក់គេដោយការងរង៉ក់។

"ហើយវាពាក់ព័ន្ធអីនឹងបង វាជាមាត់របស់ខ្ញុំ"

អ្នកកំលោះសើចញឹមៗ កែវភ្នែករបស់គេស្អាតជាងដួងតារានៅលើមេឃនាពេលនេះទៅទៀត។ នាងស្អប់ខ្លួនឯងណាស់ ដែលមើលឃើញគេស្អាតគ្រប់ពេលជានិច្ច ទាំងដែលគេសាហាវចំពោះអារម្មណ៍របស់នាងសឹងស្លាប់។

"យើងជិតរៀបការនឹងគ្នាហើយ"

នាងអួលដើម.ក ចុកទ្រូង។

"វាគ្រាន់តែជាការចាប់ផ្ដើម ដែលបងបដិសេធមិនបាន"

អ្នកកំលោះផ្ងៀង.កមើលនាង ហើយឱនមើលបបូរមាត់ក្រពុំ ដែលជាំតិចៗមិនដាក់ភ្នែក ព្រមទាំងលួចលេបទឹកមាត់ដែរ។





Scanned with CamScanner

"យើងមិនសូវបានជួបគ្នា ប៉ុន្តែមើលទៅអូនដូចដឹងចិត្តរបស់បងច្បាស់"

យ្យូលី កាន់តែតូចចិត្ត ពេលគេនិយាយបែបនេះ ទើបងាកមុខចេញ មិនព្រមមើលមុខគេ។

"ចំពោះតែរឿងមួយនេះប៉ុណ្ណោះ"

អ្នកកំលោះដកដង្ហើមធំ ទើបងើបដើរទៅមុខពីរជំហាន លើកដៃឱបទ្រូង ងើយមើលផ្ទៃមេឃពេលព្រលប់។

"មិនគួរណាក្មេងសុភាពរាបសារ ទន់ភ្លន់ថ្ងៃមុន ពេលវេលាប្រែប្រួលឲ្យក្លាយជាមនុស្សស្រីទំនើង ចូលចិត្តប្រើតែអារម្មណ៍"

"ព្រោះខ្ញុំមិនល្អហ្នឹងអី ការពិតពេលនេះបង ម៉ាត បដិសេធមង្គលការទាន់ពេល ខ្ញុំព្រមទទួលយកការសម្រេចចិត្តរបស់បង មិនថាបែបណាក៏ដោយ"

អ្នកដែលឈរបែរខ្នងដាក់ បែរមុខយឺតៗមករក ហើយដើរមកឈរទល់មុខ។

ពន្លឺពេញវង់របស់ព្រះចន្ទ ចាំងមកលើខ្នងរបស់គេ ធ្វើឲ្យគេមើលទៅអាថ៌កំបាំង គួរឲ្យខ្លាច។

"បងមិនមែនជាមនុស្សរារែក អ្វីដែលបងសម្រេចចិត្តរួចហើយ គឺមិនកែប្រែ បងសង្ឃឹមថាអូនយល់"

"ចាំ ខ្ញុំយល់" នាងតបដោយសំឡេងរឹង ព្យាយាមលាក់ការឈឺចាប់នៅក្នុងទ្រូងឲ្យជិតបំផុត "ហើយខ្ញុំនឹងប្រគល់សេរីភាពឲ្យបងឲ្យឆាប់បំផុត តាមដែលអាចធ្វើបាន"

"កុំនិយាយរឿងអនាគត ដែលមិនទាន់មកដល់ ព្រោះជួនកាល វាអាចមិនដូចអូនយល់ក៏ថាបាន"

នាងក្រមុំចាប់កង់រទេះរបស់ខ្លួន បង្វិលចេញឲ្យឆ្ងាយ ខណៈដែល



ទឹកភ្នែកហូរកាន់ថ្ពាល់។

"តែខ្ញុំជឿថាខ្លួនឯងដឹងច្បាស់ថា អ្វីនឹងកើតឡើងបន្ទាប់ពីនេះ ខ្ញុំសុំចូលផ្ទះវិញហើយ"

"បងជូនទៅ"

"មិនបាច់ទេ ខ្ញុំជួយខ្លួនឯងបាន"

គេមិនព្រមធ្វើតាមតម្រូវការរបស់ យ្យូលី ដោយការដើរមកចាប់រទេះរុញរបស់នាង។

"កុំឲ្យខ្ញុំពិការទាំងជើង ពិការទាំងដៃ ឲ្យខ្ញុំជួយខ្លួនឯងទៅ"

ការតវ៉ាដ៏សោកសៅរបស់នាង ធ្វើឲ្យ ម៉ាទិនេស បង្ខំចិត្តប្រលែងដៃពីរទេះ និងឈរមើលនាងបង្វិលវាចូលទៅក្នុងផ្ទះ ដោយខ្សែភ្នែកខ្លោចផ្សា។

គេខាំថ្គាម ឡើងប៉ោងថ្គាល់ត្រង់ថ្គាម អារម្មណ៍តានតឹងនៅក្នុងបេះដូងកំពុងធ្វើឲ្យគេវេទនា។ អ្នកកំលោះបែរខ្លួន ដើរយឺតៗសម្តៅរថយន្តទំនើប ដោយគ្រប់ពេលនោះអត់គិតដល់អតីតកាលមិនបាន។

យ្យូលី ក្មេងជាងគេជាងដប់ប្រាំឆ្នាំ កាលពីនៅតូច នាងទាំងជាត់ ទាំងខ្មៅ និងតគ្រិច នោះហើយដែលធ្វើឲ្យគេចេះតែគេចពីនាង ដោយមានតែនាងម្នាក់ប៉ុណ្ណោះ ដែលចូលចិត្តតាមគេគ្រប់ពេលវេលា រហូតដល់មានឧបទ្ទវហេតុកើតឡើងនោះឯង ទើបធ្វើឲ្យគេ និងនាងឃ្លាតឆ្ងាយពីគ្នា។

គេដកដង្ហើមធំម្តងទៀត បើកទ្វារឡាន ឡើងទៅអង្គុយកាន់ចង្កូតរថយន្ត ភ្នែកក៏សម្លឹងទៅកាន់ផ្ទះរបស់នាងក្រមុំ ស្រមោលស្ងង់ៗនៅក្រោយវាំងនននដែលគេចាំបានថានោះគឺបន្ទប់ដេករបស់នាងញ៉ាវ បន្ទាប់មកក៏បាត់ ទើបគេសម្រេចចិត្តបញ្ជារថយន្តស្ទុតទំនើបចេញពីភូមិគ្រឹះដ៏ស្ងៀមស្ងៃ។





Scanned with CamScanner

# ២

ដប់ថ្ងៃក្រោយមក ពិធីមង្គលការក៏ប្រារព្ធឡើងយ៉ាងអធិកអធម ជាពិធីមង្គលការដែលអ្នកផងនាំគ្នាកោតសរសើរយ៉ាងខ្លាំង តែមិនមែនមកពីអំណោយជូនភ្ញៀវជាមាសពេជ្រ គឺមកពីកូនកំលោះនិងកូនក្រមុំមានសម្រស់រូបឆោមដូចមិនមែនមនុស្សដើរដីធម្មតាទូទៅ ទាស់ត្រង់បន្តិចគឺកូនក្រមុំពិការជើងដើរមិនរួចត្រូវអង្គុយនៅលើរទេះរុញប៉ុណ្ណោះ។

សំឡេងបិទទ្វារបន្ទប់ផ្សំដំណេកបន្លឺឡើងជាលើកចុងក្រោយ ស្របពេលដែលភាពតានតឹងនៅក្នុងទ្រូងរបស់ យូលី ត្រូវផ្ទុះ ពេលត្រូវនៅក្នុងបន្ទប់នេះជាមួយកូនកំលោះតែពីរនាក់ ថែមទាំងជារាត្រីផ្សំដំណេក ដែលជាពេលវេលាមានសុភមង្គលបំផុតនៅក្នុងជីវិតរបស់កូនស្រីម្នាក់ ប៉ុន្តែមិនមែនជាពេលវេលាមានសុភមង្គលបំផុតនៅក្នុងជីវិតរបស់នាង ព្រោះ ម៉ាទិនេស មិនបានធ្វើឫកក្រេកកាមដាក់នាងអីបន្តិច។

កូនកំលោះនៅក្នុងឈុតពណ៌សស្អាត ដើរមកឈរក្បែរគ្រែ បន្ទាប់ពីចាស់ទុំដើរចេញពីបន្ទប់ផ្សំដំណេក។ កែវភ្នែកមុតស្រួចដែលសម្លឹងមើលនាងនៅតែសោះកក្រោះ ព្រងើយកន្តើយដូចមុនដដែល មិនបង្ហាញឲ្យឃើញឫកពាជាកូនកំលោះដែលបានត្រៀមខ្លួនរួចរាល់ ដើម្បីប្រគល់សេចក្តីសុខឲ្យកូនក្រមុំនៅរាត្រីផ្សំដំណេក។ ប្រហែលមកពីគេមិនចង់ប៉ះពាល់នាងហើយមើលទៅ។

យូលី អន់ចិត្តផង តូចចិត្តផង តែព្យាយាមលាក់អារម្មណ៍នោះទុកឲ្យជ្រៅ ដោយបង្ហាញឲ្យឃើញពីអារម្មណ៍ដែលផ្ទុយពីនោះ។



"ខ្ញុំចេញទៅដេកនៅបន្ទប់មួយទៀត"

"ធ្វើបែបហ្នឹងមិនបានទេ ចាស់ទុំនឹងស្តីបន្ទោសឲ្យ"

កូនក្រមុំពើងទ្រូង តូចចិត្តដល់ថ្នាក់រលីងរលោងទឹកភ្នែក។

"គ្រាន់តែត្រូវស្តីបន្ទោស តែយ៉ាងហោចណាស់ក៏ធ្វើឲ្យបង ម៉ាត បាត់ធុញថប់បានដែរ"

"បងធុញថប់ ?" គេត្បកសួរ។

"ចាំ ខ្ញុំដឹងថាបងធុញថប់ប៉ុនណា"

នាងក្រមុំរំកិលតួទដើម្បីចុះពីគ្រែ ទាំងដែលពិបាកធ្វើ ទើប ម៉ាទិនេស ហាមប្រាម ដោយទឹកមុខកាច។

"ចង់ទៅណា ?"

"ចូលបន្ទប់ទឹក"

"ទៅយ៉ាងម៉េច ?"

នាងសម្លឹងរទេះរុញរបស់ខ្លួន ដែល ហុងស៊ីល យកមកទុកឲ្យ។

"នោះអី រទេះរុញរបស់ខ្ញុំ"

"ចាំបងជួយ មិនបាច់ប្រើវាទេ"

គេមានបំណងល្អ តែ យូលី មិនចង់ឲ្យគេវេទនាខ្លួនជាងនេះ ទើបប្រឹងឈោង តែត្រូវគេដើរមកពាំងមុខ។

"កុំរឹង លីលី បងមិនចូលចិត្តក្មេងរឹងក្បាល"

"បង ម៉ាត ចៀសចេញទៅ"



អ្នកកំលោះលោមករក ចុងច្រមុះសឹងតែជល់នឹងថ្ពាល់រលោងទៅហើយ ធ្វើឲ្យ យូលី ភ្ញាក់ព្រើតនឹងភាពស្និទ្ធស្នាលនេះ មុខឡើងក្រហមង៉ាំង ស្ទុះថយក្រោយវិញលឿនដូចព្យុះ។



Scanned with CamScanner

"ចង់ធ្វើអី?"

ម៉ាទិនេស ដកដង្ហើមធំ ខាំថ្គាមឡើងប៉ោងថ្ពាល់។

"បីអូនទៅបន្ទប់ទឹក"

"ប្រាប់ហើយតើ ថាខ្ញុំទៅខ្លួនឯងបាន"

គេគ្រវីក្បាលតិចៗ ហើយលើកបីភរិយាថ្មោងថ្មី។

"កុំចចេស បងមិនធ្វើអីអូនទេ"

ធិះ! មិនបាច់ប្រាប់ក៏នាងដឹងដែរ ថាគេមិនបានគិតថានឹងធ្វើស្អីនាង ព្រោះគេមិនបានស្រឡាញ់នាង មិនប្រាថ្នាខ្លួនប្រាណរបស់នាង...ការតូចចិត្តលុកលុយដើមទ្រូងម្តងហើយម្តងទៀតដូចទឹករលកបោកបក់ឆ្នេរ។

"ចាំ ខ្ញុំដឹង"

គេញញឹម គ្រវីក្បាលហួចចិត្ត ហើយបីនាងនាំចូលបន្ទប់ទឹកធំទូលាយ ដោយដាក់នាងលើកៅអីវែងដែលត្រូវកុម្ម៉ង់ធ្វើដើម្បីនាងជាពិសេសបន្ទាប់មកក៏អង្គុញជើង ឈរនៅចំពោះមុខ។

"សួរតាមត្រង់ចុះ ងូតទឹកខ្លួនឯងបានមែនឬ?"

មុខរបស់នាងឡើងក្រហមព្រឿងៗ និងងាកមុខគេចពីខ្សែភ្នែកមុតស្រួចដែលមើលមកដូចចង់ចំអន់។

"គឺ...ងូតខ្លួនឯងរហូត"

"តែមាន ហុងស៊ីល ចាំជួយ"

"ចាំ"

"ឲ្យបងជួយងូតទឹកឲ្យ"

នាងបើកភ្នែកធំៗ ហើយស្រែកអស់សំឡេងជាការបដិសេធ។

"មិនបាច់ទេ ខ្ញុំអាចងូតដោយខ្លួនបាន គ្រាន់តែជួយបីខ្ញុំទៅដាក់ក្នុងអាង



ទៅបានហើយ"

"ចុះពេលឡើងម៉ោវិញ តើធ្វើយ៉ាងម៉េច? ឲ្យបងងូតឲ្យល្អជាង"

"ប្រាប់ថាមិនបាច់ទេ ខ្ញុំងូតខ្លួនឯង"

ម៉ាទិនេស ផ្ងៀង.កបន្តិច មើលភរិយាមុខក្រហមដោយនឹកអស់សំណើចពេលមើលដឹងថានាងខ្មាស។

"នេះខ្មាសបងឬ?"

"អត់...អត់មានទេ"

"បងទៅហៅ ហុងស៊ីល ឲ្យមកជួយងូតឲ្យ" អ្នកកំលោះងើបឈរ ដោយឈានថយក្រោយបន្តិច ពេលប្រាប់។

"ប្រាប់ថាមិន..."

នាងនិយាយមិនទាន់ចប់ផង ម៉ាទិនេស ក៏ដើរចេញពីបន្ទប់ទឹកទៅហើយ ហើយសំឡេងបិទទ្វារបន្លឺឡើង ដំណាលនឹងបេះដូងរបស់នាងដែលត្រូវបិទទ្វារចាក់សោទុកដូចរាល់ដង។

"មិនបាច់ម៉ោធ្វើល្អដាក់ខ្ញុំទេ...ដឹងថាគ្រាន់តែវេទនាខ្ញុំ..." នាងសោកសៅ និងរលីងរលោងទឹកភ្នែកឲ្យទាល់តែបាន មួយសន្ទុះ ហុងស៊ីល ក៏ដើរចូលមកជួយការងារនាងដូចសព្វមួយដង។

ពិធីមង្គលការមួយនេះ វានៅឆ្ងាយពីការរំពឹងទុករបស់នាងពន់ពេក ប៉ុន្តែឲ្យធ្វើឲ្យយ៉ាងណា បើបុរសដែលរៀបការជាមួយនាង គេធ្វើព្រោះចាំបាច់។



"អ្នកនាងសម្រាក"

ហុងស៊ីល នាំចៅហ្វាយមកគ្រែ ហើយទាញភួយដណ្តប់ឲ្យ។

"ចុះបង ម៉ាត?"

យ៉ូលី មើលទៅវិញបន្ទប់ មិនឃើញ ម៉ាទិនេស ទើបសួរនាំ ចំណែក ហុងស៊ីល ក៏មើលតាម ហើយឆ្លើយទាំងសង្ស័យ។

"មិញនៅក្នុងនេះតើ សង្ស័យចេញទៅខាងក្រៅហើយ ចាំខ្ញុំទៅតាមឲ្យ"

"មិនបាច់ទេ គេចង់ធ្វើអីក៏តាមតែគេទៅ"

"តែនេះជារាត្រីមង្គលការរបស់នាង"

ទឹកមុខរបស់ ហុងស៊ីល បង្ហាញឲ្យឃើញថាមិនសប្បាយចិត្ត។

"ខ្ញុំអូខេ ហើយក៏ងងុយដេកណាស់ដែរ ចំណែកបង ម៉ាត ចូលមកឬអត់ក៏ស្រេចតែគេ"

នាងនិយាយបញ្ចប់សាច់រឿងនេះ ហើយបិទភ្នែកលាក់ការឈឺចាប់ ប៉ុន្តែ ហុងស៊ីល មើលដឹង។

"កុំគិតច្រើនអីអ្នកនាង ធ្វើចិត្តឲ្យរីករាយ នេះជាថ្ងៃមង្គលដែលអ្នកនាងត្រូវតែមានសេចក្តីសុខបំផុត" ហុងស៊ីល ច្របាច់ដៃហៅហ្វាយស្រីតិចៗ "ខ្ញុំទៅសិនហើយ"

"រាត្រីសួស្តី ហុងស៊ីល"

"រាត្រីសួស្តី អ្នកនាង"

ពេល ហុងស៊ីល ដើរចេញពីបន្ទប់ផ្សំដំណេក ទើប យ៉ូលី បើកភ្នែក ឲ្យទឹកភ្នែកដែលដក់ក្នុងប្រឡង់ភ្នែកហូរតាមកន្ទុយភ្នែកបេះដូងក៏ឈឺចាប់ពេលមិនអាចស្រវេស្រវាយកអ្វីដែលខ្លួនប្រាថ្នាបាន ហើយក៏ដេកលក់ទាំងទឹកភ្នែក។

ខ្យល់ត្រជាក់នាពេលរាត្រីដែលបក់រំភើយៗ មិនអាចធ្វើឲ្យរាងកាយរបស់ ម៉ាទិនេស ចុះត្រជាក់ ខាងក្នុងនៅតែក្តៅដោយអារម្មណ៍គួរឲ្យអាម៉ាស់ អារម្មណ៍របស់មនុស្សប្រុស ដែលបណ្តោយឲ្យតណ្ហារាគៈមានអំណាចជាងខួរក្បាល។



គេឈរស្ងៀម ដៃក្តាប់បង្កាន់ដៃឈើរបស់រនាំងឡើងមុតក្រចក ដោយមិនដឹងខ្លួន ប្រឹងហាមប្រាមគំនិតគួរឲ្យខ្ពើមរអើមនោះ ប៉ុន្តែវាពិបាកមែនទែន ព្រោះពេលនេះដឹងច្បាស់ហើយ យ៉ូលី ជាភរិយារបស់គេស្របច្បាប់។ គេចង់ប៉ះពាល់នាងដូចដែលស្រមើស្រមៃយូរមកហើយចង់ពិនិត្យរាងកាយតូចច្រឡឹងដែលក្រសោបដោយសម្លៀកបំពាក់ពណ៌ស្រស់នោះ ថាឲ្យអារម្មណ៍យ៉ាងណាពេលបានស្ទាបអង្អែល។

*ឆ្កួតមែន!*

គេជេរខ្លួនឯង ដោយកំហឹង ដែលមានអារម្មណ៍ត្រេកកាម ទាំងដែលភរិយាមានរាងកាយទន់ទ្រាយ។ គេគួរតែឲ្យពេលវេលានាង គួរតែឲ្យនាងបានត្រៀមកាយត្រៀមចិត្ត មិនមែនចេះតែចង់ចាប់បង្ខំបែបនេះ។

ខួរក្បាលរបស់គេគិតឃើញ តែរាងកាយបែរជាមិនព្រមធ្វើតាម នៅតែរឹងនៅតែពុះកញ្ជ្រោល ស្ទើរតែផ្ទុះទៅហើយ ដែលប្រាកដណាស់ថាគេមិនអាចចូលទៅដេករួមគ្រែជាមួយភរិយាបាន មិនអីចឹងគេមុខជាមិនអាចទប់អារម្មណ៍របស់ខ្លួនបាន អាចចាត់ការនាងពេញមួយរាត្រីក៏ថាបាន ទាំងដែលនាងមិនពេញចិត្តប្រគល់ឲ្យ។

"លោក ម៉ាត រួចរាល់ហើយ"

សំឡេងរបស់ ហុងស៊ីល ធ្វើឲ្យគេភ្ញាក់ស្មារតី ទើបសម្រួបទឹកមុខ និងបែរខ្លួនទៅរកអ្នកហៅ។

"អរគុណ ហុងស៊ីល"

ម្ចាស់ឈ្មោះសើចញឹមៗ ហើយសម្រេចចិត្តសួរ៖



"អត់ទោស លោកចូលបន្ទប់ផ្សំដំណេកទេ ? ជូនអីអ្នកនាងចូលសម្រាកហើយ"

ម៉ាទិនេស គ្រវីក្បាល។

"នៅទេ នាងទៅសម្រាកចុះ យប់ជ្រៅហើយ"

"តែ..." ហុងស៊ីល មិនសប្បាយចិត្ត។

"ទៅចុះ ខាងណោះ ចាំខ្ញុំចាត់ការ"

អ្នកកំលោះរូបសង្ហាសើចញឹមៗ និងនិយាយបញ្ចប់រឿងដោយការបែរខ្នង មើលផ្ទៃមេឃងងឹតវិញ ទើប ហុងស៊ីល គ្មានជម្រើស ត្រូវដើរចេញទៅទាំងព្រួយបារម្ភ។

ពេលបាននៅម្នាក់ឯងបន្ត គេក៏ដកដង្ហើមធំ និងខាំថ្គាមណែន។ គេសម្រេចចិត្តមិនចូលបន្ទប់ផ្សំដំណេកវិញ មិនមែនដោយសាររើសអើង មិនចង់ប៉ះពាល់ តែមកពីអាណិត យ្យូលី។

ម៉ាទិនេស បែរខ្លួន ដើរសំដៅបន្ទប់ដេកមួយទៀត ដែលនៅមិនឆ្ងាយប៉ុន្មាន បើកទ្វារចូលទៅសម្ងំដេកនៅក្នុងនោះ។

**ព្រឹកថ្ងៃបន្ទាប់ នៅតុអាហារក្នុងភូមិគ្រឹះរបស់ត្រកូល ម៉ាឡេសាសស្លូ ម៉ារៀ និង ម៉ារិអូ អង្គុយទទួលទានអាហារពេលព្រឹកមុនទៅហើយ ដោយមានកូនប្រុសច្បង ម៉ាទិនេស ចូលរួម។**

យ្យូលី ត្រូវ ហុងស៊ីល រុញចៅហ្វាយស្រីចូលមក នាងក្រមុំក៏រាក់ទាក់ឪពុកម្តាយក្មេកដោយការគោរព ហើយរាក់ទាក់ស្វាមីតាមច្បាប់របស់ខ្លួនដោយសំឡេងខ្សាវៗ។

"អរុណសួស្តី លីលី" ម៉ារៀ រាក់ទាក់ ខណៈដែល ម៉ារិអូ ញញឹមដាក់ ទើបនាងញញឹមដាក់ចាស់ទុំទាំងពីរ ហើយចូលទៅអង្គុយក្បែរ ម៉ាទិនេស។

"យប់មិញដេកលក់ស្រួលទេ ?"



សំណួររបស់ ម៉ារៀ ធ្វើឲ្យអ្នកដែលកំពុងតែចាប់ស្លាបព្រាទៅជាភាំង ទឹកមុខបង្ហាញឲ្យឃើញពីភាពរារែក បន្ទាប់មកក៏សម្រេចចិត្តឆ្លើយតបទាំងមិនពេញសំឡេង។

"លក់...ស្រួល...អ៊ំស្រី...អឺ...ម៉ាក់"

"ដេកលក់ស្រួលក៏ល្អហើយ" ម៉ារៀ ញញឹម "ម៉ាក់ចង់ឲ្យ លីលី នៅទីនេះមានសេចក្តីសុខទាំងកាយទាំងចិត្ត ម៉ាក់របស់កូននឹងមិនបារម្ភពេលត្រឡប់ទៅព្យាបាលខ្លួននៅអ៊ីតាលីវិញ"

នាងប្រឹងញញឹម ទាំងដែលនៅក្នុងទ្រូងនៅឆ្ងាយពីពាក្យថាសេចក្តីសុខពន់ពេក។

"អរគុណម៉ាក់"

ម៉ារៀ ញញឹមម្តងទៀត ហើយងាកទៅរកកូនប្រុសច្បង។

"ចុះ ម៉ាត ដេកលក់ស្រួលឬអត់ ?"

អ្នកដែលកំពុងចាត់ការអាហារពេលព្រឹកដោយមិនមាត់មិន.ក ងើយមុខកែវភ្នែកមុតស្រួចងាកទៅមើលភរិយាបន្តិច ហើយឆ្លើយដោយសំឡេងរាបស្មើ។

"ខ្ញុំដេកលក់ស្រួល ពូកទន់ល្អណាស់"

យ្យូលី ក្តាប់ស្លាបព្រាណែនដៃ ពេលបានឮចម្លើយរបស់ស្វាមីថ្មោងថ្មី។ គេត្រូវតែដេកលក់ស្រួលហើយ ព្រោះមិនបានដេកជាមួយនាង។

អ្នកម្តាយញញឹមពព្រាយ ព្រោះគិតនៅក្នុងផ្លូវល្អ តែក៏ត្រូវភាំងពេលដែលបានឮសំឡេងរបស់អ៊ំស្រី អាយរីន មេផ្ទះដែលតាមចៅហ្វាយនាយមកពីអ៊ីតាលី ដែលបន្លឺឡើងនៅក្រោយខ្នង។



"លោក ម៉ាត មានន័យដល់គ្រែនៅក្នុងបន្ទប់ផ្សំដំណេកឬ"

ម៉ាទិនេស ផ្អៀងកមើលអ៊ំស្រី អាយរីន ដោយទឹកមុខព្រួយបារម្ភ។

"យ៉ាងម៉េចឬអីស្រី ?"

"អីយ៉ា គឺព្រឹកមិញខ្ញុំឃើញលោកដើរចេញពីបន្ទប់សម្រាប់ភ្ញៀវ ទើបខ្ញុំគិតថាពូកដែលថាទន់ គួរតែជាពូកនៅក្នុងបន្ទប់សម្រាប់ភ្ញៀវជាងពូកនៅក្នុងបន្ទប់ផ្សំដំណេក"

ទឹកមុខរបស់ ម៉ាទិនេស ស្រពោន ហើយកាន់តែស្រពោន ពេលងាកទៅទៅរកម្តាយ ឃើញគាត់សម្លក់សម្លឹងមកខ្លួន។

យ៉ូលី ឈ្ងោកមុខឈ្ងោកមាត់លាក់ការអាម៉ាស់អស់ពីសមត្ថភាព ទឹកភ្នែករកកលចង់ស្រក់ ពេលគ្រប់គ្នានៅក្នុងបន្ទប់អាហារដឹងអស់ហើយថានាងគឺកូនក្រមុំដែលត្រូវទុកចោលនៅក្នុងបន្ទប់ផ្សំដំណេក។

"ចង់ដោះសាយ៉ាងម៉េច ម៉ាត ?"

សំណួររបស់អ្នកម្តាយ ធ្វើឲ្យអ្នកកំលោះដកដង្ហើមធំ ហើយសម្រេចចិត្តឆ្លើយការពិត។

"ខ្ញុំមិនចង់រំខាន លីលី ឃើញថាដេកលក់ហើយ"

"មែនឬ លីលី ?" ម៉ារៀ សួរកូនប្រសា។

យ៉ូលី ងើយមុខ មកប្រសព្វភ្នែកនឹងស្វាមីបន្តិច ហើយសម្រេចចិត្តឆ្លើយតបដោយសំឡេងខ្សាវៗ។

"អូ...ចាស"

"តែកូនកំលោះមិនគួរទុកកូនក្រមុំឲ្យដេកតែម្នាក់ឯងនៅរាត្រីផ្សំដំណេកចំមែន កូននេះ" ម៉ារៀ ស្តីបន្ទោសឲ្យកូនប្រុស ទើបត្រូវ ម៉ារិអូ ហាមប្រាម។

"កូនមានហេតុផល អូនធ្វើចិត្តឲ្យត្រជាក់"

"បងកាន់ជើងកូនគ្រប់គ្នាហ្នឹង បែបនេះហ្នឹងអី ទើបមានចរិតមិនយោគយល់ដល់អ្នកដទៃ" ម៉ារៀ ងាកទៅថាឲ្យស្វាមី ទើបធ្វើឲ្យប្រមុខត្រកូល



ស្ងើចហេះៗ ហើយទទួលទានអាហារបន្តដោយមិនមាត់មិន.ក។

"យប់នេះចូលទៅដេកបន្ទប់ផ្សំដំណេកវិញទៅ"

ម៉ាទិនេស មិនបានឆ្លើយតប ទើបធ្វើឲ្យអ្នកម្តាយមិនពេញចិត្តជាខ្លាំង។

"អីចឹងប៉ាម៉ាក់នឹងនៅ ទាល់តែឯងចូលទៅដេកនៅបន្ទប់ផ្សំដំណេកហើយចាំទៅ អ៊ីតាលី វិញ"

"អូខេម៉ាក់ ខ្ញុំនឹងចូលទៅដេកនៅបន្ទប់ផ្សំដំណេក"

ម៉ាទិនេស ដកដង្ហើមធំ ខណៈដែល យ៉ូលី អាម៉ាស់ជាខ្លាំង។ នេះនាងដល់ថ្នាក់ត្រូវប្រើម្តាយក្មេកឲ្យជួយនិយាយឲ្យ ម៉ាទិនេស ចូលផ្សំដំណេកផងឬ។

ទឹកភ្នែកហូររហាម តែនាងប្រញាប់លើកខ្នងដៃជូតចោល ហើយដាក់ស្លាបព្រាចុះ។

"ខ្ញុំសុំទៅសិនហើយ"

"អាំ ទើបតែញ៉ាំបានបន្តិចហ្នឹង លីលី" ម្តាយក្មេកសួរនាំដោយការព្រួយបារម្ភ។

"ខ្ញុំមិនសូវឃ្លានទេ សុំទៅសិនហើយ" នាងប្រាប់ ម៉ារៀ និង ម៉ារិអូ ហើយងាកទៅនិយាយជាមួយ ហុងស៊ីល "នាំខ្ញុំទៅបន្ទប់ ខ្ញុំឈឺក្បាល"

"ចាំបងជូនទៅ" ម៉ាទិនេស ដាក់ស្លាបព្រាចុះហើយងើបឈរ។

"កុំអី បង ម៉ាត ញ៉ាំបន្តទៅ ខ្ញុំមិនរំខានទេ"

"រំខានស្អី លីលី កុំភ្លេចថា ម៉ាត ជាប្តីរបស់កូនហើយ"

ពាក្យថា ប្តី ធ្វើឲ្យនាងឈឺចាប់កាន់តែខ្លាំង ដូចមានអ្នកណាយកកាំបិតមកចាក់ចំបេះដូង។



"តែខ្ញុំចង់ជួយខ្លួនឯង អរគុណម៉ាក់ តោះ ហុងស៊ីល" នាងញញឹមដាក់ម្តាយក្មេកម្តងទៀត ហើយឲ្យ ហុងស៊ីល នាំខ្លួនចេញពីបន្ទប់អាហារ។

ម៉ាទិនេស នៅតែឈរស្ងៀមបែបនោះតាមមើលភរិយាពីក្រោយ ដោយទឹកមុខមិនសប្បាយចិត្ត។

"ប្រពន្ធងរហើយ ឆាប់ទៅលួងទៅ ម៉ាត"

សម្ដីរបស់ម្ដាយ ធ្វើឲ្យ ម៉ាទិនេស ដកដង្ហើមធំ។

"អ៊ីចឹងខ្ញុំទៅសិនហើយ"

"ឈប់សិន"

"បាទ" កូនប្រុសឈប់ដើរ ហើយងាកទៅរកម្ដាយ "ម៉ាក់មានការអី?"

"ថ្ងៃនេះនាំប្រពន្ធទៅបើកភ្នែកបើកត្រចៀកផង យ៉ាងណាក៏កូនសម្រាកពីការងារដល់ទៅប្រាំថ្ងៃ"

"បាទម៉ាក់"

អ្នកកំលោះឆ្លើយហើយក៏ដើរចេញពីបន្ទប់អាហារ ដែលស្របពេលនោះ ជីយ៉ន សាស្ត្រាចារ្យដែលបង្រៀននៅមហាវិទ្យាល័យក៏ដើរចូលមកល្មម។

"សួស្ដីលោកនាយក មិនដឹងថារំខានឬអត់?"

អ្នកកំលោះលើកចិញ្ចើម ហើយសម្របទឹកមុខឲ្យរាបស្មើ។

"សាស្ត្រាចារ្យ គីម មានការអីឬ បានជាមករកខ្ញុំដល់ទីនេះ?"

ជីយ៉ន ម្ចាស់ផ្ទះដើរមកជិត បុញមាត់បុញកនិយាយដោយសំឡេងផ្អែមល្ហែម ធ្វើឲ្យ យូលី ដែលអង្គុយលើរទេះរុញនៅមិនឆ្ងាយប៉ុន្មាន ត្រូវខាំធ្មេញក្រតៗដោយអារម្មណ៍ប្រចណ្ឌហួងហែង។

"ខ្ញុំមានរឿងសំខាន់ត្រូវមកសុំយោបល់ពីលោកនាយក"

"អ៊ីចឹងចាំឲ្យខ្ញុំត្រឡប់ទៅធ្វើការវិញសិនបានទេ ព្រោះពេលនេះខ្ញុំសុំច្បាប់"

ជីយ៉ន ធ្វើទឹកមុខអន្ទះអន្ទែង។



"ចាំមិនបានទេ គឺ...ថាប្រញាប់ធ្វើឲ្យរួច"

"ស្អីឬ?"

"លោកនាយក ចាំការតាំងពិព័រណ៍ស្រឡាញ់ការអានលើកទីដប់ពីរបានទេ ដែលរៀបចំឡើងនៅថ្ងៃខានស្អែកនេះ"

"បាទ ចាំបាន"

អ្នកកំលោះងក់ក្បាល ហើយនាំនាងដើរចូលបន្ទប់ទទួលភ្ញៀវ ពេលឮថាជាការងារសំខាន់ ខណៈដែល យូលី ប្រាប់ឲ្យអ្នកមើលថែរបស់ខ្លួនរុញរទេះទៅឈប់នៅមុខបន្ទប់ទទួលភ្ញៀវភ្លាម ដើម្បីលួចស្ដាប់។

"គឺមានរឿងជាច្រើនទៀតដែលមិនទាន់រួចរាល់ ជាពិសេសរឿងទីតាំង"

"តែរឿងនេះពេលប្រជុំ យើងបានចាត់ចែងឲ្យទទួលខុសត្រូវតាមតួនាទីហើយមិនអ៊ីចឹង ខ្ញុំថាមិនគួរមានបញ្ហា"

"របស់អ្នកផ្សេងគ្មានបញ្ហាអីទេ តែរបស់ខ្ញុំ..." សាស្ត្រាចារ្យក្រមុំធ្វើជាសោកសៅ សម្រក់ទឹកភ្នែក "ឲ្យខ្ញុំសុំទោសផងដែលគ្មានសមត្ថភាព តែខ្ញុំសម្រេចចិត្តមិនបានពិតមែនថាគួរធ្វើយ៉ាងណា"

"ខ្ញុំជឿជាក់សាស្ត្រាចារ្យ យ៉ាងណាការងារត្រូវតែចេញមកល្អ"

"តែខ្ញុំមិនជឿជាក់ខ្លួនឯង"

និយាយហើយ ជីយ៉ន ក៏ងើយមុខ មកប្រសព្វនឹងភ្នែករបស់ ម៉ាទិនេស ដោយមានចេតនាដាក់ស្ពានឲ្យ តែអ្នកកំលោះមិនបានបង្ហាញឫកពាថាដឹងឮអ្វីឬនិយាយឲ្យស្រួលស្ដាប់គឺមិនបានចាប់អារម្មណ៍។

"ទើបខ្ញុំត្រូវពន់មុខមករកលោកនាយក...រំខានឲ្យលោកនាយកទៅជួយសម្រេចចិត្តឲ្យបន្តិច"



"ខ្ញុំមិនទំនេរទេ"

"សូមអង្វរលោកនាយក ចាត់ទុកជាធ្វើដើម្បីឲ្យការពិព័រណ៍លើកនេះទទួលបានភាពជោគជ័យផងទៅ ហើយចាត់ទុកជាជួយឲ្យខ្ញុំរួចផុតពីការត្រូវមិត្តរួមការងារសើចចំអក"

ជីយ៉ន សម្រក់ទឹកភ្នែក និងនិយាយឲ្យខ្លួនឯងមើលទៅគួរឲ្យអាណិតបំផុត ធ្វើឲ្យ ម៉ាទិនេស រារែក ប៉ុន្តែមិនទាន់បានឆ្លើយផង សំឡេងកង់រទេះរុញក៏បន្លឺឡើងទើបងាកទៅមើលឃើញថា យ្យូលី ឆ្លងកាត់មកបន្ទប់ទទួលភ្ញៀវល្មម។ អ្នកកំលោះតាមមើលដោយទឹកមុខរាបស្មើក៏ពិតមែន តែចិត្តវិញវាផ្ទុយពីនោះ។

"អូខេ តែខ្ញុំត្រូវនាំភរិយាទៅដែរ"

ជីយ៉ន ធ្វើទឹកមុខមិនពេញចិត្ត តែប្រញាប់សើចបន្លប់។

"ចាស បានតើ លោកស្រី អ៊ីន គួរតែមានគំនិតចំពោះរឿងនេះគួរសម នាងនឹងបានជួយរើសម៉ូតស្អាតៗឲ្យខ្ញុំដែរ"

ម៉ាទិនេស ងើបឈរ និងញញឹមដាក់ភ្ញៀវ។

"ខ្ញុំក៏គិតថាអ៊ីចឹង លីលី មានគំនិតផ្នែកសិល្បៈ និងការតុបតែង"

ជីយ៉ន ខាំធ្មេញ ពេលបានឮការសរសើរភរិយាពីមាត់របស់ ម៉ាទិនេស បុរសដែលនាងលួចប៉ងប្រាថ្នា។

"ល្អមែនទែន នេះបើមិនទាស់ត្រង់ថាលោកស្រី អ៊ីន ពិការ ថ្មើរណោះនាងជាវិចិត្រករល្បីទៅហើយ"

ជីយ៉ន ពេញចិត្តដែលបានដៀមដាម ប៉ុន្តែបានត្រឹមមួយវិនាទីប៉ុណ្ណោះ ព្រោះទឹកមុខរបស់ ម៉ាទិនេស ឡើងម៉ាំ ដែលធ្វើឲ្យនាងប្រញាប់កែខៃពាក្យសម្ដីរបស់ខ្លួន។

"ខ្ញុំចង់មានន័យថាលោកស្រី អ៊ីន គួរតែធ្វើគ្រប់យ៉ាងបានល្អ មិនថានាងនៅក្នុងសភាពបែបណាក៏ដោយ"



"បាទ ព្រោះសម្រាប់ខ្ញុំ លីលី មិនធ្លាប់ពិការទេ"

"អូ...ចាំ...មែន" ជីយ៉ន ខាំធ្មេញតប និងសើចបន្លប់។

"សាស្ត្រាចារ្យ គីម ទៅចាំនៅមហាវិទ្យាល័យមុនទៅ ខ្ញុំទៅតាមក្រោយ"

"អឺ...ខ្ញុំជិះតាក់ស៊ីមក បើលោកនាយកមិនរើសអើង ខ្ញុំសុំដោយសារឡានទៅផងបានទេ"

កែវភ្នែករបស់ ម៉ាទិនេស ឡើងរឹង តែមិនប៉ុន្មានវិនាទីក៏ជម្មតាវិញ ដូចសំឡេងដែលបន្លឺឡើង។

"បាទ"

"អរគុណច្រើន" នាងងក់ក្បាលដាក់គេដោយការសប្បាយចិត្ត។

"អ៊ីចឹងរង់ចាំមួយភ្លែត ខ្ញុំទៅប្រាប់ភរិយាខ្ញុំសិន"

"អញ្ជើញតាមសម្រួល ខ្ញុំរង់ចាំបាន"

ម៉ាទិនេស ញញឹមម្ដងទៀត ហើយដើរចេញពីបន្ទប់ទទួលភ្ញៀវ ឯ ជីយ៉ន ញញឹមញញែមពេលនៅម្នាក់ឯង ភ្នែកមើលទៅជុំវិញខ្លួន ទឹកមុខក៏រំភើប។

"មានសុទ្ធតែរបស់ល្អៗថ្លៃៗ បែបនេះសមាមាត្របន្តិចនឹងការដណ្ដើម"

កែវភ្នែករបស់នាងបង្ហាញឲ្យឃើញពីភ្លើងឫស្យានិងញញឹមពេញចិត្តម្ដងទៀត ពេលដឹងខ្លួនជិតបានជិះរថយន្តស្គតជាមួយ ម៉ាទិនេស តែពីរនាក់ ព្រោះជឿជាក់ថាប្រពន្ធខ្វិនរបស់គេជិះឡានរបស់ខ្លួន។

"អ្នកណាប្រើឲ្យពិការ ជួយមិនបានទេ ហ៊ឺៗ"

"ខ្ញុំមិនទៅ អញ្ជើញបងទៅម្នាក់ឯងទៅ" យ្យូលី បដិសេធដោយសំឡេងរឹងកំព្រឹស ពេលស្វាមីដើរមកប្រាប់ថាគេនឹងនាំនាងទៅមើលការងារនៅមហា-វិទ្យាល័យ ទាំងដែលគេសុំច្បាប់សម្រាកសោះ ប៉ុន្តែបែរជាត្រូវចេញទៅធ្វើការងារ



ទៀត ប្រហែលមកពីស្រីម្នាក់នោះ។

"អូនត្រូវទៅ ព្រោះពេលចេញពីមហាវិទ្យាល័យ យើងនឹងទៅមើលកុន"

"ខ្ញុំប្រាប់ថាមិនទៅគឺមិនទៅ" នាងងាកទៅប្រកែក ទឹកមុខបង្ហាញឲ្យឃើញពីការតូចចិត្ត។

"អ្នកនាង ធ្វើចិត្តឲ្យត្រជាក់" ហុងស៊ីល ដែលឈរបួញខ្លួននៅក្នុងហេតុការណ៍ ដាស់តឿនស្មារតីរបស់ចៅហ្វាយ តែ យ៉ូលី មិនខ្វល់។

"នាំខ្ញុំទៅសួនបន្តិច ខ្ញុំចង់ទៅស្រូបយកខ្យល់អាកាស"

"កុំជំទាស់បញ្ជាបង លីលី បងប្រាប់ថាឲ្យទៅគឺត្រូវតែទៅ" អ្នកកំលោះដើរមកពាំងមុខហើយអង្គុយចោងហោងលើកែងជើង និយាយដោយចិត្តត្រជាក់ "កុំរឹងដូចកូនក្មេងទៀត ពេលនេះអូនរៀបការជាមួយបងរួចហើយ"

"គ្រាន់តែជាមង្គលការ មិនឃើញមានអីប្រែប្រួល រឿងរវាងយើង"

ម៉ាទិនេស ដកដង្ហើមធំ ហើយងើបឈរ ប៉ុន្តែឱនមកសម្លឹងមុខនាង។

"ឲ្យ ហុងស៊ីល ទៅតែងខ្លួនឲ្យ បងទៅចាំនៅឡាន"

"ខ្ញុំប្រាប់ថាមិនទៅ!"

"អីចឹងបងតែងខ្លួនឲ្យអូន"

ពេលបានឮប្រយោគនេះ ថ្ពាល់របស់នាងក្រមុំក៏ឡើងក្រហម។

"ជ្រើសរើសទៅ ឲ្យ ហុងស៊ីល ជួយតែងខ្លួនឲ្យ ឬឲ្យបងជួយតែង"

សំឡេងរបស់គេរាបស្មើ ប៉ុន្តែមួយភ្លែតនោះនៅក្នុងកែវភ្នែករបស់គេមានភ្លើងម្យ៉ាង ទាស់ត្រង់នាងថាមើលមិនទាន់ មិនយល់ពីន័យផង វាក៏រលុបបាត់។

"អីចឹងឲ្យលោក ម៉ាត ជួយអ្នកនាងទៅ" ហុងស៊ីល បង្ហាប់ ដោយទឹកមុខញញឹម ដែលធ្វើឲ្យ យ៉ូលី អឹមអៀន។

"បងជួយខ្ញុំតែងខ្លួនបន្តិច"



ម៉ាទិនេស អស់សំណើចតិចៗ ហើយងើបឈរត្រង់ខ្លួន។

"តែប៉ុណ្ណឹង អីចឹងបងទៅចាំនៅឡាន សង្ឃឹមថាមិនបាច់ឡើងទៅតាមទៀត"

"មនុស្សផ្ដាច់ការ" នាងតវ៉ាគេនឹងមុខ តែ ម៉ាទិនេស គិតតែញញឹម ហើយគ្រវីក្បាលដាក់ បន្ទាប់មកក៏ដើរចេញពីបន្ទប់ផ្សំដំណេក ដោយ យ៉ូលី នៅតែមានមុខក្រហមប្រឿងៗ ធ្វើឲ្យ ហុងស៊ីល អត់បង្ហាប់មិនបាន។

"ការពិតអ្នកនាងគួរតែឲ្យលោក ម៉ាត ជួយតែងខ្លួនឲ្យ"

"ហុងស៊ីល ម៉េចក៏និយាយបែបនេះ ខ្ញុំជាមនុស្សស្រី"

"អីយ៉ា លោក ម៉ាត មិនមែនអ្នកដទៃសម្រាប់អ្នកនាងឯណា ជាស្វាមីតើ"

អ្នកដែលអង្គុយលើរទេះរុញ ពេបមាត់ដោយការឈឺចិត្ត។

"គ្រាន់តែជាស្វាមីក្នុងនាម ដែលរៀបការព្រោះការចាំបាច់"

"កុំគិតច្រើនអីអ្នកនាង ត្រឹមលោក ម៉ាត ល្អដាក់អ្នកនាង គឺគួរតែគ្រប់គ្រាន់ហើយ"

នាងក្រមុំឈ្ងោកមុខមើលដៃខ្លួនឯងដែលស្រាក់ដាក់លើភ្លៅ ដោយមានទឹកភ្នែកស្រក់តក់ៗដាក់។

នាងត្រូវការបេះដូងរបស់ ម៉ាទិនេស ត្រូវការមករហូត តែដឹងច្បាស់ថាសាច់មួយដុំនោះគ្មានថ្ងៃក្លាយជារបស់ខ្លួន ទោះយ៉ាងណា ក៏ ម៉ាទិនេស មិនស្រឡាញ់ស្រីខ្វិនដូចនាងដែរ។

**ពេលឃើញ យ៉ូលី តាមកន្ទុយភ្នែក ដីយ៉ន ក៏ធ្វើជាសើចកក្អិចដាក់** ម៉ាទិនេស ហើយធ្វើជាជំពប់ដួល ដើម្បីឲ្យអ្នកកំលោះជួយទប់។



"អ៊ូយ! សុំទោសលោកនាយក ខ្ញុំស្លាក់ស្លើតបន្តិច"

ម៉ាទិនេស ជួយគ្រាហ៍ហើយនិយាយតាមច្បាប់សុភាពបុរស។

"មិនបាច់សុំទោសទេ វាជាឧបទ្ទវហេតុ ប៉ុន្តែជើងអូខេទេ ?"

"អូខេ មិនធ្ងន់ធ្ងរទេ"

ជីយ៉ន ធ្វើមុខគួរឲ្យអាណិតដាក់អ្នកកំលោះ ហើយងាកទៅធ្វើមុខធ្វើមាត់បេះបួយដាក់ យូលី ដែលត្រូវ ហុងស៊ីល រុញរទេះចូលមកជិត។

"អរគុណលោកនាយកដែលបារម្ភពីខ្ញុំ"

"បាទ" អ្នកកំលោះញញឹម ហើយងាកទៅរក យូលី ពេលឃើញថានាងមកដល់ហើយ "ហុងស៊ីល រុញ លីលី ទៅឡានរបស់ខ្ញុំ"

"ចាំ លោក ម៉ាត" ហុងស៊ីល ធ្វើតាមបញ្ជា តែត្រូវថៅហ្វាយផ្ទាល់ខ្លួនស្រែកសួរស្វាមីក្មុងនាមដោយការសង្ស័យ។

"ម៉េចចាំបាច់ទៅឡានរបស់បង ម៉ាត ?"

"មែនហ្នឹង" ជីយ៉ន ក៏សង្ស័យដែរ ហើយក៏មិនពេញចិត្តជាខ្លាំង ខណៈដែល ម៉ាទិនេស ញញឹម ឱនទៅមើលមុខភរិយា។

"អូនជាភរិយារបស់បង គឺត្រូវតែជិះឡានជាមួយបង"

"តែលោកស្រី អឺន គួរតែអង្គុយមិនស្រួល គួរតែជិះឡានធំជាង នៅមានរទេះរុញទៀត" ជីយ៉ន បញ្ចេញយោបល់។

"មែនហ្នឹង ឲ្យខ្ញុំទៅឡានរបស់ខ្ញុំដូចមុនទៅ"

ម៉ាទិនេស គ្រវីក្បាលតិចៗ។

"មិនបាន បងមិនអនុញ្ញាត"

និយាយហើយ គេក៏លើកបីនាងភ្លាម ធ្វើឲ្យ យូលី ភ្ញាក់ព្រើត រហ័សលើកដៃឱប.កគេ។

"បង ម៉ាត...ដាក់ខ្ញុំចុះ"



អ្នកកំលោះគ្រវីក្បាលម្តងទៀត។

"កុំរឹង"

បន្ទាប់មកគេក៏បីនាងសំដៅរថយន្តស្ពត ដោយមាន ហុងស៊ីល ម្ចីម្នាដើរទៅបើកទ្វារឲ្យ ឯ ជីយ៉ន ក៏រត់តាមដែរ និងសួរដោយការឃ្នើសចិត្ត។

"ហើយខ្ញុំទៅយ៉ាងម៉េច លោកនាយក ?"

បន្ទាប់ពី ម៉ាទិនេស ដាក់ភរិយាយក្នុងរថយន្តស្ពតរបស់ខ្លួនរួចរាល់ ទើបងាកមកប្រាប់មិត្តរួមការងារ ដោយញញឹមដាក់យ៉ាងសុភាព។

"សាស្ត្រាចារ្យ គីម ជាភ្ញៀវ ទៅឡានធំល្អជាង"

"តែ..."

"ចាំជួបគ្នានៅមហាវិទ្យាល័យ" ពេលប្រាប់ភ្ញៀវហើយ គេក៏ងាកមករកហុងស៊ីល "ហុងស៊ីល យករទេះរបស់អ្នកនាងឡើងឡានផង"

"បាសលោក ម៉ាត" ហុងស៊ីល ទទួលបញ្ជាដោយទឹកមុខញញឹម។

ម៉ាទិនេស ញញឹមដាក់ម្តងទៀត ហើយដើរវាងទៅឡើងខាងចង្កូតដោយមាន ជីយ៉ន តាមមើលដោយការមិនពេញចិត្ត ព្រោះគិតថាខ្លួនគួរតែបានអង្គុយពើងទ្រូងជំនួសកន្លែងដែល យូលី អង្គុយ។

ហុងស៊ីល តាមមើលឡានរបស់ថៅហ្វាយទាល់តែបាត់ពីភ្នែក ហើយងាកមកធ្វើមុខមិនពេញចិត្តដាក់ ជីយ៉ន។

"ប្តីគេគឺត្រូវតែរើសប្រពន្ធគេជារឿងធម្មតា គ្រាន់តែជាកូនឈ្នួល គ្មានអ្នកណាគេចាប់អារម្មណ៍ទេ"

"នេះឯងថាឲ្យអ្នកណាហ៎ា!" ជីយ៉ន ងាកមកសម្លក់សម្លឹង ហុងស៊ីល។

"គឺពួកមិនប្រមាណខ្លួន"

និយាយហើយ ហុងស៊ីល ក៏រុញរទេះរុញរបស់ថៅហ្វាយសំដៅឡានធំ



ដែលថៃកុងកំពុងរង់ចាំ។

"មិឆ្កួត...ឯងថាឲ្យយើងតើ!"

គ្មានអ្នកណាគេយកចិត្តទុកដាក់នឹង ជីយ៉ន ព្រោះមិនយូរប៉ុន្មាន ឡានធំក៏បើកចេញពីចំណតនៅមុខភូមិគ្រឹះស្ដឹមស្ដៃកាត់មុខ ទើបនាងស្រែកហៅ តែឡានមិនព្រមឈប់។

"អាពួកចង្រៃយក៏!"

លទ្ធផល នាងបានត្រឹមតែស្រែកប្រកាច់ប្រកិនម្នាក់ឯងប៉ុណ្ណោះ ហើយក៏ដើរហូរញើសកក្លាក់ទៅបក់ដៃហៅតាក់ស៊ី។

យ៉ូលី គិតតែអង្គុយស្ងប់ស្ងាត់នៅក្នុងរថយន្ត ខណៈដែល ម៉ាទិនេស បើកចម្រៀងកំដរអារម្មណ៍ និងច្រៀងតាមឲ្យរហ៊ឹម ធ្វើឲ្យនាងអត់ជ្រេញមិនបាន ព្រោះគិតថាការដែលគេមានអារម្មណ៍ល្អបែបនេះ ព្រោះមកពីស្រីមាត់ក្រហមម្នាក់នោះ។

"តាមពិតទៅបង ម៉ាត គួរតែឲ្យស្រីម្នាក់នោះមកអង្គុយជំនួសខ្ញុំ"

"អូនចង់មានន័យដល់សាស្ត្រាចារ្យ គីម?" អ្នកកំលោះសួរដោយសំឡេងរាបស្មើ។

"ចាស"

គេសើចញឹមៗ។

"ឡានរបស់បងត្រូវតែឲ្យប្រពន្ធអង្គុយ ម៉េចនឹងឲ្យអ្នកផ្សេងមកអង្គុយបានទៅ"

នាងគួរតែសប្បាយចិត្តមែនទេនឹងចម្លើយគ្មានអារម្មណ៍របស់ ម៉ាទិនេស ...នាងក្រមុំក្ដាប់ដៃណែន។



"តែសាស្ត្រាចារ្យ គីម អាចមិនពេញចិត្តក៏ថាបាន"

លើកនេះអ្នកកំលោះងាកមកមើលអ្នកអង្គុយក្បែរមួយដង្ហើម។

"បងចាំបាច់ត្រូវចាប់អារម្មណ៍ដែរឬ?"

មែនហើយថ្នាក់នាងជាប្រពន្ធ គេមិនឃើញចាប់អារម្មណ៍ផង។

"មិនដឹងទេ ក្រែងលោជួនកាលបងក្រែងចិត្តនាងក៏ថាបាន"

"សាស្ត្រាចារ្យ គីម គ្រាន់តែជាបុគ្គលិកនៅមហាវិទ្យាល័យ គ្មានអីលើសពីនោះ អូនសប្បាយចិត្តចុះ ឈប់ប្រចណ្ឌទៅ"

អ្នកដែលត្រូវនិយាយចំ ភ្ញាក់ព្រើត មុខក្ដៅភាយៗ តែប្រញាប់បដិសេធបន្លប់ដោយការដំឡើងសំឡេង។

"អ្នកណា...អ្នកណាថាខ្ញុំប្រចណ្ឌ..."

ម៉ាទិនេស អស់សំណើចតិចៗ គ្រវីក្បាលហួសចិត្ត ខណៈនោះក៏យកចិត្តទុកដាក់បញ្ឆោចង្កូតឡាន ដោយមិននិយាយអ្វីទៀត។

យ៉ូលី លួចព្រួសខ្យល់ដង្ហើមចេញមកតាមមាត់តិចៗ ខណៈដែលមុខនៅតែក្ដៅគគុក និងក្រហមឆ្អាំង។

មួយសន្ទុះ រថយន្តស្ពតទំនើបក៏បើកមកចតនៅមុខហាងកាហ្វេមួយដែលតុបតែងឲ្យអារម្មណ៍ត្រជាក់ស្រួល។ យ៉ូលី មើលតាមកញ្ចក់បង្អួចរថយន្ត ហើយងាកមកមើលចំហៀងមុខសង្ហារបស់ ម៉ាទិនេស។

"បង ម៉ាត ចតធ្វើអី?"

"អូនចូលចិត្តញ៉ាំខេកមិនអីចឹង"

មែនហើយនាងចូលចិត្តញ៉ាំខេក តែមិនមែនជារឿងដែល ម៉ាទិនេស ត្រូវមកយកចិត្តទុកដាក់មិនអីចឹង!



"មែន តែពេលនេះបង ម៉ាត ត្រូវត្រឡប់ទៅមហាវិទ្យាល័យ ភ្លេចហើយ



Scanned with CamScanner

ឬថាសាស្ត្រាចារ្យ គីម រង់ចាំ"

អ្នកកំលោះញាក់ស្មាបន្តិច ហើយដោះខ្សែក្រវ៉ាត់ការពារពីខ្លួន លោមករកនាង។ ក្លិនក្រអូបប្រហើរដែលជាក្លិនខ្លួនរបស់គេ ភាយចូលច្រមុះ ធ្វើឲ្យនាងស្រវឹង និងក្តៅខ្លួនភ្លាម។

"បង ម៉ាត...ចង់ធ្វើអី ?"

នាងសួរដោយសំឡេងញ័រ និងបើកភ្នែកធំៗ ពេលមុខសង្ហាចូលមកជិតកាន់តែកៀក ធ្វើឲ្យចំហាយក្តៅឧណ្ហៗចេញពីខ្យល់ដង្ហើមរបស់គេស្រោចលើថ្ពាល់របស់នាង។

អ្នកកំលោះញញឹម គ្រវាសច្រមុះលើថ្ពាល់រលោង ហើយជួយដោះខ្សែក្រវ៉ាត់ការពារឲ្យ ពេលរួចរាល់ទើបងើបមកអង្គុយត្រង់ខ្លួន។

នាងក្រមុំដកដង្ហើមចូលមិនពេញពោះមុខមាត់ក្រហមង៉ាំងនិងប្រឹងថយទៅពិតខ្នងនឹងទ្វារឡានខាងខ្លួន។

"គិតថាបងធ្វើអី"

"អត់ អត់មានទេ"

គេមើលមកដោយទឹកមុខញឹមៗ។

"យើងចូលទៅញ៉ាំខេកប្អូនដប់ជុំសិនទៅ ហើយចាំទៅមហាវិទ្យាល័យ" គេនិយាយលេង ហើយចុះពីឡាន ដើរវាង មកបើកទ្វារឲ្យនាង។

"ខ្ញុំគ្មានរទេះ...អូយ..."

នាងនិយាយមិនទាន់ចប់ស្រួលបួលផង ក៏ត្រូវគេលើកបី។

"បង ម៉ាត...ដាក់ខ្ញុំចុះ"

អ្នកកំលោះងើបឈរត្រង់ខ្លួន សើចក្អាកក្អាយ ហើយប្រើត្រគាកម៉ាំមួនរុញទ្វារបិទ និងចាក់សោរ។



"បើដាក់ចុះ ធ្លាក់ស្លាប់ល្មម"

អ្នកកំលោះញញឹម ហើយបីនាងចូលហាងកាហ្វេ និងដើរតាមបុគ្គលិកនាំនាងទៅដាក់លើសាឡុង។

"ញ៉ាំខេកអីដែរ ?"

អ្នកកំលោះដាក់បង្អួយក្បែរ ព្រមទាំងងាកមកសួរដោយការយកចិត្តទុកដាក់ យកចិត្តទុកដាក់ដែលធ្វើឲ្យនាងមានអារម្មណ៍ថាមិនស៊ាំ។

"បង ម៉ាត ខិតចេញបន្តិចទៅ ខ្ញុំថប់ដង្ហើម"

គេនៅតែអង្គុយធ្វើព្រងើយ បៀតនាងដូចដើម ទើប យ្យូលី ខាំមាត់ឈ្ងោកមុខឈ្ងោកមាត់គេចពីខ្សែភ្នែក មានស្នាមញញឹមរបស់បុគ្គលិកដែលមើលមក។

"យកខេកក្រូច និងខេកសូកូឡា" គេកុម្ម៉ង់ខេកដែលនាងចូលចិត្ត ហើយងាកមករកនាងម្តងទៀត "អូនយកភេសជ្ជៈអី កាហ្វេ ?"

"អត់ទេ ខ្ញុំសុំទឹកសុទ្ធ"

អ្នកកំលោះញញឹមដាក់នាង ហើយងាកទៅរកបុគ្គលិក។

"អីចឹងសុំទឹកសុទ្ធមួយកែវ កាប៉ូជីណូក្តៅមួយពែង"

"សូមចាំមួយភ្លែត" បុគ្គលិកទទួលយកមីនុយវិញ ហើយដើរចេញទៅភ្លាម។

ពេលនៅជាមួយគ្នាតែពីរនាក់ យ្យូលី អត់មិនបាននឹងរករឿងបញ្ឈឺដងគេទៀត។

"មិនស្មានថាសាស្ត្រាចារ្យមីះៗដូចបង ម៉ាត ក៏ចេះខូចដែរ"

អ្នកកំលោះញញឹម មើលភរិយា។



"បងនៅមានរឿងជាច្រើនទៀត ដែលលាក់នៅក្រោមបុគ្គលិកលក្ខណៈ

ដែលគ្រប់គ្នាឃើញ អូននឹងបានឃើញវាម្ដងបន្តិចៗ ហើយបងសង្ឃឹមថាអូនទប់ទល់នឹងវាបាន"

"មានអ្វីដែលអាក្រក់ជាងនេះទៀតឬ"

"មិនដឹងទេថាអាក្រក់ ឬល្អ ដឹងត្រឹមថាយ៉ាងណាអូនត្រូវតែទប់ទល់ឲ្យបាន ព្រោះយើងទាំងពីររៀបការរួចហើយ"

"រៀបការរួចក៏អាចលែងលះបាន"

"បងមិនមែនជាមនុស្សប្រុសដែលនិយមរៀបការច្រើនដង ត្រឹមម្ដងក្នុងមួយជីវិតគឺគ្រប់គ្រាន់ពេកហើយ"

សំឡេងរបស់គេប្រាកដប្រជា ប្រាប់ឲ្យដឹងថាអ្នកនិយាយគ្មានអារម្មណ៍លេងសើចៗ

"តែខ្ញុំមិនចង់ធ្វើឲ្យបង ម៉ាត ត្រូវយកអនាគតមកបោះចោលលើមនុស្សពិការដូចខ្ញុំ ត្រឹមបងព្រមរៀបការជាមួយខ្ញុំតាមសំណូមពររបស់ចាស់ទុំ ប៉ុណ្ណឹងគឺលើសពេកហើយ"

"កុំគិតជំនួសបង រឿងខ្លះអូនមិនអាចដឹងក៏ថាបាន" គេសម្លឹងមើលមុខនាងមិនដាក់ភ្នែក ខ្សែភ្នែកជ្រាលជ្រៅ មិនអាចវាស់ស្ទង់ដឹងជម្រៅរបស់វា។

យ៉ូលី ងាកមុខចេញ ដែលស្របពេលនេះ ទូរសព្ទដៃរបស់ ម៉ាទិនេស ក៏បន្លឺឡើង។

"ហាឡូ"

(លោកនាយក ខ្ញុំចាំយូរហើយ មិនឃើញលោក?)

សំឡេងរបស់ ជីយ៉ន ឮឲ្យស្រួចរលែមចេញពីទូរសព្ទ ទើប ម៉ាទិនេស មើលមុខនាងបន្តិច ហើយឆ្លើយតប។

"ខ្ញុំនិងភរិយាជាប់ធុរៈនៅតាមផ្លូវ មិនលើសពីមួយម៉ោង ខ្ញុំនឹងទៅដល់



មហាវិទ្យាល័យ ប៉ុណ្ណឹងចុះ"

(ឈប់សិន លោកនាយក...)

ម៉ាទិនេស លែងចាប់អារម្មណ៍អ្នកស្រែកហៅតាមទូរសព្ទ និងចុចផ្ដាច់ការសន្ទនាភ្លាម។

"បង ម៉ាត គួរតែយកចិត្តទុកដាក់នាងខ្លះទៅ ព្រោះមើលទៅនាងចាប់អារម្មណ៍បងជាពិសេស"

"ពេលនេះបងមានអូនទាំងមូលទៅហើយ បងមិនចាប់អារម្មណ៍អ្នកណាទៀតទេ"

នាងក្រមុំគេចពីខ្សែភ្នែករបស់គេ ដោយមិនគិតថាជឿសម្ដីរបស់គេ។

អ្នកណាប្រាកដប្រជានឹងស្រីខ្វិនដូចនាងទៅ ជាមនុស្សប្រុសសម្បូរបែបដូច ម៉ាទិនេស។

មួយសន្ទុះបុគ្គលិកក៏លើកខេកមកឲ្យ ក្លិនរបស់វាជារសជាតិដែលនាងចូលចិត្តខ្លាំង ធ្វើឲ្យនាងញញឹមដោយមិនដឹងខ្លួន។ នាងដួសខេកសាច់ម៉ដ្ឋខៃទទួលទានមួយម៉ាត់ហើយមួយម៉ាត់ទៀត ដោយការពេញចិត្តរបស់ ម៉ាទិនេស ដែលអង្គុយមើល។

"បើអស់ចាំបងកុម្ម៉ង់ឲ្យទៀត"

អ្នកដែលកំពុងតែហាមាត់ទទួលទានក៏ទៅជាចំហមាត់ឆ្គង បន្ទាប់មកក៏និយាយដោយការអឹមអៀន។

"ខ្ញុំញ៉ាំតែប៉ុណ្ណឹងទេ ច្រើនជាងនេះខ្លាចធាត់"

"បើចូលចិត្ត ញ៉ាំទៅ បងចង់ឃើញអូនមានសេចក្ដីសុខ"

នាងក្រមុំសម្លឹងមើលមុខគេ ហើយមើលមកខេកក្រូចរបស់ខ្លួន ដោយបេះដូងលោតញាប់។ នាងស្អប់ខ្លួនឯងណាស់ដែលមិនធ្លាប់ហាមចិត្តស្រឡាញ់



ដែលមានចំពោះគេបាន ត្រឹម ម៉ាទិនេស ធ្វើល្អដាក់បន្តិច នាងក៏ឈ្លក់វង្វេងខ្លាំងដល់ថ្នាក់នេះទៅហើយ។

*បេះដូងអើយបេះដូង...ម៉េចក៏មិនចេះស្ដាប់បង្គាប់បែបនេះ!*



# ៣

ពេលឃើញរថយន្តស្ពតរបស់ ម៉ាទិនេស ចូលមកចត ជីយ៉ន ក៏ស្ទុះរត់ទៅរកភ្លាម ដោយមាន យ៉ូលី សម្លឹងមើលតាមកញ្ចក់រថយន្ត ដោយការមិនពេញចិត្ត តែព្យាយាមលាក់វាអស់ពីសមត្ថភាព ពេលងាកទៅអ្នកនៅក្បែរខ្លួន។

"បង ម៉ាត ឆាប់ទៅៗ"

នាងប្រញាប់ប្រញាល់ដោះខ្សែក្រវាត់ការពាររបស់ខ្លួន ព្រោះមិនចង់ញាប់ញ័រ ដោយសារភាពស្និទ្ធស្នាលទៀត។

"ម៉េចចាំបាច់ដេញ បងនាំអូនមកគឺត្រូវតែមើលថែអូន"

អ្នកកំលោះបើកទ្វារចុះ ហើយដើរមកបើកទ្វារខាងនាង និងឱនមករក។

"ចាំរទេះរុញមួយភ្លែត លីលី"

អ្នកកំលោះនិយាយដោយសំឡេងពីរោះ ប៉ុន្តែហេតុអ្វីបេះដូងរបស់នាងទៅជាឈឺចាប់ដល់ថ្នាក់នេះ ប្រហែលមកពីខ្សែភ្នែកប្រមាថមើលងាយរបស់ ជីយ៉ន ដែលមើលមកនោះឯង។

"បង ម៉ាត ទៅចុះ ខ្ញុំរង់ចាំ ហុងស៊ីល ម្នាក់ឯងបាន"

"បងជាស្វាមីរបស់អូន ត្រូវតែមើលថែអូនឲ្យបានល្អ"

សម្ដីរបស់ ម៉ាទិនេស ធ្វើឲ្យ ជីយ៉ន លួចពេបមាត់ដោយការជិនឆ្អន់ តែគេចមិនផុតពីខ្សែភ្នែករបស់ យ៉ូលី។

មិនប៉ុន្មាននាទីក្រោយមក ហុងស៊ីល ក៏រុញរទេះមករកចៅហ្វាយ ទើប ម៉ាទិនេស លើកបីភរិយាមកដាក់លើរទេះរុញថ្នមៗ។



"អរគុណ"

ពេលឃើញ ម៉ាទិនេស គិតតែយកចិត្តយកថ្លើមភរិយាខ្វិន ជីយ៉ន អត់មិនបាននឹងដៀមដាមតាមចរិត។

"តាមចិត្តលោកស្រី អ៊ិន ទៅ លោកនាយក យ៉ាងណាចូលទៅក៏ជួយអ៊ីមិនបាន ថ្នាក់ខ្លួនឯងជួយមិនបានផង"

"លីលី ជាមនុស្សពូកែ ទោះរាងកាយមិនពេញលក្ខណៈ ប៉ុន្តែខួរក្បាលពេញមួយរយភាគរយ ខ្ញុំហ៊ានធានា"

"អឺ...ខ្ញុំគ្រាន់តែមិនចង់រំខានលោកស្រី អ៊ិន ប៉ុណ្ណោះលោកនាយក"

ជីយ៉ន ប្លោះទឹកមុខ ពេល ម៉ាទិនេស តវ៉ា ជំនួសភរិយាខ្វិនរបស់គេ។

ខណៈដែល យូលី ងើបភ្នែកមើលស្វាមីជាការអរគុណ ទោះមិនសូវជឿជាក់ថា គេមានចេតនាការពារនាង ឬគ្រាន់តែការពារកិត្តិយស កេរ្តិ៍ឈ្មោះរបស់ខ្លួនឯង។

ម៉ាទិនេស ញញឹមសោះកក្រោះដាក់ អ្នកនៅក្រោមកបង្គាប់បញ្ជា ហើយរុញរទេះរបស់ភរិយាចូលកន្លែងសម្រាប់រៀបចំកម្មវិធីតាំងពិព័រណ៍ ខណៈពេលដែល ជីយ៉ន តាមមើលដោយកំហឹង។

"មិនដឹងជាការពារស្អីណាស់ណា គ្រាន់តែមីខ្វិនម្នាក់"

"ប្តីស្រឡាញ់ប្រពន្ធគេខ្លាំង ពួកឆ្កែបានតែព្រួសឈើ.កប៉ុណ្ណោះ"

ហុងស៊ុល សើចចំអក ហើយក៏ដើរពើងទ្រូងតាមចៅហ្វាយទាំងពីរចូលទៅខាងក្នុង។

"មីកញ្ជះ"

ជីយ៉ន ខាំធ្មេញក្រតៗ ដោយការមួម៉ៅ ហើយក៏ដើរចូលទៅខាងក្នុងដោយចៀសមិនបាន។



...

យូលី អង្គុយមើលខ្នងរបស់ ម៉ាទិនេស ដែលនៅឆ្ងាយគួរសមដោយអារម្មណ៍ភ្លឹកភ្លាំង ក្នុងខួរក្បាលមានរឿងជាច្រើនដែលពិបាកនឹងដោះស្រាយ ទោះគេសុភាព ទន់ភ្លន់ និងយកចិត្តទុកដាក់ចំពោះនាងយ៉ាងណា ប៉ុន្តែនាងដឹងច្បាស់ថា តាមពិតទៅគេគ្មានសេចក្តីសុខ។

ការខូចចិត្តនិងវេទនា វាស្ទះពេញក្នុងទ្រូង ដែលវាមានឥទ្ធិពលចំពោះសភាពផ្លូវចិត្តជាខ្លាំង ទឹកភ្នែកក៏រលីងរលោង ហើយរឹះតែស្រក់ បើមិនបានឮសំឡេងសម្រិបជើងមនុស្សចូលមកពីខាងក្រោយ។

"ហុងស៊ុល ឬ" នាងងាកទៅមើលព្រោះគិតថា ជាហុងស៊ុល ដែលទៅទិញទឹកមកឲ្យ ប៉ុន្តែបែរជាឃើញ ជីយ៉ន ញញឹមដាក់ ទាស់ត្រង់ថា មិនមែនជាស្នាមញញឹមរីករាយ។

នាងក្រមុំខ្ទឹបមាត់ និងងាកមុខមកវិញ ព្រោះធុញទ្រាន់នឹងតមាត់ត.កនឹងស្រីម្នាក់នេះ។

"គួរឲ្យអាណិត ធ្វើស្អីក៏មិនស្រួល"

"ខ្ញុំស៊ាំហើយ" នាងថ្នមសំឡេង និងចាប់កង់រទេះបង្វិល តែត្រូវ ជីយ៉ន ស្ទុះមកពាំងមុខ បន្ទាប់មកក៏សើចចំអកចេញមុខដោយមិនលាក់លៀម។

"ចង់ទៅណា នៅនិយាយគ្នាសិន លោកស្រី អ៊ិន "

"ខ្ញុំគ្មានស្អីនិយាយជាមួយនាងទេ" នាងក្រមុំពើងទ្រូងមើលដៃគូសន្ទនាដោយកំហឹង "ចៀសចេញ"

ជីយ៉ន មិនព្រមចៀស ថែមទាំងឱនមករកទៀតផង ភ្នែកដែលតុបតែងដោយរោមភ្នែកក្រាស់ឃ្មឹក ក៏មើលនាងមិនព្រមព្រិច។



"កាលមុនខ្ញុំឆ្ងល់ថា ហេតុអីមនុស្សប្រុសល្អឥតខ្ចោះដូចលោកនាយក

ម៉ាត ព្រមរៀបការនឹងនាង...ស្រីខ្ទិនដូចនាង"

យ្យូលី ក្តាប់ដៃណែន ប្រឹងទប់កំហឹង។

"តែពេលនេះបានចម្លើយហើយ" ដីយ៉ន សើចក្អាកក្អាយដោយការពេញចិត្ត ខុសពី យ្យូលី។

"លោកនាយក ម៉ាឡេសាសសូ ជាបុរសចិត្តល្អ ទន់ភ្លន់និងប៉ិនអាណិត និស្សិតស្រីៗនៅទីនេះស្រឡាញ់លោកនាយកគ្រប់គ្នា ព្រោះលោកនាយកមានមេត្តាចំពោះគ្រប់គ្នា ដូច្នេះហើយមិនប្លែកទេថា ហេតុអីបានជាលោកនាយកព្រមរៀបការជាមួយស្រីខ្ទិនដូចនាង..."

យ្យូលី មានអារម្មណ៍មិនខុសពីត្រូវចាប់បោះចូលទៅក្នុងបឹងដែលសុទ្ធតែពស់ពិស ធ្វើឲ្យឈឺចាប់និងអាម៉ាស់ សឹងតែដាច់ខ្យល់ទៅហើយ។

"ប្រហែលមកពីអាណិត អាណិតដែលមិនអាចក្លាយជាស្រឡាញ់បាន" ដីយ៉ន សើចមិនឈប់ "នែ៎! សួរតាមត្រង់ចុះ លោកនាយកធ្លាប់ដេកជាមួយឬអត់?"

សំណួរចំៗចំពោះស្រីនៅចំពោះមុខ ធ្វើឲ្យ យ្យូលី ភាំង និយាយមិនចេញឈឺឡើងចុកទ្រូង។

"ធ្វើមុខបែបនេះ បញ្ជាក់ថាលោកនាយកមិនចាប់អារម្មណ៍មែនទេ ដូចថាអីចឹង ត្រឹមសម្រស់ស្អាតវាមិនគ្រាន់ទេ ត្រូវតែដល់ចិត្តដល់ថ្លើមដែរ ទើបមនុស្សប្រុសឈ្លក់វង្វេង ប៉ុន្តែមើលតាមសភាពរបស់នាងហើយ មិនគួរណាតបស្នងស្នេហ៍មនុស្សប្រុសបាន ថែមទាំងជាបុរសមានតម្រូវការផ្លូវភេទ ខ្លាំងលោកនាយក នាងគួរតែនៅក្រៅសង្វៀន"

យ្យូលី ខ្ទាំថ្ពាក់ដៃរទេះរុញឡើងខ្លាំងដោយភ្លេចខ្លួន។

"ទោះខ្ញុំយ៉ាងណា ក៏មិនពាក់ព័ន្ធនឹងនាង..." នាងប្រមុំខាំធ្មេញក្រតៗ



"បើគ្រាន់តែជាអ្នកក្រៅមិនមែនទេ សាស្ត្រាចារ្យ គីម"

នាងញញឹមចម្អកទាំងដែលនៅក្នុងចិត្តឈឺចាប់ ព្រោះសម្តីរបស់ ដីយ៉ន គឺជាការពិតដែលមិនអាចបដិសេធបាន។

ដីយ៉ន ខាំមាត់ មើលអ្នកដែលខ្លួននិយាយជាមួយដោយកំហឹង។

"ខ្ញុំគ្រាន់តែចង់ឲ្យនាងមើលឃើញការពិតប៉ុណ្ណោះ ទៅសិនហើយ ខ្ញុំទៅជួយលោកនាយកកិច្ចការងារសិន ចំណែកនាង...អង្គុយខ្ទិនតែម្នាក់ឯងនៅត្រង់នេះទៅ"

និយាយហើយ ដីយ៉ន ក៏ធ្វើពើយដើរចេញទៅភ្លាម ពេលនោះ ហុងស៊ីន ក៏ដើរមកវិញល្មម។

"នាងនោះមករំខានអី អ្នកនាងឬអត់?" ហុងស៊ីល សួរដោយការមិនសប្បាយចិត្ត យ្យូលី ក៏ព្រិចភ្នែកបណ្តេញទឹកភ្នែក ហើយឆ្លើយដោយសំឡេងខ្សាវៗ។

"គ្មានស្អីទេ"

អ្នកមើលថែមិនជឿ តែមិនចង់ដេញដោលចៅហ្វាយនាយ ព្រោះមើលទៅទឹកមុខមិនសូវល្អ។

"អ្នកនាងឃ្លានហើយឬនៅ?"

"ខ្ញុំចង់ទៅផ្ទះ នាំខ្ញុំទៅផ្ទះ" ទីបំផុតនាងនិយាយពាក្យនេះចេញមកឲ្យទាន់តែបាន ទើប ហុងស៊ីន លុតជង្គង់នៅចំពោះមុខ។

"កុំទាន់អាលទៅវិញអី ពេលរួចរាល់ធុរៈនៅទីនេះហើយ លោក ម៉ាក នឹងនាំអ្នកនាងទៅដើរលេងបន្ត"



"ខ្ញុំមិនចង់ទៅណាទេ ខ្ញុំចង់ទៅផ្ទះ"

"អីចឹងខ្ញុំទៅសុំការអនុញ្ញាតពីលោក ម៉ាត សិន"

យ្យូលី ដៀងមើល ម៉ាទិនេស ដែលពេលនេះមានស្រ៊ាៗឡោមពីមុខ ឡោមពីក្រោយដោយការតូចចិត្ត។

"កុំទៅរំខាន យើងទៅវិញទៅ"

"តែ..."

"ឥឡូវ បងលែងស្រឡាញ់ខ្ញុំហើយឬ"

ទឹកមុខសោកសៅរបស់ ចៅហ្វាយ ធ្វើឲ្យ ហុងស៊ុល មិនអាចជំទាស់ចិត្តបាន បានត្រឹមតែងើបឈរ នឹងងក់ក្បាលធ្វើតាមបញ្ជា។

"អូខេ អីចឹងយើងទៅផ្ទះវិញ"

យ្យូលី មិននិយាយអីទៀត តែងាកទៅមើល ម៉ាទិនេស ម្តងទៀត ហើយឲ្យសញ្ញាដល់ ហុងស៊ុល នាំខ្លួនឯងទៅឡាន។

ម៉ាទិនេស ធ្វើការរួចរាល់ ទើបដើរមករក យ្យូលី តែមិនឃើញភរិយា ទើបងាកមើលជុំវិញខ្លួន ប្រុងទូរសព្ទរក តែ ជីយ៉ន ស្ទុះមករាយការណ៍។

"ទៅវិញហើយឬ?"

"ចាំ ឮអ៊ីចឹងធុញ"

ទោះទឹកមុខរបស់ ម៉ាទិនេស នៅតែរាបស្មើ ប៉ុន្តែ ជីយ៉ន អាចកំពុងតែមើលដឹងថាគេកំពុងតែមានអារម្មណ៍អី ទើបនាងបួញមាត់បួញ.ក បង្កើតភាពប្រេះឆាឲ្យគ្រួសារអ្នកដទៃភ្លាម។

"មនុស្សស្រី បើមិនបានចាប់អារម្មណ៍ ឬយកចិត្តទុកដាក់អីប្រាកដប្រាជាគឺងាយធុញទ្រាន់អីបែបនេះឯង"

និយាយហើយនាងក៏សើចតិចៗ បន្ទាប់មកក៏ធ្វើជាលើកដៃបិទមាត់។

"អូយ...ខ្ញុំមិនមែនចង់មានន័យថា លោកស្រី អិន មិនចាប់អារម្មណ៍



លោកនាយកទេ"

ម៉ាទិនេស សើចញឹមៗ។

"ខ្ញុំទៅសិនហើយ"

"លោកនាយក ចង់ទៅណា?"

"ទៅរកភរិយា"

អ្នកកំលោះតបយ៉ាងសុភាព ប៉ុន្តែវាធ្វើឲ្យរំជើបរំជួយដល់ទងបេះដូងរបស់អ្នកស្តាប់តែម្តង។

"តែ... ខ្ញុំចង់អញ្ជើញលោកនាយកទទួលទានអាហារមួយពេលជាការអរគុណ"

"អរគុណ តែខ្ញុំមិនទំនេរទេ សុំទៅមុនហើយ"

និយាយហើយ ម៉ាទិនេស ក៏ដើរចេញភ្លាម ខណៈដែល ជីយ៉ន បានត្រឹមតែតាមមើលដោយការឈ្ងើសចិត្ត។

"មិនដឹងជាចាប់អារម្មណ៍ស្អីណាស់ណា គ្រាន់តែមីប្រពន្ធខ្វិនម្នាក់"

នាងដកដង្ហើមធំដោយការឈ្ងើសចិត្ត មុខក៏ក្រមូវដោយកំហឹង។

**យ្យូល អង្គុយសោកសៅនៅសួនក្រោយផ្ទះ សម្តីរបស់ ជីយ៉ន នៅតែ** ចាក់ទម្លុះបេះដូងរបស់នាង។ ទោះដឹងថាគួរបំភ្លេចវា កុំយកចិត្តទុកដាក់សម្តីរបស់ស្រីប៉ិនប្រណែនម្នាក់នោះ ប៉ុន្តែនាងធ្វើមិនបាន ព្រោះអ្វីដែលបានឮ គឺជារឿងពិត។

នាងគ្រាន់តែជាស្រីខ្វិន មិនអាចបានទទួលក្តីស្រឡាញ់ពីស្វាមីរូបសង្ហាល្អឥតខ្ចោះដូច ម៉ាទិនេស បាន មិនថាជាតិនេះឬជាតិណាក៏ដោយ ដែលគេនៅជាមួយនាង ព្រោះជាបញ្ហារបស់ចាស់ទុំ និងប្រហែលអាណិត។



នាងរហ័សលើកដៃជូតទឹកភ្នែក ដែលហូរកាត់ថ្ពាល់ ពេលបានឮសម្រិប
ជើងមនុស្ស ហើយគិតថា ជា ហុងស៊ីល។

"ហុងស៊ីល...បង ម៉ាត មកវិញហើយឬនៅ?"

"មកវិញហើយ"

សំឡេងគ្រលរដែលបន្លឺឡើង ធ្វើឲ្យនាងដឹងថាអ្នកដែលដើរមករកខ្លួន
មិនមែន ហុងស៊ីល តែជា ម៉ាទិនេស។

"បង ម៉ាត"

នាងហៅឈ្មោះគេដោយសំឡេងខ្សាវៗ ហើយងាកមុខចេញ ពេលដែល
គេដើរមកឈរទល់មុខ។

"មកវិញមុនធ្វើអី?"

"ខ្ញុំចង់មកផ្ទះ"

"តែយើងត្រូវទៅដើរលេងបន្ត បងប្រាប់ឲ្យដឹងហើយតើ" គេដាក់បង្កុយ
លើកែងជើង សម្លឹងមើលមុខនាងមិនដាក់ភ្នែក។

យូលី ទប់បបូរមាត់ ងើយមុខមកប្រសព្វភ្នែកនឹងគេ។

"ខ្ញុំមិនចង់ទៅ"

"ទើបមកផ្ទះមុន ដោយមិនប្រាប់បងមួយម៉ាត់"

"បង ម៉ាត ចាប់អារម្មណ៍ដែរឬថាខ្ញុំនៅឬមិននៅ" នាងតវ៉ាដោយកំហឹង
ព្រោះមិនអាចគ្រប់គ្រងខ្លួនឯងបាន។

"ម៉េចក៏អូននិយាយបែបនេះ អូនជាប្រពន្ធបង បងត្រូវតែចង់ឲ្យអូននៅ
ក្បែរហើយ"

នាងញញឹម ចម្អកភាពគួរឲ្យសង្វេគរបស់ខ្លួន។

"គ្រាន់តែជាប្រពន្ធខ្វិនជើង មិនអាចធ្វើឲ្យបងពេញចិត្តបានទេ"



"លីលី...កុំនិយាយបែបនេះទៀត"

"យ៉ាងម៉េច! វាជារឿងពិត ខ្ញុំជាមនុស្សខ្វិន" នាងស្រែកខ្លាំងៗ "បើបង
ចង់លែងលះ ប្រាប់មក ខ្ញុំនឹងប្រគល់សេរីភាពឲ្យបងបានគ្រប់ពេល"

"យូលី!" អ្នកកំលោះហៅនាងពេញឈ្មោះ តែនាងងាកមុខចេញពីមុខ
ក្រហមង៉ាំងរបស់គេ។

"ខ្ញុំទៅសម្រាកហើយ"

នាងចាប់កង់រទេះបង្វិល តែត្រូវគេទាញមកវិញ ព្រមទាំងខិតទៅជិត។

"បង ម៉ាត...ចង់ធ្វើស្អី?" នាងភ្ញាក់ព្រើត សួរដោយសំឡេងញ័រពេល
មុខសង្ហានៅជិតពេកហើយ។

"ថើបប្រពន្ធ"

"អ៊ុប!"

សំឡេងឧទានចុងក្រោយរបស់នាងត្រូវលេបចូលទៅក្នុងបំពង់.ក តាម
ដោយការថើបខ្លាំងៗ ស្របពេលដែលការដាក់ទោសផ្ទះប៉ុង គេក្រសោបកញ្ចឹង
.ករបស់នាង សង្កត់ខ្លាំងៗ ហើយងើយមុខមកទទួលយកការថើបរបស់ខ្លួន។

ការប៉ះពាល់ទន់ល្មើយពីបបូរមាត់របស់ ម៉ាទិនេស ធ្វើឲ្យនាងក្រមុំ
ភ្លឹតភ្លើន ដៃទាំងពីរដែលរុញដើមទ្រូងជំទូលាយ ពេលនេះបែរជាឱប.ករបស់គេ
និងបង្អើបបបូរមាត់ទទួលយកអណ្ដាតដែលចូលមក។

"អាំ..." សំឡេងថ្ងូចថ្ងូររបស់នាងបន្លឺឡើងតិចៗ ប្រាប់ឲ្យដឹងថានាង
កំពុងតែធ្លាក់ទៅក្នុងអន្លង់ស្នេហាយ៉ាងជ្រៅ ហើយការតបស្នងរបស់នាងធ្វើឲ្យ
អ្នកកំលោះគ្រហឹមដោយការពេញចិត្ត ហើយងើបចេញ។

មុខរបស់នាងក្រមុំឡើងក្រហម ហើយលើកដៃអង្អែលបបូរមាត់ហើមជាំ
របស់ខ្លួនដោយភ្លេចខ្លួន និងបើកភ្នែកធំៗសម្លឹងមុខ។



"កុំរឹងដាក់បងទៀត"

គេសម្លឹងមុខនាងមិនដាក់ភ្នែក ប៉ុន្តែទឹកមុខមិនបានបញ្ជាក់អារម្មណ៍អ្វី។ ការថើបអម្បាញ់មិញវាគ្រាន់តែជាការភ្លេចខ្លួនមួយខណៈ របស់គេប៉ុណ្ណោះ... ឃ្យូលី គិតដោយការតូចចិត្ត។

"ខ្ញុំ...ឡើងបន្ទប់វិញ"

"បងនាំទៅ"

ខ្លួនប្រាណរបស់នាងនៅតែញ័រ ដោយអារម្មណ៍ផ្អែមល្ហែម ដែលកើតចេញពីបបូរមាត់របស់ ម៉ាទិនេស។

"ខ្ញុំមើលថែខ្លួនឯងបាន បង ម៉ាត ទៅសម្រាកចុះ"

អ្នកកំលោះងើបឈរពេញកម្ពស់ ទឹកមុខនៅតែរាបស្មើ។

"ប៉ារបស់ ហុងស៊ីល ចូលមន្ទីរពេទ្យ"

"ចា៎ ?"

"បងទើបតែដឹងអម្បាញ់មិញពេលត្រឡប់មកវិញ មួយសន្ទុះទៀត ហុងស៊ីល នឹងតេរមកប្រាប់អូនដោយផ្ទាល់"

ទឹកមុខរបស់ ឃ្យូលី មានការមិនសប្បាយចិត្តភ្លាម។

"ប៉ារបស់ ហុងស៊ីល កើតអី បងម៉ាត ?"

"បងក៏មិនទាន់ដឹងដែរ ប៉ុន្តែឲ្យគេទៅតាមមើលហើយ មួយសន្ទុះប្រហែលដឹងហើយថា មានអីកើតឡើង"

"ព្រះអើយ !"

"គ្មានអីគួរឲ្យបារម្ភទេ ជឿបងចុះ"

សំឡេងរបស់ ម៉ាទិនេស ស្រទន់ ធ្វើឲ្យនាងក្រមុំងើយមុខសោកសៅមើលគេ។



"បង ម៉ាត នាំខ្ញុំទៅរក ហុងស៊ីល បានទេ ?"

អ្នកកំលោះគ្រវីក្បាល។

"រាងកាយរបស់អូនមិនសូវរឹងមាំ បងមិនចង់ឲ្យទៅពេទ្យ ចាំស្ដាប់ដំណឹងនៅទីនេះហើយ"

"តែខ្ញុំបារម្ភពី ហុងស៊ីល"

"កុំរឹង ស្ដាប់បង្គាប់បង គ្រប់យ៉ាងនឹងល្អប្រសើរ"

អ្នកកំលោះនិយាយដោយសំឡេងពីរោះ តែមានភាពផ្ដាច់ការ បន្ទាប់មកក៏ឱនមករកនាង។

"ថ្ងៃនេះ និងយប់នេះបងជាអ្នកមើលថែអូនជំនួស ហុងស៊ីល"

"អី...មិនបាច់ទេ ខ្ញុំមើលថែខ្លួនឯងបាន"

នាងងាកមុខចេញពីកែវភ្នែកមុតស្រួច ថ្ពាល់នៅតែក្រហម ខណៈនោះដៃក៏ចាប់បង្វិលកង់រទេះ តែគេមិនព្រម។

"បងជួយ"

"មិនបាច់"

ទោះនាងបដិសេធយ៉ាងណា ក៏គេមិនស្ដាប់ ថែមទាំងលើកនាងបីទៀតផង។

"ដាក់ខ្ញុំចុះ...ខ្ញុំ"

អ្នកកំលោះគ្រវីក្បាល ដោយទឹកមុខមានស្នាមញញឹមលម្អ។

"មិនដាក់ចុះ យើងឡើងទៅបន្ទប់ បងនាំទៅសម្រាក"

"តែមិនចាំបាច់បីទេ"

"អ្នកណាប្រើឲ្យអូនរឹងក្បាល នៅឲ្យស្ងៀម មិនអីចឹងបងនឹងថើបអូនម្ដងទៀត"



នាងក្រមុំលើកដៃបិទមាត់ កែវភ្នែកមូលភ្លំបង្ហាញឲ្យឃើញការអឹមអៀនធ្វើឲ្យ ម៉ាទិនេស សើចតិចៗដោយការចូលចិត្ត ខណៈនោះក៏បីនាងចូលផ្ទះ។

"អ៊ំ អាយរីន ជួយទៅប្រាប់គេឲ្យយករទេះរបស់ លីលី ចូលផ្ទះផង"

អាយរីន ឃើញ ម៉ាទិនេស បីភរិយាដើរចូលមក ក៏អត់មិនបាននឹងញញឹមដោយការពេញចិត្តពេញថ្លើម។

"ចាំ ចាំខ្ញុំចាត់ចែងឲ្យ"

"អរគុណ"

ម៉ាទិនេស អរគុណអ៊ំស្រីហើយក៏ដើរសំដៅជណ្ដើរ ខណៈនោះ យ៉ុលី ក៏ត្រូវជ្រប់មុខនឹងដើមទ្រូងធំទូលាយដោយការអឹមអៀន បេះដូងក៏លោតញាប់ស្ទើតែធ្លាយចេញពីទ្រូងទៅហើយ។

*ម៉ាទិនេស ស្រឡាញ់នាងតែបន្តិច ប្រហែលជាល្អមិនតិចទេ!*

ម៉ាទិនេស ដាក់ភរិយាទៅលើគ្រែថ្មមៗ ហើយដាក់បង្អុយលើកែងជើងមើលមុខនាង។

"ចង់បានទឹកក្រូចមួយកែវទេ ចាំបងឲ្យគេយកមកឲ្យ"

នាងក្រមុំគ្រវីក្បាលតិចៗ ដោយមិនមើលមុខគេចំ ឯបេះដូងក៏លោតមិនត្រូវចង្វាក់ វាតែងតែបែបនេះពេលនៅជិត ម៉ាទិនេស។

"ខ្ញុំមិនទាន់ស្រេកទេ"

"អីចឹងយកខេកទេ ?" គេនៅតែសួរនាំបន្ត ប៉ុន្តែនាងគ្រវីក្បាលបដិសេធដដែល។

"អរគុណ តែខ្ញុំមិនទាន់ឃ្លាន ខ្ញុំចង់គេង"

"អូខេ" គេងើបឈរជួយដាក់នាងឲ្យដេក ហើយទាញភួយដណ្ដប់ឲ្យ។



"អូនគេងទៅ បងទៅងូតទឹកសិន"

"ចាំ"

នាងឆ្លើយ និងគិតថាគេដើរចេញពីបន្ទប់ ប៉ុន្តែបែរជាមិនដូចការគិតព្រោះឃើញគេដើរចូលបន្ទប់តែងខ្លួនដែលនៅក្រោយទ្វាររុញ មួយសន្ទុះក៏ចេញមកវិញ ដោយមានតែកន្សែងពោះគោរុំចង្កេះប៉ុណ្ណោះ។

"អា៎... បងម៉ាត...តែងខ្លួនឲ្យរួចរាល់ទៅ"

គេឈ្ងោកមើលសភាពខ្លួនឯង ហើយសួរភរិយាដោយការងឿងឆ្ងល់។

"បងមិនបានស្រាតឯណា"

"តែ...បងតែងខ្លួនគ្មានរបៀប ឆាប់ស្លៀកពាក់ទៅ"

សំឡេងសើចរបស់គេឮនៅក្បែរត្រចៀក និងឮកាន់តែជិតទៅៗ ។

"បងងូតទឹក ក៏ត្រូវតែតែងខ្លួនបែបនេះហើយ"

"តែ...បងមិនបាននៅក្នុងបន្ទប់តែម្នាក់ឯង មានខ្ញុំម្នាក់ទៀតដែរ" នាងស្ទុះងើបអង្គុយ ទើប ម៉ាទិនេស ផ្ទឹមភ្នែកមើលមកដោយការសង្ស័យ។

"នេះអូន...ងើបអង្គុយខ្លួនឯងបានឬ ?"

"អឺ..." នាងភាំងភ្លាម "...ខ្ញុំព្យាយាម...វាលំបាកខ្លាំងណាស់ដើម្បីអង្គុយដោយខ្លួនឯងបាន គឺធ្វើបានតែពេលខ្លះប៉ុណ្ណោះ"

អ្នកកំលោះដើរមករក ស្រវាទាញដៃនាងទៅក្ដោប។

"បងថា បើអូនយកចិត្តទុកដាក់ធ្វើកាយចលនា អូនត្រូវតែជា ជឿបង"

នាងសម្លឹងមុខគេ ដោយមុខក្រហម ពេលឱនមើលដើមទ្រូងធំទូលាយដែលមានរោមក្រាស់ឃ្មឹកវាយប៉ាយ។



"ខ្ញុំមិនអាចជាទេ"

"ជា បងលើកទឹកចិត្តអូនជានិច្ច"

នាងក្រមុំដកដៃចេញពីដៃរបស់គេ ហើយនិយាយបញ្ចប់ការសន្ទនា។

"បងម៉ាត ទៅងូតទឹកទៅ ខ្ញុំសម្រាកហើយ"

អ្នកកំលោះមើលមុខនាងមួយសន្ទុះ ទើបសើចញឹមៗ ហើយដើរចូលបន្ទប់ទឹក។

យ៉ូលី លួចដកដង្ហើមធំ ជូរទ្រូងខ្សាក ហើយផ្តួលខ្លួនដេកម្តងទៀត ដោយក្នុងខួរក្បាលមានរឿងជាច្រើន ថែមទាំងមាន ម៉ាទិនេស នៅក្នុងរឿងអស់នោះទៀតផង។

មិនដឹងថាដេកលក់តាំងពីពេលណា ប៉ុន្តែពេលដឹងខ្លួនតិមានអ្វីម្យ៉ាងប៉ះថ្ពាល់ យ៉ូលី ក៏បើកភ្នែកភ្លាម ហើយក៏បើកធំៗ ពេលឃើញមុខរបស់ ម៉ាទិនេស នៅជិត និងជាងនោះទៅទៀត គឺគេកំពុងញញឹម។

"បងធ្វើឲ្យអូនភ្ញាក់"

នាងក្រមុំខ្ទឹបមាត់ មុខក្រហមបេះដូងលោតញាប់ ពុលនឹងក្លិនសាប៊ូក្រអូប ដែលភាយចេញពីរាងកាយរបស់គេ។

"អឺ...បងងូតទឹករួចហើយឬ?"

"មួយសន្ទុះហើយ" នាងក្រមុំងើបអង្គុយ និងងាកមុខចេញ ព្រោះការអឹមអៀនវាណែនទ្រូងពេក។

"អឺចឹង...ខ្ញុំសុំទៅងូតទឹកសិន"

"អូនងូតខ្លួនឯងបានឬ?"

សំណួរងឿងឆ្ងល់របស់គេ ធ្វើឲ្យអ្នកដែលកំពុងតែរំកិលខ្លួន ទៅជាធ្មឹងភ្លាម ហើយងាកមកគ្រវីក្បាលដាក់។

"មិន...បាន"



ម៉ាទិនេស ដែលសង្ហានៅក្នុងឈុតជម្មតា ញញឹមមើលមុខភរិយា។

"ចាំបងជួយ"

"អឺ ...មិនបាច់" នាងភ្ញាក់ បើកភ្នែកធំៗ ខណៈដែលគេផ្ងៀង.ក មើលដោយការសង្ស័យ។

"បើបងមិនជួយ អូនងូតទឹកយ៉ាងម៉េច កុំភ្លេចថា ហុងស៊ុល មិននៅថ្ងៃនេះ" សំឡេងរបស់គេប្រាកដប្រជា។

"តែអ្នកដទៃក៏មានដែរតើ ឲ្យ អ៊ំស្រី អាយរីន មកជួយខ្ញុំក៏បាន"

"ហើយម៉េចចាំបាច់ធ្វើអីចឹង ទាំងដែលអូនមានបងជាស្វាមីហើយ" គេផ្ងៀង.កមើលនាងដោយរង់ចាំចម្លើយ ខណៈដែលនាងតបមិនពេញសំឡេង។

"គឺ...ខ្ញុំ...មិនចង់រំខានបង ម៉ាត "

"មិនរំខានទេ បងរីករាយ"

គេខិតទៅជិតបន្តិចទៀត ប្រុងលើកនាងបី តែនាងស្រែកហាមខ្លាំងៗ។

"កុំ"

"កើតអី លីលី បងគ្រាន់តែចង់ជួយងូតទឹកឲ្យប៉ុណ្ណោះ"

គេមើលនាងដោយទឹកមុខហួសចិត្ត តែថ្ពាល់របស់នាងឡើងក្រហមខ្លួនក៏ក្តៅភាយៗ។

"ខ្ញុំ...ខ្ញុំខ្មាសបង"

ពេលឮពាក្យសារភាពរបស់នាងហើយ ស្វាមីសង្ហាក៏សើចក្អាកក្អាយធ្វើឲ្យនាងកាន់តែអៀន។

"បងសើចអី មានអីគួរឲ្យសើច" នាងធ្វើមុខខ្សូរដាក់ ហើយគេក៏ប្រើពេលពីរបីដង្ហើម ដើម្បីតបត។



"បងស្មានថារឿងអីតើ គ្រាន់តែខ្មាសបងឬ"

"តិ...វាខ្មាស ហើយអ៊ំមិនសក្តិសមដែរ" នាងឱនមុខជ្រប់ ថ្ពាល់ទាំងពីរនៅតែក្រហម ក្រហមព្រឿងៗ។

ម៉ាទិនេស លូកដៃទៅក្ដោបដៃរបស់នាង ក្ដោបណែន និងក្ដោបកាន់តែណែន ពេលនាងទាញចេញ។

"បងជាស្វាមីរបស់អូនហើយ មិនបាច់ខ្មាសបងទេ យល់ទេ"

នាងខ្ទឹបមាត់ ទោះគេនិយាយបែបនេះ ប៉ុន្តែការតូចចិត្តនៅណែនទ្រូង។

"បងម៉ាត...មិនទាន់ជាស្វាមីរបស់ខ្ញុំទេ" នាងកញ្ឆក់ដៃចេញមួយទំហឹង និងផ្ទួលខ្លួនដេកវិញ "អូនមិនងូតទឹកទេ ចង់ដេកជាង"

ម៉ាទិនេស មើលភរិយាដោយអារម្មណ៍តានតឹង ហើយក៏ដកដង្ហើមចូលឲ្យខ្លាំងៗ សម្រេចចិត្តដើរឡើងគ្រែ និងផ្ទួលខ្លួនដេកក្បែរ។

"បងចង់ធ្វើអី ?" នាងភ្ញាក់។

"ឈឺក្បាល ចង់ដេកមួយស្របក់"

គេនិយាយ ព្រមទាំងបែរមុខមករក ដៃក៏ដាក់លើខ្លួនរបស់នាង ត្រង់ចុងដង្ហើមល្មម ធ្វើឲ្យ យូលី រឹងខ្លួនស្ដូក សរសៃប្រសាទទាំងអស់ឡើងរឹង។

"បង...បងម៉ាត...ខិតចេញបន្តិចទៅ"

"ថី ? បងឱបបន្តិចមិនបានឬ" នេះគេកំពុងលេងល្បែងអីជាមួយនាង ហេតុអីបានជាទាក់ទាញឲ្យរាងកាយរបស់នាងជ្រួលច្របល់ដល់ថ្នាក់នេះ !

"បងម៉ាត...ទៅដេកបន្ទប់ដដែលទៅ"

"អត់ទេ បងនឹងចូលមកដេកជាមួយអូនរាល់យប់"

និយាយហើយ អ្នកកំលោះក៏បិទភ្នែក និងនៅតែដាក់ដៃលើខ្លួននាងដដែល។

"តែ...ខ្ញុំថប់ដង្ហើម"



[illegible] ក្រហម [illegible]

[illegible] បើធ្វើទៅចាំជា"

ថ្ពាល់របស់នាងឡើងក្រហមង៉ាំង ត្រង់ប្រឡោះភ្លៅក្ដៅគគុក [illegible] ម៉ាទិនេស គឺជារឿងគ្រោះថ្នាក់បំផុតសម្រាប់នាង។

"តែ...បងមកឱបស្រីពិការដូចខ្ញុំធ្វើអី ខ្ញុំថាបងទៅដេកបន្ទប់ដែលដេកកាលពីយប់មិញទៅ"

"ទោះអូនមានតែក្បាលនិងពោះវៀនក៏បងឱបបែបនេះដែរ ឱបឲ្យស្លាប់រៀងខ្លួន"

"អូយ...បងម៉ាត...ខ្ញុំដកដង្ហើមមិនចេញ"

អ្នកកំលោះខិតមកជិត ឱបរឹតនាងកាន់តែណែន ធ្វើឲ្យរាងកាយទាំងពីរសឹងតែរលាយក្លាយជាសាច់មួយ។

"ដេកឲ្យស្ងៀមទៅ"

"តែបងម៉ាត..."

"បើមិនឈប់រើ បងអាចធ្វើលើសពីឱប"

ពាក្យគំរាមរបស់គេធ្វើឲ្យនាងភ័យនិងងឿងឆ្ងល់ ហើយក៏បើកភ្នែកធំៗ។

"បងម៉ាត ចង់មានន័យ..."

"ស៊ូច..."

គេឲ្យសញ្ញាស្ងៀមស្ងាត់ ទើបនាងមិនហ៊ានសូម្បីតែដកដង្ហើម រាងកាយរបស់គេនៅជិតខ្លាំងណាស់ ធ្វើឲ្យនាងធុំក្លិនក្រអូបប្រហើរ ចេញពីស្បែករបស់គេ។ ម៉ាទិនេស កំពុងតែធ្វើឲ្យនាងខ្វល់ខ្វាយចិត្តពេកហើយ ហើយនេះនាងអាចបិទភ្នែកឲ្យដេកលក់បានមែនឬ...គ្មានផ្លូវទេ គ្មានផ្លូវដេកលក់បានទេ បើធ្លាក់នៅក្នុងរង្វង់ដៃរបស់បុរស តើរ៉ហ៊ិកត៍ ដូច ម៉ាទិនេស បែបនេះ។



"បងម៉ាត...ខ្ញុំ..."

នាងសម្រេចចិត្តនិយាយតិចៗ តែសំឡេងដកដង្ហើមថេរដែលបន្លឺឡើងនៅក្បែរត្រចៀក ធ្វើឲ្យដឹងថាគេដេកលក់ទៅហើយ។

"នែ៎ បងម៉ាត ដេកលក់បានមែនឬ?"

នាងដកដង្ហើមធំ ហើយខាំមាត់តស៊ូនឹងអារម្មណ៍ម្យ៉ាងដែលកំពុងផ្ទុះនៅក្នុងរាងកាយអស់ពីសមត្ថភាព។



# ៤

យូលី បើកភ្នែក បន្ទាប់ពីដេកលក់មួយសន្ទុះដោយមិនដឹងខ្លួន ហើយផ្អៀង.ក ដើម្បីមើលអ្នកនៅក្បែរខ្លួន តែបែរជាឃើញភាពទទេស្អាត។ នាងក្រមុំញញឹមសោកសៅដាក់ខ្លួនឯង ពេលងើបអង្គុយ ស្របពេលនោះទ្វារបន្ទប់ក៏ត្រូវរុញចូលមកល្មម។

បុរសគ្រងឈុតជម្មតាសាមញ្ញដើរចូលមក ដោយកាន់ថាសអាហារធំមកជាមួយ។ គេមើលមកនាងដោយទឹកមុខញញឹម និងរាក់ទាក់ដោយសំឡេងពិរោះពិសា។

"ភ្ញាក់យូរហើយឬ?"

នាងក្រមុំខ្ទឹបមាត់ កែវភ្នែកមូលក្លំធ្វើម៉ក់ៗមើលគេ បុរសដែលកំពុងមមាញឹកនឹងការយកចានអាហារចេញពីថាសធំ។

*ហេតុអ្វីបានជា ម៉ាទិនេស សម្បូរបែបយ៉ាងណា?*

*គេសុភាពនិងទន់ភ្លន់បែបនេះដាក់មនុស្សស្រីគ្រប់គ្នាឬអត់?*

យូលី សង្ស័យជាខ្លាំង ទៅជាភ្លេចឆ្លើយសំណួររបស់គេ ទាល់តែគេសួរម្តងទៀត ទើបភ្ញាក់ស្មារតី។

"មិនទាន់ឆ្លើយប្រាប់បងទេ លីលី"

"អឺ...បង ម៉ាត ថាម៉េច?"

គេងើបឈរពេញកម្ពស់ ហើយដើរមកឈរក្បែរគ្រែ ចំពីមុខនាង ដែលស្នាមញញឹមរបស់គេធ្វើឲ្យបេះដូងរបស់នាងកន្ត្រាក់។



"បងសួរថាភ្ញាក់យូរហើយឬ?"

"ទើប...ភ្ញាក់"

កែវភ្នែកមុតស្រួចដែលមើលមក ធ្វើឲ្យនាងអៀន ត្រូវងាកមើលទៅផ្សេង ទើបឮសំឡេងសើចហ៊ឺៗរបស់គេ។

"ឃ្លានហើយនៅ?"

"នៅ"

"ទោះមិនទាន់ឃ្លានក៏ត្រូវញ៉ាំដែរ នេះម៉ោង៧ហើយ តិចកើតរោគក្រពះ"

"អរគុណ តែខ្ញុំមិនទាន់ឃ្លានពិតមែន"

គេគ្រវីក្បាលតិចៗ ហើយបន្ទន់ខ្លួន។

"មិនឃ្លានក៏ត្រូវញ៉ាំតិចតួចដែរ ហាមរឹងដាក់បង ថ្ងៃនេះ"

និយាយហើយ គេក៏លើកនាងបី ទើប យ្យូលី លើកដៃស្រវាឱប.កគេ។

"បងម៉ាត...ដាក់ខ្ញុំចុះទៅ"

"បងមិនធ្វើអីទេ គ្រាន់តែនាំទៅអង្គុយលើសាឡុង ដើម្បីញ៉ាំបាយ"

ទឹកមុខរបស់អ្នកកំលោះនៅតែមានស្នាមញញឹមលម្អ ខណៈដែលដាក់នាងលើសាឡុងវែង ហើយលុតជង្គង់នៅពីមុខ។

"ថ្ងៃនេះមានរបស់ដែលអូនចូលចិត្តដែរ"

"របស់ចូលចិត្តឬ?"

"បាទ"

អ្នកកំលោះបើកគម្របចានថ្មដែលមានក្បូរក្សាច់ចេញ ក្លិនឈ្ងុយរបស់ម្ហូបភាយចូលច្រមុះ ធ្វើឲ្យពោះនាងកូរគ្រូកៗដោយសារការស្រេកឃ្លាន។

"សាច់ផាកឡូវហ្នឹងអី បងចាំបានថាអូនចូលចិត្តញ៉ាំណាស់"

នាងក្រមុំជ្រួញច្រមុះដាក់គេ មើលពងមាន់ធំៗនៅក្នុងចានដោយការ



រញ្ចចិត្តពេញថ្លើម។

"ឆ្លាប់ចូលចិត្តតែពេលនេះមិនចូលចិត្តខ្លាំងដូចពីមុនទេ"

"បងមិនជឿ" គេនិយាយហើយក៏អស់សំណើច "មនុស្សធ្លាប់ចូលចិត្តអី គឺត្រូវតែចូលចិត្តបែបហ្នឹង"

សម្ដីរបស់គេធ្វើឲ្យនាងភាំងបន្តិច ហើយងើបភ្នែកមកប្រសព្វនឹងកែវភ្នែកមុតស្រួច។

"បើរបស់ខ្លះសក្តិសមឲ្យត្រឹមតែចងចាំប៉ុណ្ណោះ"

"អូនមានន័យ..." អ្នកកំលោះជ្រឹមភ្នែកមើលម្ចាស់មុខស្រស់ស្អាត។

"គ្មានអីទេ" នាងបញ្ចប់ការសន្ទនាដោយប្រធានបទនេះ ហើយលូកដៃចាប់ស្លាព្រា។

"អរគុណច្រើន បងម៉ាត ដែលខំចំណាយពេលមើលថែខ្ញុំ"

"អូនជាប្រពន្ធបង ហ្នឹងណា"

ពាក្យថា ប្រពន្ធ ចេញពីមាត់របស់គេធ្វើឲ្យនាងអួលដើម.ក។ ប្រពន្ធឬគ្រាន់តែជាប្រពន្ធដែលគេមិនប្រាថ្នាប៉ុណ្ណោះ។

"ទោះមិនមែនខ្ញុំ ក៏បង ម៉ាត មើលថែគ្រប់គ្នាបានល្អជានិច្ច" សម្ដីរបស់ជីយ៉ន នៅតែចាក់ដោតបេះដូងរបស់នាង។

"វាមិនដូចគ្នាទេ បងធ្វើឲ្យអូន ធ្វើចេញពីចិត្តពិតមែន មិនបានធ្វើពុត ឬរក្សារូបភាព"

គេឡើងមកអង្គុយលើសាឡុងក្បែរ ក្លិនក្រអូបសិចស៊ីចេញពីរាងកាយមាំមួន ធ្វើឲ្យនាងឈ្លក់ទៀតហើយ រាងកាយក្ដៅភាយៗ វាតែងតែបែបនេះពេលដែលនៅជិត ម៉ាទិនេស។



"បងម៉ាត...ខិតចេញបន្តិចទៅ"

"ហេតុអី ?" គេសួរតែមិនព្រមខិតចេញ។

"គឺ...ខ្ញុំញ៉ាំបាយមិនស្រួល"

"មិនឃើញកើតអី"

"ចាំ ?" នាងងាកខ្វាច់ទៅរក ហើយឃើញថាគេញញឹមច្រឡឹមដាក់។

"ចាំបងបញ្ចុក"

នាងភាំងមួយដង្ហើម ខ្លួនប្រាណក៏ទៅជាស្រៀស ជាពិសេសចុងទ្រូងដែលក្តោបដោយអាវក្នុង ពណ៌ស្រស់។

"ខ្ញុំ...ញ៉ាំខ្លួនឯងបាន"

"បងដឹងថាអូនញ៉ាំខ្លួនឯងបាន ប៉ុន្តែបងចង់បញ្ចុកហ្នឹងណា"

គេញញឹម និងបញ្ជាក់សម្តីខ្លួនឯងដោយការទាញស្លាព្រា និងសមពីដៃរបស់នាង។

"បងម៉ាត ឲ្យមកវិញ"

"នៅឲ្យស្ងៀមទៅ"

"តែខ្ញុំញ៉ាំខ្លួនឯងបានពិតមែន" នាងបដិសេធ តែគេមិនព្រមស្តាប់។

"ប្រាប់ថា បងដឹងហើយថាអូនញ៉ាំខ្លួនឯងបាន តែបងចង់បញ្ចុកប្រពន្ធប្ញាស់ទេ យ៉ូលី" គេហៅឈ្មោះរបស់នាងពេញដោយសំឡេងកាច នោះហើយដែលធ្វើឲ្យនាងខ្ចីបមាត់ តែគេបែរជាសើចចូលចិត្ត ហើយដួសផាកឡូវក្នុងចានមកលាយនឹងបាយទន់ល្មៀយ លើកបញ្ចុកនាង។

"ហាមាត់"

នាងក្រមុំនៅតែខ្ចីបមាត់ដដែល។

"បើបញ្ចុកដោយស្លាព្រាមិនបាន បងនឹងបញ្ចុកដោយមាត់ អូនចូលចិត្តឲ្យបងប្រើមាត់មែនទេ"



លើកនេះ នាងបើកភ្នែកស្មើរលៀន និងចំហមាត់ផ្លង ក្រវីក្បាលដូចកូនឆ្កែ ថ្ពាល់ទាំងពីរឡើងក្រហមង៉ាំង។

"មិន...មិនមែនអីចឹង"

ម៉ាទិនេស ញញឹមគ្រប់ពេលវេលា។

"បើមិនចង់ឲ្យបងប្រើមាត់បញ្ចុក ហាមាត់មក ហើយញ៉ាំបាយ"

នាងចង់ប្រឆាំងនឹងមនុស្សផ្តាច់ការខ្លាំងណាស់ តែដឹងច្បាស់ថាស្ថានការណ៍បែបនេះខ្លួនឯងមិនគួរណាឈ្នះ ទើបព្រមហាមាត់ធ្វើតាមបញ្ជា ធ្វើឲ្យម៉ាទិនេស សើចក្អាកក្អាយ ដោយការពេញចិត្ត។

"ត្រូវតែបែបនេះ អាំ...ឆ្ងាញ់មែនទេ"

"ខ្ញុំញ៉ាំខ្លួនឯងឆ្ងាញ់ជាង" នាងតបដោយទឹកមុខមិនស្រស់ តែគេមិនខ្វល់ នៅតែបញ្ចុកបន្ត។

"នេះញ៉ាំពងក្រហមផងនឹងឆាប់ធំ"

នាងហាមាត់ ទទួលយកបាយស្លាព្រាទីពីរ ហើយក៏អត់តវ៉ាមិនបាន។

"ខ្ញុំមិនមែនក្មេងទេ មិនត្រូវការធំទៀតទេ"

"មែនហើយបងភ្លេចទៅ អូនមិនមែនជាក្មេងស្រមេកស្រមក ដូចកាលពីជាងដប់ឆ្នាំមុនឯណា"

រំពេចនោះ ការពេញចិត្តបង្ហាញឲ្យឃើញនៅលើកែវភ្នែកមុតស្រួចរបស់ម៉ាទិនេស ប៉ុន្តែវាបានត្រឹមតែមួយភ្លែតប៉ុណ្ណោះ ភាពខ្មៅងងឹតដែលមើលមិនយល់ក៏មានវត្តមានវិញ។

"ចាំ ខ្ញុំគ្រាន់តែជាក្មេងលេងដី មិនស្អាតមិនគួរឲ្យស្រឡាញ់ដូចគូបណ្តើររបស់បង" នាងបញ្ឈឺដោយការតូចចិត្ត ម៉ាទិនេស ក៏សើចញឹមៗ។



"ទោះអូនមិនពេញដៃ ពេញជើងស៊ូស្រីៗអស់នោះមិនបាន តែបង



Scanned with CamScanner

ចូលចិត្តភាពធម្មជាតិរបស់អូន"

នាងក្រមុំងាកមុខចេញ ដឹងច្បាស់ថាគេនិយាយរក្សាទឹកចិត្តខ្លួនឯង។

"ខ្ញុំគួរសប្បាយចិត្តមែនទេ ?"

"អឺ គឺសប្បាយចិត្ត"

តែហេតុអីពេលនេះអារម្មណ៍របស់នាង នៅឆ្ងាយពីពាក្យថា សប្បាយចិត្តហៅមិនឮតែម្តង។

"បងម៉ាត បានហើយ ខ្ញុំឆ្អែតហើយ" នាងហាមាត់ ព្រោះបេះដូងវាឈឺខ្លាំងដល់ថ្នាក់ញ៉ាំមិនចូល។

"ទើបតែញ៉ាំបាយបានបីបួនម៉ាត់ហ្នឹង ម៉េចក៏ឆាប់ឆ្អែតម្ល៉េះ"

"ខ្ញុំមិនឃ្លាន អរគុណដែលជួយ"

នាងងាកមុខចេញម្តងទៀត សំឡេងនិងទឹកមុខសោះកក្រោះ ធ្វើឲ្យម៉ាទិនេស សង្កេតឃើញមិនពិបាក។

"បងមិនដឹងទេថា ហេតុអីបានជាអូនចូលចិត្តគេចមុខពីបង ចូលចិត្តធ្វើដូចបងគ្មានរូបរាង តែសម្រាប់បង អូនជាមនុស្សស្រីតែម្នាក់គត់ដែលបងចង់មើលថែមួយជីវិត"

"ព្រោះបងគ្មានជម្រើសមែនទេ"

នាងបង្ខំចិត្តងាកមកប្រឈមមុខនឹងគេម្តងទៀត ទឹកភ្នែកពីរតំណក់ស្រក់ចុះដោយគួរឲ្យអាម៉ាស់។ នាងស្អប់ខ្លួនឯងដែលតែងតែឈឺចាប់ជានិច្ច ពេលគិតថា ម៉ាទិនេស មិនស្រឡាញ់ខ្លួន។

"ថ្ងៃមួយ អូននឹងដឹង"

"ពេលនេះ ខ្ញុំដឹងហើយ"

"វាអាចមិនមែនជាការពិតក៏ថាបាន"



គេដាក់ចានបាយនៅលើថាស ហើយងើបឈរ ទឹកមុខក៏រាបស្មើ មើលមិនយល់អារម្មណ៍។

"បងសុំពេលមួយភ្លែត តិចទៀតមកវិញ"

"ចាំ តែតាមសម្រួលចុះ មិនបាច់បារម្ភពីខ្ញុំ"

នាងក្រមុំខាំមាត់តប ដោយសំឡេងខ្សាវៗនិងញ័រ តាមមើល ម៉ាទិនេស ដែលដើរចេញទៅបាត់ ហើយទឹកភ្នែកក៏ហូរសស្រាក់។

*ហេតុអីនាង...មិនរឹងមាំបែបនេះ ?*

ម៉ាទិនេស ឈរឱបដៃស្រូបយកខ្យល់អាកាសនៅរានហាលដែលលយចេញពីតួភូមិគ្រឹះ កែវភ្នែកពណ៌ខៀវចាស់ពេលនេះត្រូវភាពងងឹតលុបឲ្យមានពណ៌ដូចគ្នា មុខសង្ហារាបស្មើ មើលមិនយល់អារម្មណ៍ថ្ពាល់ត្រង់ថ្គាមឡើងរឹងគ្រប់ពេលវេលា។ អ្វីម្យ៉ាងនៅក្នុងទ្រូងកំពុងតែសម្លាប់ និងធ្វើឲ្យគេវេទនាខ្លាំង។

រសជាតិផ្អែមល្ហែមពីបបូរមាត់ក្រពុំរបស់ យូលី នៅតែជិតជាមជាប់អារម្មណ៍ ហើយវាក៏ធ្វើឲ្យគេស្រេកឃ្លានខ្លាំង ដល់ថ្នាក់គួរឲ្យខ្លាចចិត្តខ្លួនឯង។ គេប្រាថ្នាភរិយាយ៉ាងខ្លាំង ក្នុងខួរក្បាលស្រមើស្រមៃដល់ការរួមរក្សជាមួយនាងរាប់មិនអស់ ប៉ុន្តែគេប៉ះពាល់នាងមិនបាន នាងមិនរឹងមាំ ហើយគេគួរតែរង់ចាំដោយចិត្តត្រជាក់ ដើម្បីឲ្យនាងយល់ព្រម។

ម៉ាទិនេស ខាំថ្គាមណែន ដាក់ដៃលើរនាំងរានហាល ខ្ទាំសាច់ឈើខ្លាំងៗដើម្បីគ្រប់គ្រងតម្រូវការ ដែលកំពុងតែផ្ទុះរបស់ខ្លួនអស់ពីសមត្ថភាព។

គេស្អប់ខ្លួនឯងខ្លាំងណាស់ដែលចេះតែគិតរឿងលើគ្រែ ស្អប់ខ្លួនឯងដែលចេះតែស្រេកឃ្លានភរិយាដោយគ្មានទីបញ្ចប់។ គេចង់ថើបជញ្ជក់បបូរមាត់របស់នាងខ្លាំងៗ ថើបទាល់តែជាំ បន្ទាប់មកក៏ចាប់បោះនាងទៅលើគ្រែ និង



គ្រប់គ្រងនាងដោយមិនប្រណី។

*ឆ្កួតមែន!*

តេជេរខ្លួនឯងដោយការមួម៉ៅ ពេបមាត់ដោយការខ្ពើមខ្លួនឯងជាខ្លាំង។

គេធ្លាប់គ្រប់គ្រងខ្លួនឯងបានល្អមិនអីចឹង មិនធ្លាប់មានបញ្ហានិងរឿងអស់នេះសូម្បីតែម្តង ប៉ុន្តែហេតុអីពេលនៅជាមួយ យ្យូលី គេបែរជាមានអារម្មណ៍ខ្លាំង នាងមានឥទ្ធិពលចំពោះរាងកាយរបស់គេខ្លាំង ដល់ថ្នាក់...គួរឲ្យខ្លាច។

គេលើកដៃអង្អែលមុខខ្លាំងៗ ថ្ពាល់ត្រង់ថ្គាមឡើងរឹងកំព្រឹស ហើយសម្រេចចិត្តថាយប់នេះ មិនអាចដេករួមគ្រែជាមួយភរិយាបាន មិនអីចឹងមុខជាបានចាប់បង្ខំនាងមិនខាន ប៉ុន្តែបើមិនដេកបន្ទប់តែមួយ គេក៏អត់បារម្ភពីនាងមិនបាន ដូច្នេះហើយគួរតែដេកលើសាឡុងនិងមើលនាងដេកនៅលើគ្រែគ្រប់ពេលវេលា។

គេដើរចូលបន្ទប់ផ្សំដំណេកវិញ ឃើញភរិយាដេកលក់បាត់ទៅហើយ។

គេដើរទៅដាក់បង្អុយនៅជិតគ្រែថ្នមៗ បំផុតតាមដែលអាចធ្វើបាន កែវភ្នែកមុតស្រួចក៏សម្លឹងមើលមុខស្រស់ស្អាតដោយការសរសើរ។

យ្យូលី មិនមែនជាស្រីដែលស្អាតដល់ថ្នាក់មើលហើយស្រឡាំងកាំង តែនាងមានរង្វង់មុខស្រស់ស្រទន់ កាន់តែមើលកាន់តែលង់។ មិនគួរឲ្យជឿថាកូនទារូបអាក្រក់កាលពីអតីត ពេលធំពេញក្រមុំ ស្រស់ស្អាតដល់ថ្នាក់នេះ។ គេនៅចងចាំវិនាទីដំបូងដែលឃើញនាងបានច្បាស់ បន្ទាប់ពីខានជួបគ្នាយូរ។

បេះដូងរបស់គេលោតដុកដាក់ ពោះវៀនពោះតាំងរមួល ហាក់ដូចពោះវៀនក្នុងពោះប្រហោងធ្លុង ហាក់ដូចមានទឹកក្តួចនៅក្នុងនោះ បន្ទាប់មកខ្យល់ដង្ហើមក៏ត្រូវផ្តាច់ពីសួត ពេលបានប្រសព្វភ្នែកនឹងនាង។

គេសម្លឹងមើល មើលនាងដែលអង្គុយលើរទេះរុញគ្រប់ពេលវេលា ដែលអាចធ្វើបានផ្ចិតគ្រប់យ៉ាងដែលនៅលើមុខស្រស់ស្អាត។ គេនៅចាំបានច្បាស់ថា កាលណោះរាងកាយក្តៅគគុកតបទទួលយកមន្តស្នេហ៍របស់នាងខ្លាំងប៉ុណ្ណា ដែលពេលនេះក៏មិនខុសពីពេលនោះ។

ម៉ាទិនេស ខាំថ្គាមណែនដោយការមួម៉ៅ ពេលរាងកាយរបស់គេមានប្រតិកម្មម្តងទៀតយ៉ាងខ្លាំងក្លា។ គេសម្លឹងមើលមុខស្រស់ស្អាត បបូរមាត់ កចិញ្ចើម ចង្កា សមគ្នាឥតខ្ចោះ ហើយរំពេចនោះក៏មិនអាចហាមចិត្តខ្លួនឯងបានទៀត ទើបឱនទៅថើបបបូរមាត់ក្រពុំថ្នមៗ។

គេនៅស្ងៀមមួយសន្ទុះ ទើបកម្រើកមាត់ផ្ចិតយកភាពផ្អែមល្ហែម រហូតដល់ពេលមួយដែលមិនអាចគ្រប់គ្រងភ្លើងនៅក្នុងខ្លួនបាន ទើបរសថើបកាន់តែក្តៅ និងខ្លាំងក្លាដាក់សម្ពាធ ធ្វើឲ្យនាងក្រមុំបើកភ្នែក តែប្រាកដណាស់ថា នាងគ្មានឱកាសបានតវ៉ា។

"អី..."

ម៉ាទិនេស មិនបណ្តោយឲ្យនាងបានត្រៀមខ្លួន គេបឺតជញ្ជក់បបូរមាត់ខ្លាំងៗ ព្រមទាំងទ្រោបពីលើ ធ្វើឲ្យនាងក្រមុំប៉ះដើមទ្រូងហាប់ណែនដោយសាច់ដុំគួរឲ្យខ្លាំរបស់គេ។

នាងបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល ប៉ុន្តែអារម្មណ៍ក្តៅគគុក ដែលម៉ាទិនេស ប្រគល់ឲ្យ ធ្វើឲ្យនាងកំពុងជ្រួលច្រាល់ និង មានអារម្មណ៍មួយរំពេចបន្ទាប់ពីគួរតែរើបម្រះ បែរទៅរទន់ តបស្នងដោយការពេញចិត្ត រាងកាយកំពុងតែរលាយមិនខុសពីរបស់រាវ។

គេនៅតែថើបបបូរមាត់របស់នាងជាបន្តបន្ទាប់ ថើបដោយក្តីស្រេកឃ្លាន ជ្រៀតអណ្តាតចូលមករឹតរួតអណ្តាតរបស់នាង ខណៈដែលដៃអូសទៅរកកំប៉េះគូទ ច្របាច់ខ្លាំងៗគួរឲ្យខ្ញាញ់ ហើយអូសមករកត្រគាក ក្រវិលនៅត្រង់នោះ។



ពេលនេះអារម្មណ៍របស់ យ៉ូលី ហោះហើរ ធ្លាក់ចូលជ្រោះប្រាថ្នាដោយមិនអាចឡើងមកវិញបាន រាងកាយរបស់នាងក្ដៅហាក់ដូចមានភ្នក់ភ្លើងនៅក្នុងនោះ ឈាមក៏ក្ដៅ ធ្វើឲ្យដើមទ្រូងរីកមាឌកាន់ធំចុងរបស់វាដែលគ្រសោបដោយអាវក្នុងពណ៌ស្រស់ ឡើងរឹងគួរឲ្យខ្មាស ប៉ុន្តែនាងគ្រប់គ្រងរាងកាយមិនបាន។

"អ៊ំា..."

នាងក្រមុំញ័រខ្លួនទទ្រើត ការថើបរបស់ ម៉ាទិនេស មិនដូចលើកមុនៗ វាកាចសាហាវ គួរឲ្យខ្លាច ប្រាប់ឲ្យដឹងថាគេមិនមែនជាសុភាពបុរសដែលឃើញ ប៉ុន្តែនាងលែងខ្វល់ពីអ្វីទៀតហើយ ក្រៅពីការប៉ះពាល់ពីបបូរមាត់ក្ដៅនិងបាតដៃរបស់ ម៉ាទិនេស ប៉ុណ្ណោះ។

នេះនាងកំពុងតែវង្វេងចូលទៅក្នុងភពណា ហេតុអីបានជារាងកាយរីកមាឌ ហោះហើរ ដូចដុំសំឡីបែបនេះ អណ្ដាតត្រឹមដែលត្រវាសមកដល់.កដួសដង ធ្វើឲ្យនាងកាន់តែហោះហើរទៅឆ្ងាយសែនឆ្ងាយ។

"អា...អា...បងម៉ាត..."

នាងត្រសុលទៅរក និងថ្ងូចថ្ងូរហៅឈ្មោះរបស់គេ នោះហើយដែលធ្វើឲ្យគេស្ទុះងើបចេញឆ្ងាយភ្លាម ហាក់ដូចរាងកាយរបស់នាងជារងើកភ្លើង។

"បង...សុំទោស"

គេចុះពីគ្រែឈរឲ្យឆ្ងាយច្រើនជំហាន សម្លឹងមើលមុខនាង ព្រមទាំងលើកដៃអង្អែលមុខសង្កាខ្លាំងៗ។

"វាមិនគួរកើតឡើង បងសុំទោស..."

គេសុំទោសម្ដងហើយម្ដងទៀត ដែលធ្វើឲ្យនាងឈឺចាប់បន្តិច អារម្មណ៍ស្រៀវស្រើបអម្បាញ់មិញ ក៏រលាយបាត់អស់ សល់តែការឈឺចាប់ប៉ុណ្ណោះ។

"មិន...អីទេ នាងអាម៉ាស់ស្ទើរតែរត់ចូលក្រោមគ្រែទៅហើយ "រាត្រីសួស្ដី



ខ្ញុំងងុយដេកហើយ"

ម៉ាទិនេស ខាំមាត់ដើរមករក ទាញភួយដណ្ដប់ឲ្យ ខណៈនោះក៏ប្រឹងទប់អារម្មណ៍ចង់រួមរក្សនឹងកិរិយាដល់ថ្នាក់ឈឺពេញខ្លួន។

"រាត្រីសួស្ដី" នាងក្រមុំបិទភ្នែក ហើយទឹកភ្នែកក៏ហូរមកបកអាក្រាតភាពគួរឲ្យវេទនារបស់ខ្លួន។ នាងស្អប់ខ្លួនឯងខ្លាំងដែលនៅតែមានសង្ឃឹម សង្ឃឹមថាគេនឹងទាញទៅឱប ទាញទៅថើបម្ដងទៀត។

ម៉ាទិនេស គ្រាន់តែភ្លេចខ្លួនប៉ុណ្ណោះ ការពិតគេមិនបានត្រូវការនាង... ស្រីខ្ទិនដូចនាងបានត្រឹមតែដេកឱបសំបុត្រអាពាហ៍ពិពាហ៍ ចាត់ទុកជាបុណ្យណាស់ទៅហើយ។

ម៉ាទិនេស ឈរមើល យ៉ូលី ដេកលក់ដោយអារម្មណ៍វេទនា។ គេត្រូវប្រើការព្យាយាមដោយខ្លាំងៗ ទម្រាំតែអាចនាំខ្លួនឯងដើរទៅអង្គុយលើសាឡុងមាត់បង្អួចបាន ដែលនៅក្នុងខួរក្បាលមានតែតណ្ហា ថែមទាំងខ្លួនប្រាណនៅតែក្ដៅខ្លាំង។ ពេលនេះគេមានសភាពមិនខុសពីក្មេងស្ទាវទើបតែមានស្នេហាយ៉ាងអីចឹង។

*ឆ្កួតមែន!*

គេក្រហឹមនៅក្នុងចិត្តដោយការម្ហួម៉ៅ ហើយខាំមាត់ផ្ដួលខ្លួនដេកនៅលើសាឡុង។ ភាពត្រជាក់ចេញពីសាឡុងរត់ចូលមកក្នុងស្បែក តែបែរជាមិនអាចចូលពន្លត់ភ្លើងក្ដៅនៅក្នុងខ្លួនបាន។ គេប្រហែលជាត្រូវដេកវេទនា ព្រោះតែតម្រូវការបែបនេះពេញមួយយប់ហើយ។



**"ប៉ាម៉ាក់មិននៅពីរបីថ្ងៃទៀតទេឬ?"** ម៉ាទិនេស សួរដោយការសង្ស័យពេលម្ដាយប្រាប់ពីការត្រឡប់ទៅអ៊ីតាលីឲ្យដឹងនៅក្នុងបន្ទប់អាហារ នាព្រឹកថ្ងៃ

បន្ទាប់។

"តិប៉ា មានការងារបន្ទាន់ ទើបម៉ាក់ប្រញាប់ត្រឡប់ទៅវិញដែរ"

"អូននៅបន្តក៏បានដែរ បន្តម្នាក់ឯងបាន"

ម៉ារិអូ មិនចង់រំខានសេចក្តីសុខរបស់ភរិយា។

"អូនមិនចង់ធ្វើដំណើរម្នាក់ឯង" ម៉ារៀ ប្រាប់ស្វាមី ហើយងាកមករក កូនប្រុសនិងកូនប្រសាច្បង "ចាំ គ្រីស្មាក់ ម៉ាក់មកលេង ឬ ម៉ាត នាំ លីលី ទៅ អ៊ីតាលីក៏បាន"

"ចាំជិតដល់ថ្ងៃ ខ្ញុំនឹងរៀបគម្រោងមើលម្តងទៀតម៉ាក់" ម៉ាទិនេស សើច ញឹមៗ។

"អឺ អីចឹងក៏បាន" ម៉ារៀ ងក់ក្បាលដាក់សម្តីរបស់កូនប្រុសច្បង ហើយ ងាកទៅរក ហេវ៉ាន់ ដែលដើរចូលមកល្មម "ហេវ៉ាន់ ម៉ែ មិនទាន់មកទៀតឬ?"

"ចាស" ហេវ៉ាន់ តបដោយសំឡេងខ្សាវៗ ទើប ម៉ារៀ ដកដង្ហើមធំ និង គ្រវីក្បាលហួសចិត្ត។

"សរុបទៅខ្ញុំមកកូរ៉េខាងត្បូងលើកនេះមិនជួបកូនប្រុស បីនាក់ទៀត ម្នាក់នាំកូនប្រុសទៅដើរលេង ម្នាក់ទៀតនាំប្រពន្ធទៅហាន់នីមូន ចំណែកអ្នក នៅលើវក៏គិតតែរវក់នឹងការងារ"

ម៉ារិអូ អស់សំណើច។

"តិកូនមានក្រុមគ្រួសារអស់ទៅហើយ ចង់ឲ្យទំនេរមកជួបជុំដូចកាល ពីមុនម៉េចនឹងបាន"

ម៉ារៀ ជ្រួញប្រមុះដាក់ស្វាមី។

"អីយ៉ា តិអត់តូចចិត្តមិនបានហ្នឹងណា ថ្នាក់អ្នកនៅលើវក៏ចាត់ទុកការងារ ល្អជាងម្តាយវាទៅទៀត"



"ម៉ែ ជាគ្រូពេទ្យ យ៉ាងណាក៏ត្រូវផ្តោតសំខាន់ទៅលើជីវិតអ្នកជំងឺជាង រឿងផ្ទាល់ខ្លួនស្រាប់ហើយ" ម៉ារិអូ និយាយតាមសាច់រឿង។

"បងកាន់ជើងកូនប្រុសរហូត ពេលណាទើបកាន់ជើងអូនម្តងទៅ ម៉ារិអូ" ស្វាមីអស់សំណើចក្អាកក្អាយ ហើយទទួលទានបន្ត មានតែ ម៉ារៀ ប៉ុណ្ណោះដែលនិយាយមិនព្រមឈប់។

"ម៉ាក់ឮថា ហុងស៊ីន មនុស្សរបស់ លីលី សុំច្បាប់ពីការងារឬ"

"អឺ...ចាំម៉ាក់ ប៉ារបស់ ហុងស៊ីល គ្រោះថ្នាក់ ទើប ហុងស៊ីល ត្រូវទៅ មើលថែនៅមន្ទីរពេទ្យ"

"អាំ ហើយបែបនេះអ្នកណាមើលថែ លីលី អញ្ចេះចុះ ឲ្យ ហេវ៉ាន់ ជួយ សិនបានទេ" ម៉ារៀ មានបំណងល្អ តែកូនប្រុសច្បងជំទាស់យ៉ាងសុភាព។

"ខ្ញុំមើលថែនាងបាន មិនបាច់រំខាន ហេវ៉ាន់ ទេ"

មុខរបស់នាងក្រមុំឡើងក្រហមង៉ាំង ឈ្ងោកមុខឈ្ងោកមាត់គេចពី ខ្សែភ្នែកមុតស្រួចដែលមើលមក។

"ម៉ាត ជាប្រុស មើលថែប្អូនមិនល្អដូចមនុស្សស្រីគ្នាឯងទេ ឲ្យ ហេវ៉ាន់ ទៅជួយល្អជាង"

"ខ្ញុំធ្វើបាន ដោយការពេញចិត្តទៀតផង"

"តែខ្ញុំចង់ឲ្យ ហេវ៉ាន់ ជួយមើលថែខ្ញុំ"

ម៉ាទិនេស ងាកខ្ទាប់មកមើលមុខភរិយា។

"មិនបានទេ បងជាស្វាមីរបស់អូន បងមើលថែអូនបាន"

"តែខ្ញុំ...មិនចង់រំខានបង ម៉ាត ជាងនេះ..."

"បើរំខាន បងនឹងប្រាប់" ទោះសំឡេងរាបស្មើ តែមានអំណាច ធ្វើឲ្យនាង មិនហ៊ានជំទាស់ទៀត។



ម៉ារៀ ឃើញកូនប្រុសនិងកូនប្រសាសម្លឹងមុខគ្នាបែបនេះ ក៏អត់ញញឹម ដោយការពេញចិត្តមិនបាន។

"យប់មិញ ម៉ាត មិនធ្វើឲ្យម៉ាក់អស់សង្ឃឹមទេមែនទេ"

ម៉ាទិនេស ងាកទៅមើលមុខម្តាយ ថ្ពាល់ឡើងក្រហម។

"ម៉ាក់មានន័យដល់អី ?"

ម៉ារៀ សើចខិកៗ។

"ម៉ាក់ចង់បីចៅឆាប់ៗកូនឆាប់មានទៅឲ្យធំទាន់កូនរបស់ មីក និង មេត"

យ្យូលី ឈ្ងោកមុខមើលចានអាហាររបស់ខ្លួន ទឹកភ្នែកក៏រលីងរលោង ពេលការពិតនេះវារត់មកបុកនឹងដើមទ្រូង។

"ខ្ញុំនឹងព្យាយាម"

"ល្អណាស់កូនសម្លាញ់ ម៉ាក់ចូលចិត្តមានចៅឲ្យច្រើនៗ"

ម៉ារៀ និយាយដោយមានសេចក្តីសុខ ដោយមិនសង្កេតទឹកមុខរបស់ យ្យូលី ថាកំពុងទុក្ខវេទនាប៉ុណ្ណា។

ឯ ម៉ាទិនេស ក៏ក្តាប់ស្លាបព្រាណែនដៃ ថ្ពាល់ត្រង់ថ្គាមឡើងប៉ោង ព្រោះ អ្វីម្យ៉ាងនៅក្នុងខ្លួនកំពុងតែជ្រួលច្រាល់។

"ខ្ញុំនឹងរកអ្នកជំនាញកាយចលនាមានថ្មីដៃមកជួយមើលថែ លីលី ម៉ាក់ គិតយ៉ាងម៉េចដែរ" ម៉ារៀ ញញឹមពព្រាយ ជាការយល់ស្រប ខណៈដែល យ្យូលី មានទឹកមុខស្លេកស្លាំង លាក់មិនជិត។

"ក៏ល្អដែរ ម៉ាត លីលីនិងឆាប់ជា"

"អឺ...ខ្ញុំមិនត្រូវការទេ" នាងបដិសេធបំណងល្អរបស់ ម៉ាទិនេស។

"ហេតុអី ? លីលី មិនចង់ជាឬ ?" អ្នកកំលោះសួរដោយការសង្ស័យ។

"មែនហ្នឹង លីលី ម៉ាក់ថាកូនគួរធ្វើ" ម៉ារៀ គាំទ្រគំនិតកូនប្រុសច្បង



ពេញបន្ទុក ខណៈដែល ម៉ារិអូ អង្គុយស្តាប់ដោយមិនមាត់មិន.ក តាមចរិតដែល មិនចូលចិត្តជ្រៀតជ្រែកការងាររបស់អ្នកដទៃ។

"អឺ...គឺខ្ញុំ...ដឹងថាវាគ្មានប្រយោជន៍"

"លីលី" ម៉ាទិនេស ដាក់ដៃលើដៃរបស់ភរិយា ហើយក្តោបមិនព្រមលែង ពេលនាងទាញចេញ "ស្តាប់បង អូនមានឱកាសជា គ្រាន់តែព្យាយាមធ្វើចលនា ញឹកញាប់ប៉ុណ្ណោះ ជឿបង...បងសន្យាថានឹងធ្វើឲ្យអូនដើរបានវិញ"

នាងខ្ទឹបមាត់ ទាញដៃខ្លួនឯងចេញពីការក្តាប់របស់គេបានសម្រេច។

"អរគុណ តែខ្ញុំ...អង្គុយលើរទេះនេះល្អហើយ វាជាជាតុពិតរបស់ខ្ញុំ"

"ហើយអូនមិនចង់ដើរទៅណាមកណាដោយជើងខ្លួនឯងទេឬ ?"

"ខ្ញុំ..."

"មិនបាច់ខ្លាចទេ បងនិងគ្រប់គ្នាលើកទឹកចិត្តអូនជានិច្ច យើងនឹងស៊ូ ជាមួយគ្នា អូនត្រូវតែដើរបានវិញ" នាងគួរតែសប្បាយចិត្ត រំភើបចិត្តនឹងទឹកចិត្ត របស់ ម៉ាទិនេស ដែលបែរជាខ្វល់ខ្វាយទៅវិញ។

"តែខ្ញុំ..."

"ជឿបងទៅ លីលី ហ្វឹកហាត់ធ្វើកាយចលនា ចាប់ផ្តើមធ្វើម្តងទៀត ម៉ាក់ លើកទឹកចិត្តកូនជានិច្ច"

យ្យូលី ត្រូវការបដិសេធ តែមិនអាចនិយាយពាក្យអីចេញមកបានទៀត ធ្វើបានត្រឹមតែងក់ក្បាលបានតិចៗប៉ុណ្ណោះ។

"ល្អណាស់ លីលី "

ម៉ាទិនេស ក្តោបដៃភរិយាម្តងទៀត និងញញឹមពព្រាយ ដោយការ សប្បាយចិត្ត ធ្វើឲ្យនាងមានអារម្មណ៍ដឹងខុស។



"អរគុណបង ម៉ាត"

"បងរីករាយធ្វើដើម្បីអូន"

ម៉ារៀ ញញឹមមានសេចក្ដីសុខ មើលកូនប្រុសច្បងដោយដឹងទាន់គំនិត។ ម៉ាទិនេស ទទួលបញ្ជារបស់ម្ដាយឲ្យរៀបការជាមួយ យូលី ព្រោះស្នេហាមិនមែនព្រោះបដិសេធមិនបានដូចដែលគ្រប់គ្នាយល់។

"ហើយកូនទៅរកអ្នកជំនាញធ្វើកាយចលនាល្អៗមកពីណា ឲ្យម៉ាក់ជួយរកទេ?"

"នៅមន្ទីរពេទ្យរបស់យើងមានអ្នកជំនាញច្រើនណាស់ម៉ាក់ ខ្ញុំនឹងឲ្យ ម៉ៃ ជួយរើសឲ្យម្នាក់" សំឡេងរបស់ ម៉ាទិនេស នៅតែរីករាយ មុខសង្ហាដូចទេវបុត្រ កាន់តែមានមន្ដស្នេហ៍ ពេលគេញញឹម ធ្វើឲ្យ យូលី លួចមើលមុខស្វាមី ដោយអារម្មណ៍ឈ្លក់វង្វេង។

ពេលណា ទើបនាងអាចឈប់ស្រឡាញ់ ម៉ាទិនេស បានទៅ...យូរៗទៅ កាន់តែស្រឡាញ់ខ្លាំង ដកចិត្តមកវិញមិនបាន បើបណ្ដោយឲ្យនៅតែបែបនេះបន្ត ប្រហែលបណ្ដោយឲ្យស្រឡាញ់អស់ពីបេះដូងជានិរន្តរ៍។



# ៥

"អ្នកនាង...មកដោយរបៀបណា?" ហុងស៊ីល ភ្ញាក់ផ្អើលជាខ្លាំង ពេលចូលមកក្នុងបន្ទប់សម្រាករបស់ឪពុក ឃើញ យូលី។

"គឺលួចមកហ្នឹងអី" នាងក្រមុំញញឹមពព្រាយដាក់អ្នកមើលថែជំនិត ហើយក៏ដើរមករកនិងសួរនាំពីអាការៈរបស់អ្នកជំងឺ ដោយការព្រួយបារម្ភ "នេះអ៊ំប្រុសយ៉ាងម៉េចហើយ ពេទ្យប្រាប់ថាមិនធ្ងន់ធ្ងរទេមែនទេ?"

ហុងស៊ីល ញញឹមទាំងទឹកភ្នែក មើលទៅហ្វាយជាការអរគុណ។

"អរគុណច្រើនអ្នកនាងដែលបារម្ភពីប៉ារបស់ខ្ញុំ ប៉ុន្តែប៉ាផុតគ្រោះថ្នាក់ហើយ ខ្ញុំសុំទោសដែលមិនបានតេរទៅប្រាប់"

"មិនអីទេ ខ្ញុំដឹងថាបងពិបាកឆ្លៀតពេល"

នាងក្រមុំដើរមកស្រវាចាប់ដៃអ្នកមើលថែទៅក្ដោប។

"រឿងថ្លៃចាយវាយខ្ញុំជាអ្នកទទួលខុសត្រូវ បងកុំបារម្ភអី"

"កុំអីអ្នកនាង ខ្ញុំមានហើយ" ហុងស៊ីល ក្រែងរអែងចិត្តទៅហ្វាយ។

"កុំនិយាយបែបនេះ ខ្ញុំរីករាយជួយ ប៉ាបងក៏ដូចជាប៉ាខ្ញុំដែរ"

ហុងស៊ីល រលីងរលោងទឹកភ្នែក ឱនគំនាប់ទៅហ្វាយ។

"អរគុណច្រើនអ្នកនាង"

"មិនបាច់អរគុណទេ ខ្ញុំរីករាយជួយ"



យូលី ញញឹម ដើរទៅដាក់បង្អួយលើសាឡុងនៅមាត់បង្អួច ហុងស៊ីល ក៏ម្នីម្នាដើរមកឈរក្បែរ។

"អ្នកនាងលួចចេញមកបែបនេះ បើលោក ម៉ាត ដឹង តើគិតយ៉ាងម៉េច តិចមានរឿងធំ"

"ខ្ញុំមិនខ្លាច"

"ធ្វើឯងនិយាយឡូយ នេះបើលោក ម៉ាត ដឹងថាអ្នកនាងដើរបានតាំងពីយូរហើយសង្ស័យខឹងដាច់ក្បាលដាច់កន្ទុយ"

នៅក្នុងកែវភ្នែករបស់ យ្យូលី មានភាពខ្វល់ខ្វាយឲ្យឃើញបន្តិច តែនាងរហ័សបន្លប់។

"តាមតែគេទៅ ខ្ញុំមិនចាប់អារម្មណ៍"

"ចំណាប់អារម្មណ៍ទាំងអស់របស់អ្នកនាងនៅលោក ម៉ាត តែម្នាក់"

"បងកុំនិយាយបែបនេះ" នាងធ្វើមុខងរង៉ក់ ព្រោះសម្ដីរបស់ ហុងស៊ុល ជាការពិត។

"ហេតុអី ខ្ញុំនិយាយការពិត គ្រប់ខ្យល់ដង្ហើមចេញចូលរបស់អ្នកនាងមានតែលោក ម៉ាត ម្នាក់គត់"

អ្នកដែលត្រូវបង្អាប់ មុខឡើងក្រហម។

"បានហើយ មិនបាច់និយាយរឿងនេះទេ តែបងវិញ យ៉ាងម៉េចដែរ បានដេកខ្លះទេ មុខស្លេកស្លក់ណាស់"

"ខ្ញុំដេកបានតិច ភ្ញាក់ពេញមួយយប់ បារម្ភពីលោកប៉ា ប៉ុន្តែពេលនេះសប្បាយចិត្តហើយ ពេលដឹងថាប៉ាផុតគ្រោះថ្នាក់" ហុងស៊ុល សើចញឹមៗ "ចុះអ្នកនាងវិញយ៉ាងម៉េចដែរយប់មិញ ?"

"អឺ..." ថ្ពាល់របស់នាងឡើងក្រហមង៉ាំង "គឺសុខសប្បាយ គ្មានស្អីទេ សួរធ្វើអី ?"

"អីយ៉ា ខ្ញុំស្មានថាមានអីល្អៗកើតឡើងចំពោះអ្នកនាងរបស់ខ្ញុំហើយតើ"



អ្នកដែលត្រូវបង្អាប់ អៀនឡើងមុខខ្មៅ។

"តើមានស្អីទៅ ខ្ញុំដេកតែខ្ញុំ"

"ចុះលោក ម៉ាត ?"

"គេដេកកន្លែងរបស់គេ មិនពាក់ព័ន្ធនឹងខ្ញុំទេ"

"ម៉េចចាំបាច់អៀន ខ្ញុំគ្រាន់តែសួរលេងៗ" ហុងស៊ុល សើចខឹកៗ។

"អត់មានទេ មិនបានអៀនទេ"

ថ្ពាល់របស់ យ្យូលី នៅតែក្រហម រសជាតិថើបដ៏ក្ដៅគគុកកាលពីយប់មិញនៅតែធ្វើឲ្យរាងកាយរបស់នាងស្រៀវស្រើបបានគ្រប់វិនាទី។

"អូខេ មិនអៀនក៏មិនអៀន តែលោក ម៉ាត ព្រមឲ្យអ្នកនាងបាត់ពីភ្នែកបានដោយរបៀបណា ?"

យ្យូលី បានឮសំណួរនេះហើយក៏ដកដង្ហើមធំដោយការព្រួយបារម្ភ។

"ខ្ញុំប្រឡំងើបអង្គុយឲ្យបង ម៉ាត ឃើញ"

"ស្លាប់ហើយ !"

"មិនទាន់ស្លាប់ទេបង តែបង ម៉ាត រកអ្នកជំនាញមកធ្វើកាយចលនាឲ្យខ្ញុំហ្នឹងទើបស្លាប់មែនទែន"

ហុងស៊ុល មានទឹកមុខមិនសប្បាយចិត្តភ្លាម។

"បើអ្នកជំនាញពូកែមកឃើញអ្នកនាង គេច្បាស់ជាដឹងហើយថាអ្នកនាងដើរបានតាំងពីយូរម្ល៉េះ"

"ហ្នឹងហើយ ខ្ញុំខ្លាចមែនទែន"

លើកនេះទាំងចៅហ្វាយទាំងកូនចៅធ្វើមុខតានតឹងដាក់គ្នា។



"បងថាខ្ញុំគួរធ្វើយ៉ាងណា ឬថាលោតឲ្យឡានបុក បាក់ឆ្អឹងខ្នងម្ដងទៀត"

"ធ្វើបែបហ្នឹងមិនបានទេ"

"ហើយខ្ញុំធ្វើយ៉ាងម៉េចទៅ បើអ្នកជំនាញដឹងថាខ្ញុំដើរបាន បង ម៉ាត ក៏ត្រូវតែដឹងដែរ"

ហុងស៊ីល ដើរទៅដើរមក ប្រឹងគិត។

"ខ្ញុំថាអ្នកនាងគួរប្រាប់ការពិតដល់លោក ម៉ាត ថាដើរបានល្អទេ មិនចាំបាច់បិទបាំងទៀត"

"នោះជាជម្រើសចុងក្រោយ" នាងក្រមុំតបដោយទឹកមុខសោកសៅ "បងក៏ដឹងដែរថាបើខ្ញុំមិនទន់ជ្រាយ មិនពិការ បង ម៉ាត ក៏មិនរៀបការជាមួយខ្ញុំដែរ បើបង ម៉ាត ដឹងការពិត គេច្បាស់ជាបោះបង់ខ្ញុំ"

"ការពិតជារឿងដែលមិនស្លាប់ អ្នកនាង"

"មែន ការពិតជារឿងមិនស្លាប់ តែអ្នកស្លាប់គឺអ្នកដែលប្រាប់ការពិត" នាងដកដង្ហើមធំដោយអារម្មណ៍ខ្វល់ខ្វាយ "ខ្ញុំនឹងទិញទឹកចិត្តអ្នកជំនាញរបស់បង ម៉ាត ដើម្បីឲ្យគេធ្វើជាបក្ខពួករបស់យើង"

"វិធីនេះវាល្អហើយ ប៉ុន្តែបើអ្នកជំនាញនោះជាមនុស្សល្អ ហើយមិនព្រមធ្វើតាមតម្រូវការរបស់អ្នកនាង តើគិតយ៉ាងម៉េច ខ្ញុំថាយើងប្រាប់ការពិតទៅ"

នាងក្រមុំគ្រវីក្បាល។

"ខ្ញុំខ្ជិននៅលើករទេះបែបនេះហើយល្អ មិនព្រមប្រាប់ការពិតដល់បង ម៉ាត ជាដាច់ខាត"

"អ្នកនាង"

"បងមិនបាច់និយាយទេ ខ្ញុំសម្រេចចិត្តហើយ"

ហុងស៊ីល ដកដង្ហើមធំដោយចិត្តខ្វល់ខ្វាយ តែមិនអាចជំទាស់ចិត្តចៅហ្វាយរបស់ខ្លួនបាន ត្រូវធ្វើតាម។

"ហើយនេះអ្នកនាងត្រឡប់ទៅផ្ទះវិញយ៉ាងម៉េច ?"

"ប្រហែលឡើងជញ្ជាំងដដែលហ្នឹង តែយ៉ាងបន្តិចត្រង់គ្មានបងជួយមើលផ្លូវឲ្យដូចមុនៗ"

"អញ្ចេះចុះ ចាំខ្ញុំទៅវិញជាមួយ ព្រលប់ខ្ញុំមកមើលថៃប៉ាវិញ"

"ល្អឬ ខ្ញុំមិនចង់រំខានទេ"

"រំខានអី ខ្ញុំរីករាយធ្វើ ម្យ៉ាងទៀតប៉ាមានគិលានុបដ្ឋាយិកាចាំមើលថែហើយ"

យូលី មើលមុខអ្នកមើលថែរបស់ខ្លួនជាការអរគុណ។

"អរគុណ ខ្ញុំស្រឡាញ់បងមែនទែន"

"ខ្ញុំក៏ស្រឡាញ់អ្នកនាង"

"អ៊ីចឹងមុនពេលទៅវិញ នាំខ្ញុំទៅទិញរបស់នៅហាងបន្តិច ឡេលាបមុខរបស់ខ្ញុំអស់ហើយ"

"ចាំ អ្នកនាង"

យូលី ញញឹមពព្រាយដោយការសប្បាយចិត្ត។

ជីយ៉ន លើកដៃញីភ្នែកខ្លាំងៗ ពេលដែលឃើញមនុស្សស្រីម្នាក់ដែលមានមុខមាត់ប្រហែលមែនទែន។

"ដូច..." នាងកំពុងតែដើរសំដៅទៅ តែសំឡេងរបស់ប្អូនប្រុសម្ដាយទីទៃក៏បន្លឺឡើង។

"សួស្ដីបងស្រី"

"អាំ តេយ៉ុង មកហើយឬ"



គីម តេយ៉ុង ប្អូនប្រុសម្ដាយទីទៃដែលទើបបញ្ចប់ការសិក្សាមកពីបរទេសដោយប្រាក់របស់នាងបានប្រាំពីរខែជាងហើយ ដើរមកឈរទល់មុខ។

"បាទ" អ្នកដែលមានមុខមាត់សង្ហាតាមបែបបុរសកូរ៉េ ញញឹមពព្រាយ ហើយងាកទៅមើលតាមភ្នែករបស់បងស្រីដោយការសង្ស័យ "បងរកមើលអ្នកណា?"

"អឺ...ជួនអីបងឃើញអ្នកដែលធ្លាប់ស្គាល់គ្នា"

"អីចឹងបងទៅរាក់ទាក់មិត្តភក្តិសិនទៅ ខ្ញុំដើរម្តុំៗនេះ"

ជីយ៉ន គ្រវីក្បាល។

"មិនទៅទេ បងគួរតែចាំមនុស្សខុស នាងនោះមិនគួរណាដើរហើរបានបើចេញមកដើរបែបនេះគួរតែអង្គុយលើរទេះរុញ"

អ្នកនិយាយញញឹមចំអកឡកឡឺយ។

"បងចង់មានន័យដល់អ្នកណា?"

"ស្រីខ្ញិនដែលសំណាងល្អបានរៀបការជាមួយបុរសល្អឥតខ្ចោះ"

តេយ៉ុង អស់សំណើច។

"បងចង់មានន័យដល់រឿងប្រលោមលោកមែនទេ"

"ជារឿងពិត ហើយក៏ជារឿងជិតខ្លួនបងដែរ" នាងធ្វើមុខធុញថប់បំផុត "បងនេះខំប៉ងតាំងពីយូរ សុខៗក៏ត្រូវមីខ្ញិនដណ្តើមយកទៅរៀបការ វាគួរឲ្យឈឺចិត្តណាស់"

"រកថ្មីទៅ បងស្រីខ្ញុំទាំងស្អាតទាំងពូកែ បុរសណាក៏ចង់បានធ្វើជាឧត្តមភរិយាដែរ"

"តែបងមិនចង់បានប្រុសៗអស់នោះធ្វើជាប្តី" នាងញញឹមលាក់កំណួច "អ្នកដែលបងចង់បាន...គឺប្តីមីខ្ញិននោះឯង ចាំមើល បងនឹងដណ្តើមយកឲ្យបាន"

តេយ៉ុង មិនចូលចិត្តគំនិតបងស្រី តែមិនចង់និយាយឲ្យឃ្នើសចិត្ត ទើបប្តូររឿងនិយាយ។



"ខ្ញុំសប្បាយចិត្ត ដែលបងព្រមឲ្យខ្ញុំប៉ាវបាយថ្ងៃនេះ"

"គឺបងទំនេរល្មម តែឯងវិញ ចង់ប៉ាវស្អី ប្រាប់ឲ្យដឹងមុន ថាបងញ៉ាំច្រើន"

ប្អូនប្រុសអស់សំណើច។

"ឲ្យបងជ្រើសរើសខ្លួនឯង ថ្ងៃនេះខ្ញុំបើកប្រាក់ខែ ចង់ញ៉ាំអី ខ្ញុំជូនតាមសំណើបងទាំងអស់"

"ច្បាស់ហើយ?"

"បាទ"

"ល្អ អីចឹងបងញ៉ាំតែរបស់ថ្លៃ ឲ្យឯងអស់ពីកាបូប"

"អញ្ជើញតាមចិត្ត បងស្រីតែម្នាក់ ខ្ញុំប៉ាវបាន"

តេយ៉ុង ដើរតាមបងស្រីម្តាយទីទៃរបស់ខ្លួនមកឈប់នៅមុខភោជនីយដ្ឋានមួយដែលទាំងធំ និងមានការតុបតែងស្អាត។

"បងចូលទៅចាំទៅ ខ្ញុំសុំចូលបន្ទប់ទឹកមួយភ្លែត"

"អឺ ឆាប់មកវិញផង មិនអីចឹងស៊ីខ្ទេច"

"បាទ"

ជីយ៉ន ដើរចូលទៅក្នុងភោជនីយដ្ឋាន រើសតុនៅជិតភ្ញៀវម្នាក់។

"នោះ...មីកញ្ជះតើ វាមកជាមួយអ្នកណា"

ហុងស៊ីល បានដឹងថាត្រូវសម្លឹង ទើបងើបមុខ ហើយក៏ស្លេកមុខភ្លាមពេលឃើញថាជា ជីយ៉ន។

*ស្លាប់ហើយ!*

ហុងស៊ីល ភ្ញាក់ស្ទើរតែស្លុត ម្ទីម្នាឈោកចុចទូរសព្ទដៃផ្ញើសារទៅឲ្យ



ចៅហ្វាយដែលពេលនេះចូលបន្ទប់ទឹក បន្ទាប់មកក៏ហៅបុគ្គលិកគិតលុយ ទាំងដែលអាហារនៅពេញតុ។

"គិតលុយ"

នាងហៅបុគ្គលិកមកគិតលុយដោយភាពរហេរហាន់ ជីយ៉ន ក៏ងើបចេញពីតុខ្លួនឯង ដើរមករាក់ទាក់ដោយការប្រមាថ។

"កញ្ជះដូចឯងមានលុយចេញឬអត់ បើគ្មានប្រាប់ខ្ញុំ ខ្ញុំរីករាយជួយ" ជីយ៉ន សើចចំអក "ព្រោះតាមធម្មតា ខ្ញុំតែងតែធ្វើបុណ្យដាក់សត្វជាប្រចាំ តែបើធ្វើបុណ្យដាក់ឯងម្នាក់ទៀតក៏ប្រហែលមិនអីដែរ"

ហុងស៊ីល ក្ដាប់ដៃណែន សម្លឹងមុខ ជីយ៉ន ដោយការស្អប់ខ្ពើម។

"ទោះខ្ញុំជាកញ្ជះ តែខ្ញុំមិនធ្លាប់មានចិត្តគំនិតស្មោកគ្រោក ចេះតែចង់ដណ្ដើមយកប្ដីគេ ដូចអ្នកខ្លះនៅម្ដុំនេះទេ"

ជីយ៉ន ប្រាល់ឈាមពេញមុខ គ្រប់គ្រងខ្លួនឯងមិនបាន។

"នេះឯងថាឲ្យអ្នកណា មីកញ្ជះ!"

"មិនបាននិយាយឈ្មោះអ្នកណាទេ តែបើអ្នកណាចង់យកក៏យកទៅ ខ្ញុំរីករាយប្រគល់ឲ្យដោយមិនគិតប្រាក់"

និយាយចប់ ហុងស៊ីល ក៏យកប្រាក់អាប់ពីបុគ្គលិក ហើយងើបឈរ។

"ទៅមុនហើយ ប្រញាប់ទៅលាងមាត់ ព្រោះទឹកមាត់ផ្អែផ្អូតខ្ជាតមកចំ"

ហុងស៊ីល ដើរចេញទៅ ដោយយកស្មាកៀសនឹងដើមដៃរបស់ ជីយ៉ន ចេញពីភោជនីយដ្ឋានភ្លាម ខណៈដែល ជីយ៉ន តាមមើលដោយកំហឹង។

"ជួបគ្នាលើកក្រោយ ដឹងតែផ្ដាប់មុខនាងឯង!"

**ស្រីម្នាក់ ដែលដើរបញ្ច្រាសផ្លូវនឹងខ្លួនចូលបន្ទប់ទឹកពុងផ្សារទំនើបល្បី**

ធ្វើឲ្យ តេយ៉ុង ភាំង ដល់ថ្នាក់តាមមើលសឹងបាក់ក។

"ទេពធីតា..."

គេមិនធ្លាប់ឃើញស្រីណាស្អាតបែបនេះ និងមិនធ្លាប់មានស្រីណាធ្វើឲ្យបេះដូងរបស់គេលោតញាប់ដល់ថ្នាក់នេះ ដូចពិភពលោកទាំងមូលឈប់វិលនិងមានតែនាងម្នាក់ប៉ុណ្ណោះដែលធ្វើសកម្មភាព ទើបគេប្រញាប់ប្រញាល់ដើរតាម និងស្រែកហៅ។

"អ្នកនាង..."

"ចាំ?" យូលី ងាកទៅរក ពេលបានឮសំឡេងហៅនៅជិតបង្កើយ "ហៅខ្ញុំឬ?"

កាន់តែមើលជិតកាន់តែស្អាត គេភាវនាឲ្យនាងនៅទំនេរ គ្មានគូ តែក៏ត្រូវអស់សង្ឃឹម ពេលឃើញចិញ្ចៀនពេជ្រនៅនឹងម្រាមដៃនាងខាងឆ្វេង ដែលពន្លឺវាចាំងចាក់ភ្នែកតែម្ដង។

យូលី ជ្រីមភ្នែកមើលបុរសដែលមិនធ្លាប់ស្គាល់ហៅខ្លួនដោយការមិនទុកចិត្ត។

"បើលោកគ្មានការអីទេខ្ញុំទៅហើយ"

"ឈប់"

នាងរលាស់ដៃខ្លួនឯងចេញពីដៃគេភ្លាម និងថយចេញឲ្យឆ្ងាយ។

"ខ្ញុំសុំទោស"

តេយ៉ុង សុំទោសសុំពៃភ្លាម ពេលដឹងថាខ្លួនឯងគ្មានមារយាទចាប់ដៃរបស់នាង។

"មិនអីទេ"



នាងលែងចាប់អារម្មណ៍ពីអ្វីទៀត ម្នីម្នាដើរចេញទៅភ្លាម ហើយជួបនឹង

ហុងស៊ីល ដែលដើរមកពាំងមុខ។

"បង...ចេញមកធ្វើអី ញ៉ាំឆ្អែតហើយឬ?"

"យ៉ាប់ហើយអ្នកនាង" ទឹកមុខរបស់ ហុងស៊ីល មិនល្អ។

"មានរឿងអី?"

"ខ្ញុំជួបស្រីចំពុះក្រហមនៅក្នុងហាងសំណាងល្អដែលអ្នកនាងចូលបន្ទប់ទឹក មិនអីចឹងយ៉ាប់មិនខាន"

ឮហើយ យ៉ូលី ក៏ភ្ញាក់ផ្អើលណាស់ដែរ មុខឡើងស្លេកស្លាំង។

"អីចឹងយើងឆាប់ទៅផ្ទះទៅ ខ្ញុំខ្លាច"

"អីចឹងតោះ តិចនាងចំពុះក្រហមនោះមកឃើញទៀត ចូលចិត្តរករឿងអ្នកនាងស្រាប់ផង"

និយាយហើយ ហុងស៊ីល ក៏ដឹកដៃចៅហ្វាយដើរចេញពីផ្សារទំនើបជាបន្ទាន់ ដោយមាន តេយ៉ុង តាមមើលដោយអារម្មណ៍អាឡោះអាល័យ។

"ទេពធីតាមានម្ចាស់ហើយ យើងបានត្រឹមតែមើល..."

អ្នកកំលោះដកដង្ហើមធំដោយភាពអស់សង្ឃឹម តែទោះដូច្នោះក៏មិនអាចឈប់នឹកដល់មុខមាត់ស្រស់ស្អាតរបស់មនុស្សស្រី ដែលខ្លួនទើបតែបានជួប និងនៅតែនឹកគ្រប់វិនាទី...នេះគេឆ្កួតទៅហើយ!

"អ្នកនាងចាំនៅត្រង់នេះហើយ ខ្ញុំទៅយករទេះសិន" ហុងស៊ីល ប្រាប់ឲ្យចៅហ្វាយ ពួននៅក្រោយគុម្ពផ្កា។

"ខ្ញុំឡើងទៅជាមួយក៏បានដែរ"

"មិនបានទេ បើលោក ម៉ាត ត្រឡប់មកវិញតើគិតយ៉ាងម៉េច ហើយម្យ៉ាងទៀតទីនេះមិនមែនជាផ្ទះរបស់យើង បើពួកអ្នកបម្រើឃើញថាអ្នកនាងដើរបាន



ច្បាស់ជាមានរឿង"

យ៉ូលី ធ្វើមាត់ស្រួច ហើយងក់ក្បាល។

"ក៏បាន អីចឹងឆាប់មកវិញ ខ្ញុំសម្ងំនៅត្រង់នេះ"

"ចាំ ចាំមួយភ្លែតអ្នកនាង"

ហុងស៊ីល រង់ចាំទាល់តែចៅហ្វាយចូលទៅពួននៅក្រោយគុម្ពផ្កា ទើបបែរខ្លួនដើរលបៗចូលក្នុងផ្ទះ តែក៏ត្រូវទប់ដំណើរ ពេលឃើញ ម៉ាទិនេស នៅចំពោះមុខ។

"លោក ម៉ាត!"

"មកវិញហើយឬ ហុងស៊ីល" អ្នកកំលោះរាក់ទាក់។

"អឺ...ចាំ" នាងម៉ាន់ទឹកមុខស្លេកស្លាំង។

"ហើយប៉ាយ៉ាងម៉េចដែរ ស្អែកទំនេរខ្ញុំនឹងទៅសួរសុខទុក"

"ប៉ាធូរហើយ នេះខ្ញុំមកយកខោអាវ ហើយប្រញាប់ទៅកំដរគាត់"

នាងព្យាយាមគ្រប់គ្រងសំឡេងឲ្យជម្មតាបំផុត ប៉ុន្តែ ម៉ាទិនេស នៅតែសង្ស័យ។

"មានអីឬអត់ ម៉េចក៏សំឡេងញ័រម្ល៉េះ"

"អឺ...អត់ទេ អត់មានអីទេ"

"អឺម គ្មានអីក៏ល្អហើយ"

អ្នកកំលោះសើចញឹមៗហើយដើរសំដៅគុម្ពផ្កាដែល យ៉ូលី ពួននៅក្រោយនោះ ទើប ហុងស៊ីល ស្រែកហៅខ្លាំងៗ។

"លោក ម៉ាត"

អ្នកកំលោះបែរមករក ដោយលើកចិញ្ចើមដាក់។

"មានការអី?"



"អី..."

នាងព្យាយាមរកដំណោះស្រាយ "គិថា...អ្នកនាងនៅឯណានៅពេលនេះ ខ្ញុំចង់ទៅរក"

"ហេវ៉ាន់ ប្រាប់ថាគេងលក់ក្នុងបន្ទប់តាំងពីព្រឹកម្ល៉េះ" អ្នកកំលោះឆ្លើយហើយក៏លើកដៃមើលនាឡិកា "នេះម៉ោងពីររសៀលហើយ ម៉េចក៏គេងយូរម្ល៉េះ"

"អុំ តាមធម្មតាអ្នកនាងចូលចិត្តគេង គេងបែបនេះរហូត លោក ម៉ាត"

"មែនឬ?"

"មែន ពេលនៅផ្ទះ ខ្ញុំនេះត្រូវដេកតាម ព្រោះអ្នកនាងគេងពេញមួយថ្ងៃ"

អ្នកកំលោះងក់ក្បាលហើយក៏ដើរសំដៅកៅអីធំនៅក្រោមដើមឈើដែលនៅមិនឆ្ងាយពីគុម្ពផ្កាដែល យូលី លាក់ខ្លួន ព្រមទាំងដាក់បង្គុយចុះ។

ហុងស៊ីល ឃើញថាមិនស្រួលទើបរិះរកវិធីកែខៃ ព្រោះ ម៉ាទិនេស នៅតែអង្គុយត្រង់នោះ យូលី ប្រហែលជាដេកលក់នៅក្រោយគុម្ពផ្កានោះមិនខាន។

"អី...លោក ម៉ាត"

ហុងស៊ីល ដើរមកឈរទល់មុខ។

"មានការអី?"

"គឺខ្ញុំមានរឿងចង់ពិភាក្សា"

"រឿងអី តែប្រាប់ឲ្យដឹងមុនថាបើជារឿងបេះដូងខ្ញុំជួយមិនបានទេ ព្រោះខ្ញុំក៏យោងអាត្មាខ្លួនឯងមិនបានដែរ"

និយាយហើយគេក៏អស់សំណើច មុខសង្ហាមានភាពស្រស់ស្រាយ។

"រឿងរបស់អ្នកនាង"

ស្នាមញញឹមរបស់ ម៉ាទិនេស រលប់ពីមុខភ្លាម ខ្សែភ្នែកក៏ប្រាកដប្រជា។

"មានអីឬ លីលី កើតអី?"



"គឺរឿងធ្វើកាយចលនា" នាងនិយាយខ្សឹបៗ "គឺអ្នកនាងមិនចូលចិត្តខ្លាំងណាស់ នាងប្រាប់ថាឈឺ មិនចង់ធ្វើ ទើបខ្ញុំ...មិនចង់ឲ្យលោកបង្ខំចិត្តនាង"

ម៉ាទិនេស គ្រវីក្បាលបដិសេធភ្លាម។

"ខ្ញុំធ្វើនូវអ្វីដែលនាងនិងអ្នកនាងរបស់នាងត្រូវការមិនបានទេ ព្រោះការធ្វើកាយចលនានឹងធ្វើឲ្យ យូលី ដើរបានវិញ"

"តែអ្នកនាងមិនចូលចិត្ត..."

"មិនចូលចិត្តក៏ត្រូវធ្វើ ឬនាងចង់ឃើញអ្នកនាងរបស់នាងអង្គុយលើរទេះរុញមួយជីវិត"

"មិនមែនអីចឹងទេ" ហុងស៊ីល គ្រវីក្បាល។

"អីចឹងអ្វីដែលខ្ញុំជ្រើសរើស ជាជម្រើសដែលល្អបំផុតសម្រាប់ លីលី"

"អីចឹងសុំពេលឲ្យអ្នកនាងធ្វើចិត្តបានទេលោក ម៉ាត ពីរបីខែក៏បានដែរ"

អ្នកកំលោះសម្លឹងមុខអ្នកនិយាយហើយងើបឈរ។

"ឃើញថាមិនបានទេ"

"ហេតុអី?"

"ខ្ញុំទាក់ទងអ្នកជំនាញរួចហើយ ស្អែកយើងចាប់ផ្តើម ឲ្យ លីលី ធ្វើកាយចលនា"

"អី..."

"ខ្ញុំទៅសិនហើយ ទើបតែនឹកឃើញថាភ្លេចបញ្ជាក់ពេលវេលាដល់អ្នកជំនាញដែលមកស្អែកនេះ"អ្នកកំលោះញញឹមដាក់ម្តងទៀតហើយដើរចេញទៅ ដោយ ហុងស៊ីល ឈរឆ្ងឹងបើកភ្នែកធំៗ ភ្ញាក់ផ្អើលមិនចាញ់អ្នកដែលពួននៅក្រោយគុម្ពផ្កា។



"អ្នកនាង ស្លាប់ហើយ...អ្នកជំនាញមកស្អែកនេះហើយ"

"ខ្ញុំឮហើយ..." នាងក្រមុំងើបឈរ មើលមនុស្សជំនិតរបស់ខ្លួនដោយទឹកមុខខ្វល់ខ្វាយ តើបែបនេះនាងគិតយ៉ាងម៉េចទៅ។

**ទម្រាំនាងអាចឡើងមកអង្គុយលើរទេះរុញ ដោយគ្មានអ្នកណានៅផ្ទះ** ភូមិគ្រឹះម៉ាឡេសាសសូសង្ស័យ ក៏ធ្វើឲ្យហត់គួរសម។ យ៉ូលី អង្គុយព្រួសខ្យល់ដង្ហើមចេញមកតាមមាត់ពេលអង្គុយនៅលើរទេះរុញ ដោយមាន ហុងស៊ុល ឈរជូតញើសចេញពីថ្ងាស។

"អ្នកនាង ហើយយប់នេះឲ្យខ្ញុំកំដរទេ ?"

"បងទៅកំដរប៉ាទៅ ខ្ញុំនៅបាន"

"តែខ្ញុំខ្លាចលោក ម៉ាត ចាប់បានថ្ងៃណាមួយថាអ្នកនាងធ្វើពុតជាពិការ"

"ស្ងួច..."

នាងក្រមុំលើកម្រាមដៃសង្កត់បបូរមាត់ខ្លួនឯង ធ្វើជាសញ្ញាឲ្យដៃគូសន្ទនាឈប់និយាយ "កុំនិយាយ តិចមានអ្នកណាមកឮ"

"សុំទោសអ្នកនាង ខ្ញុំបារម្ភពេកទើបមិនបានជាប្រយ័ត្ន ពេលនេះខ្ញុំបារម្ភពីអ្នកនាងពិតមែន"

"អរគុណ តែខ្ញុំមិនអីទេ បងទៅកំដរប៉ាចុះ"

"ពេលព្រលប់ចាំខ្ញុំទៅ ពេលនេះនៅជួយងូតទឹកឲ្យអ្នកនាងសិន"

យ៉ូលី មើលអ្នកបម្រើជំនិតដោយចិត្តរំភើប។

"ក្រៅពីប៉ាម៉ាក់ មានតែបងទេដែលស្រឡាញ់ខ្ញុំ"

ហុងស៊ុល លុតជង្គង់ក្បែររទេះរុញ ទាញដៃចៅហ្វាយមកក្ដោប។

"ខ្ញុំមើលថែអ្នកនាងជាងដប់ឆ្នាំទៅហើយ ត្រូវតែស្រឡាញ់ ត្រូវតែមានជិតស្និទ្ធជារឿងធម្មតា ដែលសំខាន់អ្នកនាងចិត្តល្អចំពោះខ្ញុំណាស់"

"សរុបទៅយើងស្រឡាញ់គ្នាណាំ"

"ចាំ អ្នកនាង"

ចៅហ្វាយនិងកូនចៅកំពុងនិយាយគ្នានៅវាលស្មៅមុខផ្ទះ រថយន្តទំនើបមួយគ្រឿងក៏បើកចូលមកចតល្មម។

"ឡានអ្នកណា ?" នាងជ្រើមភ្នែកមើល។

"សាស្ត្រាចារ្យ គីម ស្អីគេនោះហ្នឹងអីអ្នកនាង"

ទឹកមុខរបស់ យ៉ូលី ឡើងក្រមូវភ្លាម។

"មិនដឹងជាមកធ្វើស្អី ព្រឹកល្ងាច មិនចេះខ្មាសគេមែន"

"មែនហ្នឹង ចាំខ្ញុំទៅបណ្ដេញឲ្យ"

យ៉ូលី ស្រវាចាប់ដៃអ្នកមើលថែខ្លួនភ្លាម។

"មិនបាច់ទេ ខ្ញុំចង់មើលថាស្រីម្នាក់នោះយកហេតុផលអីមកធ្វើជាលេសទៀត"

ហុងស៊ុល មិនទាន់បាននិយាយអីផង ជីយ៉ន ក៏ដើរកែក្រាយមករករឿងទៅហើយ។

"សួស្ដីលោកស្រី អ៊ីន មិនដឹងថាជើងយ៉ាងម៉េចដែរ"

យ៉ូលី ខឹង តែព្យាយាមទប់ និងញញឹមពព្រាយដាក់។

"ជើងនៅតែដដែល ប៉ុន្តែសម្ដីអាក្រក់ជាងមុន"

ជីយ៉ន ពេបមាត់ដាក់ បន្ទាប់មកក៏ធ្វើជាញញឹម។

"ហើយមិនជ្រាបថាបានផ្សំដំណោកនឹងស្វាមីខ្លះហើយឬនៅ"

ម្ដងនេះមុខរបស់ យ៉ូលី ឡើងក្រមូវ។

"វាមិនមែនជារឿងរបស់អ្នកក្រៅដូចនាង"

"បន្តិចទៀតអាចមិនមែនជាអ្នកក្រៅក៏ថាបាន" សាស្ត្រាចារ្យក្រមុំបុញ



មាត់បួញកនិយាយ ធ្វើឲ្យ ហុងស៊ីល ជិនឆ្អន់ រមាស់ដៃរមាស់ជើងចង់ទះឲ្យបែកមាត់។

"ភ្ញាក់ឡើង ភ្ញាក់ឡើងសាស្ត្រាចារ្យ គីម"

"ស្អីឯង មីកញ្ជះ"

"អៅ! គឺដែលប្រាប់ថាអាចមិនបានត្រឹមតែជាអ្នកក្រៅ យល់សប្តុប្ត បើយល់សប្តពេក ប្រយ័ត្នក្លាយជាយល់សប្តខ្យល់"

"មីកញ្ជះ!"

"សាស្ត្រាចារ្យ គីម មករកបង ម៉ាត ក៏ឆាប់ទៅរកគេទៅ កុំមករករឿងឈ្លោះនឹងខ្ញុំ ព្រោះនាងគ្មានថ្ងៃឈ្នះទេ" យ្យូលី គំរាម។

ជីយ៉ន ពេបមាត់ញញឹម សម្លឹងស្រីខ្ទិននៅចំពោះមុខដោយការប្រមាថ តែក៏ចងចិញ្ចើម ពេលចាំសម្លៀកបំពាក់នៅលើដងខ្លួនរបស់ យ្យូលី បាន។

"ខោអាវនេះ...ខ្ញុំដូចឃើញពាក់នៅហាង ឬស្រីម្នាក់នោះជានាង អិន យ្យូលី"

យ្យូលី និង ហុងស៊ីល ងាកមើលមុខគ្នា បន្ទាប់មក ហុងស៊ីល ក៏រហ័សកម្ចាយការសង្ស័យនេះ។

"នែ! សាស្ត្រាចារ្យ គីម អ្នកនាងរបស់ខ្ញុំអង្គុយលើរទេះរុញក្នុងផ្ទះពេញមួយថ្ងៃម៉េចនឹងអាចចេញទៅណាមកណាបានទៅ"

"មែនហ្នឹង...ខ្ញុំក៏គិតថាអីចឹង មនុស្សខ្វិនជើងដូចនាង ម៉េចនឹងអាចដើរហាងឲ្យរំភើយបែបនោះបានទៅ ប្រហែលគ្រាន់តែជាខោអាវដូចគ្នាប៉ុណ្ណោះ" ជីយ៉ន យល់ស្របនឹងសម្ដីរបស់ ហុងស៊ីល។

"មែន ខ្ញុំអង្គុយតែលើរទេះ ដើរហើរទៅខាងក្រៅផ្ទះម៉េចនឹងបាន" យ្យូលី បញ្ជាក់ នោះហើយដែលធ្វើឲ្យ ជីយ៉ន ឈប់សង្ស័យ ព្រមទាំងចាប់អារម្មណ៍អ្នក



ដែលខ្លួនមករកភ្លាម។

"លោកនាយកនៅឯណា?"

"នាងមានការអីនឹងលោក ម៉ាត មករកទាំងយប់ព្រលប់" ហុងស៊ីល អត់មិនបាននឹងសួរ ខណៈដែល យ្យូលី អង្គុយធ្វើមុខរាបស្មើទាំងដែលនៅក្នុងចិត្តកំពុងក្ដៅ។

"ខ្ញុំមានធុរៈ ឆ្លើយមកថាលោកនាយកនៅឯណា?"

"មិនប្រាប់"

"ប្រាប់គេទៅបង ហុងស៊ីល ឲ្យបង ម៉ាត ជាអ្នកសម្រេចចិត្ត"

ហុងស៊ីល មិនយល់ស្របនឹងបញ្ជារបស់ចៅហ្វាយ ប៉ុន្តែមិនអាចជំទាស់បាន។

"នៅក្នុងផ្ទះ"

"តែប៉ុណ្ណឹង"

ជីយ៉ន ដើរពើងទ្រូងចូលទៅក្នុងភូមិគ្រឹះ ដោយមាន ហុងស៊ីល តាមមើលពីក្រោយដោយការមិនពេញចិត្ត។

"អ្នកនាង ទៅចិត្តល្អដាក់ស្រីចំពុះក្រហមនោះធ្វើអី"

"ខ្ញុំមិនធ្លាប់ចិត្តល្អដាក់មនុស្សមិនល្អទេបង ហុងស៊ីល"

ហុងស៊ីល ងាកខ្ទាប់មកមើលចៅហ្វាយ។

"អ្នកនាង...មានផែនការអីមែនទេ?"

យ្យូលី មិនឆ្លើយ ប៉ុន្តែមុខស្រស់ស្អាតលម្អដោយស្នាមញញឹម។



**"ទៅជាមួយខ្ញុំបន្តិចទៅ ខ្ញុំសម្រេចចិត្តមិនបានពិតមែន" ជីយ៉ន អង្វរករ**ម៉ាទិនេស ឲ្យចេញទៅមើលកន្លែងរៀបចំការតាំងពិព័រណ៍ម្តងទៀត។

"តែខ្ញុំចាំបានថាខ្ញុំសម្រេចចិត្តជ្រើសរើសពណ៌រួចហើយ"

"តិ...ដល់ពេលធ្វើមែនទែន ពណ៌ដែលលោករើសឲ្យវាមិនស៊ីនឹងចំណុចផ្សេងទៀត ទើបខ្ញុំគិតថាគួរតែរើសពណ៌ថ្មី អីចឹងហើយទើបត្រូវពន់មុខមករំខានលោកនាយកម្តងទៀត"

"ខ្ញុំជាសាស្ត្រាចារ្យគឺមសម្រេចចិត្តដោយខ្លួនឯងបាន"អ្នកកំលោះបដិសេធយ៉ាងសុភាព ប៉ុន្តែ ដីយ៉ន មិនព្រមដកថយ យ៉ាងណាក៏យប់នេះត្រូវអូស ម៉ាទិនេស ទៅស៊ីឲ្យបាន។

"ខ្ញុំសុំទោស...ខ្ញុំសម្រេចចិត្តខ្លួនឯងមិនបានទេ បើគ្មានលោកនាយកចាំណែនាំ"

នាងលោទៅមុខបន្តិច ដើម្បីឲ្យដើមទ្រូងជំហួសមាឌប្រាល់ចេញពីកអាវអក្សរ៉ៃ ធ្វើឲ្យ ម៉ាទិនេស ពេលឃើញហើយក៏ងាកមុខចេញ ទើបនាងងើបឈរហើយដើរមកអង្គុយជិត។

"សូមអង្វរលោកនាយក...ជួយខ្ញុំម្តងទៀតទៅ"

អ្នកកំលោះខិតចេញឲ្យឆ្ងាយ ប៉ុន្តែត្រូវនាងស្រវាចាប់ដៃជាប់ ថែមទាំងធ្វើសំឡេងម៉ឺកម៉ូក់ដាក់ទៀតផង។

"សូមអង្វរ សូមអង្វរ ខ្ញុំសន្យាថានឹងតបស្នងលោកនាយកទាំងខ្លួនប្រាណ...និងបេះដូង"

ម៉ាទិនេស ព្យាយាមមិនបង្ហាញអាកប្បកិរិយាពាល ទើបត្រូវខាំមាត់និយាយយ៉ាងសុភាព ព្រមទាំងខិតចេញ។

"អូខេ ខ្ញុំនឹងទៅជួយម្តងទៀត"

គេងើបឈរ ធ្វើឲ្យស្រីស្អាតញញឹមពព្រាយដោយការសប្បាយចិត្ត។

"ជាការពិតណាំ"



"បាទ ព្រោះកម្មវិធីនេះជាកម្មវិធីរបស់មហាវិទ្យាល័យខ្ញុំ អ្វីដែលខ្ញុំជួយបាន ខ្ញុំរីករាយជួយ"

"អរគុណលោកនាយកច្រើន អីចឹងខ្ញុំអង្គុយចាំនៅត្រង់នេះ"

"បាទ"

ម៉ាទិនេស ដើរចេញផុតពីទ្វារបន្ទប់ទទួលភ្ញៀវមិនដល់ប្រាំវិនាទី សំឡេងថ្ងូរថ្ងូរដោយការឈឺចាប់របស់ យ្យូលី ក៏បន្លឺឡើង ធ្វើឲ្យ ដីយ៉ន ស្ទុះទៅមើលហេតុការណ៍ ឃើញ យ្យូលី ធ្លាក់ពីរទេះរុញ។

"លីលី..." ម៉ាទិនេស ស្ទុះទៅលើកភរិយា ទឹកមុខបង្ហាញឲ្យឃើញពីការភិតភ័យ "លីលី កើតអីទេ ឈឺត្រង់ណាឬអត់ ប្រាប់បងមកមើល ឈឺត្រង់ណាលីលី..."

គេលើកដៃស្ទាបមុខ ស្ទាបខ្លួនប្រាណរបស់នាងដោយការព្រួយបារម្ភ។

"ខ្ញុំមិនអីទេ មិនឈឺប៉ុន្មានទេ"

"ម៉េចក៏ថាមិនឈឺ ដួលបែបនេះ"

យ្យូលី ចង់ដឹងណាស់ថាអាការៈព្រួយបារម្ភដែលគេបង្ហាញឲ្យឃើញនៅពេលនេះវាជាការពិតឬអត់។

"ហើយនេះ ហុងស៊ីល ទៅណា ម៉េចក៏បណ្ដោយឲ្យអូននៅតែម្នាក់ឯង"

"ហុងស៊ីល...ទៅរៀបចំទឹកឲ្យខ្ញុំងូត"

"ហើយបណ្ដោយឲ្យប្រពន្ធរបស់បងនៅតែម្នាក់ឯងលើរទេះរុញនេះ" គេមួម៉ៅ មុខឡើងក្រហម "លើកក្រោយបងបណ្ដោយឲ្យអូននៅតែម្នាក់ឯងមិនបានទេ បងមិនចង់ឲ្យអូនឈឺខ្លួនបែបនេះទៀត"

"អឺ...ខ្ញុំមិនអីពិតមែនបង ម៉ាត"

"លើកនេះសំណាងល្អចុះលើកក្រោយ បើដួលទៀត ហើយបោកក្បាល





Scanned with CamScanner

បងមិនក្លាយជាពោះម៉ាយប្រពន្ធស្លាប់ទៅហើយទេ" គេបញ្ឈឺឌឹងធ្វើឲ្យ យូលី មានអារម្មណ៍ដឹងខុស ដែលបង្កើតស្ថានការណ៍បែបនេះ។

"អឺ..."

"ម៉ោះ បងបីទៅបន្ទប់ ហើយតាមពេទ្យមកពិនិត្យអាការៈ" គេលើកបីនាងងើបឈរពេញកម្ពស់។

"លោកនាយក ចុះ...រឿងទៅជាមួយខ្ញុំ?" ជីយ៉ន តវ៉ា ទើបអ្នកកំលោះងាកទៅរកអ្នកនិយាយ ហើយសុំទោសសុំពៃរ៍។

"ខ្ញុំចេញទៅជាមួយសាស្ត្រាចារ្យ គីម មិនបានទេ សុំទោសផង ប្រពន្ធខ្ញុំមានគ្រោះថ្នាក់"

"តែ..."

"ខ្ញុំបារម្ភពីប្រពន្ធខ្ញុំ"

ជីយ៉ន និយាយមិនចេញ និងប្រសព្វភ្នែកជាមួយ យូលី ដោយចៃដន្យនោះហើយ ទើបធ្វើឲ្យដឹងហេតុការណ៍ទាំងអស់ ថាវាត្រូវបានបង្កើតឡើង មិនមែនជាការពិតប៉ុន្តែទោះនាងនិយាយអីទៅក៏គ្មានប្រយោជន៍ថែមទាំងពេលនេះ យូលី មិចភ្នែក ធ្វើឫកអ្នកឈ្នះដាក់ទៀតផង។

"បង ម៉ាត...បងទៅជាមួយសាស្ត្រាចារ្យ គីម ទៅ ខ្ញុំមិនអីពិតមែន"

"គ្មានអ្វីសំខាន់សម្រាប់បង ដូចសុវត្ថិភាពរបស់អូន"

"តែអូនក្រែងថាសាស្ត្រាចារ្យ គីម មិនពេញចិត្ត" នាងក្រមុំញញឹមចម្អកនៅចុងមាត់ ដែល ម៉ាទិនេស មើលមិនឃើញ មានតែ ជីយ៉ន ម្នាក់ប៉ុណ្ណោះដែលមើលឃើញច្បាស់ពេញភ្នែកទាំងពីរ។

"សាស្ត្រាចារ្យ គីម យល់ពីខ្ញុំមែនទេ"

"អឺ...ចាស ខ្ញុំយល់"



"អីចឹងខ្ញុំមិនបានជូនដំណើរទេ សុំនាំភរិយាទៅសម្រាកសិនហើយ ហើយ សូមឲ្យការតាំងពិព័រណ៌ចេញមកបានល្អ"

"ចាំ អរគុណ"

ជីយ៉ន បង្ខំចិត្តទទួល ប្រឹងញញឹមញញែម ទាំងដែលនៅខាងក្នុងក្តៅហាក់ដូចភ្លើង។ នាងសម្លឹងមើលខ្នងរបស់ ម៉ាទិនេស ដែលបីមីខ្ញិននោះឡើងជណ្តើរដោយកំហឹង។

"ផ្ញើទុកសិនចុះមីខ្ញិន"

នាងនិយាយរង៉ូវៗដោយកំហឹង និងសឹងតែស្រែកខ្លាំងៗ ពេល យូលី ដែលលើកដៃឱប.ករបស់ ម៉ាទិនេស ងាកមកគ្រវីដៃដាក់ជាការឡកឡឺយ។

"មីឆ្កួត...យើងនឹងដណ្តើមប្តីឯងឲ្យបាន ចាំមើល!"

និយាយហើយ ជីយ៉ន ក៏ដើរតន្រ្តំជើងឡើងឡាន ចេញពីភូមិគ្រឹះម៉ាឡេសាសសូ ភ្លាម។

ម៉ាទិនេស ដាក់ភរិយាទៅលើគ្រែថ្នមៗ ហើយដាក់បង្អុយក្បែរ សម្លឹងមើលមុខស្រស់ស្រទន់ដោយខ្សែភ្នែកជ្រាលជ្រៅ មើលមិនធ្លុះអារម្មណ៍។

"អូយ...ឈឺបង ម៉ាត"

អ្នកកំលោះសើចញឹមៗ លើកដៃញីសក់ក្បាលរបស់នាងព្រោះគ្នាញ់។

"ឈប់លេងទៅ សាស្ត្រាចារ្យ គីម មិននៅត្រង់នេះទេ"

អ្នកស្តាប់ទៅជាភាំង ហើយសួរគេដោយសំឡេងរដាក់រដុប។

"បង ម៉ាត...និយាយអី ខ្ញុំមិនដឹងរឿងទេ"

នាងគេចខ្សែភ្នែកពីគេ ប៉ុន្តែត្រូវ ម៉ាទិនេស ប្រើម្រាមដៃផ្ញើយចង្កា បង្ខំឲ្យប្រសព្វភ្នែកជាមួយ។



"គឺដឹងរឿងដែលអូនមិនបានធ្លាក់ពីលើទេះហ្នឹងអី"

"បងយល់ច្រឡំហើយ ខ្ញុំ...ធ្លាក់ពិតមែន"

"បើធ្លាក់មែន ច្បាស់ជាមានស្នាមជាំអីខ្លះហើយ តែនេះគ្មាន"

"គឺ..."

"កុំកុហក"

គេនៅតែញញឹម និងមើលមក ទើបនាងមិនដឹងថាបដិសេធធ្វើអីទៀត។

"ចាស ខ្ញុំកុហក"

"តែប៉ុណ្ណឹង" គេអស់សំណើច ធ្វើឲ្យនាងក្តៅមុខព្រោះខ្មាស។

"បើដឹងថាខ្ញុំកុហក ហើយម៉េចក៏មិនចេញទៅជាមួយស្រីម្នាក់នោះ មកនៅជាមួយខ្ញុំធ្វើអី"

"បងមិនចង់ទៅណាទេ បានអូនធ្វើជាលេសល្មម"

"សាស្ត្រាចារ្យ គីម ស្អាត បងមិនចង់នៅជិតទេឬ" នាងបញ្ឈឺ "អ៊ូយ..."

រាងតូចស្តើងត្រូវទាញទៅឱប មុខសង្ហាក៏ឱនមករក ស្ទើរតែប៉ះគ្នាទៅហើយ។

"បង ម៉ាត..." បេះដូងរបស់នាងលោតខុកដាក់។

"ហ៊ឺ...យ៉ាងម៉េច ?"

"លែង លែងខ្ញុំសិន"

អ្នកកំលោះគ្រវីក្បាល ថែមទាំងឱនមកជិត ធ្វើឲ្យចុងច្រមុះជល់គ្នា និងធ្វើឲ្យបេះដូងរបស់នាងលោតញាប់ស្ទើរតែធ្លាយចេញពីទ្រូង។

"មិនលែង ចង់ថើបប្រពន្ធ"

"បង ម៉ាត..."

"មិនបានឬ ?"



"អឺ...មិន...មិនបាន"

គេគ្រវីក្បាលបដិសេធចម្លើយរបស់នាង។

"វាត្រូវតែបាន អូនជាប្រពន្ធបង...មែនទេ..."

"តែ...ខ្ញុំមិនត្រូវការ"

នាងអៀនឡើងចង់ជ្រែកមុខក្តៅរបស់ខ្លួនក្នុងដៃទៅហើយ។ ហេតុអីបានជា ម៉ាទិនេស ចូលចិត្តបង្កើតភាពជ្រួលច្របល់ឲ្យនាងបែបនេះ ដឹងទេថានាងវេទនាអារម្មណ៍។

"តែបងត្រូវការ..."

"តែ..."

គេញញឹម កែវភ្នែកមានពន្លឺផ្លេកៗ។

"គ្មានតែ វាជាការដាក់ទោសក្មេងដែលហ៊ានកុហក"

"អ៊ុប...អឺ..."

ការថើបដោយការទាមទារចាប់ផ្តើមឡើង អមដោយអារម្មណ៍រំភើបខ្លាំងក្លាដែលហោះឡើងទៅលើហាក់ដូចកាំជ្រួចនៅយប់ឆ្លងឆ្នាំ។នាងខ្ទាំដើមដៃរបស់គេ និងប្រាប់ខ្លួនឯងឲ្យបិទមាត់ កុំសហការ ប៉ុន្តែបែរជាបង្អើបមាត់ តបទទួលការថើបជញ្ជក់របស់ស្វាមីដោយការពេញចិត្ត លើសពាក្យថារីករាយទៅទៀត។

"អាំ..."

នាងដកដង្ហើមដង្ហក់ ពេល ម៉ាទិនេស ជ្រែកអណ្តាតក្តៅចូលមកក្នុងប្រអប់មាត់ រឹតរួតអណ្តាតរបស់នាងដោយក្តីស្រេកឃ្លាន។ រាងកាយរបស់នាងរីកដូចផ្កាពេលព្រឹក ក្នុងខួរក្បាលទៅជាពណ៌ស ក្រៅពីការប៉ះពាល់ដ៏ក្តៅគគុករបស់គេ។



"អុំ!...សុំទោស"

ហុងស៊ីល ដែលដើរចេញមក បន្ទាប់ពីលាយទឹកក្តៅឲ្យចៅហ្វាយរួចរាល់ក៏ឧទានដោយការភ្ញាក់ផ្អើល និងលើកដៃបិទមុខភ្លាម ពេលឃើញថាចៅហ្វាយទាំងពីរកំពុងតែថើបគ្នា។

ម៉ាទិនេស បានឮសំឡេងឧទានរបស់ ហុងស៊ីល ក៏ដកបបូរមាត់ចេញហើយព្រលែងដៃពីរាងកាយតូចច្រឡឹង និងងើបឈរ។

"នាងនៅក្នុងនេះយូរហើយឬ?"

"អឺ...យូរ...ហើយ លាយទឹកក្តៅឲ្យអ្នកនាង" ហុងស៊ីល ឈ្ងោកមុខឈ្ងោកមាត់គេចពីខ្សែភ្នែករបស់ចៅហ្វាយប្រុស។

"អីចឹងងូតទឹកឲ្យ លីលី ផង ខ្ញុំចេញទៅដើរលេងខាងក្រៅមួយភ្លែត"

"ចាសលោក"

ទ្វារបន្ទប់ត្រូវបិទ ស្របពេលដែលខ្នងរបស់ ម៉ាទិនេស ត្រូវបាត់ពីភ្នែក។

យ្យូលី គេចខ្សែភ្នែកពី ហុងស៊ីល ដោយការអឹមអៀន ហើយបែរខ្នងដាក់ដោយខ្លួនប្រាណនៅតែញ័រ បន្ទាប់ពីត្រូវការទាមទាររបស់ ម៉ាទិនេស ចាត់ការអស់ជាច្រើនដង្ហើម។

"អ្នកនាង"

"អឺ...បង ហុងស៊ីល...ខ្ញុំចង់ងូតទឹកហើយ"

ហុងស៊ីល ដើរមកឈរទល់មុខចៅហ្វាយ ព្រមទាំងមើលបបូរមាត់ក្រពុំដែលហើមជាំដោយទឹកមុខញញឹម។

"អ្នកនាងឈឺមាត់ទេ?"

មុខរបស់ យ្យូលី កាន់តែក្រហម ប្រញាប់លើកដៃបិទមាត់ខ្លួនឯងភ្លាម។

"បង ហុងស៊ីល កុំបង្អាប់ខ្ញុំ"



ហុងស៊ីល សើចតិចៗ។

"ខ្ញុំសប្បាយចិត្តដែលឃើញអ្នកនាងមានក្តីសុខ ការពិតលោក ម៉ាត ក៏គួរឲ្យស្រឡាញ់ នេះបើមិនធ្លាប់ដឹងថាត្រូវបង្ខំឲ្យរៀបការ ខ្ញុំប្រហែលគិតថាគាត់ស្រឡាញ់អ្នកនាងពិតប្រាកដ"

ទឹកមុខរបស់ យ្យូលី ទៅជាស្លុត ពេលនឹកដល់ការពិតនេះ។

"គ្មានប្រុសណាស្រឡាញ់មនុស្សពិការដូចខ្ញុំទេ"

"តែអ្នកនាងមិនបានពិការផង"

នាងក្រមុំអង្គុយសោកសៅ បន្ទាប់មកក៏ពង្រឹងស្មារតី ចុះពីគ្រែ ដើរសំដៅបន្ទប់ទឹក ដោយមាន ហុងស៊ីល ដើរតាម តែត្រូវនាងឃាត់។

"ចាំខ្ញុំនៅខាងក្រៅហើយ ខ្ញុំងូតខ្លួនឯង"

"ចាសអ្នកនាង"

យ្យូលី ដើរចូលបន្ទប់ទឹក សម្លឹងមើលមនុស្សស្រីដែលមានទឹកសោកសៅម្នាក់ក្នុងកញ្ចក់ធំ បន្ទាប់មកក៏លើកដៃប៉ះបបូរមាត់ហើមរបស់ខ្លួនថ្នមៗ។

"ហេតុអីពេលថើប...មិនឃើញឈឺ" អ្នកនិយាយមានការងឿងឆ្ងល់មែនទែន។



# ៦

ព្រឹកថ្ងៃបន្ទាប់ យ្យូលី ត្រូវនាំមកជួបអ្នកជំនាញកាយចលនា ដែល ម៉ាទិនេស រៀបចំឲ្យ ហើយនាងក៏ត្រូវបើកភ្នែកធំៗដោយការភ្ញាក់ផ្អើលជាខ្លាំង ពេលឃើញមុខរបស់អ្នកជំនាញកាយចលនា។

បុរសម្នាក់នេះ...នាងជួបនៅមុខបន្ទប់ទឹកក្នុងហាងនោះអី ពីម្សិលមិញនេះឯង ហើយមើលទៅគេក៏ភ្ញាក់ផ្អើលពេលឃើញនាង និងចង់និយាយ តែមិននិយាយ។

"លីលី...នេះ លោក គីម តេយ៉ុង អ្នកជំនាញកាយចលនា ជំនាញជាងគេនៅមន្ទីរពេទ្យរបស់ ម៉ៃ"

យ្យូលី ញញឹមមិនចេញ នៅតែបុកពោះភឹបៗ។

"អឺ...សួ សួស្តី អ្នកជំនាញ គីម"

អ្នកដែលត្រូវរាក់ទាក់ញញឹមដាក់យ៉ាងសុភាព។

"សួស្តី...លោកស្រី អ៊ិន"

ពន្លឺភ្នែករបស់បុរសនៅចំពោះមុខបង្ហាញឲ្យឃើញពីការសង្ស័យជាខ្លាំង តែសំណាងល្អដែលគេមិននិយាយ មិនសួរនាំអីនៅចំពោះមុខ ម៉ាទិនេស។

"អឺ...ចាំ"

"មិនជ្រាបថាលោកស្រី...ដើរមិនបានយូរហើយឬនៅ?"

"អឺ...យូរហើយ តាំងពីមានគ្រោះថ្នាក់"

តេយ៉ុង ងក់ក្បាលតិចៗជាការទទួលដឹង។



"តាមដែលបានមើលប្រវត្តិព្យាបាលលោកស្រីធ្លាប់ធ្វើកាយចលនាច្រើនឆ្នាំបន្ទាប់ពីមានគ្រោះថ្នាក់"

"ចាំ"

"បើមែន ខ្ញុំគិតថាលោកស្រីគួរតែដើរបានតាំងពីយូរហើយ ព្រោះអាការៈរបស់លោកស្រី គ្រាន់តែបាក់ឆ្អឹងខ្នងទៅសង្កត់ខួរឆ្អឹងតែបន្តិចប៉ុណ្ណោះ ខួរឆ្អឹងរងការប៉ះទង្គិចមិនធ្ងន់ធ្ងរ ធ្វើចលនាមួយឆ្នាំពីរ គួរតែអាចដើរបានធម្មតាហើយ"

"គឺ...ខ្ញុំមិនសូវបានធ្វើ"

យ្យូលី ខ្លាច ម៉ាទិនេស ដឹងការពិតមែនទែន ទើបខ្វល់ខ្វាយនិងនឹកដល់ហុងស៊ីល ដែលពេលនេះកំដរឪពុកនៅមន្ទីរពេទ្យ។ បើ ហុងស៊ីល នៅនឹងអាចជួយរកដំណោះស្រាយឲ្យនាងបាន ថាគួរធ្វើយ៉ាងណា។

តេយ៉ុង ញញឹម មើលអ្នកអង្គុយលើរទេះរុញដោយដឹងគំនិតរបស់នាង តែគេមិនបកអាក្រាតនាង។

"អីចឹងចាប់ផ្តើមជាថ្មី ធានាថាលោកស្រីត្រូវតែដើរបានមិនខាន"

"ខ្ញុំជាមនុស្សខ្ជិល បើមិនចង់ធ្វើ គឺមិនធ្វើ"

"លីលី" ម៉ាទិនេស ហាមប្រាម។

"ខ្ញុំនិយាយការពិត បង ម៉ាត នាំមនុស្សរបស់បងទៅវិញទៅ ខ្ញុំមិនចង់ធ្វើអីទាំងអស់"

នាងចាប់កង់រទេះបង្វិលចេញ តែត្រូវ ម៉ាទិនេស ពាំងមុខ។

"កុំរឹង លីលី បងចង់ឲ្យអូនជា"

"បងខ្មាសគេទៅវិញទេ ដែលមានប្រពន្ធពិការ"

តេយ៉ុង មានអារម្មណ៍ប្លែកៗ ដែលឃើញទំនាក់ទំនងស្វាមីភរិយារបស់មនុស្សស្រីដែលខ្លួនលង់ស្នេហ៍តាំងពីឃើញដំបូង។ គេព្យាយមកាត់ចិត្ត តែវា



Scanned with CamScanner

លំបាកធ្វើមែនទែន ព្រោះ យ៉ូលី ស្អាតពេកហើយ។

"បើបងខ្មាសគេ បងមុខជាមិនរៀបការជាមួយអូនទេ"

នាងពើងទ្រូងដាក់គេ ដោយទឹកភ្នែករលីងរលោង។

"បងរៀបការជាមួយខ្ញុំ ព្រោះបងគ្មានជម្រើសទៅវិញទេ"

"យ៉ូលី"

ពេលណាក៏ដោយដែល ម៉ាទិនេស មានទោសៈ គេនឹងហៅឈ្មោះពេញរបស់នាង។

"ខ្ញុំទៅហើយ"

នាងបង្វិលរទេះចេញទៅ ធ្វើឲ្យ ម៉ាទិនេស តាមមើល និងគ្រវីក្បាលដោយការហត់ចិត្ត។

"ចាំខ្ញុំទៅបញ្ចុះបញ្ចូល" តេយ៉ុង យកអាសា។

"មិនសម្រេចទេ លីលី ទំនើងណាស់ ព្រោះត្រូវទម្រើសតាំងពីនាងមានគ្រោះថ្នាក់ ដើរមិនបាន" ម៉ាទិនេស អធិប្បាយប្រាប់អ្នកជំនាញ។

"តែខ្ញុំមានវិធី ធានាថាលោកស្រី អ៊ីន ត្រូវតែយល់ព្រមធ្វើកាយចលនា"

"វិធីអី ?" ម៉ាទិនេស ចងចិញ្ចើម តេយ៉ុង ក៏សើចញឹមៗ។

"ខ្ញុំនឹងបញ្ចុះបញ្ចូលថាការដើរបាន វាល្អយ៉ាងណា ធានាថាខ្ញុំចាត់ការបាន"

ម៉ាទិនេស ដកដង្ហើមធំ ធូរទ្រូង។

"អ៊ីចឹងពឹងពាក់លោកហើយ សង្ឃឹមថាបានសម្រេច"

"បាទ អ៊ីចឹងខ្ញុំសុំអនុញ្ញាតដើរទៅតាមលោកស្រី អ៊ីន"

"បាទ"

ម៉ាទិនេស តាមមើលអ្នកជំនាញដើរចេញទៅទាល់តែបាត់ពីភ្នែក ដោយ



មានអារម្មណ៍ប្លែកៗ តែព្យាយាមធ្វើចិត្តទូលាយតាមដែលអាចធ្វើបាន ហើយពេលនោះ សំឡេងទូរសព្ទដៃបន្លឺឡើង ទើបគេចុចទទួល។

"ម៉េច ម៉ែ ?"

( ខ្ញុំគ្រាន់តែតេរទៅសួរដំណឹង )

"រឿងអ្នកជំនាញ តឹម ឬ ?"

ម៉ាទិនេស ដកដង្ហើមធំ ហើយតបប្អូនប្រុស។

"គឺដូចយើងគិតអ៊ីចឹង មិនព្រមទេ"

( អាំ! ហើយបងធ្វើយ៉ាងម៉េចទៅអ៊ីចឹង ? )

"អ្នកជំនាញ តឹម ទៅនិយាយឲ្យហើយ តែបើមិនព្រមចេញម៉ោទៀត បងនឹងត្រូវផ្តាច់ការដាក់ហើយ"

មេសាន់ អស់សំណើច។

( បងហ៊ានធ្វើអីខ្លាំងៗដាក់ លីលី ឬ ខ្ញុំឃើញទំយើរហូត )

ថ្ពាល់របស់បងប្រុសឡើងក្រហម ដោយគ្មានអ្នកណាឃើញ។

"ទំយើស្អី បងមិនបានទំយើនាងទេ ដែលឃើញសុភាពដាក់ព្រោះ លីលី មិនរឹងមាំ ទើបបងមិនចង់ធ្វើឲ្យឈឺសចិត្ត"

( ខ្ញុំថាបងកំពុងចូលជំរំខ្លាចប្រពន្ធតាម មីក និង មេត ម្នាក់ទៀតហើយ )

"អាឆ្កួត គ្មានផ្លូវទេ មនុស្សដូចបងខ្លាចប្រពន្ធធ្វើអី គ្រាន់តែក្រែងចិត្តនៅពេលខ្លះប៉ុណ្ណោះ"

មេសាន់ សើចក្អាកក្អាយ ឡើងរឹងពោះទៅហើយ។

( អូខេ មិនខ្លាចប្រពន្ធក៏មិនខ្លាច តែបើបានលទ្ធផលយ៉ាងណា បងជួយតេរម៉ោប្រាប់ខ្ញុំផង កុំឲ្យខ្ញុំជ្រួលច្រាល់ )

"ឯងជ្រួលច្រាល់អី លីលី ជាប្រពន្ធបង មិនមែនប្រពន្ធឯងទេ"



Scanned with CamScanner

( ប្រចណ្ឌសូម្បីតែប្អូនខ្លួនឯង )

"បងមិនបានប្រចណ្ឌ គ្រាន់តែនិយាយឲ្យឯងឃើញការពិតលេង"

មេសាន់ គ្រវីក្បាលដោយការអាចិត្ត។

( និយាយជាមួយសាស្ត្រាចារ្យនេះឈឺក្បាលផស់គេ អីចឹងខ្ញុំទៅពិនិត្យអ្នកជំងឺបន្តល្អជាង )

"ហៅ! ឈប់សិន បងមានការចង់សួរបន្តិច"

( បាទ ? )

"បងដាក់សំណើអ្នកជំនាញ សុំស្រីមិនអីចឹង ហើយម៉េចក៏ឯងបញ្ជូនបមនុស្សប្រុសម៉ោ ថែមទាំងមានមុខមាត់ល្អទៀត"

មេសាន់ ផ្ទុះសំណើច។

( មិនប្រចណ្ឌមែនឬ បងធំ )

"អត់មានទេ មិនបានប្រចណ្ឌ គ្រាន់តែចង់ដឹងលេងៗ" បងប្រុសនៅតែនិយាយដោយសំឡេងរាបស្មើដដែល។

( អ្នកជំនាញ គីម មានថ្វីដៃល្អបំផុតនៅទីនេះ ទើបខ្ញុំគិតថាគួរតែអាចធ្វើឲ្យ លីលី ដើរបានឆាប់ៗនេះ )

ម៉ាទិនេស ដកដង្ហើមធំ ហើយបញ្ឈឺឌីដងប្អូនប្រុស។

"អរគុណសម្រាប់បំណងល្អរបស់ឯង ម៉ៃ"

( ដោយក្ដីរីករាយបង ម៉ាត អីចឹងខ្ញុំទៅពិនិត្យអ្នកជំងឺសិនហើយ មានអ្នកជំងឺចាំច្រើន )

"អ្ហឹម ទៅចុះ"

ម៉ាទិនេស ដាក់ទូរសព្ទចុះ ហើយក៏ដើរចេញពីបន្ទប់ទទួលភ្ញៀវ សំដៅរានហាលជាន់ក្រោម ដែលលយចេញទៅវាលស្មៅ អាចមើលឃើញ យ្យូលី



ដែលកំពុងនិយាយជាមួយអ្នកជំនាញល្មម ទើបឈរស្ងៀមនៅត្រង់នោះ ដោយទឹកមុខរាបស្មើ លាក់អារម្មណ៍នៅខាងក្នុង។

"លោកត្រូវការលុយប៉ុន្មាន ខ្ញុំរីករាយឲ្យដោយមិនតថ្លៃ" យ្យូលី ងើយមុខមើល តេយ៉ុង និងនិយាយដោយទឹកមុខប្រាកដប្រជា។

តេយ៉ុង សើចញឹមៗ មើលស្រីមុខស្រស់ ដោយខ្សែភ្នែកអ្នកដែលកាន់សន្លឹកបៀធំជាង។

"ចង់ឲ្យលុយខ្ញុំរឿងអី ?"

"គឺ...រឿងដែលឲ្យលោកបិទមាត់ និងចេញពីទីនេះ កុំម៉ោទៀត"

អ្នកជំនាញសង្ហានៅតែញញឹម គ្រវីក្បាលតិចៗ ដាក់បង្អុយលើកែងជើងនៅចំពោះមុខនាង។

យ្យូលី ភ្ញាក់ ព្រោះនៅជិតពេក ទើបបង្វិលកង់រទេះថយក្រោយភ្លាម។

"កុំចូលមកជិតខ្ញុំពេក!"

តេយ៉ុង ថយចេញ តែភ្នែកសម្លឹងមុខនាងដោយការពេញចិត្តដដែល។

"ខ្ញុំមិនយល់ ហេតុអីលោកស្រីចាំបាច់ធ្វើពុតជាពិការ ឬថាត្រូវការសាកចិត្តស្វាមីសង្ហារបស់លោកស្រី"

មុខរបស់ យ្យូលី ឡើងក្រមូវ មើលគេដោយកំហឹង ដែលហ៊ាននិយាយរឿងផ្ទាល់ខ្លួនរបស់នាង។

"កុំចេះដឹងរឿងរបស់ខ្ញុំ"

"ខ្ញុំក៏មិនចង់ចេះដែរ បើខ្ញុំមិនឃើញការពិតផ្ទាល់ភ្នែកថាលោកស្រី ដើរបាន..."

"នេះលោក...និយាយធ្វើអី តិចបង ម៉ាត ឮ" នាងស្ដីឲ្យគេដោយភ័យបុក



ពោះតិចៗ។

"បើមិនចង់ឲ្យខ្ញុំនិយាយ អ៊ីចឹងព្រមឲ្យខ្ញុំធ្វើកាយចលនាទៅ គ្រប់យ៉ាងនៅតែជាអាថ៌កំបាំងដដែល"

"លោកឃើញហើយតើថាខ្ញុំដើរបាន អ៊ីចឹងហើយ ខ្ញុំមិនចាំបាច់អីត្រូវធ្វើកាយចលនា"

តេយ៉ុង ញញឹមម្ដងទៀត។

"តែស្វាមីរបស់លោកស្រីមិនទាន់ដឹងហ្នឹងណា៎ ថាភរិយារបស់ខ្លួនដើរបានហើយ"

"នេះលោក...ចង់គំរាមខ្ញុំ ?"

"ខ្ញុំមិនបានគំរាម គ្រាន់តែ...ចង់ឲ្យលោកស្រីលេងតាមហ្គេមប៉ុណ្ណោះ"

"តែខ្ញុំមិនត្រូវការ វាគ្មានប្រយោជន៍អីសម្រាប់ខ្ញុំទេ"

"មានប្រយោជន៍ ព្រោះវានឹងធ្វើឲ្យលោក ម៉ាឡេសាសសូ នៅតែជឿថាលោកស្រីដើរមិនបាន ដូចដែលលោកស្រីចង់ឲ្យយល់"

យ្យូលី ក្ដាប់ដៃណែន មើលគេដោយកំហឹង និងចង់សម្លាប់មនុស្សប្រុសដែលគិតតែញញឹមបេះបួយនៅចំពោះមុខមែនទែន។

"លោក...មនុស្សចង្រៃ!"

"អរគុណដែលសរសើរ"

"ខ្ញុំកំពុងជេរលោក!"

តេយ៉ុង សើច និងងើបឈរ។

"សរុបទៅ ខ្ញុំនឹងទៅប្រាប់លោក ម៉ាឡេសាសសូ ថាលោកស្រីយល់ព្រមឲ្យខ្ញុំធ្វើការហើយ"

នាងខាំធ្មេញសម្លឹងមុខគេដោយកំហឹង តែមិនអាចចាត់ការគេបាន។



*ហេតុអី ហេតុអីមនុស្សមានរាប់រយពាន់លាន ម៉េចក៏មកចំប្រុសម្នាក់នេះ មនុស្សប្រុសដែលឃើញនាងដើរបាន!*

"អ៊ីចឹងសម្រេចតាមនេះ ខ្ញុំនឹងមកជួបលោកស្រីនៅថ្ងៃស្អែក ហើយយើងនឹងចាប់ផ្ដើមធ្វើកាយចលនាខ្លែងក្លាយ"

តេយ៉ុង សង្កត់ធ្ងន់ទៅលើពាក្យថា ក្លែងក្លាយ ជាងពាក្យផ្សេង ហើយវាក៏ធ្វើឲ្យនាងទ័លច្រក។

"សង្ឃឹមថាលោករក្សាសន្យា ហាមប្រាប់រឿងរបស់ខ្ញុំដើរបាន ដល់បង ម៉ាត ជាដាច់ខាត ហាមឲ្យគេសង្ស័យដែរ"

"បើដរាបណាដែលលោកស្រីជាអ្នកជំងឺល្អ ខ្ញុំនឹងបិទមាត់ឲ្យជិត"

"ជាតិមុនលោកជាចោរមែនទេ បានជាគិតតែគំរាម"

តេយ៉ុង អស់សំណើច។

"ខ្ញុំមិនបានគំរាម តែខ្ញុំជាមនុស្សម៉ាត់ណាម៉ាត់ហ្នឹង"

និយាយចប់ គេក៏បែរខ្នង ដើរចូលភូមិគ្រឹះ ដោយមាន យ្យូលី តាមមើលដោយកំហឹង។

"ម៉េចក៏ស៊ិយអីយ៉ាងនេះ អ៊ីន យ្យូលី"

នាងក្រមុំលើកដៃអង្អែលមុខដោយអារម្មណ៍តានតឹង។

"ព្រះអើយ! ពេលនេះធ្វើម៉េចទៅ ទើបអាចចៀសផុតពីការគំរាមរបស់មនុស្សចង្រៃនោះបាន"

ខណៈដែល យ្យូលី កំពុងតានតឹងឡើងចង់ផ្ទុះសរសៃឈាមទៅហើយ តេយ៉ុង ក៏ដើរមកដល់ ម៉ាទិនេស ល្មម។



"គ្រប់យ៉ាងអូខេហើយលោក" គេរាយការណ៍ មុនពេល ម៉ាទិនេស សួរ។

"មិនគួរឲ្យជឿថា លីលី យល់ព្រមបែបនេះ"

"នាងចង់ដើរបាន"

ម៉ាទិនេស មើលអ្នកដែលមានកម្ពស់ទាបជាងខ្លួនដោយទឹកមុខញញឹមជាការអរគុណ។

"អរគុណដែលអាចជួយបញ្ចុះបញ្ចូលភរិយារបស់ខ្ញុំបានសម្រេច បើនាងដើរបានពេលណា ខ្ញុំនឹងឲ្យ ម៉ៃ ឲ្យប្រណីសលោកជាពិសេស"

"ខ្ញុំធ្វើតាមតួនាទី ហើយក៏រីករាយជាខ្លាំងបើឃើញអ្នកជំងឺរបស់ខ្លួនអាចដើរបានធម្មតា"

"ហើយលោកចាប់ផ្ដើមការងារបានពេលណាដែរ ?"

"ស្អែកនេះ"

ម៉ាទិនេស ងក់ក្បាលតិចៗ ខណៈនោះក៏នាំ តេយ៉ុង ដើរសំដៅទីធ្លាមុខភូមិគ្រឹះ។

"ស្អែកជួបគ្នា"

"បាទ"

តេយ៉ុង ញញឹមដាក់ចៅហ្វាយ ហើយឡើងឡាន បើកចេញទៅ។

ម៉ាទិនេស ដកដង្ហើមធំ ខណៈនោះក៏ងាកទៅមើល យ៉ូលី ដែលអង្គុយលើរទេះរុញនៅទីធ្លាមុខផ្ទះ ដោយការសង្ស័យ។

"ម៉េចក៏ព្រមស្រួលៗបែបនេះ"

ជីយ៉ន មើលមុខប្អូនប្រុសម្ដាយទីទៃដោយការងឿងឆ្ងល់ ពេលឃើញថាមករកនាងដល់ផ្ទះ។

"ខ្យល់អីបក់ឯងម៉ោ ?"

"ខ្យល់នឹកបងស្រីហ្នឹងអី"



ជីយ៉ន ធ្វើភ្នែកឡៀមឡាមមើលលើដោយការជិនឆ្អន់ប្អូនប្រុស។

"ទើបជួបគ្នាពីម្សិលមិញអីចឹង ម៉ោនឹកម៉ោនុងស្អី មានស្អីក៏និយាយម៉ោអាជើងល្អ"

តេយ៉ុង ដើរតាមបងស្រីចូលទៅក្នុងផ្ទះ ទៅដាក់បង្គុយលើសាឡុង។

"គ្មានស្អីពិតមែន គ្រាន់តែខ្ញុំឆ្លងកាត់ ទើបឆៀងចូលម៉ោ"

"ឆ្លងកាត់ ? ម៉េចក៏ឆ្លង មន្ទីរពេទ្យនិងផ្ទះបងម្នាក់មួយផ្លូវមិនអីចឹង"

ជីយ៉ន ដើរចេញពីផ្ទះបាយ ហុចកែវទឹកត្រជាក់ឲ្យប្អូនប្រុស។

"ខ្ញុំប្រហែលមិនទៅធ្វើការនៅមន្ទីរពេទ្យច្រើនខែ"

"ឯងត្រូវបណ្ដេញចេញឬ ?"

"មិនមែនទេ តែខ្ញុំបានទទួលបញ្ជាឲ្យមកជួយមើលថែអ្នកជំងឺម្នាក់ ដែលផ្ទះរបស់នាងនៅផ្លូវស្របនឹងផ្ទះរបស់បងល្មម"

"អ្នកណា បងស្គាល់ឬអត់ ?" ជីយ៉ន ចងចិញ្ចើម។

"បងប្រហែលមិនស្គាល់ទេ"

"អ៊ឹម មែន តែថាម្នាក់ហ្នឹងកើតអី ម៉េចក៏ត្រូវធ្វើកាយចលនា ?"

តេយ៉ុង អ៊ែនខ្នងនឹងបង្អែកសាឡុង ព្រមទាំងសើចញឹមៗ ពេលនឹកដល់មុខស្រស់ស្អាតរបស់ យ៉ូលី។

"នាងមានគ្រោះថ្នាក់កាលនៅក្មេង ទើបត្រូវអង្គុយលើរទេះរុញរហូត"

ពាក្យថា រទេះរុញ ធ្វើឲ្យសាស្ត្រាចារ្យក្រមុំបើកត្រចៀកធំៗ។

"អង្គុយលើរទេះរុញឬ ?"

"បាទ តែការពិតដើរ..."

តេយ៉ុង កំពុងតែនិយាយការពិតប្រាប់បងស្រី តែសំឡេងទូរសព្ទរបស់ជីយ៉ន បន្លឺឡើង ទើបគេផ្អាកនិយាយ។



Scanned with CamScanner

*រ៉ះទៅហើយ!*

គេព្រួសខ្យល់ដង្ហើមចេញមកតាមមាត់ ធូរទ្រូងខ្សាកតែម្ដង ខណៈនោះក៏មើលបងស្រីនិយាយទូរសព្ទទាល់តែចប់។

"និយាយបន្តទៅ"

"និយាយឬ ត្រង់ណា?" គេធ្វើជាមិនដឹងអី។

"ត្រង់កន្លែងដែលឯងនិយាយមិនទាន់អស់ហ្នឹងអី ការពិតស្អី?"

"អ៊ំ! គ្មានអីទេ បងស្រី"

ជីយ៉ន មើលមុខប្អូនប្រុសដោយការសង្ស័យនិងមិនអស់ចិត្ត។

"បងថាឯងច្បាស់ជាបិទបាំងស្អីបងមិនខាន"

"អត់មានទេ" តេយ៉ុង គ្រវីក្បាលខ្លាំងៗ ដើម្បីបញ្ជាក់ចម្លើយរបស់ខ្លួន។

ពេលឃើញថាដេញដោលទៅក៏គ្មានប្រយោជន៍ ទើប ជីយ៉ន សួរពីអ្វីដែលខ្លួនឯងសង្ស័យ។

"ចុះអ៊ំស្រីម្នាក់នោះ មើលទៅទំនងអាចដើរបានឬអត់?"

តេយ៉ុង អស់សំណើច ពេលឮបងស្រីហៅ យូលី ថា អ៊ំស្រី។

"នាងក្មេងជាងបងទៅទៀត"

"អេាំ! អីចឹងឬ បងស្មានថាចាស់ជាងតើ"

"លោកស្រី អ៊ីន នៅក្មេងទេ"

ឈ្មោះដែលបានឮពីមាត់ប្អូនប្រុស ធ្វើឲ្យ ជីយ៉ន បើកភ្នែកធំៗតែម្ដង។

"ថាម៉េច? នេះឯង...ទៅធ្វើកាយចលនាឲ្យ...មីខ្ញិននោះឬ?"

"បងនិយាយពីអ្នកណា?"

ជីយ៉ន ស្ទុះងើបឈរ មុខឡើងក្រមូវ។

"គឺមីលោកស្រី អ៊ីន មីខ្ញិនអាសិរពិសនោះ"



"ម៉េចក៏បងហៅនាងបែបនេះ" តេយ៉ុង ឆ្ងល់ជាខ្លាំងនឹងប្រតិកម្មរបស់បងស្រី។

"ព្រោះវាជាមារជ្រែកបេះដូងរបស់បង"

"ថាម៉េច?"

"បងប៉ងលោកនាយក គី ម៉ាទិនេស ម៉ាឡេសាសសូ ច្រើនឆ្នាំហើយ តែវាបែរជាម៉ោឆក់យកធ្វើប្ដី បងស្អប់វា"

ជីយ៉ន ខាំធ្មេញនិយាយ ហើយងាកមកសម្លឹងមុខប្អូនប្រុស។

"ហាមទៅធ្វើឲ្យវាដាច់ខាត"

"តែនោះជាការងាររបស់ខ្ញុំ"

"ធ្វើឲ្យអ្នកផ្សេងទៅ បងមិនត្រូវការឲ្យវាដើរបាន បងចង់ឃើញវាខ្ញិនដើរមិនបានមួយជីវិត"

តេយ៉ុង ព្រួសខ្យល់ដង្ហើមចេញមកតាមមាត់ ដោយមិនស្រួលចិត្ត។

"បងស្រី ខ្ញុំគ្រាន់តែធ្វើការតាមតួនាទីដែលត្រូវបញ្ជា បងជួយបែងចែកផង"

"មិនបាន! ឯងហាមទៅរវីរវល់នឹងវា ហាមទៅជួយវាដាច់ខាត"

"តែខ្ញុំ..."

"ភ្លេចហើយម៉្លេស ថាបងមានគុណចំពោះឯងប៉ុនណា បើគ្មានបង ឯងបានទៅរៀនដល់បរទេសទេ" ជីយ៉ន ទាមទារគុណដោយទឹកមុខឆ្មាសឆ្មើម។

"ខ្ញុំរំភើបនឹងគុណបុណ្យរបស់បងស្រីជានិច្ច តែខ្ញុំមិនអាចបដិសេធបញ្ជារបស់ចៅហ្វាយបាន មិនអីចឹងខ្ញុំនឹងអត់ការងារធ្វើ"

"ទៅរកនៅមន្ទីរពេទ្យផ្សេងធ្វើក៏បាន មិនឃើញពិបាក ឯងមានប្ញីដែលល្បីសិងស្លាប់ គីម តេយ៉ុង"



"បាទ ខ្ញុំអាចរកការងារនៅមន្ទីរពេទ្យផ្សេងបាន តែមានកន្លែងណាល្អដូចមន្ទីរពេទ្យត្រកូល ម៉ាឡេសាសសូ ទៅ"

ការពិតចេញពីមាត់របស់ប្អូនប្រុស ធ្វើឲ្យ ជីយ៉ន ភាំងមួយខណៈ ហើយក្នុងខួរក្បាលក៏ព្យាយាមរិះរកផ្លូវចេញដែលល្អបំផុត មិនយូរប៉ុន្មានក៏គិតឃើញ។

"អីចឹងធ្វើបែបនេះ"

ស្នាមញញឹមមានល្បិចកលដែលលម្អលើមុខរបស់បងស្រី ធ្វើឲ្យ តេយ៉ុង មានអារម្មណ៍មិនសប្បាយចិត្ត។

"នេះបងស្រីមិនមែនចង់ធ្វើស្អីមិនល្អទេ មែនទេ ?"

ជីយ៉ន គ្រវីក្បាលតិចៗ ព្រមទាំងញញឹមពេញចិត្តជាការបន្លប់ ដោយក្នុងខួរក្បាលមានផែនការ។

"រឿងល្អទៅវិញទេ"

"រឿងអី ?"

នាងដើរមកអង្គុយលើសាឡុង ដែលងើបចេញអម្បាញ់មិញ និងសម្លឹងមុខប្អូនប្រុសម្តាយទីទៃមិនដាក់ភ្នែក។

"ឯងថាមីខ្ញិននោះស្អាតទេ ?"

តេយ៉ុង គេចខ្សែភ្នែកពីបងស្រី ព្រោះខ្លួនលួចគិតមិនស្មោះត្រង់ចំពោះយ្យូលី។

"គេចភ្នែកធ្វើអី មានន័យថាឯងលួចគិតអីចំពោះមីខ្ញិននោះមែនទេ ?"

"អត់មានទេ"

ជីយ៉ន សើចក្អាកក្អាយ ហើយលើកដៃគ្រវី។

"ឯងមិនបាច់បិទបាំងបងទេ ត្រង់នេះមានតែបងស្រីរបស់ឯងម្នាក់ គ្មានអ្នកផ្សេងទេ"



"ខ្ញុំ...មិនបានគិតអីចំពោះលោកស្រី អ៊ីន ទេ"

"តាំងពីតូចដល់ធំ ឯងមិនចេះកុហក គឺម តេយ៉ុង"

តេយ៉ុង និយាយមិនចេញ បានត្រឹមតែគេចភ្នែកពីបងស្រី ការអៀសចិត្តកំពុងផ្ទុះក្នុងទ្រូង។

យ្យូលី មានស្វាមីហើយ គេមិនគួរគិតបែបនេះចំពោះនាង។

"បងត្រូវការឲ្យឯងជួយធ្វើឲ្យពីរនាក់នោះលែងលះគ្នា ព្រោះបងត្រូវការលោក នាយក"

"ខ្ញុំធ្វើមិនបានទេ"

"ថី ? ខ្លាចស្អី ?" ជីយ៉ន សម្លឹងមុខប្អូនប្រុសនិងសួរជាការស្ទាបស្ទង់។

"ខ្ញុំមិនបានខ្លាចស្អីទេ តែខ្ញុំមិនចង់ធ្វើឲ្យប្តីប្រពន្ធគេលែងលះគ្នា បងស្រីកាត់ចិត្តទៅ"

ជីយ៉ន ញញឹមចម្អក និងញាក់ស្មា។

"ហេតុអីត្រូវកាត់ចិត្ត ព្រោះបងស្រឡាញ់លោកនាយក យ៉ាងណាក៏បងត្រូវតែដណ្តើមយកឲ្យបាន"

"តែលោក ម៉ាឡេសាសសូ មានលោកស្រី អ៊ីន ជាភរិយាហើយ ខ្ញុំថាបងកុំទៅរវីរវល់អី"

"គ្រាន់តែជាប្រពន្ធក្នុងនាម ប្រពន្ធដែលប្តីមិនដេកជាមួយ មិនឃើញគួរឲ្យអាណិតត្រង់ណា"

"ថាម៉េច ? លោកស្រី អ៊ីន និងលោក ម៉ាឡេសាសសូ មិនធ្លាប់មាន..."

"មែន បងទាយថាមិនទាន់មានស្អីៗគ្នា"

តេយ៉ុង មានអារម្មណ៍ពុះកញ្ជ្រោលនៅក្នុងទ្រូងកាន់តែខ្លាំងទៅៗ ហើយគិតថាបើអីចឹងមែន គេនៅមានសិទ្ធិ។



"ខ្ញុំទិនបែបហ្នឹង ប្រុសណាដេកជាមួយទៅ" ជីយ៉ន ប្រមាថមើលងាយអ្នកដែលខ្លួននិយាយដើម "សរុបទៅ ឯងយល់ព្រមជួយបងហើយមែនទេ ?"

"ខ្ញុំប្រហែលជួយអីបងមិនបានច្រើនទេ ព្រោះបើខ្ញុំធ្វើអីមិនល្អ ច្បាស់ជាត្រូវបណ្ដេញចេញមិនខាន"

"គ្រាន់តែរៀបចំឆាកឲ្យលោកនាយកឃើញមីខ្ញុំទិននោះក្បត់ចិត្តទៅបានហើយ ឯងធ្វើបានទេ ?"

"តែវាខុស បងស្រី"

"វាខុសស្អីណាស់ណាទៅ គ្រាន់តែធ្វើឲ្យគម្របត្រូវឆ្នាំងប៉ុណ្ណោះ សរុបគឺធ្វើតាមនេះ គីម តេយ៉ុង"

តេយ៉ុង មិនបានតបបងស្រី គិតតែអង្គុយស្ងៀម ដោយទឹកមុខតានតឹងខណៈដែល ជីយ៉ន អង្គុយញញឹមមានសេចក្ដីសុខ ព្រោះព្រះជាម្ចាស់កំពុងតែប្រទានពរដល់នាងហើយ ទ្រង់ប្រទានវិធីកម្ចាត់មារជ្រែកបេះដូងចេញពីជីវិតរបស់នាងហើយ។

**យ្យូលី បិទភ្នែកភ្លាមពេលទ្វារបន្ទប់ដេកត្រូវបើកនិងបិទ ដោយមិនបាច់**ប្រាប់ក៏ដឹងថាអ្នកណាដើរចូលមកក្នុងបន្ទប់ដេកនៅពេលថ្មើរណេះ។

ម៉ាទិនេស ម៉ាឡេសាសសូ សាស្ត្រាចារ្យវ័យក្មេងសុភាពរាបសារ និងជាស្វាមីក្នុងនាមរបស់នាងនោះឯង។

ពូកទ្រុឌ ដែលវាធ្វើឲ្យបេះដូងរបស់នាងញ័រនិងប្រឹងអត់ដង្ហើម តែព្រោះរំភើបពេក ទើបព្រួសវាចេញមកតាមមាត់។

"បងស្មានថាអូនគេងលក់ហើយតើ"

ព្រោះគេនិយាយនៅជិត ទើបនាងបង្ខំចិត្តបើកភ្នែក។



"គេងជិតលក់ហើយ"

*ហេតុអី ហេតុអី ម៉ាទិនេស សង្ហាម្ល៉េះ សូម្បីតែនៅក្នុងឈុតដេកក៏សង្ហាញ្ញយចិត្ត!*

"អីចឹង...ខ្ញុំគេងបន្ត"

"ឈប់សិន បងមានរឿងចង់សួរ"

គេផ្លូលខ្លួនដេកក្បែរ និងផ្ទៀងមុខមករក ឲ្យខ្យល់ដង្ហើមភាយឲ្យលើមុខរបស់នាង នោះហើយដែលធ្វើឲ្យនាងក្តៅខ្លួន ចង់ខិតចេញឲ្យឆ្ងាយ ទាស់ត្រង់រឿងដែលកុហកថាពិការជើង។

"តែខ្ញុំងងុយ"

"មិនទាន់យប់ជ្រៅផង កុំរឹង"

ខ្សែភ្នែករបស់គេដែលមើលមក ធ្វើឲ្យនាងសឹងតែរលាយ ទើបមើលទៅផ្សេង។

"បង...ម៉ាត មានអីក៏ឆាប់និយាយម៉ោ"

"ហេតុអីក៏ព្រមធ្វើកាយចលនា ?"

នាងឆ្លោយងើបភ្នែកមើលស្វាមី។

"គឺ...គ្មានអីទេ ខ្ញុំគ្រាន់តែចង់ដើរបានប៉ុណ្ណោះ"

"ចុះម៉េចក៏ពេលបងសុំ អូនមិនព្រម តែពេលអ្នកជំនាញ គីម ដើរទៅនិយាយតែមួយភ្លែត អូនបែរជាព្រមស្តាប់សម្តីគេស្រួលៗ"

នេះបើទឹកមុខរបស់ ម៉ាទិនេស ក្រមូវតែបន្តិច នាងប្រហែលគិតថាគេប្រចណ្ឌនាងនិងអ្នកជំនាញ គីម តែនេះបែរជាគ្មានស្លាកស្នាមនៃការមិនពេញចិត្ត វាមានតែភាពសោះកក្រោះ គ្មានអារម្មណ៍អី។



"ខ្ញុំប្តូរចិត្ត"



Scanned with CamScanner

"កុំកុហកបង"

"បងម៉ាត ដាក់សម្ពាធខ្ញុំធ្វើអី ?"

"ព្រោះបងចង់ដឹង ថាហេតុអីអូនប្តូរចិត្តស្រួលៗម្ល៉េះ ទាំងដែលប្រកែកដាច់អហង្ការ"

នេះបើនាងមិនបកស្រាយការសង្ស័យ យប់នេះ ម៉ាទិនេស ប្រហែលមិនឈប់ដេញដោលនាងទេ។

"គឺអ្នកជំនាញ គីម សង្ហា ខ្ញុំចាញ់ប្រុសសង្ហា" នាងបញ្ឈឺ។

ម៉ាទិនេស នៅស្ងៀម ខ្សែភ្នែកមុតស្រួចសម្លឹងមើលនាងមិនដាក់ ខណៈដែល យ្យូលី ខ្ទិបបបូរមាត់ ខឹងដែលគេគ្មានអាការៈប្រចណ្ឌហួងហែងឲ្យឃើញ ទាំងដែលនាងប្រកាសថាប្រុសផ្សេងសង្ហាជាង។

គេប្រហែលមិនបានគិតស្អីមកលើនាងមែនហ្នឹង។

"អីចឹងល្អហើយ បែបនេះនឹងយកចិត្តទុកដាក់ធ្វើកាយចលនា ជើងនឹងឆាប់ជា" គេង៉េបអង្គុយភ្លាម។

"បង ម៉ាត ចង់ទៅណា ?" នាងក្រមុំស្រវាចាប់ដៃគេ និងសួរដោយការងឿងឆ្ងល់។

"បងទើបតែនឹកឃើញ ថាពិនិត្យកិច្ចការនិស្សិតមិនទាន់រួច" គេបេះដៃនាងចេញពីដៃរបស់ខ្លួន ហើយចុះពីគ្រែ "អូនគេងមុនទៅ បងបែបជាចូលម៉ោវិញយប់ជ្រៅ ឬមិនអីចឹងអាចគេងនៅបន្ទប់ធ្វើការ"

"បងម៉ាត ខឹងអីខ្ញុំឬអត់ ?"

ម៉ាទិនេស គ្រវីក្បាល និងញញឹមចុងមាត់។

"បងខឹងអីខ្ញុំ ខ្ញុំមិនបានធ្វើអីខុស ផ្ទុយទៅវិញបងគួរតែឲ្យរង្វាន់ខ្ញុំទើបត្រូវ ដែលខ្ញុំមិនរឹងទទឹង ព្រមព្យាបាលខ្លួន"



"គឺ..."

"បងទៅហើយ សុបិនល្អ"

នាងហៅម្តងទៀត តែគេចេញទៅបាត់ទៅហើយ ទើបនាងដកដង្ហើមធំនិងង៉េបអង្គុយ លើកដៃជ្រងសក់ដែលសើងមម៉ើងរបស់ខ្លួន។

"មិនខឹង ហើយម៉េចក៏ដើរចេញទៅប៉ុបប៉ាប់បែបនេះ"

យ្យូលី ដកដង្ហើមធំម្តងហើយម្តងទៀត ទម្រាំផ្តួលខ្លួនដេក និងបិទភ្នែកដេកឲ្យលក់បាន ទ្រូងណែនដោយការតូចចិត្ត។



# ៧

ព្រឹកថ្ងៃបន្ទាប់ តេយ៉ុង ក៏ធ្វើដំណើរមកធ្វើតួនាទីរបស់ខ្លួននៅភូមិគ្រឹះ ម៉ាឡេសាសសូ។ គេរាក់ទាក់ មេសាន់ ដែលកំពុងចេញពីផ្ទះដើម្បីទៅធ្វើការ ហើយទៅរក យ្យូលី និង ម៉ាទិនេស។

"សួស្ដីលោក ម៉ាឡេសាសសូ លោកស្រី អិន"

"សួស្ដី លោក គីម"

ម៉ាទិនេស រាក់ទាក់វិញយ៉ាងសុភាព ខណៈដែល យ្យូលី បង្ខំចិត្តញញឹមដាក់គេ។

"ខ្ញុំផ្ញើភរិយាផង"

"ដោយក្ដីរីករាយ"

តេយ៉ុង ដើរមកឈរក្រោយខ្នង យ្យូលី ចាប់រទេះរុញរបស់នាង។

"ខ្ញុំនឹងព្យាយាមធ្វើឲ្យលោកស្រីដើរបានឲ្យឆាប់បំផុត"

ម៉ាទិនេស ញញឹម ហើយដៀងមើលភរិយា។

"យកចិត្តទុកដាក់ លីលី អត់ធ្មត់បន្តិច"

"ចាំ"

នាងត្រូវការកម្លាំងចិត្តពីគេច្រើនជាងនេះ តែគេបែរជាសោះកក្រោះ គ្មានអារម្មណ៍អី។

"តោះយើង អ្នកជំនាញ គីម"

"ខ្ញុំទៅសិនហើយលោក"

តេយ៉ុង និយាដាក់ ម៉ាទិនេស ម្ដងទៀត ហើយរុញរទេះរុញ យ្យូលី ដើរចេញពីបន្ទប់ទទួលភ្ញៀវ។

"មនុស្សឆ្កួត...ម៉េចចាំបាច់សោះកក្រោះបែបនេះ"

ពេលឮដូច្នេះ តេយ៉ុង ក៏អត់សើចមិនបាន។

"លោកស្រីកំពុងតូចចិត្តនឹងស្វាមីឬ?"

"មិនបានតូចចិត្តទេ"

"មិនបានតូចចិត្ត ចុះម៉េចក៏ធ្វើមុខក្រមូវ"

តេយ៉ុង រុញនាងទៅក្នុងសួន ហើយដើរវាងមកលុតជង្គង់នៅចំពោះមុខនាង។

"លោកកុំចេះបានទេ ចង់ធ្វើអីក៏ឆាប់ធ្វើទៅ"

"ខ្ញុំធ្វើអីបានទៅ បើលោកស្រីមិនចាំបាច់ធ្វើចលនាផង លោកស្រីដើរបានតើ"

យ្យូលី ប្ដោះទឹកមុខ ហើយងាកទៅមើលក្នុងផ្ទះ ឃើញ ម៉ាទិនេស ឈរឱបដៃមើលមក។

"តែយ៉ាងណាក៏ត្រូវលេងល្ខោនបន្ត តិចបង ម៉ាក សង្ស័យ"

តេយ៉ុង ផ្អៀងខ្លួនមើលតាមខ្សែភ្នែកនាង ដែលមើលទៅក្នុងផ្ទះ ហើយពេលឃើញ ម៉ាទិនេស កំពុងមើលមកក៏ងាកមកញញឹមដាក់ យ្យូលី។

"ខ្ញុំថាស្វាមីរបស់លោកស្រីបារម្ភពីលោកស្រីណាស់"

"គេគ្រាន់តែចង់ឲ្យខ្ញុំដើរបានឆាប់ៗប៉ុណ្ណោះ គេនឹងមិនខ្មាសអ្នកជទៃដែលមានប្រពន្ធពិការ"

នាងនិយាយបណ្ដើរ រលីងរលោងទឹកភ្នែកបណ្ដើរ តែរហ័សព្រិចភ្នែកបណ្ដេញវា។

តេយ៉ុង មើលនារីនៅចំពោះមុខដោយការព្រួយបារម្ភ។ ទោះ ជីយ៉ន ត្រូវ



Scanned with CamScanner

ការឲ្យគេបំផ្លាញក្រុមគ្រួសារនេះឲ្យលែងលះគ្នា តែពេលដល់វេលាមែនទែន គេមិនអាចធ្វើបែបហ្នឹងបាន ព្រោះអាណិត យ្សូលី។

"ត្រឹមលោកស្រីប្រាប់ស្វាមីថាដើរបាន ប៉ុណ្ណឹងគ្រប់យ៉ាងក៏អូរខេទៅហើយ"

នាងក្រមុំស្លឹកមុខ។

"គ្រប់យ៉ាងនឹងចប់ទៅវិញទេ ហេតុផលមួយ បងម៉ាត រៀបការជាមួយខ្ញុំព្រោះតែអាណិត"

តេយ៉ុង ផ្ទៀង.កបន្តិច។

"អ៊ីចឹងមានន័យថាលោកស្រីមិនព្រមប្រាប់ការពិត ព្រោះខ្លាចស្វាមីអស់ក្ដីអាណិតចំពោះលោកស្រីឬ?"

យ្សូលី មិនឆ្លើយ គិតតែអង្អុយស្ងៀម ទើបធ្វើឲ្យអ្នកជំនាញកំលោះយល់បានច្បាស់។

"លោកស្រីប្រហែលស្រឡាញ់ស្វាមីខ្លាំង"

"មែន ខ្ញុំស្រឡាញ់បង ម៉ាត ខ្លាំង ស្រឡាញ់តាំងពីតូច"

តេយ៉ុង ឈឺឆៀបក្នុងទ្រូង ដឹងខ្លួនភ្លាមថា អស់សង្ឃឹមចំពោះ យ្សូលី ហើយ។ ទោះគេធ្វើឲ្យពីរនាក់នេះលែងលះគ្នា ក៏ យ្សូលី គ្មានផ្លូវយកចិត្តមើលគេទេ ព្រោះបេះដូងរបស់នាងមានម្ចាស់រួចទៅហើយ។

គេឈឺចាប់និងសោកសៅ ចង់តែឈប់បំពេញការងារនេះ តែព្រោះមានទំនួលខុសត្រូវ ទើបគេត្រូវធ្វើការបន្ត។

"គួរឲ្យច្រណែនលោក ម៉ាឡេសាសសូ"

"គួរឲ្យច្រណែនត្រង់ណា គេមិនបានចាប់អារម្មណ៍បេះដូងខ្ញុំទេ"

"ម៉េចក៏លោកស្រីដឹងថាលោក ម៉ាឡេសាសសូ មិនបានចាប់អារម្មណ៍បេះដូងរបស់លោកស្រី?"



"គឺ..."

គេមិនព្រមប៉ះពាល់នាង មិនព្រមរួមដំណេកនឹងនាង ហ្នឹងអីចម្លើយ។

"គ្មានអីទេ ខ្ញុំចេះតែទាយ"

"អ៊ីចឹងខ្ញុំថាលោកស្រីគួរតែពិសោធ"

នាងផ្ទៀង.កមើលគេដោយការងឿងឆ្ងល់។

"លោកនិយាយស្អី ខ្ញុំមិនយល់"

"យើងធ្វើជាស្និទ្ធស្នាលគ្នាឲ្យលោក ម៉ាឡេសាសសូ ឃើញ បើគាត់មានចិត្តចំពោះលោកស្រី គាត់ច្បាស់ជាប្រចណ្ឌ"

"តែ..."

"ឬលោកស្រីខ្លាច?"

"ខ្ញុំមុនខ្លាចទេ តែខ្ញុំមិនចង់ស្និទ្ធស្នាលនឹងប្រុសផ្សេង" យ្សូលី ឆ្លើយប្រាប់គេតាមត្រង់ ដែលធ្វើឲ្យអ្នកជំនាញសង្ហាញញឹមសោកសៅ។

"ជឿជាក់ខ្ញុំបាន ទោះខ្ញុំចូលចិត្តលោកស្រីតាំងពីឃើញដំបូង តែខ្ញុំក៏ជាមនុស្សមានសីលធម៌ យ៉ាងណាក៏មិនដណ្ដើមប្រពន្ធគេដែរ"

"ថាម៉េច លោក...ចូលចិត្តខ្ញុំឬ?" នាងបើកភ្នែកធំៗដោយមិនចង់ជឿ។

"បាទ" តេយ៉ុង ងក់ក្បាលតិចៗ។

យ្សូលី អស់សំណើច អ្នកដែលនៅទល់មុខនាងសើចមិនសម។ ពួកគេនិយាយគ្នាស្និទ្ធស្នាល ក្រោមខ្សែភ្នែកមុតស្រួចដែលមើលមកមិនព្រិច។

ម៉ាទិនេស មានអារម្មណ៍ថាមានភ្នក់ភ្លើងឆេះនៅក្នុងទ្រូង ខាំថ្គាមណែនឡើងប៉ោងថ្ពាល់។

'គឺអ្នកជំនាញ គីម សង្ហា ខ្ញុំចាញ់ប្រុសសង្ហា'

សម្ដីរបស់ យ្សូលី កាលពីយប់មិញឮខ្ទរក្នុងសោត្រប្រសាទម្ដងទៀត



ធ្វើឲ្យដៃទាំងពីររបស់គេដែលចាប់រនាំងឈើក្តាប់ណែន។

"កុំគិតច្រើន គ្មានអីទេ" គេប្រាប់ខ្លួនឯងខ្សឹបៗ ហើយងាកមុខចេញពីរូបភាពនោះ "លីលី គ្រាន់តែជួបអ្នកដែលនិយាយត្រូវគ្នា និងមានវ័យស្រករគ្នាប៉ុណ្ណោះ មិនយូរទេ នាងនឹងដើរបានហើយ"

ហេតុផលជាច្រើនត្រូវយកលុបរូបភាពដែលឃើញអម្បាញ់មិញ តែវាក៏មិនអាចកាត់បន្ថយអារម្មណ៍ប្រចណ្ឌហួងហែងដែលកំពុងពុះនៅក្នុងទ្រូងបាន។

ម៉ាទិនេស ដកដង្ហើមធំម្តងទៀត ហើយខាំមាត់ ដើរចូលក្នុងផ្ទះ សំដៅបន្ទប់ទទួលភ្ញៀវ។

មែនហើយ ត្រូវធ្វើការ ខួរក្បាលនឹងឈប់គិតផ្តេសៗ ឈប់គិតផ្តេសផ្តាសចំពោះអ្វីដែលវាគួរឲ្យស្អប់ខ្ពើម។

**បន្ទាប់ពីព្រមព្រៀងធ្វើតាមការណែនាំរបស់ តេយ៉ុង ហើយ យូលី ក៏ដើរតួជាអ្នកសម្តែងតុក្កតាមាសបានល្អឥតខ្ចោះ។**

នាងលើកដៃគ្រវីដាក់គេ និងធ្វើទឹកមុខអាឡោះអាល័យជាខ្លាំង ហើយពេលឃើញ ម៉ាទិនេស ឈរមើលនៅមាត់ទ្វារផ្ទះ នាងក៏លួចញញឹមដោយការពេញចិត្ត។

"ស្អែកជួបគ្នា ខ្ញុំរង់ចាំ"

"បាទ"

ពេល តេយ៉ុង ឡើងឡានបើកចេញទៅ ទើបនាងឲ្យ ហុងស៊ីល នាំចូលផ្ទះ។

"ហុងស៊ីល ទៅមើលថៃប៉ាទៅ លីលី ចាំខ្ញុំមើលថៃ" ម៉ាទិនេស ដើរមកពាំងមុខ។



"កុំអាលទៅ ហុងស៊ីល" យូលី ប្រាប់មនុស្សរបស់ខ្លួន ហើយមើលមុខម៉ាទិនេស។

"អរគុណសម្រាប់បំណងរបស់បង ម៉ាត ខ្ញុំមិនរំខានបងទេ"

"លីលី" គេដើរមកពាំងមុខ ពេល យូលី បង្វិលកង់រទេះរុញចេញ "កុំរឹងដាក់បង"

"ខ្ញុំមិនបានរឹង គ្រាន់តែខ្ញុំមិនចង់រំខានបង ម៉ាត ប៉ុណ្ណោះ"

"ការមើលថៃប្រពន្ធ មិនមែនជារឿងដែលប្តីត្រូវធ្វើទេឬ?"

សម្តីរបស់គេ ធ្វើឲ្យមុខរបស់នាងឡើងក្រហមង៉ាំង ចំណែក ហុងស៊ីល ក៏លួចញញឹម។

"គឺ..."

"ហុងស៊ីល ទៅចុះ"

"អឺ...ចាំ លោក ម៉ាត"

ហុងស៊ីល ឈ្ងោកមុខឈ្ងោកមាត់ទទួលបញ្ជារបស់ ម៉ាទិនេស ហើយបាញ់ខ្សែភ្នែកសុំទោសសុំពៃរ៍ដាក់ យូលី ពេលដើរចេញទៅ។

"ហុងស៊ីល...ហុងស៊ីល ឈប់សិន"

"មិនបាច់ហៅអ្នកណាទេ នៅជាមួយបងនេះហើយ"

និយាយហើយ គេក៏លើកនាងបី ដោយ យូលី លើកដៃឱប.ករឹងមាំភ្លាមព្រោះខ្លាចធ្លាក់។

"បង ម៉ាត"

"មិនបាច់ហៅទេ" អ្នកកំលោះញញឹមដាក់ "ថ្ងៃនេះចាំបងងូតទឹកឲ្យ ហើយបើរឹង នឹងខាំឲ្យសព្វសាច់"

នាងក្រមុំបើកភ្នែកធំៗ ថ្ពាល់ទាំងសងខាងឡើងក្រហម។

"បង ម៉ាត...និយាយអី"

"គឺដូចដែលបានឮហ្នឹង"

គេដើរឡើងជណ្តើរ ដើរសំដៅបន្ទប់ដេក ហើយដាក់នាងទៅលើគ្រែថ្មមៗ បន្ទាប់មកក៏លើកដៃច្រត់ចង្កេះ ឈរសម្លក់នាងថ្មៃ។

"បងទៅលាយទឹកក្តៅឲ្យសិន មិនយូរទេ"

"បង ម៉ាត...ខ្ញុំងូតខ្លួនឯងបាន"

"ចាំបងជួយដុសខ្នងឲ្យ"

"តែ..."

"តែអី ហ៊ឺ?"

គេផ្ងៀង.កមើលមក មុខសង្ហាលម្អដោយស្នាមញញឹមគ្រប់រហូត។

*នេះគេកំពុងលេងសើចនឹងនាងមែនទេ?*

"ខ្ញុំ...ខ្មាស"

ពេលបានឮដូច្នេះ អ្នកកំលោះក៏អស់សំណើច។

"អីចឹងបងងូតជាមួយក៏បាន យើងនឹងស្មើភាពគ្នា"

"ឆ្កួតឬបង ម៉ាត អត់ទេ អូនខ្លាចកើតពពៃភ្នែក"

នេះវាកាន់តែធ្ងន់ធ្ងរ បើ ម៉ាទិនេស ងូតទឹកជាមួយ នាងមុខជា...មុខជាគិតតែសម្លឹងមើលគេ ហៀរទឹកមាត់កក្លាក់ដូចមនុស្សឡប់សតិមិនខាន។

ម៉ាទិនេស សើចហ៊ីៗ និងជ្រឹមភ្នែកមើលនាង។

"មិនអីទេ បើកើត ចាំបងជូនទៅព្យាបាលនៅមន្ទីរពេទ្យរបស់ ម៉ែ"

"បង ម៉ាត"

គេសើចតិចៗ ហើយក៏បែរខ្លួន ដើរចូលបន្ទប់ទឹក ទុកឲ្យ យូលី អង្គុយក្រហមមុខនិងខ្វល់ខ្វាយចិត្តនៅលើគ្រែតែម្នាក់ឯង។



*ធ្វើម៉េចទៅ ធ្វើម៉េច បើ...បើ ម៉ាទិនេស ងូតជាមួយ គេច្បាស់ជាឃើញរាងកាយរបស់នាង ឃើញទាំងអស់!*

ទឹកមុខរបស់ យូលី បង្ហាញឲ្យឃើញពីភាពខ្វល់ខ្វាយ។

ហើយបើ ម៉ាទិនេស មិនចូលចិត្តអ្វីដែលឃើញ តើគិតយ៉ាងម៉េច ព្រោះនាងគ្មានរាងកាយដូចស្រីបង្ហាញម៉ូត តាមដែលបុរសៗចង់បាន។

នាងមានដើមទ្រូងធំ ត្រគាកធំ ជើងក៏មិនស្រឡូនស្អាត សំណាងបន្តិចដែលមានចង្កេះតូច មិនអីចឹងពេញមួយតួខ្លួនរបស់នាងគ្មានអីល្អឲ្យមើល។

នាងក្រមុំលើកដៃម្ខាងអង្អែលមុខខ្លាំងៗ ដៃម្ខាងទៀតលើកក្តោបទ្រូងនិងជកដង្ហើមធំ ពេលនឹកដល់ឈុតក្នុងម៉ូតបុរាណជាប់នឹងខ្លួន។ នេះបើកាលពីព្រឹកយកឈុតក្នុងសិចស៊ីមកពាក់ ប្រហែលមិនខ្វល់ចិត្តបែបនេះទេ។

"ទឹកក្តៅឧណ្ហៗលាយរួចហើយ"

ម៉ាទិនេស ដើរមកឈរទល់មុខនាង ហើយលោមករក និងសម្លឹងមុខនាងដោយការពិចារណា។

"ក្តៅឬ ថ្ពាល់ក្រហម"

នាងក្រមុំលើកដៃក្រសោបមុខខ្លួនឯង។

"អឺ...មែន ក្តៅណាស់ ក្តៅមែនទែន បង ម៉ាត ជួយបន្ថែមលេខម៉ាស៊ីនត្រជាក់ឲ្យបន្តិចបានទេ"

"ក្តៅគឺត្រូវតែងូតទឹក ទើបជួយបាន"

និយាយហើយ គេក៏ងើបឈរត្រង់ខ្លួន ហើយដោះសម្លៀកបំពាក់ខ្លួនឯងឲ្យដើមទ្រូងធំទូលាយមានរោមក្រាស់ស្ថិតនៅចំពោះខ្សែភ្នែក នោះហើយដែលធ្វើឲ្យនាងដកដង្ហើមមិនពេញពោះ។



"បង...ម៉ាត ដោះអាវធ្វើអី"

នាងខាំមាត់ងាកមុខចេញ ឮសំឡេងសើចតិចៗរបស់គេមិនឈប់។

"បងងូតទឹកជាមួយអូនហ្នឹងអី"

"កុំ ខ្ញុំមិនចូលចិត្តងូតទឹកជាមួយអ្នកដទៃ"

"បងមិនមែនអ្នកដទៃ"

គេដើរមកឈរទល់មុខ និងលូកដៃទៅផ្ទើយចង្ការបស់នាង បង្ខាប់ឲ្យងាកមករក។

"បងជាប្ដីរបស់អូន លីលី"

"តែយើង...មិនទាន់..."

ម៉ាទិនេស ដឹងច្បាស់ថាភរិយាចង់និយាយអី ទើបញញឹមពព្រាយ។

"មិនយូរទេ"

នាងក្រមុំបើកភ្នែកធំៗ ប្រញាប់គេចភ្នែក។

"អឺ...ខ្ញុំងងុយដេក សុំដេកសិនបានទេ ?"

"មិនបានទេ ត្រូវងូតទឹក"

និយាយហើយ គេក៏ខិតមកជិត និងស្រវាឱបនាង។

"ម៉ោះ បងដោះអាវឲ្យ"

"កុំ...កុំបង ម៉ាត"

គេមិនខ្វល់ ចាប់នាងប្រឡេះឡេវអាវ។

"បង ម៉ាត...ខ្ញុំខ្មាស" នាងនិយាយខ្សឹបៗ។

"មិនបាច់ខ្មាសទេ អូនជារបស់បង ភ្លេចហើយអី"

ថ្ងៃនេះគេចង់លេងសៀតអី ហេតុអីបានជានិយាយស្ដីផ្អែមល្ហែម និងធ្វើអ្វីបែបនេះ។

"តែខ្ញុំមិនធ្លាប់..." នាងគ្រញែងខ្លួន ពេលត្រូវប្រឡេះឡេវអាវចុងក្រោយ ទើបដួលផ្ងារក្រោយ ទៅលើគ្រែ ដោយមានគេតាមមកទ្រាបពីលើ។

"បង ម៉ាត...ងើបឡើង"

"ហេតុអី ?"គេសួរកែវភ្នែកមុតស្រួចមើលមុខស្រស់ស្អាតដែលពេលនេះក្រហមង៉ាំង។

"គឺ...ខ្ញុំធ្ងន់"

គេញញឹម ទម្លាក់ទម្ងន់ខ្លួនទៅលើដៃម្ខាង ខណៈនោះក៏ឱនមុខសង្ហាមកជិត។

"បងសុំថើបអូនមុននាំទៅងូតទឹក"

"បង ម៉ាត"

នាងដកដង្ហើមមិនពេញពោះ និងបើកភ្នែកធំៗ ទាំងស្រៀវទាំងភ័យដល់ថ្នាក់ញែកអារម្មណ៍ពីរនេះមិនចេញពីគ្នា។

យូលី ប្រសព្វភ្នែកនឹងគេដោយគ្មានជម្រើស រលកក្ដៅបង្ហូរហាងនៅក្នុងពោះ ហើយវាកាន់តែខ្លាំងទៅៗ ត្រូវកម្រើកខ្លួនឲ្យរាងកាយទាំងពីរកកិតគ្នា។

"បងមិនចូលចិត្តឲ្យអូនស្និទ្ធស្នាលនឹងប្រុសផ្សេង" ពេលនេះគេព្រមនិយាយ "ទោះប្រុសម្នាក់នោះជាអ្នកជំនាញ គីម ក៏ដោយ"

"ហេតុ...ហេតុអី ?" នាងសួរដោយមានសង្ឃឹម។

"អូនមានឋានៈជាភរិយារបស់បង បងមិនត្រូវការឲ្យអ្នកណាយកទៅនិយាយមិនល្អ"

ពេលនេះក្ដីសង្ឃឹមរលាយអស់។

"បង ម៉ាត គិតតែប៉ុណ្ណឹងទេឬ ?"

អ្នកកំលោះញញឹមទាំងតានតឹង ខ្សែភ្នែកនៅតែមានពន្លឺនៃគ្រោះថ្នាក់។

"ក្នុងខួរក្បាលរបស់បងមានគំនិតច្រើនទៀត ដែលអូនមិនដឹង បងនឹង



ប្រាប់អូនបន្តិចម្តងៗ"

*គំនិតដែលមិនធ្លាប់ស្រឡាញ់នាង!*

នាងក្រមុំគិតដោយការតូចចិត្ត និងព្យាយាមរុញច្រានគេចេញឲ្យឆ្ងាយពីខ្លួន តែរាងកាយមាំមួនមិនរង្គើ។

"ចុះពីខ្លួនខ្ញុំទៅ"

គេគ្រវីក្បាលតិចៗ ហើយឆ្មក់ថើបបបូរមាត់ក្រពុំភ្លាម។ ការប៉ះពាល់របស់គេក្តៅនិងមានតែការស្រេកឃ្លាន ខុសពីរាល់ដង ម្រាមដៃក៏លើកជ្រងសក់ទន់ល្មើយ សង្កត់កញ្ចឹង.កបន្តិច មិនឲ្យនាងគេចទៅណាបាន។

យុរ្យលី ប្រឹងខ្ទិបមាត់ ប្រឹងធ្វើចិត្តឲ្យរឹងមិនតបស្នងចំពោះភាពក្តៅគគុកលាយឡំភាពផ្អែមល្ហែមរបស់ ម៉ាទិនេស តែបេះដូងរបស់នាងមានតែគេ ងប់និងរសជាតិរបស់គេងើបមុខមិនរួច ទើបព្រមទោរទន់តាមយ៉ាងងាយ និងថើបតបគេដោយភាពជ្រាលជ្រៅ។

"អំា..."

នាងបង្អើបមាត់បញ្ចេញសំឡេងថ្ងូចថ្ងូរតិចៗ ពេលគេអូសបបូរមាត់និងអណ្តាតមកឈ្មុលនឹង.ក ដៃក៏ដាក់លើស្មាមានកម្លាំង ខ្ញាំទាញខ្លាំងៗ ពេលដៃរបស់គេលូកចូលជីវអាវដែលញែកធំ និងក្តោបដើមទ្រូងដែលលាក់ក្នុងអាវក្នុងម៉ូតបុរាណ។

គេច្របាច់ដើមទ្រូងរបស់នាង និងគ្រហឹមដោយការពេញចិត្តពេលឈ្មុលមុខនឹងជ្រលងទ្រូងទ្រលុកទ្រលន់ ហើយពេលនាងគេច គេក៏សង្កត់ និងរុញអាវក្នុងឡើងលើ។

"អ៊ូ....ធំណាស់..."

នាងបានឮសំឡេងស្អករបស់ ម៉ាទិនេស ម្តងទៀត មុនពេលប្រើម្រាមដៃ



កៀបចុងរបស់វាខ្លាំងៗ។

"អំា...អំា...អំា..."

នាងថ្ងូចថ្ងូរដោយភាពស្រៀវស្រើប ពត់ពេនរាងកាយដោយតម្រូវការ តែនោះមិនមែនជាទីបំផុតនៃភាពវេទនាដ៏ផ្អែមល្ហែម ពេលសុខៗចុងរបស់វាទៅនៅក្នុងប្រអប់មាត់របស់គេ។

"អំា...បង ម៉ាត...អំា...អំា..."

នាងស្ទើរតែភ្លេចទៅថាខ្លួនឯងកំពុងលេងល្ខោនថា ជើងទាំងពីរពិការប្រើការមិនបាន រាងកាយតូចស្តើងញ័រទទ្រើតរមៀលទៅរមៀលមកជាមួយរាងកាយមាំមួនដោយភាពស្រៀវស្រើប ដែលធ្វើឲ្យភាពមហិមារបស់គេចាក់ប្រឡោះភ្លៅរបស់នាង។

"បង ម៉ាត..."

ម៉ាទិនេស ងើបមុខពីដើមទ្រូងណែនក្បុំ សម្លឹងមើលភ្នែកមូលក្លំដែលកំពុងតែច្របូកច្របល់ នេះគេកំពុងធ្វើឆ្កួតស្អី កំពុងតបស្នងតណ្ហារបស់ខ្លួន តែភ្លេចគិតទៅថាភរិយាមិនទាន់ត្រៀមខ្លួនសម្រាប់គេ។

"បង...សុំទោស" គេខាំមាត់ ងើបចេញពីរាងកាយរបស់នាងភ្លាម និងងើបអង្គុយបែរខ្នងដាក់។

"មិន...អីទេ" នាងរលីងរលោងទឹកភ្នែក។

"បងនឹងឲ្យ ហេវ៉ាន់ ម៉ោងូតទឹកឲ្យ" គេងើបឈរ ហើយដើរទៅយកអាវមកពាក់។

"ចំា" នាងឆ្លើយដោយការតូចចិត្ត។

"សុបិនល្អ"

ម៉ាទិនេស ងាកមកមើលនាងម្តងទៀតជាលើកចុងក្រោយ ហើយដើរ



ចេញពីបន្ទប់។

យូលី បណ្ដោយឲ្យទឹកភ្នែកហូរកាត់ថ្ពាល់រហាម គិតថាហេតុផលដែល ម៉ាទិនេស ឈប់ភ្លាមៗ ប្រហែលមកពីនឹកឃើញថាមិនគួររួមរក្សនឹងប្រពន្ធពិការ ធ្វើឲ្យនាងឈឺណាស់...ឈឺសឹងតែឈប់ដកដង្ហើមទៅហើយ។

មួយសន្ទុះទ្វារបន្ទប់ត្រូវបើក ហេវ៉ាន់ ស្រីបម្រើមុខមាត់ស្រស់ស្អាតដូចទេពធីតាក៏ដើរចូលមក។

"លោក ម៉ាត ឲ្យខ្ញុំមកជួយមើលថែលោកស្រី"

យូលី ព្រិចភ្នែកញាប់ស្អេក ដើម្បីបណ្ដេញទឹកភ្នែក ហើយប្រឹងញញឹមទាំងខាងក្នុងកំពុងឈឺចាប់។

"អរគុណ"

"អ៊ីចឹងខ្ញុំទៅលាយទឹកក្ដៅឲ្យ"

"បង ម៉ាត លាយឲ្យរួចហើយ នាងគ្រាន់តែនាំខ្ញុំចូលបន្ទប់ទឹកទៅ ក្រៅពីនេះខ្ញុំចាត់ការខ្លួនឯង"

"តែលោក ម៉ាត បញ្ជាថា..."

"បង ម៉ាត មិនបានចាប់អារម្មណ៍ស្អីខ្ញុំណាស់ណា" នាងក្រមុំនិយាយដោយការតូចចិត្ត ទឹកភ្នែករលីងរលោងម្ដងទៀត។

"មិនពិតទេ លោក ម៉ាត បារម្ភពីលោកស្រីណាស់ កាលពីថ្ងៃខ្ញុំឃើញលោក ម៉ាត ដើរចេញដើរចូលបន្ទប់ធ្វើការរាល់ប្រាំនាទីម្ដង ដើម្បីទៅមើលលោកស្រីធ្វើកាយចលនា"

យូលី មិនចង់តវ៉ា ទើបអង្គុយស្ងៀម ពេលនោះក៏ឮសំឡេងឡាន។

"ឡានបង ម៉ាត"

"ចាំខ្ញុំទៅមើលឲ្យ"



ហេវ៉ាន់ ប្រញាប់ប្រញាល់ដើរទៅរកបង្អួច ទាញវាំងននចេញ។

"ចាំ សង្ស័យលោក ម៉ាត មានធុរៈ"

*ធុរៈដែលគ្មាននាងពាក់ព័ន្ធ!*

យូលី តូចចិត្តហើយតូចចិត្តទៀត ទោះព្យាយាមលួងលោមចិត្តខ្លួនឯងយ៉ាងណា តែមិនអាចព្យាបាលរបួសស្នេហានៅក្នុងទ្រូងបាន។

**ម៉ាទិនេស អន្ទះអន្ទែង ព្រោះមិនអាចរួមរក្សនឹង យូលី នៅពេលនេះ**បាន ទើបគេសម្រេចចិត្តបើកឡានចេញពីផ្ទះ សំដៅមកផាប់ដែលធ្លាប់មកជាមួយ មេតធ្យូ។

"លោកនាយក..."

នៅតាមផ្លូវដើរចូលទៅក្នុងផាប់ក៏ជួប ជីយ៉ន ដែលកំពុងត្រឡប់ទៅផ្ទះវិញល្មម ទើបនាងញញឹមសឹងតែរហែកមាត់ ព្រោះបានជួបគេ។

"សួស្ដីសាស្ត្រាចារ្យ គីម"

"សប្បាយចិត្តដល់ហើយដែលបានជួបលោកនាយកនៅទីនេះ **យើងទៅ**ផឹកជាមួយគ្នាទៅ"

ម៉ាទិនេស ញញឹមយ៉ាងសុភាពដាក់។

"សាស្ត្រាចារ្យកំពុងត្រឡប់ទៅវិញមិនអ៊ីចឹង ខ្ញុំមិនរំខានទេ"

"មិនរំខានទេ ខ្ញុំពេញចិត្ត" ស្រីស្អាតនៅតែតាមទាម "ម៉េះចាំខ្ញុំនាំដើរចូលទៅ"

និយាយហើយ នាងក៏ស្រវាឱបដៃគេ នាំដើរចូលទៅខាងក្នុងភ្លាម។

ម៉ាទិនេស មិនអាចបដិសេធបាន ទើបត្រូវដើរតាមការអូសទាញរបស់នាងដោយគ្មានជម្រើស។



Scanned with CamScanner

ពេលដាក់បង្គុយចុះហើយ ជីយ៉ន ក៏បបួលនិយាយភ្លាម។

"តែថាអ្នកមានគូហើយដូចលោកនាយកមកទេសចរណ៍រាត្រីបាន មិនខ្លាចប្រពន្ធនៅផ្ទះថាឲ្យទេ" នាងធ្វើជាសួរនាំ។

ម៉ាទិនេស ញញឹម និងលើកស្រាជិប មិនមាត់មិន.ក និងងាកមុខចេញធ្វើដូច ជីយ៉ន មិនបានអង្គុយនៅត្រង់នេះ ទើបធ្វើឲ្យស្រីស្អាតខាំមាត់ដោយការឃ្នើសចិត្ត តែត្រូវលាក់ការមិនពេញចិត្តនោះក្រោមទឹកមុខញញឹម។

"នេះខ្ញុំទើបតែដឹងថា តេយ៉ុង ទៅធ្វើការឲ្យលោកនាយក"

អ្នកដែលមើលទៅផ្សេង ងាកមករកអ្នកនិយាយភ្លាម និងសួរដោយការងឿងឆ្ងល់។

"សាស្ត្រាចារ្យ តឹម ស្គាល់គេដែរឬ ?"

"ស្គាល់ ស្គាល់ច្បាស់តែម្តង"

"យ៉ាងម៉េច ?" ម៉ាទិនេស សួរដោយការសង្ស័យ ទើប ជីយ៉ន ញញឹមពព្រាយ។

"តេយ៉ុង ជាប្អូនប្រុសរបស់ខ្ញុំ ប្អូនប្រុសម្តាយទីទៃ"

"ភ្ញា! ផែនដីមូលមែន"

"ចាំ ផែនដីមូលណាស់" នាងនៅតែញញឹមលម្អមុខមាត់ស្រស់ស្អាត

"ហើយនេះ តេយ៉ុង ធ្វើការបានល្អ ត្រូវចិត្តលោកនាយកទេ ?"

"ល្អ"

"ខ្ញុំភាវនាឲ្យលោកស្រី អ៊ិន ដើរបានឆាប់ៗ"

ម៉ាទិនេស សើចញឹមៗ ហើយលើកកែវផឹកស្រា ដោយមិនបានចាប់អារម្មណ៍នាងទៀត ខណៈដែលនាងនៅតែមើលមុខគេនិងប្រឹងរិះរកវិធីញុះញង់ឲ្យ យ៉ូលី យល់ច្រឡំចំពោះអ្នកកំលោះ។ មួយសន្ទុះក្រោយមកក៏គិតឃើញ



ទើបញញឹមពេញចិត្ត ទាញទូរសព្ទដៃមកបើកកាមេរ៉ាលួចថត ម៉ាទិនេស។

"លោកនាយក ខ្ញុំសុំចូលបន្ទប់ទឹកសិន"

"បាទ អញ្ជើញ"

ម៉ាទិនេស នៅតែមិនចាប់អារម្មណ៍ដដែល ដែលធ្វើឲ្យ ជីយ៉ន ឃ្នើសចិត្តជាខ្លាំង ម្ទីម្នាដើបចេញពីតុ ដើរទៅមុខផាប់ ផែកមើលលេខទូរសព្ទរបស់ យ៉ូលី ហើយផ្ញើរូបរបស់ ម៉ាទិនេស អបដោយសារញុះញង់។

**សាបគ្មានជាតិ ទើបប្តីត្រូវចេញមករកស៊ីនៅក្រៅផ្ទះ ចាំផ្ញើទៅឲ្យវិញពេលរួចរាល់ធុរៈ**

"ចាំមើល ទ្រាំបានប៉ុន្មានតឹក មីខ្ញិន"

នាងញញឹមពេញចិត្ត ហើយដើរចូលក្នុងផាប់វិញ តែបែរជាមិនឃើញម៉ាទិនេស។

"ប្រុសសង្ហាដែលអង្គុយតុនោះ ទៅណាហើយ ?" ពេលមើលជុំវិញខ្លួននៅតែមិនឃើញ ទើបនាងសួរអ្នករត់តុ។

"គិតលុយ ចេញទៅហើយ"

ពេលប្រាប់ហើយ អ្នករត់តុដើរចេញទៅ ទុកឲ្យ ជីយ៉ន ឈរខាំធ្មេញក្រតៗតែម្នាក់ឯង។

"អាឆ្កួត ខំដាក់ស្ពានឲ្យហើយ នៅតែមិនព្រមឆ្លងម៉ោទៀត"

នាងឃ្នើសចិត្តជាខ្លាំង តែធ្វើអីមិនបាន ក្រៅពីដើរអស់សង្ឃឹមចេញពីផាប់។



យូលី ដេករលីងរលោងទឹកភ្នែកពេលបើកសារដែលអ្នកណាក៏មិនដឹង ផ្ញើឲ្យពេលយប់ ឃើញថាជារូបរបស់ ម៉ាទិនេស អង្គុយផឹកស្រានៅក្នុងជាប់។ គេប្រហែលជុញទ្រាន់ប្រពន្ធខ្ញុំ ទើបត្រូវចេញទៅរកស៊ីនៅខាងក្រៅ។

នាងយំអណ្ដឺតអណ្ដកដោយការឈឺចាប់ ប្រឹងបិទភ្នែកដេកឲ្យលក់ តែធ្វើមិនបាន ត្រូវបណ្ដោយឲ្យខ្លួនឯងនៅជាមួយការឈឺចាប់បែបនោះ។

"បង ម៉ាត ចិត្តអាក្រក់..."



# ៨

ភាពសោះកក្រោះរវាងស្វាមីភរិយាថ្មោងថ្មី ដែលកើតឡើងនៅព្រឹកថ្ងៃនេះ ធ្វើឲ្យ ហុងស៊ីល មិនសប្បាយចិត្ត។

"អ្នកនាងកើតអីឬអត់ ?" ហុងស៊ីល សួរភ្លាម ពេលឃើញទេះរុញរបស់ចៅហ្វាយ ពេលនាំចៅហ្វាយចេញពីបន្ទប់អាហារ។

"អត់មានទេ"

"កុំបិទបាំងខ្ញុំអី មានរឿងអីនឹងលោក ម៉ាត ឬ"

សំឡេងរបស់នាងសោកសៅទៅៗធ្វើឲ្យហុងស៊ីលមិនហ៊ានដេញដោលបន្ត។

"ថ្ងៃនេះអ្នកជំនាញមកដែរទេ ?"

"ម៉ោងប្រាំបួន" នាងក្រមុំតប ហើយអង្គុយសោកសៅបន្ត ខណៈដែល ហុងស៊ីល បានតែមើលដោយក្ដីអាណិត មិនអាចជួយអ្វីបានលើសពីនេះ។

ម៉ាទិនេស ដើរចេញមកក្រៅផ្ទះ ដើរកាត់ល្ហម ទើប ហុងស៊ីល អត់មិនបាននឹងដើរទៅសួរនាំ។

"លោក ម៉ាត ចេញទៅក្រៅឬ ?"

ម៉ាទិនេស ងាកមករកអ្នកសួរ ហើយមើលទៅ យូលី ដែលងាកមុខចេញភ្លាម។



"ទៅមហាវិទ្យាល័យ ជួយមើលថែអ្នកនាងធ្វើកាយចលនាតាមអ្នកជំនាញប្រាប់ផង"



Scanned with CamScanner

"ចំា លោក"

ម៉ាទិនេស មិននិយាយអ្វីទៀត ប្រុងដើរសំដៅរថយន្ត តែទូរសព្ទដៃរោទ៍ទើបគេចុចទទួល។

"បាទសាស្ត្រាចារ្យ គីម ខ្ញុំនឹងទៅដល់មិនលើសពីម៉ោងប្រាំបីកន្លះ"

និយាយហើយគេក៏ដាក់ទូរសព្ទចុះ ចូលទៅក្នុងរថយន្តបើកចេញទៅដោយមាន យ៉ូលី តាមមើលទាល់តែបាត់ពីភ្នែក។

"អ្នកនាង...លោក ម៉ាត ប្រហែលមានការងារបន្ទាន់"

"ការងារបន្ទាន់ ជាមួយស្រីម្នាក់នោះឬ" នាងខាំមាត់ទឹកភ្នែករកកល់ចង់ស្រក់។

"ប្រហែលការងាររួម"

"កុំលួងលោមខ្ញុំអី ឲ្យខ្ញុំប្រមាណខ្លួនប្រមាណប្រាណល្អហើយ ពេលថ្ងៃលែងលះគ្នាមកដល់ នឹងមិនបាច់ឈឺចាប់ដល់ស្លាប់"

"ព្រះអើយ! អ្នកនាង..."

យ៉ូលី ប្រឹងញញឹម ទាំងដែលទឹកភ្នែកហូរដាបថ្ពាល់។ នាងវេទនាចិត្តខ្លាំងណាស់ ឈឺចាប់ស្ទើរតែដកដង្ហើមមិនចេញទៅហើយ។

**ឃើញថានៅសល់កន្លះម៉ោងទៀតទើបដល់ពេលណាត់ ទើប ជីយ៉ន មករកប្អូនប្រុសនៅផ្ទះ គិតថាមកសួរនាំរឿងដែលបញ្ញាឲ្យធ្វើ ប៉ុន្តែបែរជាបានឮរឿងដែលសឹងតែមិនចង់ជឿ។**

"ការងារមិនពិបាកទេមិត្តភក្តិ ភៀវរបស់ខ្ញុំដើរបានយូរហើយ ប៉ុន្តែនាងមិនព្រមប្រាប់អ្នកដទៃប៉ុណ្ណោះ" តេយ៉ុង កំពុងនិយាយទូរសព្ទឆ្លងប្រទេសជាមួយមិត្តជិតស្និទ្ធ។



"អឺម! អរគុណដែលតេរមកសួរ បើទំនេរពេលណា នឹងទៅរកឯង អូខេតាយៗ"

គេបញ្ចប់ការសន្ទនាដាក់ទូរសព្ទចូលហោប៉ៅខោ ហើយបែរខ្នង ក៏ទច់ដំណើរដោយការភ្ញាក់ផ្អើល ពេលឃើញបងស្រីនៅចំពោះមុខ។

"បងស្រី!"

ជីយ៉ន ញញឹមត្រជាក់ដាក់ប្អូនប្រុសម្ដាយទីទៃ។

"ម៉េចក៏ធ្វើមុខភ្ញាក់ផ្អើលម្ល៉េះ"

"អឺ...គឺខ្ញុំ..."

"ឬថាមានអាថ៌កំបាំងអីនឹងបង"

"អត់ អត់មានទេ" តេយ៉ុង ដើរចេញ តែត្រូវបងស្រីស្រវាចាប់ដៃជាប់។

"នៅនិយាយគ្នាសិន"

"ខ្ញុំត្រូវទៅធ្វើកាយចលនាឲ្យលោកស្រី អ៊ីន"

ជីយ៉ន ពេបមាត់ញញឹម និងជ្រឹមភ្នែកមើលប្អូនប្រុស។

"ដើរបានហើយតើ ម៉េចចាំបាច់ធ្វើទៀត"

"គឺ..."

"មិនគួរឲ្យជឿថាវាជារឿងពិត មីខ្វិននោះវាដើរបាន ប៉ុន្តែបែរជាធ្វើពុតអង្គុយលើរទេះរហូត"

តេយ៉ុង មានអារម្មណ៍ដឹងខុសចំពោះ យ៉ូលី មែនទែន ដែលធ្វើឲ្យធ្លាយអាថ៌កំបាំងរបស់នាង។

"បងស្រី...ខ្ញុំសូមអង្វរ កុំផ្សព្វផ្សាយរឿងនេះ"

"ថី!" ជីយ៉ន កំពុងតែកាន់សន្លឹកបៀធំជាង "ឯងខ្លាចអី បងថាវាជារឿងល្អទៅវិញទេដែលមីខ្វិននោះដើរបាន"



"វាក៏ល្អ បើលោកស្រី អ៊ីន មិនបិទបាំងរឿងនេះពីស្វាមី"

ដីយ៉ន ញញឹមពេញចិត្ត ដែនការដែលធ្វើឲ្យពីរនាក់នោះបែកខ្ញែកគ្នា កំពុងតែនៅចំពោះមុខហើយ។

"មែនហ្នឹង ម៉េចវាចាំបាច់បោកពីប្ដី"

"នាងមានហេតុផល"

"អីចឹងឬ"

"បងស្រី ចាត់ទុកថាខ្ញុំអង្វរ កុំផ្សព្វផ្សាយរឿងនេះ ខ្ញុំមិនចង់ឲ្យនាងមានបញ្ហា"

"ហ្នឹងហើយដែលបងត្រូវការ" បងស្រីពេបមាត់ញញឹម ប៉ុន្តែ តេយ៉ុង មិនព្រមលះបង់ការព្យាយាមក្នុងការអង្វរករ។

"សូមអង្វរបងស្រី...ចាត់ទុកថាយល់ដល់ខ្ញុំផងទៅ កុំប្រាប់រឿងនេះដល់លោក ម៉ាឡេសាសសូ"

ដីយ៉ន ឈរស្ងៀម ប៉ុន្តែក្នុងចិត្តកំពុងគិតផែនការ។

"ក៏បាន បងមិនប្រាប់លោកនាយកក៏បាន"

"សន្យាហើយបងស្រី" តេយ៉ុង សប្បាយចិត្តខ្លាំង។

"អឺម បងមិនប្រាប់ក៏បាន ប៉ុន្តែបើលោកនាយកចាប់បានដោយខ្លួនឯងជួយមិនបានទេ ព្រោះវានៅក្រៅទំនួលខុសត្រូវរបស់បង"

"លោក ម៉ាឡេសាសសូ គ្មានផ្លូវដឹងទេ បើខ្ញុំមិនប្រាប់ លោកស្រី អ៊ីន មិនប្រាប់ បងមិនប្រាប់"

"វាមិនច្បាស់ដែរ"

"បងចង់មានន័យថាម៉េច ?"

"អត់មានអីទេ អីចឹងបងទៅសិនហើយ ចាំជួបគ្នាពេលក្រោយ"



ដីយ៉ន ដើរញញឹមញញែមចេញពីផ្ទះរបស់ប្អូនប្រុសម្ដាយទីទៃ ខណៈដែលអ្នកកំលោះដើរតាមមកបញ្ជាក់។

"បងស្រី...សន្យាហើយ"

"នេះចាត់ទុកបងជាមនុស្សគ្មានទំនួលខុសត្រូវចំពោះកិច្ចសន្យាឬយ៉ាងម៉េច ប្រាប់ថាមិនប្រាប់គឺមិនប្រាប់ ទៅហើយ" និយាយហើយ នាងក៏ឡើងឡានបើកចេញទៅភ្លាម។

តេយ៉ុង តាមមើលឡានរបស់បងស្រីម្ដាយទីទៃដោយការមិនសប្បាយចិត្តជាខ្លាំង ទោះ ដីយ៉ន បានសន្យាហើយក៏ដោយ ប៉ុន្តែគេនៅតែមានការខ្វល់ខ្វាយ។

"មិនគួរសោះ គីម តេយ៉ុង"

គេលើកដៃទះមាត់ខ្លួនឯងទាល់តែឈឺ ប៉ុន្តែភាពខ្វល់ខ្វាយនៅតែមិនព្រមរសាយ។

**ដីយ៉ន សុំតាម ម៉ាទិនេស មកផ្ទះរបស់គេដែរ ដោយឲ្យហេតុផលថាត្រូវ**មករក តេយ៉ុង ដែលអ្នកកំលោះមិនអាចបដិសេធបាន។

ពេលចុះពីឡាន ឃើញ តេយ៉ុង និង យូលី នៅជាមួយគ្នាតែពីរនាក់ នាងក៏ញុះញង់បន្ថែម។

"អ៊ុយ! ខ្ញុំបញ្ជាក់ តេយ៉ុង ហើយថាកុំធ្វើខ្លួនស្និទ្ធស្នាលនឹងលោកស្រី អ៊ីន ពេក តែមើលចុះ..."



ម៉ាទិនេស មើលរូបភាពនៅចំពោះមុខដោយខ្សែភ្នែកត្រជាក់ស្រេង ខាំថ្គាមណែន តែមិននិយាយអី។

"ចាំខ្ញុំបញ្ជាក់ប្អូនប្រុសជាថ្មី"



Scanned with CamScanner

នាងប្រញាប់ប្រញាល់ដើរតាម ម៉ាទិនេស ចូលទៅក្នុងផ្ទះ។

"មិនបាច់ទេ ព្រោះគ្មានអីទេ"

"ម៉េចក៏ថាគ្មាន គឺ..."

ជីយ៉ន ធ្វើជាផ្អាកនិយាយ ទើប ម៉ាទិនេស ឈប់ដើរ ហើយបែរខ្លួនមកមើលមុខនាងដោយទឹកមុខងឿងឆ្ងល់។

"គឺស្អី ?"

"ខ្ញុំមិនដឹងថានិយាយទៅល្អឬអត់ ?" នាងធ្វើជាទើសទ័ល ទាំងដែលការពិតទៅចង់ជះសាំងទៅលើភ្លើងសឹងតែដាច់ខ្យល់។

"អីចឹងមិនអីទេ"

អ្នកកំលោះបែរមុខមកវិញ ហើយដើរបន្ត ទើបនាងរត់តាម មកស្រវាចាប់ដៃជាប់។

"ប្រាប់...ក៏បាន"

ទឹកមុខរាបស្មើ គ្មានអារម្មណ៍របស់ ម៉ាទិនេស ធ្វើឲ្យនាងដៅមិនបានថាគេមានអារម្មណ៍យ៉ាងណា។

"គឺ...តេយ៉ុង យកមកនិយាយឲ្យខ្ញុំស្តាប់ ពាក់ព័ន្ធនឹងលោកស្រី អ៊ីន"

ម៉ាទិនេស នៅតែឈរស្ងៀម ចាំស្តាប់។

"គឺលោកស្រី អ៊ីន...ចូលចិត្តបាញ់ខ្សែភ្នែកដាក់គេ គឺខ្ញុំមិនបានចោទទេ តែ តេយ៉ុង យកភាពតានតឹងមកកម្ចាយឲ្យខ្ញុំស្តាប់ ទើបខ្ញុំត្រូវប្រាប់លោក"

គេខាំថ្គាមណែន តែទឹកមុខរាបស្មើដដែល ធ្វើឲ្យ ជីយ៉ន ជ្រេញ។

"នោះអី ឃើញទេ"

នាងចង្អុលទៅក្រៅបង្អួច ដែលមើលឃើញ តេយ៉ុង និង យូលី ដែល ម៉ាទិនេស ក៏មើលតាម ឃើញរូបភាព តេយ៉ុង ឱនទៅរក យូលី មើលទៅដូច



ខិនទៅថើបថ្ពាល់ ទើបងាកមុខចេញ។

ជីយ៉ន ញញឹមពេញចិត្ត ព្រមទាំងសរសើរប្អូនប្រុសនៅក្នុងចិត្ត។

*ឲ្យបានអីចឹងឡើងប្អូនប្រុស!*

"លោកនាយកចង់ទៅណាហ្នឹង ?"

ពេលឃើញ ម៉ាទិនេស ដើរសំដៅជណ្តើរ នាងក៏ស្រែកសួរ។

"ខ្ញុំឡើងទៅងូតទឹក អញ្ជើញសាស្ត្រាចារ្យ គីម តាមសម្រួលចុះ"

ពេលនិយាយចប់ហើយ គេក៏ដើរគេចភ្លាម។

"មុខស្មើៗបែបនេះ ស្មានថាមិនដឹងឬថាកំពុងខឹង"

នាងញញឹមចម្អក និងរិះរកវិធីបង្កើតស្នាមប្រេះឆាឲ្យកាន់តែធំ ហើយក៏គិតឃើញ ពេលឃើញស្រីបម្រើកាន់ទឹកយកមកឲ្យ។

"អាំ!"

ប្រាវ!!!

សំឡេងស្រែកភ្ញាក់មាត់របស់ ជីយ៉ន បន្លឺឡើងអមដោយសំឡេងកែវទឹកធ្លាក់បែកខ្ចាយ ធ្វើឲ្យអ្នកបម្រើដែលទើបតែបែរខ្នង ដើរចេញទៅបានមិនប៉ុន្មានជំហាន ម្នីម្នាដើរមករកវិញ។

"កើតអីដែរទេ ?"

"ទទឹកអស់ហើយ ចេះសួរទៅកើត" ជីយ៉ន ចាប់ខោអាវទទឹករបស់ខ្លួនឲ្យអ្នកបម្រើមើល "ខ្ញុំត្រូវផ្លាស់ខោអាវ"

"អ្ហ៎! អីចឹងចាំខ្ញុំទៅរកខោអាវម៉ោឲ្យផ្លាស់"

"មិនបាច់ ចាំខ្ញុំទៅឲ្យលោកនាយករកឲ្យ"



និយាយហើយ ស្រីស្អាតក៏ដើរឡើងជណ្តើរទៅជាន់លើ ដោយមានស្រីបម្រើរត់តាមមកឃាត់។

"កុំរំខានលោក ម៉ាត អី ចាំខ្ញុំរកឲ្យ"

ជីយ៉ន ងាកខ្ទាប់មកសម្លឹងមុខអ្នកនិយាយ។

"តួនាទីរបស់នាងគឺប្រមូលអំបែងកែវឲ្យអស់ ចំណែករឿងរបស់ខ្ញុំ ខ្ញុំចាត់ការខ្លួនឯងបាន កុំម៉ោះបេះ"

"តែ..."

"ខ្ញុំជាភ្ញៀវរបស់លោកនាយក មានភ្លេចអីឬអត់នាង"

ស្រីបម្រើបានតែធ្វើមាត់ម្លូបៗ និយាយមិនចេញ ទើប ជីយ៉ន ដើរឡើងជណ្ដើរបន្ត។

"មានអីកើតឡើង ?" យ្យូលី ដែលទើបចូលមកក្នុងផ្ទះឲ្យស្រីបម្រើ។

"អី...គឺមនុស្សស្រីដែលមកជាមួយលោក ម៉ាត ធ្វើឲ្យកែវទឹកបែក ហើយខោអាវរបស់នាងទទឹកអស់"

យ្យូលី ដឹងភ្លាមថាជាអ្នកណា ទើបព្យាយាមមិនចាប់អារម្មណ៍។

"យកខោអាវឲ្យនាងផ្លាស់ហើយឬនៅ ?"

"ខ្ញុំចង់ទៅយកហើយ តែនាងប្រាប់ថាកុំបេះ នាងចាត់ការខ្លួនឯង"

"ធ្វើម៉េច ?" នាងក្រមុំសួរដោយការងឿងឆ្ងល់។

"នាងឡើងទៅរកលោក ម៉ាត ហើយ" ស្រីបម្រើតបមិនពេញសំឡេង។

យ្យូលី បានឮបែបនេះហើយក៏ក្ដាប់ដៃណែន ខាំធ្មេញក្រតៗ។

"នាំខ្ញុំឡើងទៅបន្ទប់បន្តិច ខ្ញុំទៅងូតទឹក"

"អ្ហ្ក...ចាំ"

ស្រីបម្រើដាក់ការងារប្រមូលអំបែងកែវចោល ហើយម្ដីម្ដានាំចៅហ្វាយឡើងទៅជាន់លើ។

នៅក្នុងទ្រូងរបស់ យ្យូលី ក្ដៅអន្ទះអន្ទែង មានតែការប្រចណ្ឌហួងហែង



និងសុំឲ្យខ្លួនឯងទៅដល់បន្ទប់ឲ្យឆាប់ៗ។

"បើកទ្វារចូលទៅ"

"ចា៎"

ពេលស្រីបម្រើធ្វើតាមបញ្ជា អ្វីដំបូងដែល យ្យូលី ឃើញគឺ ជីយ៉ន ពាក់ឈុតដេករបស់ខ្លួន ដែលធ្វើឲ្យនាងខឹងឆេះដាច់កន្ទុយ ចាប់កង់រទេះបង្វិលចូលទៅភ្លាម ទៅស្ដីឲ្យ។

"ម៉េចក៏ហ៊ានយកខ្លួនស្មោកគ្រោករបស់នាងមកប៉ះរបស់ខ្ញុំ!"

ជីយ៉ន ផ្ងៀង.កមើលអ្នកថាឲ្យខ្លួនដោយការឡកឡឺយ។

"គ្រាន់តែឈុតដេក មិនឃើញមានអីឲ្យហួងហែង"

"ខ្ញុំហួងហែងគ្រប់យ៉ាងដែលជារបស់ខ្ញុំ"

"អីចឹងឬ ?" ជីយ៉ន សើចចម្អក ឱនមកមើលនាងដោយទឹកមុខអ្នកដែលមានប្រៀបជាង។

"តែថ្ងៃមួយខ្ញុំអាចបានប្រើរបស់ផ្សេងរបស់នាងទៀត លោកស្រី អ៊ីន"

"នេះនាង..."

"មានអីឬ ?"

សំឡេងគ្រលរដែលបន្លឺឡើងនៅមាត់ទ្វារ ធ្វើឲ្យគ្រប់គ្នាងាកទៅមើលលើកលែងតែ យ្យូលី។

"គ្មានអីទេ លោកស្រី អ៊ីន គ្រាន់តែងឿងឆ្ងល់ថាហេតុអីខ្ញុំយកខោអាវដេករបស់នាងមកពាក់"

ម៉ាទិនេស ដើរមកឈរទល់មុខអ្នកដែលអង្គុយលើរទេះរុញ។



"បងជាអ្នកអនុញ្ញាត ព្រោះឈុតរបស់សាស្ត្រាចារ្យ គីម កំពុងបោកអ៊ុត"

"លោកស្រី អ៊ីន មិនពេញចិត្ត" ជីយ៉ន ជះសាំងទៅលើភ្លើង។

"បើមិនពេញចិត្ត អីចឹងមិនពេញចិត្តបងទៅ កុំទៅថាឲ្យសាស្ត្រាចារ្យ គីម នាងគ្មានចេតនាយកខោអាវរបស់អូនពាក់ទេ"

ការចេញមុខជំនួសរបស់ ម៉ាទិនេស ធ្វើឲ្យ យ្យូលី អួលដើម.ក ឈាមផ្លាយចេញពីបេះដូង។

"បើជាតម្រូវការរបស់បង ម៉ាត ខ្ញុំក៏គ្មានសិទ្ធិមិនពេញចិត្ត ខ្ញុំទៅហើយ"

នាងចាប់កង់រទេះបង្វិលចេញដោយការតូចចិត្ត ដោយមាន ម៉ាទិនេស ដើរតាម។

"ប្រញាប់ឡើងមកលើបែបនេះ អ្នកជំនាញ គីម មិនថាអីទេឬ?"

នាងក្រមុំឈប់បង្វិលកង់រទេះ។

"មិនពាក់ព័ន្ធនឹងអ្នកជំនាញ គីម ទេ"

"បងម៉េចនឹងដឹង យើញស្និទ្ធស្នាលគ្នា" គេបញ្ឈឺ ដោយព្យាយាមទប់ចិត្តប្រចណ្ឌ "ល្ងាចនេះ សាស្ត្រាចារ្យ គីម នៅញ៉ាំបាយជាមួយយើង"

"ចាំ" នាងតបតែមួយម៉ាត់ ហើយចាប់កង់រទេះ ដើម្បីបង្វិលបន្ត តែត្រូវគេដើរមកពាំងមុខ។

"អូនគួរបបួលអ្នកជំនាញ គីម ដែរ ឲ្យបាននៅជុំគ្នា"

ស្វាមីភរិយាថ្មោងថ្មីមើលមុខគ្នា ភាពមួហ្មងសាយភាយជុំវិញខ្លួន។

"មែនហ្នឹង ស្ដាយដល់ហើយដែលអ្នកជំនាញ គីម ត្រឡប់ទៅវិញហើយ មិនអីចឹងបាននៅញ៉ាំបាយជាមួយគ្នាបាត់" នាងខាំធ្មេញនិយាយ ហើយសម្លឹងភ្នែករបស់គេ "ចៀសចេញ ខ្ញុំទៅកន្លែងផ្សេង"

គេខាំថ្គាមណែន ហើយចៀសផ្លូវឲ្យភរិយានិងឈរមើលនាងបង្វិលកង់រទេះចេញទៅទាល់តែបាត់ពីភ្នែក។

"ត្រង់បង អូនមិនចង់និយាយរក"



ការមួម៉ៅដែលមានមេភ្លើងជាការប្រចណ្ឌហួងហែង ធ្វើឲ្យទ្រូងសឹងតែផ្ទុះទៅហើយ។

ឆ្កួតមែន ហេតុអីគេត្រូវមកប្រចណ្ឌប្រពន្ធខ្លួនឯងបែបនេះ!

អ្នកកំលោះគិតនៅក្នុងចិត្តដោយកំហឹង ហើយដើរទៅឈរនៅរានហាលមើលទៅខាងក្រៅ ដើម្បីរម្ងាប់អារម្មណ៍ដែលកំពុងផ្ទុះ តែវាបែរជាមិនធូរស្រាលការប្រចណ្ឌហួងហែងនៅតែដំក្នុងទ្រូង។

**បរិយាកាសនៅក្នុងបន្ទប់អាហារមានតែភាពតានតឹង ព្រោះថ្ងៃនេះមាន** តែ ម៉ាទិនេស យ្យូលី និង ជីយ៉ន ប៉ុណ្ណោះដែលរួមតុអាហារ ចំណែក មេសាន់មិនបានមកចូលរួម ព្រោះជាប់វះកាត់។

"ឆ្អែតហើយអី លីលី?"

ពេលឃើញភរិយាដាក់សមស្លាបព្រាចុះ ទើបគេសួរដោយការងឿងឆ្ងល់ ព្រោះនាងទទួលទានបានតែបន្តិច។

"ចាំ សុំចេញមុនហើយ"

យ្យូលី មិនគិតថានៅចាំឲ្យ ម៉ាទិនេស និយាយអីដាក់ទៀត ប្រញាប់នាំខ្លួនឯងចេញពីបន្ទប់អាហារភ្លាម។

អ្នកកំលោះតាមមើលភរិយាដោយការព្រួយបារម្ភ តែត្រូវងាកទៅរក ជីយ៉ន ពេលនាងនិយាយ។

"មើលទៅលោកស្រី អ៊ីន មិនពេញចិត្តនឹងខ្ញុំដែលយកឈុតដេករបស់នាងមកពាក់"



"លីលី មិនមែនជាមនុស្សចិត្តចង្អៀត សាស្ត្រាចារ្យ គីម កុំគិតច្រើនអី"

ម៉ាទិនេស ទទួលទានអាហារបន្តដោយមិននិយាយអីទៀត ខណៈដែល



Scanned with CamScanner

ជីយ៉ន លួចញញឹម។

"ទោះលោកនាយកនិយាយបែបនេះ តែខ្ញុំក៏មិនសប្បាយចិត្តដដែល ខ្ញុំសុំទៅនិយាយជាមួយនាងមួយភ្លែត"

នាងដាក់សបស្លាបព្រាចុះភ្លាម ពេលនិយាយចប់។

"ខ្ញុំថាមិនបាច់ទេ"

"ត្រូវតែនិយាយ មិនអ៊ីចឹងខ្ញុំមិនសប្បាយចិត្តទេ"

ម៉ាទិនេស ព្រួសខ្យល់ដង្ហើមចេញតាមមាត់តិចៗ ហើយងក់ក្បាល។

"អ៊ីចឹងតាមចិត្តសាស្ត្រាចារ្យចុះ"

"អរគុណច្រើន អ៊ីចឹងខ្ញុំសុំទៅសិនហើយ"

ស្រីស្អាតញញឹមដាក់ម្ចាស់ផ្ទះហើយម្នីម្នាដើរចេញពីបន្ទប់ទទួលអាហារទៅតាម យ៉ូលី ទាល់តែទាន់។

"ម៉េចក៏ឆាប់ឆ្អែតម្ល៉េះ ឬថារើសអើងខ្ញុំ"

យ៉ូលី អួលដើម.ក ខាំធ្មេញដោយកំហឹង។

"ខ្ញុំមិនឃ្លាន ទើបឆ្អែត តែវាមិនពាក់ព័ន្ធនិងនាងទេ សាស្ត្រាចារ្យ គីម"

ជីយ៉ន ដើរវាងមកឈរទល់មុខម្ចាស់ផ្ទះ និងសម្លឹងមុខដោយខ្សែភ្នែកអ្នកឈ្នះ។

"ជើងរបស់លោកស្រី...ដើរមិនបានមែនឬ"

យ៉ូលី អួលដើម.កម្ដងទៀត និងសម្លឹងមុខអ្នកនៅទល់មុខដោយការមិនទុកចិត្ត គិតថាហេតុអ្វីក៏ស្រីម្នាក់នេះនិយាយរឿងនេះ។

"មែន ខ្ញុំដើរមិនបាន ជាមនុស្សខ្វិន ជើងពិការ នាងក៏ឃើញហើយតើនៅមកសួររកស្អីទៀត"

យ៉ូលី មើលទឹកមុខរបស់ ជីយ៉ន លម្អដោយស្នាមញញឹម ហាក់ដូចដឹងរឿងស្អីយ៉ាងអ៊ីចឹង។

"ដែលខ្ញុំសួរលោកស្រី ព្រោះត្រូវការឲ្យច្បាស់"

"វាមិនពាក់ព័ន្ធនឹងនាងទេ ហើយកុំម៉ោរញ៉េរញ៉ៃនឹងខ្ញុំទៀត"

យ៉ូលី ប្រកាស តែ ជីយ៉ន ញញឹមចម្អកនិងឱនមកជិត។

"មានទ្រឹស្ដីមួយនិយាយថា អាថ៌កំបាំងគ្មាននៅក្នុងលោក ប្រយ័ត្នទៅ"

"នាងចង់និយាយពីអ៊ី!" នាងក្រមុំមិនស្រួលចិត្តភ្លាម ដោយអ្នកដែលត្រូវសួរញាក់ស្មាបន្តិច។

"ខ្ញុំចេះតែនិយាយទៅៗ គ្មានអីទេ ទៅសិនហើយ"

ជីយ៉ន ដើរចូលទៅក្នុងផ្ទះ ទើប យ៉ូលី តាមមើលដោយការសង្ស័យ។

"នាងនេះនិយាយប្លែកៗ"

នាងក្រមុំដកដង្ហើមធំដោយចិត្តខ្វល់ខ្វាយ ហើយសម្រេចចិត្តទូរសព្ទទៅតេយ៉ុង។

(សួស្ដីលោកស្រី អ៊ីន)

"រឿងដែលខ្ញុំដើរបាន នៅតែជាអាថ៌កំបាំងរវាងខ្ញុំនិងលោក តើមែនទេអ្នកជំនាញ គីម?"

តេយ៉ុង ភាំងបន្តិច ហើយឆ្លើយតប៖

(បាទ មែន ខ្ញុំមិនបានប្រាប់អ្នកណាទេ លោកស្រីសប្បាយចិត្តចុះ)

ទោះ តេយ៉ុង និយាយបែបនេះក៏ដោយ ក៏នាងមិនសប្បាយចិត្តដដែល ព្រោះមានអារម្មណ៍ប្លែកៗនឹងសម្ដីរបស់ ជីយ៉ន។

"ខ្ញុំទើបតែដឹងនៅថ្ងៃនេះឯងថាអ្នកជំនាញ គីម និងសាស្ត្រាចារ្យ គីម ជីយ៉ន ជាបងប្អូននឹងគ្នា ការពិតលោកគួរតែប្រាប់ខ្ញុំមុននេះ"



(អ៊ឺ សុំទោស ខ្ញុំមិនដឹងថាលោកស្រីនិងបងស្រីខ្ញុំស្គាល់គ្នា សុំទោស

ម្តងទៀត )

"ខ្ញុំមិនប្រកាន់ខឹងអីទេ តែកុំរបូតមាត់និយាយរឿងដើងរបស់ខ្ញុំឲ្យបងស្រីលោកដឹងដាច់ខាត មិនអីចឹង យើងទាំងពីរផ្តាច់ទំនាក់ទំនងជាមិត្តភក្តិភ្លាម"

( បាទ ខ្ញុំសន្យា )

**យ្យូលី ដាក់ទូរសព្ទចុះទៅហើយ តែ តេយ៉ុង នៅតែឈរក្តាប់ទូរសព្ទ។** គេមិនសប្បាយចិត្ត ព្រោះខ្លួនឯងមិនអាចរក្សាសន្យាឲ្យនាងក្រមុំបាន។

"ខ្ញុំសុំទោសលោកស្រី អ៊ីន"

គេលើកដៃអង្អែលមុខខ្លួនឯងខ្លាំងៗដោយមានអារម្មណ៍ដឹងខុស។

"ខ្ញុំភ្លាត់បាត់ទៅហើយ"

គេដកដង្ហើមធំម្តងហើយម្តងទៀត ហើយសម្រេចចិត្តតេរទៅបងស្រីដើម្បីសុំការសន្យាម្តងទៀត។

"បង ជីយ៉ន"

( តេរម៉ោមានការអី ? )

"រឿងដែលបានសន្យានឹងខ្ញុំ សូមមេត្តាកុំនិយាយ" គេបញ្ជាក់បងស្រីម្តងទៀត។

( សន្យាហើយតើ ថាមិនប្រាប់លោកនាយក បងមិនធ្វើខុសពាក្យសន្យានឹងឯងទេ កុំបារម្ភ )

"បាទ...អរគុណ"

ពេលបញ្ចប់ការសន្ទនាតាមទូរសព្ទនឹងបងស្រីម្តាយទីទៃហើយ តេយ៉ុងក៏ដកដង្ហើមធំ ដោយសង្ឃឹមថា ជីយ៉ន នឹងរក្សាសន្យាឲ្យខ្លួន។



# ៩

**ពីរសប្តាហ៍ក្រោយមក ភាពសោះអង្គើយរវាង យ្យូលី និង ម៉ាទិនេស** នៅតែមាន។ ពួកគេបញ្ឈឺគ្នាដោយសង្គ្រាមត្រជាក់ និងការឈឺចាប់រៀងខ្លួន។

"យប់នេះ បងធ្វើខួបកំណើតឲ្យអូន លីលី" ម៉ាទិនេស និយាយ បន្ទាប់ពីបន្ទប់អាហារស្ងប់ស្ងាត់យ៉ាងយូរ ទើប យ្យូលី ងើយមុខមើលគេ និងប្រឹងញញឹមដាក់។

"អរគុណ តែខ្ញុំមិនរំខានបងទេ"

"មិនរំខានអីទេ បងពេញចិត្តធ្វើឲ្យ" គេសើចញឹមៗដោយកែវភ្នែកត្រជាក់ "អូនកុំភ្លេចអញ្ជើញអ្នកជំនាញ គីម មកចូលរួមផង"

នាងក្រមុំខ្ទឹបមាត់ ងាកមុខចេញ មិនមើលគេ។

"បង ម៉ាត កុំភ្លេចអញ្ជើញសាស្ត្រាចារ្យ គីម ម៉ោផង កុំឲ្យអផ្សុក"

"បើនាងទំនេរ បងនឹងអញ្ជើញ" គេតបដោយសំឡេងរាបស្មើ និងដាក់សមស្លាបព្រាចុះ ហើយងើបឈរ។

"លោក ម៉ាត ទៅធ្វើការហើយឬ ?" ហុងស៊ុល ដែលឈរចាំបម្រើ យ្យូលី សួរអ្នកកំលោះ។

"អ្ហឹម ថ្ងៃនេះមានប្រជុំមុនចូលបង្រៀន"

និយាយហើយ ម៉ាទិនេស ក៏ដើរចេញពីបន្ទប់អាហារ ដោយមិនងាកទៅលាភរិយាមួយម៉ាត់ ដែលធ្វើឲ្យ យ្យូលី រលីងរលោងទឹកភ្នែក និងប្រឹងលាក់អារម្មណ៍។



"ហុងស៊ីល..."

"ចាំ អ្នកនាង"

"ខ្ញុំឆ្អែតហើយ នាំខ្ញុំទៅតែងខ្លួននៅបន្ទប់បន្តិច"

"តែងខ្លួន ?" ហុងស៊ីល សួរដោយការសង្ស័យ។

"ថ្ងៃនេះខ្ញុំទៅគេងជាមួយម៉ាក់"

ទឹកមុខរបស់ ហុងស៊ីល មិនសូវល្អ ពេលឮបែបនេះ។

"អឺ...មិនប្រាប់លោក ម៉ាត ទេឬ ?"

នាងក្រមុំញញឹមចម្អកខ្លួនឯង។

"ខ្ញុំនៅឬមិននៅ ក៏គេមិនចាប់អារម្មណ៍ រាល់ថ្ងៃនេះខ្ញុំមិនធ្លាប់មានរូបរាងសម្រាប់គេស្រាប់ហើយ បងក៏ឃើញ"

"អ្នកនាងគិតច្រើនពេកហើយ"

"បងមិនមែនជាខ្ញុំ បងមិនដឹងទេ"

រាល់យប់គេដេកបែរខ្នងដាក់នាង និងមិនធ្លាប់ឱបថើបដូចកាលមុនៗ ធ្វើឲ្យនាងដេកយំដោយការតូចចិត្តរាល់យប់។

"ព្រះអើយ! អ្នកនាង"

យ៉ូលី ដកដង្ហើមចូលឲ្យពេញសួត។

"នាំខ្ញុំទៅបន្ទប់ទៅ ខ្ញុំប្រញាប់ផ្លាស់ខោអាវ នឹងបានទៅរកម៉ាក់"

"ចុះកម្មវិធីយប់នេះ ?"

"គ្មានខ្ញុំក៏មិនអីដែរ"

"តែ...ជាកម្មវិធីរបស់អ្នកនាង"

"ចាំខ្ញុំគេរប្រាប់បង ម៉ាត ថាមិនបាច់ធ្វើទេ ព្រោះខ្ញុំមិនម៉ោចូលរួម" នាងខាំធ្មេញនិយាយដោយការឈឺចាប់ "នាំខ្ញុំឡើងទៅផ្លាស់ខោអាវទៅ"



"អឺ ចាំ"

ហុងស៊ីល ចាំបាច់ត្រូវធ្វើតាមបញ្ជាដោយគ្មានជម្រើស នាំចៅហ្វាយស្រីឡើងទៅបន្ទប់ដេកវិញ។

ជីយ៉ន ញញឹមដូចតួអាក្រក់ក្នុងរឿង ពេលឱកាសបកស្រោមមុខរបស់យ៉ូលី បានមកដល់ ពេល ម៉ាទិនេស ចូលមកប្រាប់ថាថ្ងៃនេះរៀបចំខួបកំណើតឲ្យភរិយា បើនាងទំនេរ សុំអញ្ជើញឲ្យទៅចូលរួម ដែលប្រាកដណាស់ថានាងត្រូវតែទៅឲ្យបាន ទៅដើម្បីឲ្យ ម៉ាទិនេស ដឹងការពិតទាំងអស់។

"ថ្ងៃនេះ ឯងស្រេចផស់ខ្ញុំមិនខាន"

ជីយ៉ន ទាញទូរសព្ទទាក់ទងទៅប្អូនប្រុសភ្លាម។

"គេយ៉ុង ថ្ងៃនេះនៅផ្ទះលោកនាយករៀបចំខួបកំណើតឲ្យមីខ្ញិន ឯងដឹងហើយនៅ...អ្ហុំ ដឹងហើយអី អីចឹងល្អ ល្ងាចជួបគ្នា ធានាថាមានសិប្រាយស៍ដែលឯងស្មានមិនដល់"

ជីយ៉ន ចុចផ្តាច់ទូរសព្ទ បញ្ចប់ការសន្ទនា មិនខ្វល់ពីសំឡេងស្រែកហៅរបស់ប្អូនប្រុស។ នាងដាក់ទូរសព្ទទៅលើតុ ហើយគិតតែពីញញឹមញញែម។

"ចង់មើលមុខឯងដល់ហើយ ថាដោះសាយ៉ាងម៉េច!"

យ៉ូលី ងាកមុខចេញពេល ម៉ាទិនេស មករកដល់ផ្ទះរបស់ម្តាយ។ នាងខាំធ្មេញ ទប់អារម្មណ៍តូចចិត្តតូចថ្លើមអស់ពីសមត្ថភាព។

"បងម៉ោយកអូនទៅផ្ទះរបស់យើង"

នាងបង្វិលកង់រទេះចេញ តែត្រូវគេដើរមកពាំងមុខ ទើបងាកទៅរកជំនួយ។



"ហុងស៊ីល...នាំខ្ញុំទៅបន្ទប់តិច"

ម៉ាទិនេស ងាកទៅសម្លឹងមុខ ហុងស៊ីល ដោយខ្សែភ្នែកកាច។

"នាងមានអីធ្វើក៏ទៅធ្វើទៅ ចាំខ្ញុំមើលថៃ លីលី"

"អឺ..."

"ទៅចុះ" គេបញ្ជាក់ម្តងទៀត ទើប ហុងស៊ីល គ្មានជម្រើស។

"អ្នកនាង ខ្ញុំទៅសិនហើយ"

"ហុង...ហុងស៊ីល ទៅណា នាំខ្ញុំទៅផង"

យ៉ូលី ស្រែកឡូឡាបានមួយភ្លែត ក៏ត្រូវស្វាមីគ្រហឹមដាក់។

"បើមិនឈប់ឡូឡា បងនឹងចាប់ថើប"

"បង ម៉ាត!"

នាងក្រមុំលើកដៃបិទមាត់របស់ខ្លួនជាបន្ទាន់ ចំណែក ម៉ាទិនេស ក៏សើចហ៊ិៗដូចតួខូចក្នុងរឿងកុន។

"បើបងធ្វើ ទោះយកមេសោមកចាក់មាត់ ក៏បញ្ឈប់បងមិនបានដែរ យ៉ូលី"

មុខរបស់អ្នកដែលត្រូវគំរាមទៅជាក្រហមង៉ាំង។

"បង...ម៉ាត មានការអីនិយាយជាមួយខ្ញុំក៏និយាយម៉ោ ខ្ញុំនឹងបានទៅសម្រាក"

"បងគ្មានអីនិយាយជាមួយអូនទេ តែបងត្រូវនាំអូនទៅផ្ទះ"

"ខ្ញុំនៅគេងជាមួយម៉ាក់!"

"ថ្ងៃផ្សេងក៏បាន តែមិនមែនថ្ងៃនេះ"

សំឡេងរបស់ ម៉ាទិនេស ដាច់ខាត ដោយនាងមិនធ្លាប់ឮ ទើបងើយមើលមុខរបស់គេ ឃើញថាមុខសង្ហាគ្មានអារម្មណ៍អីឲ្យឃើញ តែទោះដូច្នោះក៏អាចដៅអារម្មណ៍បានមិនលំបាកថាគេកំពុងតែមានការមិនពេញចិត្តប៉ុនណា។

"តែខ្ញុំចង់គេងជាមួយម៉ាក់ យប់នេះ!"

"បងប្រាប់តាំងពីព្រឹកម្ល៉េះថាយប់នេះធ្វើខួបកំណើតឲ្យអូន ឬខួរក្បាលមានបញ្ហា ចាំមិនបាន"

នាងក្រមុំពើងថ្ពាល់ សម្លឹងមុខគេ។

"ខ្ញុំចាំបាន តែខ្ញុំមិនត្រូវការ ច្បាស់ទេ!"

"ច្បាស់! តែបងមិនស្តាប់ យ៉ាងណាក៏អូនត្រូវទៅផ្ទះជាមួយបង អូនជាម្ចាស់កម្មវិធី ចាំទុក!"

"តែខ្ញុំមិនចង់ទៅ"

"អូនគ្មានជម្រើសផ្សេងទេ"

ម៉ាទិនេស សើចញឹមៗ និយាយយ៉ាងសុភាព តែខ្សែភ្នែកដែលមើលមកគួរឲ្យខ្លាចមែនទែន ហើយពេលនិយាយចប់ក៏លើកនាងបី។

"បង ម៉ាត ចង់ធ្វើអី!"

"នាំអូនទៅផ្ទះវិញ"

"ខ្ញុំទៅខ្លួនឯងបាន"

"បងម៉ោហើយ ម៉េចចាំបាច់ទៅវិញខ្លួនឯង"

គេបីនាងដើរសំដៅរថយន្តទំនើប ដោយមានអ្នកបម្រើបើកទ្វារឲ្យដោយដឹងតួនាទី ហើយដាក់នាងទៅក្នុងនោះថ្នមៗ។

"មិនបាច់បារម្ភពី ហុងស៊ីល ទេ បងឲ្យអ្នកផ្ទះមកយកហើយ"

"បង ម៉ាត ផ្តាច់ការ"

គេមិនឆ្លើយ គិតតែញញឹម ពេលដើរវាងទៅឡើងខាងចង្កូត។

"លើកក្រោយបើរឹងទៀត បងមិនចិត្តល្អបែបនេះទេ"



នាងជ្រួញច្រមុះដាក់គេដោយការជិនឆ្អន់។

"នេះចិត្តល្អហើយឬ!"

"ចិត្តល្អលើសផង"

គេសើចហ៊ឹៗ ហើយបញ្ជារថយន្តទំនើបចេញពីផ្ទះរបស់នាង។

*មនុស្សឆ្កួត គិតថានាងជាតុក្កតាឬយ៉ាងម៉េច ចង់ចាប់ធ្វើអីក៏បាន!*

នាងក្រមុំគិតដោយការតូចចិត្ត និងអង្គុយស្ងៀម មិនមាត់មិន.ក។

**"អ្នកនាង ងើបធ្វើអី តិចលោក ម៉ាត ចូលម៉ោឃើញ"**

ហុងស៊ីល ដែលដើរចូលមកក្នុងបន្ទប់ដេករបស់ចៅហ្វាយ ឧទានដោយការភ្ញាក់ផ្អើល ពេលឃើញនាងក្រមុំងើបពីរទេះរុញ ហើយដើរទៅបង្វិលខ្លួននៅមុខកញ្ចក់ធំ ទើប យូលី ងាកទៅញញឹមដាក់អ្នកមើលថែផ្ទាល់ខ្លួន។

"ខ្ញុំចង់ដឹងហ្នឹងណា៎ ថាឈុតនេះពាក់ទៅស្អាតទេ"

**"អ្នកនាងពាក់ឈុតអីក៏ស្អាតដែរ"**

ហុងស៊ីល ម្នីម្នាដើរទៅដឹកដៃចៅហ្វាយ មកអង្គុយលើរទេះរុញវិញ។

"តែអ្នកនាងត្រូវប្រយ័ត្នខ្លួន បើលោក ម៉ាត ចូលមកឃើញ ច្បាស់ជាមានរឿងធំមិនខាន"

"អរគុណ ហុងស៊ីល តែបង ម៉ាត មិនឡើងម៉ោទេ" នាងធ្វើមុខក្រមូវដោយការមិនពេញចិត្ត "ថ្មើរណេះបែបកំពុងផ្អែមល្ហែមជាមួយស្រីរបស់គេ"

"លោក ម៉ាត ជាសុភាពបុរស អ្នកណាមកនិយាយរក ក៏ត្រូវនិយាយជាមួយតាមមារយាទ"

"ត្រង់ខ្ញុំ មិនឃើញគេចង់និយាយរក" នាងនិយាយដោយការតូចចិត្ត។

"កុំនិយាយអីចឹងអីអ្នកនាង កុំធ្វើមុខក្រមូវ ថ្ងៃនេះខួបកំណើតអ្នកនាងត្រូវតែញញឹម"



"តែខ្ញុំមិនចង់ឲ្យគេរៀបចំ ចង់នៅផ្ទះញុំាបាយជាមួយម៉ាក់ជាង"

"ថ្ងៃនេះទៅលេងហើយតើ ស្អែកចាំខ្ញុំជូនអ្នកនាងទៅរកគាត់ទៀត"

យូលី ងក់ក្បាល ព្រោះគ្មានជម្រើស ហើយងើយមុខមើល ហុងស៊ីល។

"អ្នកជំនាញ គីម ម៉ោហើយនៅ?"

"ម៉ោហើយ ខ្ញុំឃើញពេលឡើងម៉ោ"

នាងក្រមញញឹមសោកសៅ។

"គេប្រាប់ខ្ញុំថា បើធ្វើជាស្និទ្ធស្នាលនឹងគេ បង ម៉ាត អាចប្រចណ្ឌខ្លះ តែធ្វើយូរហើយ មិនឃើញបង ម៉ាត បង្ហាញអាការៈអី ព្រោះបង ម៉ាត មិនធ្លាប់មានអារម្មណ៍អីចំពោះខ្ញុំ"

"កុំនិយាយបែបនេះអីអ្នកនាង កុំគិតច្រើនបែបនេះ យ៉ាងណាក៏អ្នកនាងមានឈ្មោះជាភរិយាស្របច្បាប់របស់លោក ម៉ាត យ៉ាងណាក៏មានសិទ្ធិចំពោះគាត់ជាងស្រីទាំងឡាយនៅលើលោកនេះ"

នាងដឹងថា ហុងស៊ីល ព្យាយាមលួងលោម តែវាបែរជាមិនធ្វើឲ្យនាងមានអារម្មណ៍ល្អ។

"ប្រពន្ធស្របច្បាប់...ប្រពន្ធដែលដេកឱបក្រដាសមួយសន្លឹក តែគ្មានសិទ្ធិបានឱបប្ដីខ្លួនឯង"

"កុំគិតច្រើនអីអ្នកនាង គ្រប់យ៉ាងនឹងប្រសើរឡើងឆាប់ៗនេះ"

នាងក្រមុំធ្វើបានត្រឹមតែញញឹមសោកសៅប៉ុណ្ណោះ។

"បងនាំខ្ញុំទៅខាងក្រោមទៅ កុំឲ្យគេឯងចាំយូរ"

"ខ្ញុំថាអ្នកនាងថែមគ្រែមមាត់បន្តិច ល្អទេ"

យូលី គ្រវីក្បាល។



"លាបពណ៌ផ្កាឈូកខ្ចីតិចៗទៅបានហើយ ខ្ញុំមិនចូលចិត្តពណ៌ឈាមដូចស្រីចំពុះក្រហម"

"អីចឹង...តាមចិត្តអ្នកនាង"

នាងក្រមុំប្រឹងញញឹមម្តងទៀត តែកែវភ្នែកមានតែភាពសោកសៅ គ្មានភាពរីករាយអីឲ្យឃើញ។

ហុងស៊ីល រញ្ជរទេះនាំចៅហ្វាយចុះទៅជាន់ក្រោម សំដៅកន្លែងរៀបចំពិធី ដែលជាទីធ្លាធំទូលាយនៅអាងហែលទឹក។

កន្លែងរៀបចំពិធីត្រូវបានរៀបចំស្អាត ភ្លើងពណ៌ផ្លេកៗត្រូវបំពាក់តាមសសរនិងដើមឈើ ឲ្យម្ចាស់ខួបកំណើតញញឹមដោយការចូលចិត្ត និងរាក់ទាក់ តេយ៉ុង ដែលកាន់កែវទឹកក្រូចមកហុចឲ្យ។

"រីករាយថ្ងៃកំណើត លោកស្រី អ៊ីន"

ឃ្យូលី យកកែវទឹកក្រូចមកកាន់ និងញញឹមដាក់គេ។

"អរគុណអ្នកជំនាញ គីម រីករាយដែលលោកម៉ោ"

"ខ្ញុំត្រូវតែម៉ោហើយ ថ្ងៃកំណើតរបស់លោកស្រីទាំងមូល"

"អ្នកនាង ទៅរកលោក ម៉ាត ទៅ"

ហុងស៊ីល មិនចូលចិត្តឲ្យចៅហ្វាយរបស់ខ្លួនស្និទ្ធស្នាលនឹង តេយ៉ុង ទើបបបួល តែ ឃ្យូលី ដែលងាកទៅឃើញស្វាមីរបស់ខ្លួនត្រូវស្រីៗចោមរោមក៏និយាយដោយការតូចចិត្ត។

"ឲ្យខ្ញុំទៅរំខានសេចក្តីសុខរបស់គេធ្វើអី"

"តែលោក ម៉ាត កំពុងរង់ចាំអ្នកនាង"

"ចាំខ្ញុំ..." នាងសើចចម្អកខ្លួនឯង "តែតាមដែលឃើញ បង ម៉ាត គួរតែភ្លេចទៅហើយថាមានខ្ញុំជាប្រពន្ធរបស់គេ"



"កុំគិតបែបនេះ អ្នកនាង តោះទៅ ខ្ញុំនាំទៅ"

ហុងស៊ីល នាំចៅហ្វាយទៅរក ម៉ាទិនេស ដោយមាន តេយ៉ុង ដើរតាម។

"លោក ម៉ាត អ្នកនាងម៉ោហើយ"

ម៉ាទិនេស ដែលត្រូវចោមរោមដោយនិស្សិតនិងសាស្ត្រាចារ្យស្រីៗ ងាកមើលមក ហើយញញឹមពព្រាយ និងដើរមករកភរិយា តែពេលឃើញ តេយ៉ុង នៅក្រោយខ្នង ក៏បិទស្នាមញញឹមភ្លាម។

"បងប្រុងឡើងទៅតាមអូនល្មម"

"បងចង់ថាខ្ញុំចុះម៉ោយឺត មែនទេ" នាងត្បកសួរដោយសំឡេងរឹងកំព្រឹស ហើយនិយាយបន្តដោយការតូចចិត្ត ដោយមិនឲ្យគេបាននិយាយទាន់ "ខ្ញុំម៉េចនឹងអាចធ្វើអីរហ័សរហួនដូចអ្នកមានជើងល្អធម្មតាបានទៅ"

"លីលី កុំនិយាយបែបនេះអី បងមិនទាន់បានថាអីឲ្យអូនផង"

នាងខ្ទីបមាត់ ព្រិចភ្នែកញាប់ស្អេក ដើម្បីបណ្តេញទឹកភ្នែក។

"ចង់ឲ្យខ្ញុំធ្វើអី ឆាប់ប្រាប់ម៉ោ ខ្ញុំនឹងបានធ្វើឲ្យរួចរាល់"

អ្នកកំលោះលុតជង្គង់នៅចំពោះមុខភរិយា ហើយណែនាំឲ្យនាងស្គាល់និស្សិតនិងកូនចៅនៅមហាវិទ្យាល័យរបស់ខ្លួន ទើប ឃ្យូលី បង្ខំចិត្តញញឹមដាក់ព្រោះគ្មានចិត្តរាក់ទាក់អ្នកណានោះឯង។

ហើយពេលណែនាំរួចរាល់ គេក៏នាំនាងទៅតុមួយដែលត្រូវរៀបចំស្អាតជាពិសេស។

"អូនឃ្លានហើយនៅ បងទៅដួសនំឲ្យ"

"ខ្ញុំមើលថែខ្លួនឯងបាន បងទៅនិយាយជាមួយមិត្តភក្តិបងទៅ"

"បងចង់មើលថែអូន"

នាងងើបភ្នែកមើលគេ កំពុងតែទន់ចិត្តហើយ តែត្រូវ ជីយ៉ន ចូលមក



ជ្រែក។

"លោកនាយកគេចមកនៅត្រង់នេះឯង ខ្ញុំខំតាមរក"

នាងក្រមុំខ្ពឹបមាត់ដោយកំហឹង។

"មើលទៅបង ម៉ាត មិនទំនេរទេ អញ្ជើញតាមសម្រួលទៅ ខ្ញុំនៅជាមួយ ហុងស៊ុល បាន"

ខណៈនោះឯងដែល តេយ៉ុង កាន់ចាននំមកដាក់លើតុល្មម។

"ចាំខ្ញុំមើលថៃលោកស្រីឲ្យ"

ម៉ាទិនេស ងាកទៅមើល តេយ៉ុង ដោយការមិនពេញចិត្ត តែមិនទាន់បាននិយាយអីផង ក៏ត្រូវភរិយានិយាយកាត់។

"បង ម៉ាត តាមសម្រួលចុះ ខ្ញុំមានអ្នកមើលថៃហើយ"

អ្នកកំលោះខាំថ្គាមណែន តែទឹកមុខនៅតែរាបស្មើនិងសុភាពដដែល។

"អីចឹងបងអស់បារម្ភហើយ តោះសាស្ត្រាចារ្យ គីម"

ជីយ៉ន ញញឹមព្រាយដោយការសប្បាយចិត្ត ហើយម្ចីម្នាដើរតាមម្ចាស់ផ្ទះ តែពេលដើរចេញទៅនោះ ក៏ងាកមកមិចភ្នែកជាការបេះបួយដាក់ យ៉ូលី។

"អ្នកនាង មើលស្រីចំពុះក្រហមចុះ" ហុងស៊ុល អត់មិនបាននឹងនិយាយប្រាប់ចៅហ្វាយ។

"តាមតែគេទៅ ខ្ញុំមិនចង់ចាប់អារម្មណ៍អីទេ"

និយាយហើយ នាងក៏ជូសនំដែល តេយ៉ុង ជូសឲ្យទទួលទាន ដោយលេបទាំងទឹកភ្នែក ខណៈដែល តេយ៉ុង ជកជង្គើមធំដោយអារម្មណ៍ដឹងខុស។

"សុំទោសជំនួសបងស្រីខ្ញុំផង"

យ៉ូលី ដឹងច្រើនថ្ងៃហើយថា តេយ៉ុង ជាប្អូនប្រុសម្តាយទីទៃរបស់ ជីយ៉ន ទើបប្រឹងញញឹមដាក់គេ។



"មិនអីទេ បងស្រីលោកមិនបានធ្វើអីខ្ញុំផង"

"មិនបានធ្វើបាបរាងកាយ តែធ្វើបាបចិត្តអ្នកនាង" ហុងស៊ុល និយាយដោយការជិនឆ្អន់ ហើយអត់មិនបាននឹងស្តីឲ្យ តេយ៉ុង "លោកគួរតែដាស់តឿនបងស្រីខ្លួនឯងផង ថាកុំទាក់ទងប្តីគេ"

"ខ្ញុំសុំទោស"

"កុំអីចឹងអីបង អ្នកជំនាញ គីម មិនដឹងអីទេ" យ៉ូលី នៅតែចាត់ទុកគេជាមនុស្សល្អ។

"ឲ្យតែមិនដឹងមែន"

តេយ៉ុង នៅស្ងៀម មានតែការមិនសប្បាយចិត្ត ព្រោះម្នាក់ជាបងស្រីមានគុណចំពោះខ្លួន ម្នាក់ទៀតជាស្រីដែលខ្លួនលួចស្រឡាញ់។

មិនប៉ុន្មាននាទីទៀតដល់ម៉ោងផ្លុំទៀនថ្ងៃកំណើតហើយ ទើប ហុងស៊ុល ត្រូវហៅឲ្យទៅជួយរៀបចំតុខេក ចំណែក តេយ៉ុង សុំចូលបន្ទប់ទឹក។

យ៉ូលី អង្គុយកណ្តោចកណ្តែងតែម្នាក់ឯងនៅតុមាត់អាង ជូសខេកដុំទីប្រាំទទួលទានជិតអស់មួយដុំទៀតទៅហើយ ខណៈនោះក៏មើលទៅ ម៉ាទិនេស ដែលនៅតែនិយាយលេងជាមួយសាស្ត្រាចារ្យប្រុសស្រី ដោយការតូចចិត្ត។

"ពេលប្រាប់ថាឲ្យទៅក៏ទៅ មិនឆ្លៀតម៉ោមើលប្រពន្ធមើលអីសោះ"

"តូចចិត្តនឹងប្តីឬ"

សំឡេងស្រួចរលែម តែព្មខ្សឹបៗរបស់ ជីយ៉ន បន្លឺឡើងនៅក្បែរខ្លួន ទើប យ៉ូលី ខ្ពឹបមាត់ និងងាកទៅសម្លឹងមុខដោយការមិនពេញចិត្ត។

"បង ម៉ាត មិននៅទីនេះទេ ទៅរកកន្លែងផ្សេងទៅ"

"ខ្ញុំមិនបានម៉ោរកលោកនាយកផង"



នាងក្រមុំពើងទ្រូងដាក់ដៃគូសន្ទនា។

"កុំប្រាប់ណាថាកើតចិត្តចង់និយាយជាមួយខ្ញុំ"

"អាចមែន" ជីយ៉ន សើចដូចត្មស្រីអាក្រក់។

"តែខ្ញុំមិនចង់និយាយនឹងមនុស្សអសីលធម៌ដូចនាងទេ"

"ម៉េចក៏ថាឲ្យខ្ញុំបែបនេះ ខ្ញុំធ្វើអីខុសឬ" ជីយ៉ន បេះបួយ។

"ដឹងច្បាស់ហើយនៅម៉ោសួរទៀត ចេញឲ្យឆ្ងាយពីមុខខ្ញុំទៅ ខ្ញុំមិនចង់និយាយជាមួយនាងទេ"

"ខ្ញុំក៏មិនចង់និយាយជាមួយនាងដែរ លោកស្រី អ៊ីន"

"ហើយម៉ោរកខ្ញុំធ្វើស្អី!"

"ដែលខ្ញុំម៉ោរកនេះ..." ជីយ៉ន ពេបមាត់ដាក់ "ព្រោះចង់ម៉ោតឿនដោយបំណងល្អប៉ុណ្ណោះ"

"ទុកបំណងល្អគំនិតរបស់អាក្រក់របស់នាងប្រើខ្លួនឯងទៅ ខ្ញុំមិនត្រូវការចៀសចេញ ខ្ញុំទៅកន្លែងផ្សេង"

យ្យូលី មានអារម្មណ៍មិនស្រួលចិត្តដោយមិនដឹងមូលហេតុ ទើបបង្វិលកង់រទេះរុញតាមផ្លូវមាត់អាង ដើម្បីចេញឲ្យផុតពីទីនេះ។

"ប្រយ័ត្នធ្លាក់ទឹក"

យ្យូលី ផ្អាកបង្វិលកង់រទេះ ហើយឈ្ងោកមើលកង់រទេះ ឃើញថាវានៅជិតមាត់អាងពេកហើយ។

"បើធ្លាក់ តើធ្វើម៉េច ជើងខ្វិនបែបនេះ ច្បាស់ជាលង់ទឹកស្លាប់មិនខាន"

ជីយ៉ន សើចក្អាកក្អាយ ពេលដើរមកឈរជិតរទេះរុញរបស់ យ្យូលី។

"ចេញឲ្យឆ្ងាយពីខ្ញុំទៅ!"

"ចាំខ្ញុំជួយ កុំឲ្យធ្លាក់ទឹក"



"មិនបាច់ កុំម៉ោចេះ ចេញឲ្យឆ្ងាយទៅ!"

យ្យូលី រុញស្រីចិត្តបិសាចមួយទំហឹង តែ ជីយ៉ន មិនព្រមថយ។

"ប្រាប់ថាឲ្យចេញទៅ កុំម៉ោជិតខ្ញុំ!"

"ឲ្យខ្ញុំជួយទៅ នេះកង់វិះតែធ្លាក់អាងទៅហើយ"

ជីយ៉ន សើចហ៊ីៗ ហើយប្រាកដណាស់ថាអ្វីដែលធ្វើបន្ទាប់ពីនេះ គឺរុញទាំងរទេះ ទាំងមនុស្សទម្លាក់អាងទឹក។

គ្រាំ!!

"អ៉ា...ស្លាប់ហើយ លោកស្រី អ៊ីន ធ្លាក់ទឹក"

ជីយ៉ន ស្រែកខ្លាំងៗ ដែលប្រាកដណាស់ថាគ្រប់គ្នារត់ស្រូស្រមករក។

*ចាំមើលមើល៍ ថាឯងនឹងធ្វើយ៉ាងម៉េច តើទ្រាំធ្វើខ្វិនបន្តដែរទេ!*

ជីយ៉ន គិតដោយការពេញចិត្ត ខណៈនោះក៏មើល យ្យូលី ដែលកំពុងតែលិចទៅក្នុងទឹក។

*យ៉ាងណាក៏ឯងត្រូវតែហែលទឹក ហើយលោកនាយកក៏ត្រូវតែដឹងថាឯងកុហករឿងជើងខ្វិន មីខ្វិនក្លែងក្លាយ!*

"លីលី!"

ម៉ាទិនេស ភ័យស្ទើរតែស្លុតទៅហើយ ពេលឃើញទាំងរទេះទាំងភរិយាលិចទៅក្នុងទឹក ហើយពេលនេះគេគិតអីមិនចេញ ក្រៅពីហក់ទៅក្នុងអាងហែលទៅជួយនាង។

"លីលី...លីលី មិនអីទេ"

គេមិនធ្លាប់ខ្លាចដល់ថ្នាក់នេះទេ គេបារម្ភពី យ្យូលី ខ្លាចនាងគ្រោះថ្នាក់។ មិនយូរប៉ុន្មានរាងកាយរបស់ យ្យូលី ត្រូវបីមកដាក់នៅមាត់អាង ហើយម៉ាទិនេស ក៏ជួយធ្វើស៊ីភីអឲ្យភរិយាទាល់តែដឹងខ្លួន។



"លីលី...លីលី ដឹងខ្លួនហើយ"

អ្នកកំលោះជូតទឹកចេញពីមុខរបស់ភរិយា ហើយទាញនាងមកឱបជាប់ដើមទ្រូង។

"អស់អីហើយ លីលី បងនៅទីនេះហើយ"

"អ្នកនាង...ខ្ញុំសុំទោស...ដែលមើលថែអ្នកនាងមិនបានល្អ"

ហុងស៊ីល ស្ទុះមកចាប់ដៃត្រជាក់ស្រេងរបស់ចៅហ្វាយស្រី យំរៀបរាប់ដោយការអៀសចិត្ត។

"មិនមែនជាកំហុសរបស់បងទេ ហុងស៊ីល"

ម៉ាទិនេស លើកបីភរិយា ហើយងើបឈរ។

"ខ្ញុំសុំទោសអ្នកទាំងអស់គ្នាផង កម្មវិធីថ្ងៃនេះត្រូវបញ្ចប់ត្រឹមនេះហើយ ហុងស៊ីល ជួយជូនដំណើរភ្ញៀវផង"

"ចាំ លោក ម៉ាត"

ពេល ម៉ាទិនេស បីភរិយាដើរចូលទៅក្នុងផ្ទះហើយ ទើប ហុងស៊ីល ធ្វើការតាមបញ្ជារបស់ចៅហ្វាយ ដែលពេលនោះ មេសាន់ ក៏ត្រឡប់មកពីធ្វើការល្ងាច ឃើញហេតុការណ៍ ទើបសួរនាំ។

"កម្មវិធីចប់ហើយឬ ហុងស៊ីល ?"

"មិនទាន់បានផ្ដុំខេកផងលោក ម៉ៃ តែមានរឿងកើតឡើង" ហុងស៊ីល ប្រាប់តាមត្រង់។

"មានរឿងអី ?" មេសាន់ ចងចិញ្ចើមសួរ។

"អ្នកនាងធ្លាក់ទឹក មិនដឹងកើតអីបានធ្លាក់"

"អា! ហើយកើតអីធ្ងន់ធ្ងរឬអត់ ពេលនេះនៅឯណា ?" មេសាន់ សួររកបងថ្លៃស្រីច្បងដោយការព្រួយបារម្ភ។



"អស់អីហើយ លោក ម៉ាត នាំទៅបន្ទប់ហើយ"

"អូខេ អីចឹងនាងមើលខុសត្រូវរបៀបរៀបរយនៅខាងក្រោមនេះ ខ្ញុំឡើងទៅមើលអាការៈ លីលី បន្តិច"

"ចាំ លោក ម៉ៃ"

មេសាន់ ម្នីម្នាដើរចូលទៅក្នុងផ្ទះ ឯ ហុងស៊ីល ធ្វើការរបស់ខ្លួនបន្ត ពេលរួចរាល់ក៏ឡើងទៅរកចៅហ្វាយរបស់ខ្លួនដោយការព្រួយបារម្ភ។

"ខ្ញុំសង្ស័យថាមិនមែនជាថ្ងៃដៃរបស់បង"

ពេលដើរមកដល់រថយន្ត តេយ៉ុង ក៏អត់មិនបាននឹងសួរបងស្រីដោយការសង្ស័យ។

"នែ! កុំម៉ោចោទបង គីម តេយ៉ុង"

"តែខ្ញុំឃើញបងឈរនិយាយជាមួយនាង មុនពេលនាងធ្លាក់ទឹក"

"ហើយវាពាក់ព័ន្ធអីនឹងបង បងគ្រាន់តែនិយាយតើ មិនបានរុញនាងធ្លាក់ទឹកផង ហើយម្យ៉ាងទៀត ជើងវាល្អតើ មានខ្វិនមែនទែនឯណា ធ្លាក់ទៅក៏មិនងាប់ដែរ"

និយាយហើយ នាងក៏ឆ្ងល់ថាហេតុអី យ៉ូលី មិនព្រមហែល ហេតុអីឲ្យខ្លួនឯងលង់ទឹកបែបនោះ។

"តែបងក៏ឃើញហើយតើថានាងវិះតែលង់ទឹក"

"នេះឯងឃើញវាល្អជាងបងឬ ទើបម៉ោជេរបងស្រីខ្លួនឯងបែបនេះ"

ការតវ៉ារបស់បងស្រី ធ្វើឲ្យ តេយ៉ុង ភ្ញាក់ស្មារតី។

"សុំទោស ខ្ញុំគ្រាន់តែសង្ស័យ..."

"នេះក្មួងក្មែកឯង បងអាក្រក់ដល់ម្ល៉ឹងផង"





Scanned with CamScanner

"មិនមែនទេបងស្រី ខ្ញុំ..."

"ឯងទៅផ្ទះទៅ បងក៏ទៅដែរ"

ជីយ៉ន ធ្វើមុខក្រមូវ និងម្ទីម្នាឡើងឡានរបស់ខ្លួន ដោយមិនខ្វល់ពីទឹកមុខរអៀសចិត្តរបស់ប្អូនប្រុសម្ដាយទីទៃ ហើយនៅក្នុងឡាន នាងក៏ខាំមាត់និយាយដោយការគុំកួន។

"មីខ្ទិន ម៉េចក៏ឯងល្បិចខ្ពស់ម្ល៉េះ ថ្នាក់ធ្លាក់ទឹកហើយ នៅតែមិនព្រមបញ្ចេញជាតុពិតទៀត ហើយនេះខ្ញុំធ្វើម៉េចទៅ ដើម្បីបកស្រោមមុខរបស់ឯង"

ស្រីស្អាតគិតចង់ផ្ទុះខួរទៅហើយនៅតែគិតមិនចេញ ទើបសម្រេចចិត្តថាគួរតែប្រាប់ការពិតដល់ ម៉ាទិនេស ត្រង់ៗ ដើម្បីឲ្យគេលែងលះ យ្យុលី។

"ស្អែកនេះខ្ញុំនឹងប្រាប់លោក...ប្រាប់ថាមីខ្ទិនប្រពន្ធជាទីស្រឡាញ់របស់លោក វាជាមនុស្សកុហកបោកប្រាស់"

ជីយ៉ន ញញឹមដោយការពេញចិត្ត ហើយបញ្ឆោរថយន្តចេញពីចំណតមុខភូមិគ្រឹះ ម៉ាឡេសាសស្វ។

តេយ៉ុង តាមមើលរថយន្តរបស់បងស្រីដែលបើកចេញទៅដោយការមិនសប្បាយចិត្ត។ ទោះបងស្រីបដិសេធ តែគេអាចស្មានបានថា ជីយ៉ន ត្រូវតែមានចំណែកធ្វើឲ្យភាពចលាចលនេះកើតឡើង។

"ខ្ញុំរអៀសចិត្តចំពោះលោកស្រីមែនទែន លោកស្រី អ៊ីន"

គេដកដង្ហើមធំ ហើយឡើងរថយន្តរបស់ខ្លួន បើកចេញទៅដែរ។

**យ្យុលី តាមមើលស្វាមីដែលដើរចេញពីបន្ទប់ដេកហើយទើបដកដង្ហើមធំ ធូរទ្រូងខ្សាកតែម្ដង។**

"វ៉ះតែមិនរួចខ្លួនទៅហើយ"



"អ្នកនាង ម៉េចក៏ធ្លាក់ទឹក?" ហុងស៊ីល ដែលលាក់ការសង្ស័យបានយូរទាល់តែ ម៉ាទិនេស និង មេសាន់ ចេញទៅក៏សួរនាំភ្លាម។

យ្យុលី ខាំមាត់ ទឹកមុខពោរពេញដោយកំហឹង។

"ស្រីចំពុះក្រហមរុញទម្លាក់"

"ឃើញទេ គិតអីចេះខុស" ហុងស៊ីល ខាំមាត់ "ចាំមើល ឃើញមុខពេលណា នឹងទះឲ្យផ្កាប់មុខ"

"បំភ្លេចចោលទៅ យ៉ាងណាក៏ខ្ញុំលែងអីទៅហើយ"

"អ្នកនាងព្រម តែខ្ញុំមិនព្រមទេ"

នាងក្រមុំនៅស្ងៀមមួយសន្ទុះ ទើបនិយាយ៖

"ខ្ញុំព្រមនៅស្ងៀមតែម្ដងប៉ុណ្ណោះ តែបើមានទៀត ខ្ញុំនឹងស៊ូស្លាប់"

ហុងស៊ីល ដកដង្ហើមធំ ស្រវាចាប់ដៃចៅហ្វាយមកក្ដោប។

"សំណាងល្អដែលលោក ម៉ាត មកជួយទាន់ មិនអីចឹងនាងអ្នកមិនដឹងយ៉ាងម៉េចយ៉ាងម៉ាទេ"

ហុងស៊ីល នៅតែភ័យមិនទាន់បាត់។

"នេះបើអ្នកនាងកើតអី ខ្ញុំធ្វើយ៉ាងម៉េចទៅ"

"ព្រះអើយ! ខ្ញុំមិនអីទេ បងក៏ដឹងថាខ្ញុំពូកែហែលទឹកសឹងស្លាប់"

"ខ្ញុំដឹង តែអ្នកនាងមិនព្រមហែលទឹក វ៉ះតែលង់ទៅហើយ"

"បើខ្ញុំហែល គ្រប់គ្នានឹងដឹងថាខ្ញុំមិនបានពិការ" នាងឲ្យហេតុផល។

"នេះអ្នកនាងព្រមដោះដូរអាថ៌កំបាំងនឹងជីវិតឬ"

"ខ្ញុំ...គ្រាន់តែមិនចង់ឲ្យអាថ៌កំបាំង ដែលខំបិទបាំងយូរហើយត្រូវលាតត្រដាងនៅពេលនេះ"



"ការពិត បើលោក ម៉ាត ដឹងថាអ្នកនាងដើរបាន គ្រប់យ៉ាងអាចនឹងល្អក៏

ថាបាន ខ្ញុំថាអ្នកនាងប្រាប់លោក ម៉ាត ទៅ"

យូលី គ្រវីក្បាលតិចៗ ប្រាប់ឲ្យដឹងថានៅមិនទាន់ព្រម។

"បងគិតថាបង ម៉ាត មិនខឹងឬ បើដឹងថាត្រូវបោកប្រាស់"

"តែ..."

"បងទៅសម្រាកចុះ ខ្ញុំដេកហើយ" នាងបញ្ចប់ការសន្ទនា ព្រោះមិនចង់និយាយអីទៀត។

ហុងស៊ុល ដកដង្ហើមធំ ទាញភួយដណ្ដប់ឲ្យចៅហ្វាយ ហើយនិយាយរាត្រីសួស្ដីដាក់ និងដើរចេញទៅ។

ទឹកមុខរបស់ យូលី ពេលនៅម្នាក់ឯងកាន់តែសោកសៅ បេះដូងមានតែការឈឺចាប់។

នាងមិនធ្លាប់មានអារម្មណ៍ល្អទេដែលត្រូវរស់នៅជាមួយការកុហក តែនាងគ្មានជម្រើស និងមិនអាចថយក្រោយបាន ដូច្នេះហើយមានតែត្រូវទ្រាំនៅជាមួយវាមួយជីវិត។

សំឡេងបើកទ្វារបន្ទប់ឡើង ម៉ាទិនេស ក៏ដើរមកដាក់បង្អួយនៅគែមគ្រែ។

"បាត់ភ័យហើយនៅ លីលី?"

សំឡេងពីរោះរបស់ ម៉ាទិនេស ធ្វើឲ្យបេះដូងរបស់ យូលី រីកមាឌ ទើបសើចញញឹមៗដាក់គេ។

"ខ្ញុំធូរហើយ អរគុណដែលចុះទៅជួយខ្ញុំ"

គេញញឹមដាក់ និងលើកដៃមកអង្អែលក្បាលនាងថ្នមៗ។

"វាជាតួនាទីរបស់បង ដែលត្រូវការពារប្រពន្ធខ្លួនឯង"

ថ្ពាល់របស់នាងឡើងក្រហម ពេលបានឮពាក្យថា ប្រពន្ធ ចេញពីមាត់របស់គេ ទើបខ្ទប់មាត់ និងងាកភ្នែកចេញ។



ម៉ាទិនេស លាក់ស្នាមញញឹម ហើយផ្ដួលខ្លួនដេកក្បែរ និងទាញនាងមកឱបជាប់ទ្រូង។

"បង ម៉ាត...លែងខ្ញុំទៅ"

"បងមិនធ្វើអីលើសពីឱបទេ"

អ្នកកំលោះនៅតែឱបនាងជាប់ទ្រូង ធ្វើឲ្យ យូលី ញញឹមទាំងទឹកភ្នែក ព្រោះជង្ហើយរកដើមទ្រូងកក់ក្ដៅរបស់ស្វាមីច្រើនរាត្រីហើយ។

"បង ម៉ាត មិនទៅដេកបន្ទប់បងទេឬ?"

កំលុងពេលធ្វើសង្គ្រាមត្រជាក់ដាក់គ្នា ម៉ាទិនេស តែងតែទៅដេកនៅបន្ទប់ផ្សេង។

"បងបារម្ភពីអូន មិនចង់ឲ្យបាត់ពីភ្នែកទៀតទេ" សម្ដីរបស់គេចេញពីបេះដូង។

"បង...បង ម៉ាត...បារម្ភពីខ្ញុំឬ?"

គេឱនមកផ្ដិបបបូរមាត់ក្ដៅនឹងថ្ពាសរបស់ភរិយា។

"អូនជាប្រពន្ធរបស់បង ម៉េចក៏ថាបងមិនបារម្ភ"

"តែ...បងមិនបាន..."

"មិនបានអីឬ?"

គេជ្រឹមភ្នែកមើលនាង ខណៈដែលនាងប្រឹងគេចភ្នែកពីគេ។

"អឺ...គ្មានអីទេ"

ម៉ាទិនេស នៅតែសង្ស័យ និងប្រុងសួរ តែត្រូវនាងហៅ។

"បង ម៉ាត"

"បាទ"

នាងក្រមុំធ្វើចិត្តក្លាហានប្រសព្វភ្នែកនឹងគេ។





Scanned with CamScanner

"បើ...អឺ...ខ្ញុំចង់មានន័យថា...បើថ្ងៃមួយបង ម៉ាត ដឹងថា...ខ្ញុំកុហក... បងនឹងខឹងទេ?"

"អូនកុហកបងរឿងអី ទើបសួរបែបនេះ" អ្នកកំលោះអស់សំណើចពេលឮកសួរ ទើបមនុស្សក្តៅខ្លួនគ្រវីក្បាលបដិសេធ។

"អត់ អត់មានទេ មិនបាន...មិនបានកុហកអីទេ"

ម៉ាទិនេស អស់សំណើច។

"បងមិនបានថាអីឯណា ម៉េចចាំបាច់ភ័យ"

ម៉ាទិនេស ឱនថើបបបូរមាត់ក្រពុំខ្លាំងៗ ជ្រែកអណ្តាតចូលក្នុងប្រអប់មាត់ បញ្ចប់ការសន្ទនាគ្មានបានការភ្លាម។

យ្យូលី ប្រឹងលើកដៃរុញដើមទ្រូងធំទូលាយ តែមិនយូរប៉ុន្មានក៏ទោរទន់តាមដោយការពេញចិត្ត។



# ១០

ពេលឃើញ ម៉ាទិនេស ដើរចូលមហាវិទ្យាល័យ ជីយ៉ន ក៏រត់ទៅស្ទាក់មុខនិងញញឹមពព្រាយដាក់។

"សួស្តីលោកនាយក"

"សួស្តីសាស្ត្រាចារ្យ គីម ម៉ោធ្វើការពីព្រឹកម្ល៉េះ" អ្នកកំលោះរាក់ទាក់តាមមារយាទ។

"ថ្ងៃនេះជាថ្ងៃដំបូងដែលខ្ញុំម៉ោមុនលោកនាយក"

នាងដើរតាមគេឡើងអគារ។

"អឺ...លោកស្រី អឹន យ៉ាងម៉េចហើយ ហើយនាងមានប្រាប់ទេថាហេតុអីក៏ធ្លាក់ទឹក"

"លីលី ប្រាប់ថាធ្លាក់ខ្លួនឯង" គេគ្រវីក្បាលតិចៗ។

"អឺចឹង"

ជីយ៉ន លួចព្រួសខ្យល់ដង្ហើមចេញមកតាមមាត់។

"បាទ" ម៉ាទិនេស ញញឹម "ខ្ញុំសុំទៅសិនហើយ"

"អឺ...ឈប់សិនលោកនាយក"

នាងដើររលះរលាំង មកពាំងមុខចៅហ្វាយ ទើប ម៉ាទិនេស ជ្រីមភ្នែកមើលអ្នកនៅចំពោះមុខដោយការសង្ស័យដែលលាក់ស្ទើរតែមិនជិត។



"មានការអីសាស្ត្រាចារ្យ គីម?"

"ខ្ញុំ...អឺ...ខ្ញុំមិនដឹងថាចាប់ផ្តើមយ៉ាងណា"



Scanned with CamScanner

"អីចឹងខ្ញុំសុំទៅបន្ទប់ធ្វើការសិនហើយ"

"ឈប់សិន"

នាងស្រវាចាប់ដៃរបស់គេ តែព្រលែងភ្លាម ពេលត្រូវគេមើលមកដោយខ្សែភ្នែកត្រជាក់។

"គឺខ្ញុំ...មានរឿងខ្លះដែលមិនដឹងថាត្រូវប្រាប់លោកនាយកល្អឬអត់"

"អីចឹងចាំសាស្ត្រាចារ្យ គីម សម្រេចចិត្តបាន សឹមមកប្រាប់ខ្ញុំក៏បាន ខ្ញុំទៅសិនហើយ"

"ខ្ញុំប្រាប់ លោកនាយក" នាងស្រែកប្រាប់។

ទឹកមុខរបស់ ម៉ាទិនេស នៅតែរាបស្មើ គ្មានអារម្មណ៍អី។ នេះគេមិនចង់ដឹងចង់ឃើញរឿងដែលនាងប្រាប់ទេឬយ៉ាងម៉េច...ជីយ៉ន អត់ជ្រេញមិនបាន។

"អីចឹងយើងទៅអង្គុយត្រង់ភានហាលទេ ?"

"បាទ"

នាងដើរនាំមុខទៅអង្គុយលើកៅអី ដោយ ម៉ាទិនេស ដើរទៅអង្គុយដែរតែនៅឆ្ងាយបន្តិច។

"សាស្ត្រាចារ្យ គីម មានអីចង់និយាយឲ្យស្តាប់ឬ ?"

ស្រីស្អាតសម្លឹងមុខគេ ហើយដកដង្ហើមចូលឲ្យជ្រៅៗ ទើបនិយាយ។

"រឿងរបស់លោកស្រី អីន"

ទឹកមុខរបស់ ម៉ាទិនេស មានស្លាកស្នាមស្រេកឃ្លានការចង់ដឹងភ្លាមពេលមើលមុខនាង។

"លីលី យ៉ាងម៉េច ?"

ជីយ៉ន មើលមុខបុរសដែលខ្លួនប៉ងប្រាថ្នាដោយការជិនឆ្អន់ ហើយអត់មិនបាននឹងបញ្ឈឺ។



"ពេលជារឿងរបស់លោកស្រី អីន លោកនាយកក៏ចង់ដឹងភ្លាម"

"ព្រោះ លីលី ជាភរិយារបស់ខ្ញុំ"

ចម្លើយរបស់គេ ធ្វើឲ្យនាងចុកទ្រូង បន្ទាប់មកក៏អាម៉ាស់មុខ។

"លោកស្រី អីន សំណាងល្អមែន ដែលលោកនាយកទាំងស្រឡាញ់ទាំងស្មោះត្រង់ចំពោះនាង"

ម៉ាទិនេស ដកដង្ហើមធំដោយការនឿយណាយ។

"សាស្ត្រាចារ្យ គីម ចង់ប្រាប់អីខ្ញុំក៏និយាយម៉ោ ខ្ញុំមានបង្រៀនទាំងព្រឹក"

"ខ្ញុំមិនដឹងទេថាលោកនាយកជឿសម្តីរបស់ខ្ញុំឬអត់ តែខ្ញុំសុំបញ្ជាក់ថាខ្ញុំបានឮពីមាត់ តេយ៉ុង ប្អូនប្រុសខ្ញុំពិតមែន"

ពេលបានឮឈ្មោះបុរសម្នាក់នេះ ត្រចៀករបស់ ម៉ាទិនេស ក៏បះភ្លាម។

"ប្រាប់ខ្ញុំម៉ោ មានរឿងអីដែលខ្ញុំមិនទាន់ដឹងពាក់ព័ន្ធនឹង លីលី"

ជីយ៉ន ស្ទើរតែទប់ការសប្បាយចិត្តមិនជាប់ គិតថា ម៉ាទិនេស ច្បាស់ជាស្អប់ ខ្ពើមរអើម យ៉ូលី ដល់ឆ្អឹងមិនខាន បើដឹងថាត្រូវស្រីម្នាក់នោះបោកប្រាស់ជាយូរមកហើយ។

"ខ្ញុំលួចដឹងថាលោកស្រី អីន មិនបានពិការជើងទេ"

ទឹកមុខរបស់អ្នកកំលោះហាក់ដូចស្លុត តែវិនាទីបន្ទាប់មកក៏ជម្មតាវិញព្រមទាំងងើបឈរ។

"លោកនាយកមិនជឿខ្ញុំឬ ?"

"ខ្ញុំថាសាស្ត្រាចារ្យ គីម គួរតែយល់ច្រឡំហើយ លីលី ពិការជើងតាំងពីគ្រោះថ្នាក់ចរាចរណ៍ម្ល៉េះ នាងដើរមិនបានតាំងពីពេលនោះមក"

ជីយ៉ន ស្ទុះងើបមកឈរទល់មុខគេ ហើយបញ្ជាក់៖

"តែខ្ញុំបានឮ តេយ៉ុង និយាយផ្ទាល់ត្រចៀកថាលោកស្រី អីន ដើរបាន



តាងពីយូរហើយ ហើយដែលធ្វើជាពិការ ដើរមិនបាន ព្រោះត្រូវការបង្វិលក្បាលលោកលេងប៉ុណ្ណោះ"

"ខ្ញុំមិនជឿ"

"លោកនាយក ខ្ញុំមិនបានកុហកពិតមែន បើមិនជឿ លោករកវិធីពិសោធមើលទៅ"

អ្នកដែលកំពុងដើរចេញទៅទប់ដំណើរ ហើយងាកមកមើលមុខនាង។

"ខ្ញុំចាំបាច់ត្រូវធ្វើបែបហ្នឹងឬ"

ទោះយ៉ាងណាក៏ ម៉ាទិនេស មិនព្រមជឿអ្វីដែលបានឮ។

"ចាំ លោកនាយកនឹងភ្លឺភ្នែកនោះអី និងបានដឹងថាស្រីទន់ជ្រាយគួរឲ្យអាណិតដែលលោកនាយកនឹងមើលថែមួយជីវិតដូចលោកស្រី អ៊ីន តាមពិតទៅគ្រាន់តែជាស្រីបោកប្រាស់ ស្រីកុហកម្នាក់ប៉ុណ្ណោះ"

អ្នកកំលោះខាំថ្គាមណែន។

"ខ្ញុំមិនចូលចិត្តឲ្យអ្នកណាលាបពណ៌ឲ្យភរិយារបស់ខ្ញុំទេ ទាំងនៅចំពោះមុខ ទាំងនៅក្រោយខ្នង"

"លោកនាយក ខ្ញុំនិយាយរឿងពិត"

"បើសាស្ត្រាចារ្យ គីម នៅតែមិនឈប់និយាយរឿងឆ្កួតៗនេះទៀត ខ្ញុំនឹងពិចារណារឿងការងាររបស់សាស្ត្រាចារ្យ ហើយ"

ម៉ាទិនេស សម្លឹងមុខ ជីយ៉ន ដោយខ្សែភ្នែកកាច បែបដែលនាងមិនធ្លាប់ឃើញ ទើបនាងបិទមាត់ភ្លាម។

"ខ្ញុំទៅសិនហើយ"

"អឺ...ចាំ"

គេដើរចេញទៅហើយ តែ ជីយ៉ន ឈរមើលដោយការខឹងសម្បា ដៃទាំង



ពីរក្ដាប់ណែន។

"អាល្ងង់ ម៉េចក៏ល្ងង់ម្ល៉េះ ឆ្កួតមែន!"

នាងខាំមាត់និយាយខ្សឹបៗ ហើយដើរតន្ត្រំជើងទៅបន្ទប់សម្រាករបស់សាស្ត្រាចារ្យដោយការមួម៉ៅ។

**'ខ្ញុំលួចដឹងថាលោកស្រី អ៊ីន មិនបានពិការជើងទេ'**

'តែខ្ញុំបានឮ តេយ៉ុង និយាយផ្ទាល់ត្រចៀកថាលោកស្រី អ៊ីន ដើរបានតាងពីយូរហើយ ហើយដែលធ្វើជាពិការ ដើរមិនបាន ព្រោះត្រូវការបង្វិលក្បាលលោកលេងប៉ុណ្ណោះ'

សម្ដីល្ងីល្ងើរបស់ ជីយ៉ន ដែលគេមិនគិតថាយកមកគិតបែរជាវិលវល់នៅក្នុងខួរក្បាលគ្រប់ពេលវេលា។

ម៉ាទិនេស ព្យាយាមរកហេតុផលដែល យូលី បោកប្រាស់ខ្លួន តែបែរជារកមិនឃើញ ដូច្នេះហើយវាមិនអាចទៅរួចទេ ដែលនាងបោកប្រាស់គេរឿងជើងពិការដូចដែល ជីយ៉ន ប្រាប់។

ប៉ុន្តែហេតុអី...ហេតុអីក៏គេចេះតែនឹកដល់សម្ដីរបស់ ជីយ៉ន បែបនេះ។

"លីលី ជាក្មេងគួរឲ្យស្រឡាញ់ លីលី មិនធ្លាប់កុហកអ្នកណា ដូច្នេះហើយលីលី គ្មានផ្លូវយករឿងធំបែបនេះមកកុហកបងទេ មែនទេ..."

*ទោះកាន់ជើង យូលី តែបែរជាមានអ្វីម្យ៉ាងនៅក្នុងទ្រូងវេញចេញជាការសង្ស័យ ឬថាគេគួរតែវិធីពិសោធដូចដែល ជីយ៉ន និយាយ?*



អ្នកកំលោះលើកដៃអង្អែលមុខខ្លាំងៗជាច្រើនដង ភាពច្របូកច្របល់និងអារម្មណ៍ជាច្រើនទៀតកំពុងតែធ្វើឲ្យចិត្តរបស់គេអន្ទះអន្ទែង។

គេគួរតែពិសោធ ដើម្បីកុំឲ្យការសង្ស័យវិលវល់នៅក្នុងចិត្តបែបនេះ។ គិត

ឃើញដូច្នេះហើយ ទើបគេទាញទូរសព្ទដៃចុចទៅរក យូលី តែ ហុងស៊ីល ជាអ្នកទទួលជំនួស។

(សួស្តីលោក ម៉ាត)

"លីលី ទៅណា ហុងស៊ីល?"

អ្នកកំលោះសួរនាំ ហុងស៊ីល ក៏ឆ្លើយមិនសូវពេញសំឡេង។

(កំពុងធ្វើកាយចលនាជាមួយអ្នកជំនាញ គីម)

ឃើញទេ បើ យូលី ដើរបាន មុខជាមិនឧស្សាហ៍ធ្វើកាយចលនាបែបនេះទេ គេមិនគួរសង្ស័យនាង ទាស់ត្រង់ថា...គេមិនចង់ឲ្យខ្លួនឯងនៅតែសង្ស័យបែបនេះ យ៉ាងណាក៏ត្រូវតែរកវិធីពិសោធ។

(តែខ្ញុំនៅជាមួយគ្រប់ពេល លោក ម៉ាត កុំបារម្ភអី)

"ខ្ញុំមិនទាន់បានថាអីទេ" គេព្យាយាមធ្វើសំឡេងឲ្យធម្មតាបំផុត "នាងធ្លាប់សង្ស័យទេ ហុងស៊ីល ថាហេតុអីអ្នកនាងរបស់នាងនៅតែដើរមិនបាន ទាំងដែលពេលនៅអ៊ីតាលី ធ្វើកាយចលនាច្រើនដែរ?"

(អឺ...) ហុងស៊ីល និយាយមិនចេញ។

"នាងមានអីបិទបាំងខ្ញុំឬអត់?"

(គ្មាន...គ្មានទេលោក ម៉ាត...អ្នកនាងរឹងណាស់ អ្នកជំនាញមកអង្គុយដេកៗនៅផ្ទះ តែគ្មានអ្នកណាធ្វើឲ្យអ្នកនាងព្រមធ្វើកាយចលនាជាមួយ មិនជឿ...សួរលោកស្រី ឡុងហ៊ី បាន)

ពេលដោះសាឲ្យចៅហ្វាយរួច ហុងស៊ីល ក៏ដកដង្ហើមធំ ធូរទ្រូងឡាក។

(អឺ...លោក ម៉ាត តេរម៉ោមានការអីដែរ?)

"ខ្ញុំមានប្រជុំនៅតាមខេត្ត មិននៅផ្ទះពីរបីថ្ងៃ ជួយប្រាប់ លីលី ផងថាកុំឲ្យចាំផ្លូវ"



(ហ៊ុំ! ទៅច្រើនថ្ងៃផង)

"បើការងារឆាប់រួចរាល់ នឹងម៉ោវិញមុនកំណត់ តែខ្ញុំនឹងតេរមករក លីលីញឹកញាប់ ជួយប្រាប់ផង"

(ចាំ បាន ចាំខ្ញុំជម្រាបអ្នកនាងឲ្យ)

"អូខេ អីចឹងប៉ុណ្ណឹងចុះ"

(អឺ...លោក ម៉ាត ទៅយប់នេះឬ?)

ហុងស៊ីល ប្រញាប់សួរ ព្រោះខ្លាចគេដាក់ទូរសព្ទចុះ។

"អ្ហឹម ទៅល្ងាចនេះ"

(អ្ហ៎! ចាំ)

ម៉ាទិនេស ដាក់ទូរសព្ទចុះ ហើយក៏អង្គុយស្រួលនៅតុធ្វើការ។

ចំណែក ហុងស៊ីល ពេល ម៉ាទិនេស ដាក់ទូរសព្ទចុះហើយ ក៏ម្នីម្នាទៅរាយការណ៍ប្រាប់ចៅហ្វាយ។

"អ្នកណាតេរម៉ោ?"

"លោក ម៉ាត"

"បង ម៉ាត ឬ?"

ទឹកមុខរបស់ យូលី មានតែភាពរីករាយ ធ្វើឲ្យ គេយ៉ុង ឈឺចិត្ត។

"ចាំ លោក ម៉ាត ប្រាប់ថាទៅខេត្តពីរបីថ្ងៃ យប់នេះមិនបានម៉ោផ្ទះទេ"

នាងក្រមុំថ្លោះទឹកមុខ ភាពរីករាយរសាយបន្តិចម្តងៗ។

"បង ម៉ាត ទៅជាមួយអ្នកណា បងដឹងទេ?"

"លោក ម៉ាត មិនបានប្រាប់ទេ តែប្រហែលទៅធ្វើការមែនហ្នឹង ឮថាជាការងារបន្ទាន់"



"ទោះបង ម៉ាត ទៅជាមួយស្រី ក៏ខ្ញុំគ្មានសិទ្ធិប្រចណ្ឌដែរ" អ្នកនិយាយមានតែការតូចចិត្ត ហើយងាកទៅរក តេយ៉ុង "អ្នកជំនាញ គីម លោកទៅផ្ទះចុះ ខ្ញុំឡើងទៅសម្រាកហើយ"

"បាទ ចុះស្អែកខ្ញុំម៉ោដូចជម្មតាមែនទេ ?"

យ៉ូលី មានទឹកមុខសោកសៅ និងតូចចិត្ត។

"ចាំម៉ោថ្ងៃដែលបង ម៉ាត ត្រឡប់ម៉ោវិញ"

"បាទ" តេយ៉ុង ឱនមុខជ្រប់ "អ៊ីចឹងខ្ញុំទៅសិនហើយ"

នាងសើចញឹមៗដាក់គេ ហើយឲ្យ ហុងស៊ីល នាំចូលទៅក្នុងផ្ទះ ដោយមាន តេយ៉ុង តាមមើលដោយភាពអស់សង្ឃឹម។

"មិនថាយ៉ាងណាក៏លោកស្រីមិនមើលខ្ញុំដដែល"

*មែនហើយ គេគួរតែឈប់មានក្តីសង្ឃឹមខ្យល់បែបនេះបានហើយ!*

អ្នកជំនាញសង្ហានាំមុខស្រពោនឡើងឡាន ហើយបើកចេញទៅ។

បន្ទាប់ពីបណ្តោយឲ្យចៅហ្វាយដើរទៅដើរមកនៅក្នុងបន្ទប់ដេក ជាងដប់នាទី ហុងស៊ីល ក៏ទ្រាំលែងបាន។

"អ្នកនាងឈប់ដើរទៅ ខ្ញុំវិលមុខ"

អ្នកដែលត្រូវហាមក៏ឈប់ដើរ ងាកមករក ដោយទឹកមុខខ្វល់ខ្វាយ។

"បងថាស្រីចំពុះក្រហមទៅជាមួយបង ម៉ាត ឬអត់ ?"

"មិនដឹងទេ តែលោក ម៉ាត ប្រហែលមិនធ្វើអីក្រៅផ្លូវក្រៅគន្លងទេ លោក ម៉ាត ជាមនុស្សល្អ"

យ៉ូលី ជ្រួញច្រមុះដាក់ ព្រោះមិនយល់ស្រប។

"មនុស្សល្អ...តែមិនមែនថាល្អគ្រប់ជប់ឯណា"



"អីយ៉ា អ្នកនាង ខ្ញុំថាគេងទៅ គិតទៅនាំតែឈឺក្បាលទទេៗ"

"តែខ្ញុំចង់ដឹងហ្នឹងណា៎ ទោះដេកក៏មិនលក់ដែរ"

"ហើយអ្នកនាងចង់ធ្វើយ៉ាងម៉េច ?" ហុងស៊ីល លើកដៃបិទមាត់ស្ងាបព្រោះងងុយដេក។

"ខ្ញុំនឹងតេរទៅអ្នកជំនាញ គីម សួររឿងស្រីចំពុះក្រហម"

"ល្អឬ ពួកគេជាបងប្អូននឹងគ្នា ម៉េចនឹងប្រាប់ការពិតដល់អ្នកនាងទៅ" ហុងស៊ីល មិនធ្លាប់ទុកចិត្ត តេយ៉ុង។

"អ្នកជំនាញ គីម ជាមនុស្សល្អ ខ្ញុំមានអារម្មណ៍ថាអីចឹង"

ហុងស៊ីល ដកដង្ហើមធំ។

"តែកុំស្និទ្ធស្នាលពេល ក្រែងចិត្តលោក ម៉ាត ផង"

"ដែលខ្ញុំធ្វើជាស្និទ្ធស្នាលនឹងអ្នកជំនាញ គីម គឺចង់ឲ្យបង ម៉ាត ប្រចណ្ឌ តែបងក៏ឃើញ បង ម៉ាត គ្មានអារម្មណ៍អី"

នាងនិយាយដោយការតូចចិត្ត ហើយដើរទៅយកទូរសព្ទតេរទៅ តេយ៉ុង ដោយ ហុងស៊ីល បានត្រឹមឈរមើល។

"ហាឡូ អ្នកជំនាញ គីម ខ្ញុំមានរឿងរំខានបន្តិច"

ពេលគេទទួលទូរសព្ទ នាងនិយាយសាច់ការភ្លាម។

"ខ្ញុំចង់ដឹងថាពេលនេះបងស្រីរបស់លោកនៅផ្ទះឬអត់ ឬទៅតាមខេត្ត"

(បាទ នៅផ្ទះតើ កាលពីល្ងាចយកនំមកឲ្យខ្ញុំ លោកស្រី អ៊ីន មានការអីឬអត់ ? )

"អត់មានអីទេ អ៊ីចឹងលែងរំខានហើយ ប៉ុណ្ណឹងឯង"

នាងចុចផ្តាច់ទូរសព្ទ ហើយដើរទៅរក ហុងស៊ីល លោតកញ្ឆេងដោយការសប្បាយចិត្តដាក់។



"អ្នកនាងកើតអី លោតកញ្ឆេងសប្បាយចិត្តដូចត្រូវឆ្នោត"

នាងក្រមុំញញឹមពព្រាយ កែវភ្នែកមានពន្លឺផ្លេកៗ។

"មិនឲ្យសប្បាយចិត្តម៉េចនឹងបានបង អ្នកជំនាញ គីម ប្រាប់ស្រីចំពុះក្រហមនោះមិនបានទៅខេត្តទេ នៅផ្ទះ"

បានឮហើយ ហុងស៊ីល ក៏ញញឹមពព្រាយ។

"អីចឹងអ្នកនាងគេងលក់ស្រួលហើយមែនទេ ?"

"ចាំ ដេកលក់ស្រួលហើយ"

ហុងស៊ីល ងើបឈរ លើកដៃបិទមាត់ស្វាបម្តងទៀត។

"អីចឹងអ្នកនាងសម្រាកទៅ ខ្ញុំក៏ទៅដេកដែរ សង្ស័យម៉ោពីលេបថ្នាំ ទើបងងុយដេកអីយ៉ាងនេះ"

"បងទៅចុះ សុបិនល្អ"

"សុបិនល្អអ្នកនាង ខ្ញុំទៅហើយ"

យូលី ដើរទៅបើកទ្វារឲ្យអ្នកមើលថែរបស់ខ្លួន។

"ស្អែកយើងទៅផ្សារទំនើប ខ្ញុំចង់មើលកុន"

"ល្អឬអ្នកនាង តិចមានគេឃើញ"

"បង ម៉ាត មិននៅគឺមិនឃើញ គ្មានអីត្រូវខ្លាចទេ តាមនេះ សុបិនល្អ"

យូលី ទាញទ្វារបិទ ហើយដើរច្រៀងឲ្យរហឹម ទៅផ្តួលខ្លួនដេកលើគ្រែព្រមទាំងញញឹមមានសេចក្តីសុខ។

"បង ម៉ាត មិនបានទៅជាមួយស្រីចំពុះក្រហម អីចឹងគឺមិនដូចដែលឯងគិតទេ លីលី"

នាងក្រមុំនៅតែញញឹមមានសេចក្តីសុខ ហើយគិតថាពេល ម៉ាទិនេស ត្រឡប់មកវិញនិងប្រាប់គេថានាងអាចដើរបានតិចៗហើយ ដើម្បីកុំឲ្យខ្លួនឯង



លំបាកចិត្តនឹងការកុហកបែបនេះទៀត។

**ម៉ាទិនេស អង្គុយស្រេ្តសនៅក្រោយចង្កូតរថយន្ត ដែលចតនៅក្រៅរបងផ្ទះ គិតថាចាំយប់ជ្រៅសឹមបើកចូលផ្ទះ និងឡើងទៅបន្ទប់ដេក ដើម្បីពិសោធការពិត។**

វាមិនគួរមានអីមិនល្អ យូលី មិនបានកុហកគេ អ្វីដែលបានឮគ្រាន់តែជាសម្តីខ្យល់ ជាការសន្និដ្ឋានគ្មានបានការរបស់ ជីយ៉ន ដែលអាចយល់ច្រឡំ។

*ទោះព្យាយាមគិតវិជ្ជមាន តែហេតុអី ហេតុអីត្រូវមានអារម្មណ៍ភ័យៗបែបនេះដែរ ?*

***បើអ្វីដែល ជីយ៉ន និយាយជារឿងពិត គេនឹងធ្វើយ៉ាងណា ធ្វើយ៉ាងណាចំពោះ យូលី ?***

អ្នកកំលោះដកដង្ហើមធំ មុខសង្ហាមានភាពតានតឹង ម្រាមដៃខ្ទាំចង្កូតឡានខ្លាំងៗ។

"បងមិនជឿថាអូនកុហកបងទេ លីលី"

ពេលនិយាយហើយ គេក៏បញ្ជាឡានទៅចតនៅរោងឡាន ហើយដើរចូលផ្ទះ ជួប ហេរ៉ាន់ ដែលកំពុងដើរមកបិទទ្វារផ្ទះល្មម។

"លោក ម៉ាត ទៅតាមខេត្តមិនអីចឹង ?"

"ខ្ញុំចាំថ្ងៃខុស" អ្នកកំលោះបង្ខំចិត្តញញឹមដាក់ ហេរ៉ាន់ "បិទទ្វារហើយទៅដេកចុះ ខ្ញុំឡើងដេកហើយ"

"អី ចាំ..."

ម៉ាទិនេស ញញឹមដាក់ម្តងទៀត ហើយដើរឡើងជណ្តើរ ដោយមាន ហេរ៉ាន់ តាមមើលដោយការសង្ស័យ។





Scanned with CamScanner

"ក្រែងលោកស្រី លីលី ថាលោក ម៉ាត មិននៅពីរបីថ្ងៃតើ"

"មកឈរអោភទាក់ស្អីនៅត្រង់នេះ"

សំឡេងរឹងកំព្រឹសបន្លឺឡើងនៅក្រោយខ្នង ធ្វើឲ្យ ហេរ៉ាន់ ភ្ញាក់ព្រើត និងងាកទៅរក មេសាន់ ទាំងមុខស្លេកស្លាំង។

"អត់មានទេ"

នាងបដិសេធដោយសំឡេងរដាក់រដុប ហើយបែរខ្លួន ម្ទឹម្ទាដើរចេញទៅភ្លាម តែត្រូវគេស្រវាចាប់ដៃ ដែលធ្វើឲ្យនាងបុកពោះ។

"លោក...ម៉ែ..."

គេកញ្ឆក់ដៃនាងឲ្យមកឈរទល់មុខ និងជ្រឹមភ្នែកមើល ដោយខ្សែភ្នែកស្អប់ខ្ពើម។

"យ៉ាយ៉ា ធ្លាប់ប្រាប់ខ្ញុំថានាងចូលចិត្តខ្ញុំ"

"អឺ...លោក ម៉ែ..."

មុខរបស់ ហេរ៉ាន់ ទៅជាស្លេក និងប្រឹងមួល.កដៃចេញពីដៃរបស់គេ។

"មែនទេ ?"

នាងគ្រវីក្បាលទាំងទឹកភ្នែករលីងរលោង ទើបគេឈ្លេចម្តងទៀត។

"មែនទេ ?"

"មិន...មិនមែនទេ"

"កុហក!" គេរុញនាងចេញឲ្យឆ្ងាយភ្លាមដោយការស្អប់ខ្ពើម "ចេញឲ្យផុតពីមុខខ្ញុំភ្លាម កុំម៉ោឲ្យឃើញមុខទៀត ខ្ញុំខ្ពើមនាង!"

អ្នកដែលត្រូវរុញឲ្យដួលអុកគូទហូរទឹកភ្នែកសស្រាក់ យំអណ្តឹតអណ្តកដោយការឈឺចាប់។

នេះនាងធ្វើអីខុស ហេតុអី មេសាន់ ស្អប់នាងដល់ថ្នាក់នេះ!



"ពេលខ្លះខ្ញុំក៏អត់គិតមិនបាន ថា យ៉ាយ៉ា អាចស្លាប់ព្រោះផែនការរបស់នាង"

"មិនមែន...ខ្ញុំ...មិនបានធ្វើអីទេ"

គេពេបមាត់ប្រមាថ។

"គ្មានចោរណាព្រមទទួលស្គាល់ការពិត ដោយគ្មានភ័ស្តុតាងដាក់បន្ទុកនាងក៏អីចឹងដែរ"

"លោក ម៉ែ..."

នាងយំដោយការឈឺចាប់ មិនចង់ជឿទេថា មេសាន់ គិតថានាងអាក្រក់ដល់ថ្នាក់នេះ។

"ចេញឲ្យផុតពីខ្ញុំទៅ មុនពេលខ្ញុំសម្លាប់នាង!"

នាងក្រមុំនៅតែយំអណ្តឹតអណ្តក។

"ខ្ញុំប្រាប់ថាឲ្យចេញ ចេញទៅ ទៅ!"

ហេរ៉ាន់ ស្ទុះងើប ហើយរត់សំដៅបន្ទប់សម្រាកសម្រាប់អ្នកបម្រើដោយការភ័យខ្លាច ដោយយំពេញតែផ្លូវ។

"បងមិនព្រមឲ្យអូនស្លាប់ទទេៗទេ យ៉ាយ៉ា បងសន្យា"

ទោះវាជាឧបទ្ទវហេតុដែលពង្រាត់យកជីវិតគូស្នេហ៍ តែប្រផ្នូលធ្វើឲ្យគេគិតថាមានមនុស្សមានចេតនាធ្វើឲ្យវាកើតឡើង ឧបទ្ទវហេតុដែលមានមនុស្សដាក់ផែនការ ហើយក៏មិនមែនអ្នកណាដែរ ក្រៅពី...ស្រីពេស្យាម្នាក់នោះ។

សំឡេងគោះទ្វារបន្លឺឡើង យ្យូលី ដែលដេកមិនទាន់លក់ ព្រោះកំពុងលេងទូរសព្ទដៃ ក៏ងើបក្បាលមើល។

"ហុងស៊ីល ឬ ?"



គ្មានសំឡេងឆ្លើយតប ទើបនាងចងចិញ្ចើមដោយការងឿងឆ្ងល់ ហើយលោតចុះពីគ្រែ ដើរសំដៅទ្វារបន្ទប់។

"ហុងស៊ុល ឬអត់?"

សំឡេងគោះទ្វារបន្លឺឡើងម្ដងទៀត តែបែរជាគ្មានសំឡេងអ្នកគោះតប ទើបធ្វើឲ្យនាងមិនពេញចិត្ត ទាញទ្វារបើកឲ្យធំទាំងគំហុក។

"គោះស្អីក៏គោះ ឆ្កួតទេក៏..." នាងនិយាយបានតែប៉ុណ្ណឹងក៏ធ្វើមាត់មួបៗ និងបើកភ្នែកធំៗ។

"បង...ម៉ាត"

នាងបញ្ឈរភ្នែកមួយខណៈ ពេលអ្នកគោះទ្វារមិនឈប់គឺ ម៉ាទិនេស។

"ក្រែងថា...ទៅខេត្ត?"

ម៉ាទិនេស សើចញឹមៗ តែភ្នែករបស់គេមិនញញឹមជាមួយ ដែលធ្វើឲ្យបេះដូងរបស់ យ្យូលី ធ្លាក់ទៅនៅនឹងភ្នែកគោ ហើយម្ទីម្នាដើរតាមគេចូលបន្ទប់ពេលបិទទ្វាររួច។

"បង ម៉ាត...ស្ដាប់ខ្ញុំសិន"

គេងាកមកមើលនាង ដោយទឹកមុខនៅតែមានស្នាមញញឹម។

"គិតថាបងជាក្របីឬយ៉ាងម៉េច!"

"មិនមែនបែបហ្នឹងទេ"

"ហើយវាបែបណា?"

គេសម្លក់នាងថ្មៃ ហើយឱនមើលជើងរបស់នាង ដែលធ្វើឲ្យនាងស្លេកមុខ ក្រជាក់ដល់បេះដូង។

"ខ្ញុំ...អធិប្បាយបាន បង ម៉ាត ត្រូវស្ដាប់ខ្ញុំ"

"តាមដែលបងឃើញ...មិនចាំបាច់និយាយអីទេដឹង"



ខ្សែភ្នែកមុតស្រួចដែលសម្លឹងមើលមកមានតែភាពត្រជាក់។

"មិនគួរឲ្យជឿថាសាស្ត្រាចារ្យដូចបង ត្រូវប្រពន្ធបោកបានយូរយ៉ាងនេះ"

"ខ្ញុំគ្មានចេតនាទេ"

"គ្មានចេតនា..ចុះបើមានវិញតើយ៉ាងណាទៅ"

នាងក្រមុំខ្ទឹបមាត់ មើលគេទាំងទឹកភ្នែករលីងរលោង។

"ប្រាប់ហើយតើថាមិនបានគិតថាបោកទេ"

គេញញឹមចម្អក ដើរមកឈរទល់មុខ ស្រវាចាប់ស្មាតូចស្ដើងទាំងពីរ កែវភ្នែកជះពន្លឺគួរឲ្យខ្លាច ធ្វើឲ្យនាងខ្លាចឡើងញ័រខ្លួន។

"សួរតាមត្រង់ ហេតុអីធ្វើពុតជាពិការ យ្យូលី"

អ្នកដែលកំពុងរលីងរលោងខ្ទឹបបបូរមាត់ណែន តូចចិត្តដែលគេមិនព្រមស្ដាប់។

"វាជារឿងផ្ទាល់ខ្លួនរបស់ខ្ញុំ"

"វាជារឿងរបស់បងដែរ ព្រោះបងជាស្វាមីរបស់អូន"

សំឡេងរបស់គេកាចគួរឲ្យខ្លាច តែនាងព្យាយាមទប់ការភ័យខ្លាចនោះ តបដោយទឹកមុខឆ្មាសឆ្មើម។

"គ្រាន់តែជាស្វាមីក្នុងនាម"

គេជ្រឹមភ្នែកមើលនាងមួយដង្ហើម ពន្លឺទោសៈក្នុងកែវភ្នែកមុតស្រួចដែលក្ដៅសឹងតែដុតនាងឲ្យឆេះ។

ហេតុអីថ្ងៃនេះ ម៉ាទិនេស គួរឲ្យខ្លាចម្ល៉េះ ហើយគេធ្វើឲ្យនាងខ្លាចកាន់តែខ្លាំងនឹងពាក្យតវ៉ារបស់គេ។

"ដែលបងមិនប៉ះពាល់អូន ព្រោះឃើញអូនមិនរឹងមាំ តែចាប់ពីវិនាទីនេះទៅ អូនត្រៀមខ្លួនទទួលភាពពុះកញ្ជ្រោលរបស់បងទៅ យ្យូលី"



"បង ម៉ាត...ចង់និយាយពីអី ?" នាងសួរដោយសំឡេងខ្សាវៗ និងប្រឹងរើបម្រះ តែគេមិនព្រមព្រលែងដៃ។

ម៉ាទិនេស មិនឆ្លើយ តែញញឹមឃោរឃៅដាក់ មិនទៅសល់ភាពទន់ភ្លន់លើមុខសង្ហា។

នេះគេចង់ធ្វើអី ?

"ធ្វើឲ្យមង្គលការរបស់យើងពេញលេញហ្នឹងអី"

"កុំបង ម៉ាត..." នាងគ្រវីក្បាលញាប់ស្អេក មុខមាត់ស្លេកស្លាំងគ្មានពណ៌ឈាម។

"បងក៏ចង់ដឹងដែរថាអូនប្រឆាំងបងបានប៉ុន្មានតឹក"

"បង ម៉ាត...កុំធ្វើអីខ្ញុំ"

"នេះមិនមែនជាអ្វីដែលអូនរង់ចាំយូរម៉ោហើយទេឬ"

និយាយហើយគេក៏លើកនាងគ្រវែងទៅលើគ្រែដោយមិនប្រណី។

*នេះនាង...កំពុងតែត្រូវស្វាមីចាប់រំលោភឬ ?*

# ១១

"បង ម៉ាត...កុំ..."

នាងអង្វរករ ទឹកភ្នែកហូររហាម ភ័យបុកពោះតឹបៗ មិនធ្លាប់ឃើញគេខឹងសម្បាបែបនេះសូម្បីតែម្តង។

*ហេតុអីយប់នេះ ម៉ាទិនេស គួរឲ្យខ្លាចម្ល៉េះ ?*

"កុំធ្វើអីខ្ញុំ"

"ខ្លាចអីបង បើបងមិនបានសម្លាប់អូនផង"

សូម្បីតែសំឡេងរបស់គេក៏កាចខុសពីរាល់ដងដែរ។

"ខ្ញុំដឹងថាបងកំពុងខឹង ខ្ញុំសុំទោស..."

យ៉ូលី សម្រេចចិត្តសុំទោស សង្ឃឹមថាអាចជួយឲ្យអ្នកដែលកំពុងខឹងរសាយទោសៈបានខ្លះ តែបែរជាមិនដូចការគិត ព្រោះ ម៉ាទិនេស នៅតែឈរញញឹមឡកឡឺយដដែល។ កែវភ្នែកមុតស្រួចមើលរាងកាយញ័រទទ្រើតរបស់នាងដោយខ្សែភ្នែកឃោរឃៅនិងស្រេកឃ្លាន។

"ហួសពេលនិយាយពាក្យនេះហើយ"

"បង ម៉ាត..."

"នាងគួរសប្បាយចិត្ត ពេលអ្វីដែលត្រូវការកំពុងកើតឡើង"

"ខ្ញុំ...មិនត្រូវការបែបនេះ" នាងតបដោយសំឡេងញ័រ កែវភ្នែកក៏ញ័រដោយការភ័យខ្លាច។

គេសើចចំអកដោយសំឡេងរឹងកំព្រឹស មើលនាងដោយខ្សែភ្នែកគ្មាន



ការបន្ទរបន្ថយអីទាំងអស់។

"ឈប់កុហកថាមិនត្រូវការទៅ ព្រោះបងដឹងថាអូនចង់បានវាម៉ោរហួតមែនទេ យ្យូលី"

កាន់តែស្ដាប់សម្ដីរបស់គេ នាងកាន់តែឈឺចាប់។

"ខ្ញុំគិតថាយើងចាំនិយាយគ្នាស្អែកទៅ"

នាងវារចុះពីគ្រែ តែត្រូវគេកញ្ឆក់ដៃបានទាន់ ហើយគ្រវែងទៅនៅកន្លែងដើមវិញដោយគ្មានក្ដីមេត្តា ធ្វើឲ្យនាងឈឺ ហូរទឹកភ្នែករហាម។

"បងធ្វើឲ្យខ្ញុំឈឺ"

"អូនរឹងមាំតើ អីចឹងហើយបងមិនបាច់ថ្នាក់ថ្នមអូនទៀតទេ"

គេចាប់ទាញអាវសិមិពណ៌សចេញពីរាងកាយ ទាល់តែរបូតឡេវ បោះចោលទៅលើកម្រាលឥដ្ឋ ធ្វើឲ្យនាងក្រមុំបើកភ្នែកធំៗស្មើរលៀន ពេលដើមទ្រូងធំខុលាយ ហាប់ណែនដោយសាច់ជុំសុទ្ធតែរោមស្អិតនៅចំពោះខ្សែភ្នែក។ នាងចំហមាត់ធ្លុង សឹងតែដកដង្ហើមមិនចេញនឹងភាពសម្បុរបែបរបស់គេ។

*ហេតុអីរាងកាយរបស់ ម៉ាទិនេស ស្អាតយ៉ាងនេះ!*

នាងហៀរទឹកមាត់តាមចង្វៀកមាត់ តែប្រញាប់លើកដៃជូតចេញ ពេលបានឮសំឡេងប្រមាថរបស់គេ។

"អូនជាស្រី ដែលមានសមត្ថភាពខាងទំនាក់ទំនងតាមខ្សែភ្នែកបានល្អណាស់ យ្យូលី វាធ្វើឲ្យបងដឹងថាអូនកំពុងគិតអី"

នាងងើបភ្នែកម៉េកគេ ថ្ពាល់ក្ដៅភាយៗ ក្រហមឆ្អាំង។

"ខ្ញុំ...មិនដឹងថាបង ម៉ាត កំពុងនិយាយឆ្កួតស្អី តែខ្ញុំ...មិនត្រូវការបងឲ្យប៉ះពាល់ខ្លួនខ្ញុំ..." សម្ដីរបស់នាងឮរដាក់រដុប "ដូច្នេះហើយ...បង ម៉ាត ចេញទៅសិនទៅ"



"តែបងគិតថាអូនកុហក"

គេញញឹមចំអក ហើយរលាស់ខោចេញពីជើងជាបន្ទាន់ ធ្វើឲ្យនាងបើកភ្នែកធំៗ ពេលនេះខ្លួនប្រាណរបស់គេមានតែខោបក់ស៊ីរពណ៌ខ្មៅមួយប៉ុណ្ណោះ ហើយវាស្ទើរតែបិទបាំងភាពមហិមារបស់គេមិនជិតតាមការគួរ។

នាងចំហមាត់ធ្លុង ដកដង្ហើមដង្ហក់ មានអារម្មណ៍វិលមុខចង់ខ្យល់គ ឯបេះដូងក៏លោតញាប់ ហាក់ដូចទើបតែរត់ម៉ារ៉ាតុងជុំវិញផែនដី។

"ហេតុអីធំ...អីយ...ខ្ញុំចង់និយាយថាស្រាតខោធ្វើ..." នាងក្រមុំនិយាយរដាក់រដុប "ស្លៀកខោភ្លាមបង ម៉ាត តិចខ្ញុំកើតពពែភ្នែក"

ម៉ាទិនេស ដែលពេលនេះកំពុងតែត្រូវទោសៈដឹកនាំញញឹមឡកឡឺយដាក់កាយវិការរបស់ភរិយា។

"ខោហ្នឹងជារបស់ចុងក្រោយដែលបងត្រូវស្រាត"

"បង ម៉ាត...ប្រហែលមិន..."

នាងចំហមាត់ធ្លុង ហើយសឹងតែស្លុតពេលគេចាប់ចង្កេះខោបក់ស៊ីរ ប្រុងទាញវាទម្លាក់។

"កុំបង ម៉ាត!"

នាងស្រែកហាមអស់សំឡេង និងលើកដៃបិទមុខភ្លាម ថ្ពាល់ឡើងក្ដៅនិងក្រហមដូចផ្លែឈើរី តែមិនអាចហាមប្រាមគេបាន ព្រោះមួយដង្ហើមក្រោយមក ម៉ាទិនេស ក៏ននលគកនៅចំពោះមុខ។

ម៉ាទិនេសសើចហ៊ឹៗឡើងមកលើគ្រែព្រមទាំងចាប់ទាញនាងមកឱបរឹតណែនដៃ ធ្វើឲ្យនាងបុកពោះនឹងភាពស្អិទ្ធស្នាលនេះ ទើបប្រឹងរើបម្រះ តែមិនអាចរបូតពីដៃរបស់គេ។



"លែង...លែងខ្ញុំបង ម៉ាត..."

"ហេតុអីបងត្រូវលែង បើបងមិនបានធ្វើអីខុសផង"

គេសម្លឹងមើលមុខស្រស់ស្អាតរបស់នាងដោយខ្សែភ្នែកត្រជាក់ ហើយឱនមើលគល់ទ្រូងដែលប្រាល់ចេញពី.កអាវដំណេក។

"តែខ្ញុំ...មិនត្រូវការ...លែងខ្ញុំ"

អ្នកកំលោះគ្រវីក្បាល ទឹកមុខក៏កាច។

"បងលែងអូនយូរពេកហើយ ចាប់ពីពេលនេះទៅ អូនត្រូវធ្វើតួនាទីបម្រើអារម្មណ៍បងរាល់ថ្ងៃរាល់យប់ និងគ្រប់ពេលដែលបងត្រូវការ ដើម្បីប៉ះប៉ូវការកុហករបស់អូន យុវលី" គេនិយាយដោយសំឡេងខ្សឹបៗ តែកាចនិងគួរឲ្យខ្លាចមែនទែន។

"បង ម៉ាត...កុំធ្វើបាបខ្ញុំ"

គេមិនឆ្លើយ តែរុញនាងឲ្យដួលផ្ងារក្រោយដោយមិនប្រណី និងតាមទៅទ្រាបពីលើឲ្យភាពមហិមាចាក់ភ្លៅ ធ្វើឲ្យនាងក្ដៅខ្លួន មានអារម្មណ៍ថារាងកាយកំពុងតែរលាយ។

"លែង...កុំធ្វើអីខ្ញុំ"

"ការដោះលែងអូន ជារឿងចុងក្រោយនៅលើលោកនេះដែលបងធ្វើ អូនត្រូវទទួលទោសឲ្យសក្ដិសម ពីបទដែលហ៊ានបោកបង"

"បង ម៉ាត..."

នាងថ្ងូចថ្ងូរដោយការខូចចិត្តនិងភ័យខ្លាច ដោយមិនអាចជួយខ្លួនឯងបានទៀត ពេលវិនាទីបន្ទាប់កដៃទាំងពីរត្រូវសង្កត់ទៅលើក្បាលដោយដៃម្ខាង ហើយគេក៏ប្រើដៃម្ខាងទៀតទាញសម្លៀកបំពាក់របស់នាងទាល់តែរហែក។

"អាំ...បង ម៉ាត...កុំ..."

ទោះនាងអង្វរករយ៉ាងណា តែគេក៏មិនព្រមឈប់ ឬអាណិត បបូរមាត់



ក្ដៅគគុកឱនមករក លេបត្របាក់សំឡេងស្រែកហាមប្រាមរបស់នាងដោយមិនប្រណី។

រាងតូចស្ដើងដែលពេលនេះមានតែឈុតក្នុងត្រូវខិបរឹតផ្ទឹបនឹងដើមទ្រូងធំទូលាយ។ គេថើបជញ្ជក់បបូរមាត់ផ្អែមរបស់នាងយ៉ាងឃោរឃៅ ដោយកំហឹងទោសៈដ៏ខ្លាំងក្លានិងស្រេកឃ្លាន ដែលពិបាកនឹងទប់ទល់។ នាងប្រឹងរើបម្រះតែត្រូវខិបរឹតស្ទើរតែដកដង្ហើមមិនចេញ កម្ដៅគ្មានប្រភពកំពុងហូរចូលមកក្នុងទ្រូង វាជាអ្វី...អ្វីទៅដែលកំពុងធ្វើឲ្យនាងសឹងតែរលាយក្លាយជាសាច់មួយនឹងគេ។ មាត់ដែលបឺតជញ្ជក់ខ្លាំងៗ ឬថាបាតដៃដែលកំពុងតែទាញអាវក្នុងចេញពីរាងកាយនិងខ្ទាំដើមទ្រូងណែនក្បំខ្លាំងៗ វាជាអ្វីឲ្យប្រាកដដែលធ្វើឲ្យនាងតតាំងនឹង ម៉ាទិនេស មិនបាន។

"អាំ...អាំ..."

នាងក្រមុំថ្ងូចថ្ងូរដោយមិនដឹងខ្លួន ពេលកម្ដៅដូចភ្នំភ្លើងដែលកំពុងក្ដៅហូរចូលមក។ គ្រប់ការប៉ះពាល់របស់ ម៉ាទិនេស ឃោរឃៅព្រៃផ្សៃ និងមានតែការទាមទារឲ្យតបស្នង។ នាងកំពុងតែជិតស្លាប់ កំពុងតែជិតរលាយនៅក្រោមរាងកាយមានអំណាចរបស់គេក្នុងពេលមិនយូរ។

យុវលី គិតដោយគ្មានសង្ឃឹម ពេលស្មារតីដែលនៅសល់បន្តិចបន្តួចប្រាប់ថាមិនអាចបញ្ឈប់អ្វីកើតឡើងបាន។ ម៉ាទិនេស ជាអាទិទេពសង្គ្រាម គេគ្មានផ្លូវទុកឲ្យសត្រូវរួចជីវិតទេ នាងត្រូវតែស្លាប់នៅលើគ្រែនេះ យប់នេះ។

"អាំ...អាំ..."

បបូរមាត់ក្ដៅញាក់ញ័រកាន់តែខ្លាំង បន្ទាប់មកនាងក៏បើកភ្នែកធំៗ ពុកពោះតែម្ដង ពេលអណ្ដាតក្ដៅគគុកក៏ជ្រែកចូលមកក្នុងប្រអប់មាត់ មានអារម្មណ៍ថារាងកាយកំពុងផ្ទុះ មិនទៅសល់ស្មារតីឲ្យប្រឆាំងនឹងគេទៀត។



"អ៊ំា...អ៊ំា...បង ម៉ាត..."

សំឡេងថ្ងូចថ្ងូរដ៏ពីរោះបន្លឺឡើង ធ្វើឲ្យ ម៉ាទិនេស កាន់តែលំបាកគ្រប់គ្រងខ្លួនឯង។ គេញាក់ញីកាន់តែខ្លាំង លៀនអណ្ដាតលិឍបបបូរមាត់ហើមជាំដោយការផ្ចិតផ្ចង់ ហាក់ដូចបបូរមាត់របស់នាងជាអាហារទិព្វ ហើយគ្រហឹមដោយការពេញការពេញចិត្ត ពេលទទួលបានរសជាតិផ្អែមដូចទឹកឃ្មុំ។

"ផ្អែមណាស់...អ៊ុំ..."

"បង ម៉ាត..."

ដៃទាំងពីរដែលត្រូវព្រលែងឲ្យមានសេរីភាព វារឡើងលើ ទៅឱបរឹត.ករឹងមាំ បង្ហើបបបូរមាត់បើបតបដោយការពេញចិត្តពេញថ្លើម ធ្វើឲ្យ ម៉ាទិនេស ថ្ងូចថ្ងូរដោយការប្រាថ្នាដ៏ខ្លាំងក្លា។ គេបើបជញ្ជក់ម្ដងទៀត ជ្រែកអណ្ដាតចូលទៅក្នុងប្រអប់មាត់ រឹតរួតអណ្ដាតរបស់នាងដោយក្ដីស្រេកឃ្លាន។

នាងក្រមុំរើបម្រះដោយបង្កងត្រូវភ្លើង ភ្លើងប្រាថ្នារោលរាល ធ្វើឲ្យស្បែកក្ដៅចង់ឆេះ ត្រដុសរាងកាយនឹងរាងកាយមាំពោរពេញដោយថាមពល ទើបរោមដែលចាក់នឹងស្បែកម៉ដ្ឋខៃ ធ្វើឲ្យរមាស់ តែហេតុអ្វីបែរជាធ្វើឲ្យមានអារម្មណ៍ស្រៀវស្រើបគួរឲ្យខ្មាសបែបនេះ កាន់តែត្រូវគេបើបផង ខ្ទាំដើមទ្រូងណែនក្បុំផង ធ្វើឲ្យនាងកាន់តែក្ដៅហាក់ដូចកំពុងអង្គុយក្នុងភ្នក់ភ្លើង។

"អ៊ំា...អ៊ំា...បង ម៉ាត...អ៊ំា..."

នាងស្អប់ខ្លួនឯងដែលមិនអាចឈប់រើបម្រះបាន ឈប់ថ្ងូចថ្ងូរហាក់ដូចស្រីលក់ខ្លួន តែអារម្មណ៍ដែលកើតឡើងដោយសារការប៉ះពាល់របស់ ម៉ាទិនេស វាធ្វើឲ្យនាងក្ដៅមែនទែន គេអាចធ្វើឲ្យនាងក្លាយជាស្រីក្ដៅគគុកបានត្រឹមការបើបប៉ុណ្ណោះ។

ហើយនាងកំពុងតែជិតដាច់ខ្យល់ស្លាប់ ពេលគេដកបបូរមាត់ចេញនិង



អូសអណ្ដាតមករក.ក បឺតជញ្ជក់សាច់ត្រង់នោះខ្លាំងៗ បន្ទាប់មកក៏អូសទៅខាំទងត្រចៀក និងជ្រែកចុងអណ្ដាតចូលរន្ធត្រចៀកដោយត្រូវការជន្លជន្លេញ ធ្វើឲ្យនាងញ័រខ្លួនទទ្រើត អ៊ែនខ្លួនទៅរកដោយអារម្មណ៍ស្រៀវស្រើបខ្លាំង។

"អ៊ំា...បង ម៉ាត...អ៊ំា..."

នាងក្ដៅសព្វសាច់ ជាពិសេសប្រឡោះភ្លៅ ហើយជាតិទឹកមកពីណាក៏មិនដឹងជ្រាបចេញមក និងកាន់តែជ្រាបពេលនាងមិនអាចដេកនៅស្ងៀមបានទើបរើបម្រះផង ពត់ពេនផង អង្វរករគេដោយភាពវេទនា។

"បង ម៉ាត...អ៊ំា...ជួយខ្ញុំផង...អ៊ំា..."

ទោះមិនដឹងថាខ្លួនឯងត្រូវការអ្វី តែរឿងតែមួយដែលដឹងគឺ ម៉ាទិនេស ជាបុរសតែម្នាក់គត់ដែលអាចជួយនាងបាន ទាស់ត្រង់គេមិនព្រមជួយ គេមិនចាប់អារម្មណ៍នឹងធ្វើឲ្យនាងរសាយភាពតានតឹង និងមានចេតនាថប់ដង្ហើមលើសដើម ដោយការអូសបបូរមាត់មករកស្មារលោង ខណៈដែលបាតដៃនៅតែច្របាច់ដើមទ្រូងមិនព្រមឈប់។

គេមិនធ្លាប់ឃើញដើមទ្រូងរបស់មនុស្សស្រីណាស្អាតដូចដើមទ្រូងរបស់ យ៉ូលី បែបនេះទេ វាទាំងធំ ទាំងណែនក្បុំ ទាំងទន់ល្មើយ និងអន្ទិលស៊ីបាតដៃ ធ្វើឲ្យឈ្លក់វង្វេង។ អ្នកកំលោះជ្រឹមភ្នែកមើលចុងរបស់វាដែលឡើងរឹងទាក់ទាញ អណ្ដាត ទាក់ទាញមាត់ឲ្យបឺតជញ្ជក់ដោយក្ដីស្រេកឃ្លាន។

"ដើមទ្រូងស្អាតណាស់ លីលី...អ៊ុំ..."

"អ៊ំា...អ៊ំា..."

ការប៉ះពាល់ដំបូងដែលត្រូវបឺតជញ្ជក់ ឲ្យអារម្មណ៍ស្រួចរលែមហាក់ដូចត្រូវចុងកាំបិតចាក់ តែពេលគេបឺតខ្លាំងៗ មុខស្រួចរលែមរបស់កាំបិតក៏ក្លាយជាភាពផ្អែមល្ហែមដ៏ខ្លាំងក្លា។ នាងអ៊ែនទ្រូងទៅរក មុខឡើងក្រហមង៉ាំងដោយ



អារម្មណ៍ស្រៀវស្រើបខ្លាំង។

"បង ម៉ាត...អំា...អំា..."

នាងខ្ទាំសក់ក្រាស់ អ៊ែនដើមទ្រូងមកឲ្យគេបិតជញ្ជក់បានស្រួល។

"អំា...អំា..."

ម៉ាទិនេស ដកដង្ហើមចូលឲ្យពេញសួត ដើម្បីគ្រប់គ្រងខ្លួនឯង មិនឲ្យជ្រែកភាពមហិមាចូលទៅក្នុងរាងកាយតូចច្រឡឹងភ្លាមៗ។

អ្នកកំលោះងើបខ្លួនបន្តិច សម្លឹងមើលរាងកាយរបស់ភរិយា ដែលកំពុងរើបម្រះដោយអារម្មណ៍ឈ្លក់វង្វេង មុខស្រស់ស្រទន់ឡើងក្រហមងុំាង រាងកាយក៏ទន់ល្មក ព្រោះត្រូវគេដាស់ដោយការប៉ះពាល់នៃការប្រាថ្នា។

ម្រាមដៃស្រឡូនដូចមនុស្សស្រីអូសទៅរកពោះរាបស្មើ គ្មានជាតិខ្លាញ់ ធ្វើឲ្យនាងប្រឹងឡើងរឹងពោះទទួលយកការប៉ះពាល់របស់គេដោយការពេញចិត្ត បន្ទាប់មកម្រាមដៃនោះក៏ជ្រែកចូលតាមចង្កេះខោក្នុង ហើយទាញវាទម្លាក់ពីត្រគាកមូលក្លំ ទៅរកជើងស្រឡូន។ កែវភ្នែកមុតស្រួចបើកធំៗ ពេលមើលឃើញផ្កាលីលីស្រស់ដែលលាក់ខ្លួននៅក្រោមស្លឹក។

គេគ្រហឹមឮខ្លាំងៗ ភ្លើងប្រាថ្នានៅក្នុងខ្លួនកំពុងតែឆេះសន្ធោសន្ធៅ។ យ្យូលី ស្អាតមែនទែន រាងរៅរបស់នាងហាក់ដូចនាឡិកាខ្សាច់ ដើមទ្រូងធំ ចុងមានពណ៌ស្រស់ ចង្កេះតូចសមនឹងត្រគាកមូលក្លំគួរឲ្យគ្រប់គ្រង។

គេរឹងស្ទើរតែផ្ទុះ តម្រូវការកាន់តែពុះកញ្ជ្រោលសឹងតែធ្លាយចេញមកតាមមាត់។ គេចង់យោក ចង់ត្រលែង ចង់បំបោលនៅលើរាងកាយរបស់ភរិយាឲ្យសមនឹងចិត្តចង់ ចង់ជ្រែកចូលទៅឲ្យជ្រៅៗ ឲ្យនាងស្រែកឮខ្លាំងៗ ព្រោះតែភាពស្រៀវស្រើប ហើយនាំនាងទៅកាន់ឋានសួគ៌ម្តងហើយម្តងទៀត។

អ៊ំ...នេះគេកើតអី ហេតុអីបានជាគ្រប់គ្រងខ្លួនឯងលំបាកបែបនេះ ទាំង



ដែលកាលមុនគេគ្រប់គ្រងខ្លួនឯងបានល្អជាងនេះ មិនធ្លាប់បែកឆ្វេងដោយសារសម្រស់របស់ស្រីឆ្នូមគ្រែ តែសម្រាប់ យ្យូលី ស្ត្រីម្នាក់នេះវិញបែរជាធ្វើឲ្យគេទប់ស្មារតីមិនជាប់។

"អ៊ំ...លីលី...ពេញដៃតែម្តង"

គេងើយមើលមុខក្រហមងុំាង ដែលពេលនេះកំពុងមានភាពខ្វល់ខ្វាយដោយការឈ្លក់វង្វេង ប្រចាច់ដើមទ្រូងណែនក្បុំម្តងហើយម្តងទៀត ញក់ញីចុងរបស់វាទាស់តែហើម ហើយកៀបដោយម្រាមដៃ ទាញឡើងលើ បន្ទាប់មកក៏ព្រលែងខ្លាំងៗ។

"អំា...អំា...អំា..."

យ្យូលី ថ្ងូចថ្ងូរ រើបម្រះហាក់ដូចត្រូវស្រោចដោយទឹកក្តៅ ព្រមទាំងអ៊ែនត្រគាកមកត្រដុសនឹងភាពមហិមារឹងកំព្រឹសរបស់ ម៉ាទិនេស ជាការអញ្ជើញ។

"សូមមេត្តា...បង ម៉ាត...ខ្ញុំក្តៅ...អំា..."

នាងរើបម្រះ ត្រលែងទៅត្រលែងមកនឹងពូកដោយភាពវេទនា អ៊ែនផ្កាស្រស់មករកដោយការអង្វរករ ហេតុអីក៏គេមិនព្រមជួយ...ជួយឲ្យនាងរសាយពីការឈឺចាប់ត្រង់ប្រឡោះភ្លៅ។

"សូមមេត្តា...អំា..."

"វ៉ាវ! ក្តៅគគុកណាស់ លីលី...បងទ្រាំលែងបានហើយ...អ៊ំ..."

គេគ្រហឹម ឱនមកខាំបបូរមាត់ក្រពុំម្តងទៀត បន្ទាប់មកក៏អូសបបូរមាត់ក្តៅមកបឺតចុងទ្រូង បឺតវាដោយការស្រេកឃ្លានខ្លាំង ខាំទាល់តែនាងឈឺ និងលិឍទាស់តែសើម ធ្វើឲ្យនាងស្រែកថ្ងូចថ្ងូរ ហាក់ដូចជិតដាច់ខ្យល់ស្លាប់។

"អំា...បង ម៉ាត...ជួយខ្ញុំផង...អំា...ខ្ញុំ...អឺ...អំា..."

"លីលី ចង់ឲ្យធ្វើអី...ពៅព្រលឹង...ចង់ឲ្យបងបិតមែនទេ"



"ចាំ...ចាំ...បង ម៉ាត...ជួយខ្ញុំផង...អ៊ំា..."

"ចង់ឲ្យលិឍដែរអត់ ?"

"ចាំ...បង ម៉ាត...ចង់បឺត ចង់លិឍក៏ឆាប់ធ្វើទៅ ខ្ញុំ...ក្ដៅ...ក្ដៅចង់ឆេះទៅហើយ...អ៊ំា...អ៊ំា..."

ដៃដែលខ្វាំពូក លើកមកខ្វាំសក់របស់គេខ្លាំងៗ សង្កត់ក្បាលរបស់គេឲ្យបឺតជញ្ជក់បានស្រួលជាងមុន និងខ្លាំងជាងមុនតាមដែលនាងត្រូវការ។

"ក្ដៅគគុកមែនទែន ប្រពន្ធបង"

យ៉ូលី ក្ដាប់ដៃណែន កែវភ្នែកមានផ្កាភ្លើង។

"ហុងស៊ីល យើងទៅកន្លែងផ្សេងទៅ កាហ្វេខ្ញុំចត់ខារហើយ"

"ចាំ អ្នកនាង"

ហុងស៊ីល ម៉្នីម្នាដើរតាមចៅហ្វាយចេញពីហាងកាហ្វេ ដោយមានខ្សែភ្នែកឈ្នានីសឫស្យារបស់ ជីយ៉ន តាមមើលពីក្រោយ។

"ខ្ញុំដឹង...យ៉ាងណាក៏ឯងទៅតាមលោកនាយក"

ស្នាមញញឹមរបស់ ជីយ៉ន ជាស្នាមញញឹមគួរឲ្យខ្លាច។

ពេលចុះពីរថយន្តហើយ យ៉ូលី ក៏ដើរនាំមុខ ហុងស៊ីល ចូលទៅក្នុងផ្ទះ ហើយងាកមកប្រាប់ដោយទឹកមុខខ្សោះល្វើយ។

"បងទៅសម្រាកចុះ ខ្ញុំឡើងទៅបន្ទប់ហើយ"

"ខ្ញុំទៅលាយទឹកក្ដៅឲ្យអ្នកនាងងូត"

នាងក្រមុំគ្រវីក្បាលតិចៗ និងសើចញឹមៗដាក់។

"មិនបាច់ទេ ពេលនេះខ្ញុំមិនចាំបាច់ធ្វើពុតជាពិការជើងទៀតទេ ខ្ញុំអាចមើលថែខ្លួនឯងបាន"



"មែនហើយ មិនចាំបាច់ធ្វើពុតជាពិការជើងទៀតទេ គឺអាចចេញទៅណាមកណាជាមួយប្រុសណាក៏បាន"

សំឡេងគ្រលរបន្លឺឡើងនៅក្រោយខ្នង ធ្វើក្រមុំខុសវៃយទាំងពីរងាកទៅមើលដំណាលគ្នា ទើបឃើញ ម៉ាទិនេស កំពុងដើរមករកដោយមុខក្រញូវ។

"លោក ម៉ាត មិនបានទៅធ្វើការទេឬ ?" ហុងស៊ីល ធ្វើជាសួរ ដើម្បីជួយបន្ធូរបន្ថយស្ថានការណ៍តានតឹងនៅចំពោះមុខ តែបែរជាជួយអីមិនបាន ពេលស្វាមីភរិយាសម្លក់គ្នាថ្មែ។

"ឡើងទៅនិយាយជាមួយបងនៅបន្ទប់" ម៉ាទិនេស ប្រាប់ និងស្រវាចាប់ដៃនាង។

"លែងដៃខ្ញុំ"

"ឬត្រូវឲ្យបងបី ?"

ការគំរាមរបស់គេ ធ្វើឲ្យ យ្យូលី ងាកទៅរកអ្នកមើលថែជំនិតភ្លាម តែហុងស៊ីល មិនអាចជួយអីបាន។

"ខ្ញុំ...សុំទៅសិនហើយអ្នកនាង"

"ឈប់សិន ហុងស៊ីល...ជួយខ្ញុំផង"

"គ្មានអ្នកណាជួយអូនបានទេ យ្យូលី"

នាងក្រមុំខ្ចីបមាត់ ព្រមដើរឡើងទៅបន្ទប់តាមការអូសដៃរបស់គេដោយជួយខ្លួនឯងមិនបាន។

"បង ម៉ាត...ចាក់សោទ្វារធ្វើអី" ពេលឃើញគេបិទទ្វារ ចាក់សោ នាងក៏ស្រែកសួរ។

ពេលបិទទ្វារ ចាក់សោរួចរាល់ ម៉ាទិនេស ក៏ដើរទៅរកភរិយា ដោយទឹកមុខមាំ គ្មានការបន្ធូរបន្ថយឲ្យ។

"ទៅណាជាមួយអ្នកជំនាញ គីម ?"

"ខ្ញុំមិនចាំបាច់ត្រូវប្រាប់បងទេ"



នាងពើងទ្រូង ងាកមុខចេញ ទើបត្រូវគេប្រើម្រាមដៃក្តៀយចង្កា បង្ខំឲ្យងាកមកប្រសព្វភ្នែកជាមួយ។

"ចាំបាច់! ព្រោះបងជាស្វាមីរបស់អូន"

"គ្រាន់តែ..."

"បើចង់និយាយថាគ្រាន់តែជាស្វាមីក្នុងនាម អីចឹងប្តូរពាក្យនិយាយបានហើយ" គេនិយាយកាត់ ដោយដឹងគំនិតរបស់នាង "ព្រោះអូនក៏ដឹងដែរថា យើងទាំងពីរលើសពីនោះហើយ"

គេមានចេតនានិយាយឲ្យនាងខ្មាស ឲ្យថ្ពាល់ឡើងក្រហម។

"នោះមកពី...បងចាប់បង្ខំខ្ញុំ"

អ្នកកំលោះញញឹមចុងមាត់ ទាញនាងមកឱបជាប់ទ្រូង និងរឹតកាន់តែណែន ពេលនាងរើបម្រះ។

"លែងខ្ញុំ"

"មិនលែង ហេតុអីបងត្រូវលែងអូន ក្នុងពេលដែលបងមានសិទ្ធិចំពោះអូនពេញទី"

"មនុស្សផ្តាច់អំណាច"

គេញញឹមចុងមាត់ម្តងទៀត និងឱនមុខសង្ខាមកជិត។

"ចាំទុក! ហាមចេញទៅណាមកណាជាមួយប្រុសផ្សេងទៀត ព្រោះបងមិនចូលចិត្ត"

"ខ្ញុំមិនមែនជាអ្នកទោសរបស់បងទេ"

"ព្រោះអូនមិនមែនជាអ្នកទោសហ្នឹងហើយ តែជាប្រពន្ធបង អីចឹងហើយហាមទៅណាមកណាជាមួយប្រុសផ្សេងទៀត សូម្បីតែអ្នកជំនាញ គីម"

"ហុងស៊ីល ទៅជាមួយតើ ហើយខ្ញុំក៏មិនបានធ្វើអីមិនល្អដែរ"



"បងដឹងថាអូនមិនបានធ្វើអីមិនល្អ តែបងមិនចូលចិត្តឲ្យប្រុសផ្សេងមើលប្រពន្ធបង អីចឹងហើយស្តាប់បញ្ជាបងផង"

គេមិនបានសុំចិត្ត តែជាការបញ្ជានិងគំរាម ទើបធ្វើឲ្យនាងធ្វើមុខក្រមូវដាក់ និងតវ៉ាដោយការងរង៉ក់។

"បង ម៉ាត ផ្តាច់ការ ម៉េចក៏ទំនើងបែបនេះ"

"ព្រោះបងហួងហែងអូន"

នាងក្រមុំភាំងនឹងអ្វីដែលបានឮ ព្យាយាមហាមគំនិតដែលកំពុងលោតកញ្ឆេងនៅក្នុងចិត្ត។

"បង ម៉ាត...និយាយលេងមែនទេ ?"

"ហេតុអីបងត្រូវនិយាយលេង បងហួងហែងអូន ហួងហែងប្រពន្ធបងដឹងទេ"

និយាយហើយ គេក៏សង្កត់ច្រមុះស្រួចនឹងថ្ពាល់រលោង ធ្វើឲ្យបេះដូងរបស់នាងសឹងតែខ្ទាតចេញពីទ្រូង ព្រោះលោតញាប់ពេក ហើយក៏ព្យាយាមតតាំងនឹងមន្តស្នេហ៍របស់គេដែរ តែវាលំបាកមែនទែន។

"ហើយ...ហេតុអីបង ម៉ាត ផ្អែមល្ហែមនឹងសាស្ត្រាចារ្យ គីម បាន"

ទីបំផុតនាងក៏សួរសំណួរដែលស្ទះនៅក្នុងចិត្តយូរហើយ ទើបគេសម្លឹងភ្នែកមូលក្លុំ។

"បងនិងសាស្ត្រាចារ្យ គីម គ្មានស្អីនឹងគ្នាទេ គ្រាន់តែជាមិត្តរួមការងារជាចៅហ្វាយនិងកូនចៅប៉ុណ្ណោះ"

"តែស្រីនោះចូលចិត្តរត់តាមបងរហូត"

"ទះដៃម្ខាងមិនឮទេ លីលី បើបងមិនលេងជាមួយ ក៏គ្មានអ្នកណាអូសបងឡើងគ្រែបានដែរ"



នាងជ្រួញច្រមុះដាក់អ្នកដែលមានទំនុកចិត្តខ្ពស់ចំពោះខ្លួនឯង ដោយការជិនឆ្អន់។

"ខ្ញុំនឹងមិននិយាយរក មិនជួបប្រុសណាទៀតទេ បើបងអាចរលាស់ស្រីម្នាក់នោះចេញឲ្យឆ្ងាយពីខ្លួនបាន អូខេទេ ?"

ស្នាមញញឹមលេចលើបបូរមាត់ស្អាតភ្លាម។

"បងត្រូវជួបសាស្ត្រាចារ្យ គីម នៅពេលខ្លះ ព្រោះយើងមានការងារត្រូវធ្វើជាមួយគ្នា តែបងមិនព្រមនៅជាមួយនាងតែពីរនាក់ដាច់ខាត ហើយបើអាចទៅរួច បងនឹងនាំអូនទៅជាមួយគ្រប់ពេល"

"ច្បាស់ហើយ ?"

"ច្បាស់ហើយ អូ្ន! បងមានរឿងត្រូវប្រាប់"

ម៉ាទិនេស ទាញនាងដើរទៅអង្គុយលើគ្រែជាមួយ។

"ស្អែកបងត្រូវទៅសមុទ្រខាងត្បូងជាមួយសាស្ត្រាចារ្យ គីម"

អ្នកស្តាប់រឹងខ្លួនស្លុកភ្លាម ហើយក៏ឡូឡាដោយការតូចចិត្តភ្លាមដែរ។

"ឃើញទេ ឃើញថាបងធ្វើដូចមាត់និយាយមិនបាន"

"បងនាំអូនទៅដែរ"

យ៉ូលី ងាកខ្ទាប់ទៅមើលមុខគេ។

"ច្បាស់ហើយថាខ្ញុំមិនទៅជាឆ្អឹងទទឹង.កបងនិងស្រីនោះ"

អ្នកកំលោះឱនមកសម្លឹងមុខស្រស់ស្អាតដោយចិត្តឈ្លក់វង្វេង។

"ម៉េចក៏គិតបែបនេះ លីលី ក្នុងភ្នែកបង មានតែប្រពន្ធម្នាក់គត់"

"មិនជឿ"

"ឲ្យបងធ្វើម៉េច ទើបអូនជឿ"

កែវភ្នែកមុតស្រួច សម្លឹងមើលនាងដោយការស្រេកឃ្លាន ហើយវាក៏ធ្វើ





Scanned with CamScanner

ឲ្យនាងខះ.កមួយរំពេច ជំពប់ខ្យល់ដង្ហើម រាងកាយក្តៅហាក់ដូចមានភ្នក់ភ្លើងនៅខាងក្នុង។

"ឬថា...ត្រូវធ្វើដូចយប់មិញ"

"ឆ្កួត...បង ម៉ាត លាមក"

"បងលាមកដាក់អូនតែម្នាក់ លីលី"

និយាយហើយ គេក៏អង្អែលស្មាតូចស្តើងដែលមានអាវបិទបាំង សំឡេងទៅជាស្អកខ្សោះ។

"បើអូនមិនជឿ...បងរីករាយពិសោធឲ្យអូនឃើញពេញមួយថ្ងៃ"

"បង ម៉ាត...និយាយស្អីក៏មិនដឹង"

អ្នកកំលោះញញឹមគ្រេកកាមដាក់។

"ដោះអាវចេញទៅអូនសម្លាញ់"

"ដោះ...ដោះ...ធ្វើអី...អុំយយយ!"

នាងនិយាយមិនទាន់ចប់ស្រួលបួលផង ក៏ត្រូវមនុស្សចិត្តអាក្រក់ចាប់ទាញអាវចេញពីខ្លួន ធ្វើឲ្យដាច់ឡេវ ខ្ទាតជុំទិស ដោយអាវក្នុងត្រូវចាត់ការនៅពេលបន្ត។

"បង ម៉ាត...កុំ"

"កុំហាមបង"

គេលូកដៃទៅក្រោយ ដោះតម្កក់អាវក្នុង ហើយទាញវាចេញ ឲ្យដើមទ្រូងណែនក្បុំ ដែលចុងលម្អដោយផ្លែឈើក្រហមស្រស់លោតដាក់ភ្នែក កែវភ្នែកមុតស្រួចបើកធំៗ និងនិយាយរអ៊ូៗដោយការពេញចិត្ត។

"ស្អាតណាស់ លីលី..."

ពាក្យសរសើរចេញពីមាត់របស់ស្វាមី បង្កឲ្យកើតជារលកកម្តៅដ៏ខ្លាំងក្លា



ក្នុងពោះរបស់នាង វាវិលខ្វាល់ដូចខ្យល់កួច។

"អឺ..."

នាងដកដង្ហើមចូលឲ្យពេញសួត ភាពរំភើបញាប់ញ័រនៅតែហែកហួររាងកាយ ពេលដែលខ្សែភ្នែកមុតស្រួចមិនព្រមងាកចេញ។ នាងស្រៀវស្រើបសព្វសាច់ ទោះមានអារម្មណ៍ខ្មាសអៀន តែប្រាថ្នាឲ្យគេសម្លឹងមើលពន់ពេក។

"លីលី ជារបស់បង...ហាមនៅជិតប្រុសផ្សេងទៀត ដឹងទេ"

គេចេញបញ្ជាដោយសំឡេងខ្សឹបៗ តែមានអំណាច កែវភ្នែកមិនព្រមដកចេញពីដើមទ្រូងណែនក្បុំសូម្បីតែមួយវិនាទី។

"ចាំ ខ្ញុំនឹងព្យាយាម"

ម៉ាទិនេស គ្រវីក្បាលតិចៗ។

"ត្រូវតែធ្វើឲ្យបាន ព្រោះបើមិនស្តាប់បង្គាប់ បងនឹងដាក់ទោសអូនដោយរាងកាយរបស់បងរាល់យប់"

គេលើកដៃជ្រងសក់របស់នាង កន្ត្រាក់តិចៗឲ្យនាងផ្អួលខ្លួនដេកទៅលើគ្រែ ដោយខ្លួនឯងតាមទៅទ្រាបពីលើ ហើយហាមាត់ត្របាក់លេបផ្លែឈើរីដោយក្តីស្រេកឃ្លាន ដោយផ្លែឈើមួយគ្រាប់ទៀតត្រូវម្រាមដៃរឹងមាំញក់ញី។

"អាំ...អាំ...បង ម៉ាត..."

នាងមិនអាចទប់សំឡេងថ្ងូចថ្ងូររបស់ខ្លួនបាន រាងកាយក៏ញ័រទទ្រើតហាក់ដូចត្រូវព្យុះសង្ឃរាបោកបក់ ទាំងកាយទាំងចិត្តផ្ចង់ទៅលើបាតដៃធំដែលកំពុងឈ្លីច្របាច់ដើមទ្រូងណែនក្បុំ។ គេបំបែកសតិរបស់នាងឲ្យបែកខ្ចាយដោយការត្រដុសម្រាមដៃលើដើមទ្រូងតែចុងរបស់វាឡើងរឹង ឲ្យនាងថ្ងូចថ្ងូរ អ៊ែនត្រគាកមូលភ្លុំមករកគេ អង្វរករសុំក្តីមេត្តាពីគេ។

"អាំ...អាំ..."



ពេលនៅលើគ្រែ នាងមិនធ្លាប់បានទទួលក្ដីមេត្តាពី ម៉ាទិនេស សូម្បីតែម្ដង ដែលលើកនេះក៏អ៊ីចឹងដែរ។ គេមានចេតនាល្បួងនាងទម្លាក់អន្លង់តណ្ហាជ្រៅ និងឃុំឃាំងនាងនៅក្នុងនោះ ដោយការឱនមកត្រវាសអណ្ដាតលើចុងទ្រូង និងជញ្ជក់វាដោយប្រអប់មាត់ ទាំងជញ្ជក់ ទាំងខាំញេញដោយក្ដីស្រេកឃ្លាន។ នាងដង្ហើមដង្ហក់ ទាញសក់ក្បាលគេខ្លាំងៗ ខណៈនោះក៏អ៊ែនខ្លួនទៅរកដោយមិនអាចប្រឆាំងនឹងភាពស្រៀវស្រើបបាន។

"អំា...បង ម៉ាត...អំា..."

គេបិតជញ្ជក់ដើមទ្រូងរបស់ យ៉ូលី ទាំងសងខាងមិនយូរប៉ុន្មាន ក៏ងើបចេញ ដើម្បីដោះសម្លៀកបំពាក់ដោយភាពអន្ទះអន្ទែង ធ្វើឲ្យនាងភ្លឹកមើលយ៉ាងយូរ មិនអាចដកខ្សែភ្នែកចេញពីរាងកាយសម្បូរបែបនេះបាន។ គេសិចស៊ីអង្រួនចិត្ត មានភាពជាបុរសភេទពេញខ្លួនមួយរយភាគរយ មាំមួនសព្វសាច់ជាពិសេសត្រង់នោះ...ដែលធ្វើឲ្យនាងក្រមុំលេបទឹកមាត់ក្អឹកៗ ព្រោះត្រង់នោះខុសគ្នាពីត្រង់នេះរបស់នាងឆ្ងាយណាស់។

ថ្ពាល់រលោងឡើងក្រហមង៉ាំង រាងកាយក្ដៅគគុក ហាក់ដូចមានភ្នក់ភ្លើងរាប់រយភ្នក់ដុតនៅក្នុងនោះ ទឹកដមរបស់លីលីក៏ជ្រាបចេញមកជាបន្តបន្ទាប់ ទើបនាងត្រដុសជើង ដើម្បីកម្លាយភាពតានតឹងនេះ។

"សូមមេត្តា...បង ម៉ាត..."

នាងលើកដៃឱបរាងកាយមាំមួនណែនដៃ ពេលគេឡើងមកទ្រាបពីលើម្ដងទៀត និងសម្លឹងមើលគេដោយការអង្វរករ។

"ចង់បានអីប្អូនស្រីស្អាតរបស់បង" ម៉ាទិនេស ខ្សឹបសួរដោយសំឡេងស្អក និងឱបថើបបបូរមាត់ក្រពុំម្ដងទៀត នាងក៏បង្ហើបបបូរមាត់ថើបតបដោយការប្រាថ្នាដ៏ខ្លាំងក្លាក្លាម ព្រមទាំងអ៊ែនត្រគាកទៅត្រដុសនឹងរាងកាយមាំមួន ផ្ចិត



យកអារម្មណ៍ពេលរោមរីងៗប៉ះនឹងស្បែករលោង ដែលឲ្យអារម្មណ៍ទន់ភ្លន់មានសេចក្ដីសុខ ហើយសំឡេងគ្រលរព្ញរហ៊ឹមៗនៅដើម.ក ធ្វើឲ្យនាងមានតម្រូវការកាន់តែខ្លាំង។

"សូមមេត្តា...ខ្ញុំ...ត្រូវការបង ម៉ាត...អំា..."

ម៉ាទិនេស ញញឹមដោយការស្រេកឃ្លាន លោយកខ្នើយមកសិករក្រោមត្រគាកមូលក្លុំ បន្ទាប់មកក៏ភ្ជង់ភាពមហិមានឹងភាពទន់ជ្រាយ។ យ៉ូលី ងើយក្បាលទៅក្រោយ ស្រែកថ្ងូរដោយការទន្ទឹងរង់ចាំ ហើយជ្រែកចូលទៅរកដោយថាមពលខ្លាំងក្លា។

"អំា...អំា...អំា...បង ម៉ាត..."

ភាពតឹងណែននៅតែកើតមានដូចដើម តែដែលមានច្រើនជាងរាល់ដងគឺភាពស្រៀវស្រើបដែលវាអស្ចារ្យមិនអាចគណនាបាន មានតែគេ...មានតែគេធ្វើចលនានៅក្នុងរាងកាយ វាជាទីបំផុតនៃការប្រាថ្នាហើយ។

យ៉ូលី រលីងរលោងទឹកភ្នែកដោយភាពស្កប់ស្កល់ អ៊ែនខ្លួនទៅទទួលយកការគ្រប់គ្រងយ៉ាងខ្លាំងក្លារបស់ស្វាមី។

ម៉ាទិនេស ធ្វើចលនាសាហាវទៅៗ ឲ្យនាងអណ្ដឺតអណ្ដកហៅឈ្មោះរបស់គេ ខណៈនោះក៏ផ្ចិតយកអារម្មណ៍ពេលដែលមានភាពមហិមារបស់បុរសធ្វើសកម្មភាពនៅក្នុងរាងកាយជាចង្វាក់ញាប់ស្ទេក។

"អ៊ូ...អ៊ូ លីលី...អំា..."

ចង្វាក់ប្រាថ្នារបស់គេកាន់តែក្ដៅ កាន់តែខ្លាំង ធ្វើឲ្យរាងកាយរបស់នាងចង់បាក់ជាពីរ តែភ្លើងក្ដៅគគុកដែលកំពុងដុតរាងកាយទាំងពីរមិនព្រមរលត់។ រាងកាយទាំងពីរនៅតែនែបនិត្យជិតគ្នាម្ដងហើយម្ដងទៀត រហូតដល់ការស្រេកឃ្លានទៅដល់ចំណុចខ្ពស់បំផុត សំឡេងគ្រហឹមក៏បន្លឺឡើង បន្ទរដោយសំឡេង



ថ្ងូចថ្ងូរដ៏ពីរោះ។

រាងកាយទាំងពីរញ័រទទ្រើតដោយអំណាចប្រាថ្នា វង្វេងក្នុងអ័ព្ទប្រាថ្នាដោយរកផ្លូវចេញមិនឃើញ រហូតដល់ភាពអស្ចារ្យកន្លងផុតទៅច្រើននាទី ទើបគេប្រែខ្លួនទៅដេកលើពូក ដោយមិនភ្លេចទាញនាងមកឱបជាប់ដើមទ្រូង ភ្នែកក៏សម្លឹងមើលភរិយាដោយអារម្មណ៍ផ្អែមល្ហែមនិងទន់ភ្លន់។

"ស្រីស្អាតរបស់បង..."

គេនិយាយរង៉ូវៗ ហើយនាំនាងឡើងជណ្តើរឋានសួគ៌ជាថ្មី ម្តងហើយម្តងទៀតដោយមិនចេះហត់នឿយ។



# ១៥

ពេលរសៀលថ្ងៃបន្ទាប់ ម៉ាទិនេស ក៏នាំ យ្យលី មកសមុទ្រខាងត្បូងដោយមាន ហុងស៊ីល មកជាមួយ ដោយមកជួប ជីយ៉ន ដែលនាំប្អូនប្រុសម្តាយទីទៃមកជាមួយនៅមុខសណ្ឋាគារដែលត្រូវចូលសម្រាក។ ទឹកមុខរបស់ ជីយ៉ន មិនបានបង្ហាញឲ្យឃើញពីភាពអស់សង្ឃឹមដូចដែលនាងគិត ផ្ទុយទៅវិញស្រីចំពុះក្រហមបែរជាញញឹមលាក់កំណួច។

"ខ្ញុំបើកឡានផ្លូវឆ្ងាយមិនសូវបាន ទើបពឹងពាក់ឲ្យប្អូនប្រុសបើកមក លោកនាយកប្រហែលមិនថាអីទេ ដែលខ្ញុំនាំប្អូនប្រុសមកជាមួយ"

"ខ្ញុំមិនថាអីទេ អញ្ជើញចុះ"

ទឹកមុខរបស់ម៉ាទិនេសរាបស្មើគ្មានអារម្មណ៍ប៉ុន្តែដៃរបស់គេនៅតែក្តោបដៃរបស់ យ្យលី គ្រប់ពេលវេលា។

"អីចឹងខ្ញុំនិង តេយ៉ុង សុំយកកាបូបទុកនៅបន្ទប់សិន បន្តិចទៀតចុះមកវិញ"

"អញ្ជើញ"

ជីយ៉ន ញញឹមដាក់នាងនិង ម៉ាទិនេស ហើយនាំប្អូនប្រុសដើរចូលក្នុងសណ្ឋាគារ ដែល យ្យលី ក៏តាមមើលដោយការងឿងឆ្ងល់ តែមិនបាននិយាយអី។

"ខ្ញុំថាស្រីចំពុះក្រហមនោះធ្វើខ្លួនប្លែកៗអ្នកនាង"

ហុងស៊ីល ក៏មានការសង្ស័យមិនចាញ់ចៅហ្វាយរបស់ខ្លួនដែរ។

"ប្លែកយ៉ាងម៉េច ?"



"គឺនៅតែញញឹមញញែមពេលឃើញអ្នកនាងនិងលោក ម៉ាត"

មែនហើយនាងក៏គិតអីចឹងដែរ តែមិនអាចរកហេតុផលអីមកជានាបានថាព្រោះអ្វី។

"ប្រហែលគ្មានអីទេ"

"សូមឲ្យអីចឹងចុះ ខ្ញុំថាអ្នកនាងត្រូវប្រយ័ត្នខ្លួនបន្តិច ខ្ញុំបារម្ភ"

ម៉ាទិនេស នៅឈរស្តាប់ស្រីៗសន្ទិដ្ឋានដោយមិនមាត់មិនកយ៉ាងយូរទើបនិយាយកាត់។

"អានប្រលោមលោកច្រើនពេកឬអត់ស្រីៗ"

"នេះបងគិតថាខ្ញុំនិងបង ហុងស៊ីល ប៉ិនស្រមើស្រមៃឬ"

អ្នកកំលោះអស់សំណើច។

"បងមិនបាននិយាយទេ អូននិយាយដោយខ្លួនឯង"

និយាយហើយគេក៏សើចក្អាកក្អាយ ធ្វើឲ្យ យ្យូលី ខ្វរមុខ។

"លីលី"

ម៉ាទិនេស រហ័សដើរតាម ខណៈដែល ហុងស៊ីល យួរកាបូបទៅទុកក្នុងបន្ទប់តាមតួនាទី។

"មិនបាច់តាមមកទេ"

នាងប្រឹងដើរសំដៅឆ្នេរខ្សាច់ ប៉ុន្តែគេនៅតែដើរតាម ហើយពេលទាន់ក៏ស្រវាចាប់ដៃរបស់នាង។

"ម៉េចក៏ប្រពន្ធបងប៉ិនងរម្លេះ"

"មនុស្សឆ្កួត...ខ្ញុំមិនមែនប្រពន្ធបងទេ អ៊ូយ...លែងខ្ញុំបង ម៉ាត តិចមានគេមកឃើញ" នាងឡូឡា មិនសប្បាយចិត្ត ពេលត្រូវស្វាមីទាញទៅឱបជាប់ទ្រូង។



"មិនមែនប្រពន្ធបងឬ អីចឹងបងពិសោធឲ្យមើល"

មុខរបស់នាងឡើងក្រហមង៉ាំង។

"បងឆ្កួតហើយ នែលែងខ្ញុំ នោះ...គេឯងមើលហើយ"

"អីចឹងនិយាយម្តងទៀតមកថាយើងត្រូវជាស្អីនឹងគ្នា"

"បង ម៉ាត"

គេលោមករក ទឹកមុខក៏ប្រាកដប្រជា។

"បើមិននិយាយ បងនឹងថើបនៅនៅត្រង់នេះ ថើបឲ្យហើមមាត់តែម្តង"

"បង ម៉ាត ឆ្កួត..." នាងអៀនសឹងស្លាប់ទៅហើយ។

"និយាយមក"

នាងគេចខ្សែភ្នែកពីគេ រសស្នេហាដែលគេប្រគល់ឲ្យរាល់យប់នៅតែជិតដាមជាប់ការចងចាំ។

"ហ៊ឺ...និយាយមក អូនត្រូវជាស្អីនឹងបង..." គេនិយាយបង្ហួសសំឡេងយ៉ាងវែង "ប្អូនស្រី អ្នកជិតខាង...ឬប្រពន្ធបង..."

"ប្រពន្ធ"

នាងជ្រួញច្រមុះដាក់គេដោយការជិនឆ្អន់ ខណៈដែល ម៉ាទិនេស សើចដោយការចូលចិត្ត ហើយលើកដៃក្រសោបមុខរបស់នាង ឱនថើបជញ្ជក់បបូរមាត់ធ្វើឲ្យនាងភ្ញាក់ព្រើត ប្រឹងរុញគេចេញ តែមិនយូរប៉ុន្មានក៏ទន់ខ្លួនល្អក។

"ក្រែងបងប្រាប់ថាមិន...ថើបនោះអី" នាងសួរគេដោយសំឡេងក្ងួរ មុខក៏ក្រហមព្រោះអៀន។

"គឺអូនគួរឲ្យស្រឡាញ់បងទប់ចិត្តមិនបាន" គេនិយាយហើយ ក៏ស្រវាចាប់កដៃរបស់នាង "យើងទៅដើរលេងនៅឆ្នេរខ្សាច់ទៅ ថ្ងៃនេះអាកាសធាតុល្អ ថ្ងៃក៏មិនក្តៅ"



នាងក្រមុំដែលនៅតែពុលរសថើប ត្រូវដើរតាមការដឹកដៃរបស់គេដោយគ្មានជម្រើស ខណៈនោះក៏អត់ញញឹមមានសេចក្ដីសុខមិនបាន។

**ពេលយកកាបូបទៅដាក់នៅក្នុងបន្ទប់សម្រាករួចរាល់ហើយ ជីយ៉ន ក៏**ចុះមករក ម៉ាទិនេស និងយកលេសរឿងសិក្ខាសាលាល្ងាចនេះមកប្រើដើម្បីបាននៅជិតគេ ប៉ុន្តែបែរជារកមិនឃើញ។

"បាត់ទៅណាហើយ"

"បងរកអ្នកណា?" តេយ៉ុង ដែលចុះមកដើរលេង ពេលឃើញបងស្រីក៏សួរនាំ។

"ឯងមកធ្វើស្អីត្រង់នេះ ម៉េចក៏មិនទៅរកនាងនោះទៅ"

តេយ៉ុង គ្រវីក្បាល។

"លោកស្រី អិន មកជាមួយស្វាមីរបស់គេ តើឲ្យខ្ញុំទៅរកធ្វើអី"

ជីយ៉ន ដើរមករកប្អូនប្រុស និងសម្លឹងមុខដោយការមួម៉ៅ។

"ឯងចង់ធ្វើជាមនុស្សល្អស្អីណាស់ណា គីម តេយ៉ុង បើឯងចូលចិត្ត ក៏ដណ្ដើមយកមកគ្រប់គ្រងមក មើលបងជាគំរូ បងចង់បានលោកនាយក បងត្រូវតែដណ្ដើមយកឲ្យបាន"

"ដោយមិនរើសវិធីអីចឹងឬ" គេជំទាស់ដោយការមិនយល់ស្រប។

"មែន មិនចាំបាច់គិតវិធីស្អីទេ សុំត្រឹមតែយកឲ្យបាន សុំត្រឹមតែឲ្យបានអ្វីដែលត្រូវការគឺគ្រប់គ្រាន់ហើយ"

ទឹកមុខរបស់ ជីយ៉ន ដូចតួបិសាចកាន់តែខ្លាំងទៅៗ។

"ហើយឯងត្រូវតែជួយបង"

តេយ៉ុង គ្រវីក្បាលភ្លាម។



"ខ្ញុំគ្រាន់តែបើកឡានជូនបងមកប៉ុណ្ណោះ កុំឲ្យខ្ញុំទៅពាក់ព័ន្ធ ត្រឹមខ្ញុំមិនប្រាប់ផែនការរបស់បងឲ្យលោកស្រី អិន ដឹង ចាត់ទុកថាល្អហើយ"

"គីម តេយ៉ុង!"

"ខ្ញុំដឹងថាបងមានគុណចំពោះខ្ញុំ ខ្ញុំរំភើបចិត្តណាស់ និងមិនធ្លាប់ភ្លេច តែខ្ញុំមិនអាចធ្វើអាក្រក់បាន ខ្ញុំមិនចូលចិត្តទង្វើបែបហ្នឹង ខ្ញុំសុំទោសដែលត្រូវនិយាយត្រង់ៗ...ខ្ញុំទៅសិនហើយ ចង់ទៅដើរលេង"

"បើឯងចង់ធ្វើជាមនុស្សល្អ ឯងនឹងអស់សង្ឃឹមមួយជីវិត បើឯងជួយបង ឯងនឹងបាននាងនោះធ្វើជាប្រពន្ធ ឬឯងមិនចង់បានវា គីម តេយ៉ុង"

ម្ចាស់ឈ្មោះទប់ដំណើរ ទឹកមុខក៏មាំ ប៉ុន្តែពន្លឺភ្នែកមានភាពរារែក។

"សហការនឹងបងទៅ"

នាងប្រាប់ប្អូនប្រុសម្ដងទៀត ប៉ុន្តែគេបែរជាដើរទៅមុខ មិនងាកមករកខ្លួន។

"អាប្អូនឆ្កួត! បងធ្វើម្នាក់ឯងក៏បាន មិនអង្វរឯងទេ"

នាងស្រែកខ្លាំងៗតាមពីក្រោយ ហើយដើរចូលទៅក្នុងសណ្ឋាគារវិញ។

ខណៈដែល តេយ៉ុង ដើរតាមឆ្នេរខ្សាច់ ចៃដន្យឃើញ យូលី កំពុងតែឈរឱបថើបជាមួយ ម៉ាទិនេស ល្មម ទើបគេឈប់ដើរ និងបែរខ្នងដាក់ភ្លាម ក្នុងចិត្តឈឺខ្លោចៗ។

"ម៉េចក៏ឈឺបែបនេះ" គេលើកដៃក្ដោបដើមទ្រូងខ្លួនឯង ហើយរត់ចេញពីទីនោះភ្លាម។

"អូននៅជាមួយ ហុងស៊ីល សិនទៅ ចង់ទៅដើរលេងនៅឯណា ប្រាប់ខាងសណ្ឋាគារ បងប្រាប់គេរួចហើយ" អ្នកកំលោះប្រាប់ភរិយាមុនពេលខ្លួនឯង



ចេញទៅចូលរួមធ្វើសិក្ខាសាលានៅសណ្ឋាគារជិតនេះ។

"អូនមិនចង់ទៅណាទេ ចង់លេងទឹកនៅម្តុំនេះ បងឆាប់មកវិញ"

"បាទ បងនឹងឆាប់មកវិញ"

ជីយ៉ន លួចពេបមាត់ដោយការជិនឆ្អន់ ហើយញញឹមបន្លប់។

"តោះយើងលោកនាយក តិចយឺតពេល"

ម៉ាទិនេស បើបថ្ពាល់ភរិយាមួយខ្សឹត ហើយសម្រេចកាត់ចិត្តថយចេញឲ្យឆ្ងាយ។

"បងទៅហើយ បងនឹងឆាប់មកវិញ"

"ចាំ"

ស្វាមីដើរសំដៅឡាន ទើប យ្យូលី បានប្រសព្វភ្នែកនឹង ជីយ៉ន ដោយចៃដន្យ ហើយក៏ឃើញការឡកឡឺយរបស់ស្រីចំពុះក្រហមនោះពេញភ្នែក ទើបខ្ទឹបមាត់ មានការមិនពេញចិត្ត។

"មើលខ្ញុំបែបនេះមានន័យថាម៉េច!"

ជីយ៉ន នៅតែញញឹមឡកឡឺយ ព្រមទាំងដើរមកឈរទល់មុខ។

"គ្មានស្អីទេ គ្រាន់តែ...កំពុងតែទៅធ្វើការជាមួយស្វាមីរបស់លោកស្រី... សុំទៅសិនហើយ ខ្លាចលោកនាយកចាំ"

"មើលនាងនោះបុះ វាគួរឲ្យទះផ្កាប់មុខ" ហុងស៊ីល តាមមើល ជីយ៉ន ដែលរត់តាម ម៉ាទិនេស ឡើងរថយន្តដោយការជិនឆ្អន់ ឯ យ្យូលី ក៏ជិនឆ្អន់ដែរ ប៉ុន្តែត្រូវលាក់អាការៈ។

"តាមតែគេទៅ យើងទៅដើរលេងនៅឆ្នេរខ្សាច់ទៅ"

"បាសអ្នកនាង"

ទោះព្យាយាមធ្វើចិត្តឲ្យត្រជាក់ ប៉ុន្តែហេតុអ្វីបានជាមានអារម្មណ៍មិនសប្បាយចិត្តបែបនេះ នាងមានអារម្មណ៍ថាដូចមានប្រផ្នូលស្រែកតឿនយ៉ាងអ្វីចឹង តែមិនដឹងថាវាជាអ្វី។



**យ្យូលី ដើរទៅដើរមកនៅក្នុងបន្ទប់សម្រាក ភ្នែកក្រឡេកមើលនាឡិកា** ព្យួរជញ្ជាំងសឹងតែគ្រប់ពេលវេលា។ ភាពខ្វល់ខ្វាយធ្វើឲ្យចិត្តរបស់នាងមិនស្ងប់ មិនអាចអង្គុយស្ងៀមបាន។

"អ្នកនាង អង្គុយសិនមក"

នាងងាកទៅរកអ្នកប្រាប់ ដោយទឹកមុខតានតឹង។

"ខ្ញុំអង្គុយម៉េចនឹងបាន បង ម៉ាត មិនទាន់មកផង តេរទៅក៏បិទទូរសព្ទទៀត"

"ប្រហែលអស់ថ្មទេដឹង" ហុងស៊ីល ព្យាយាមគិតនៅក្នុងផ្លូវល្អ។

"ទោះអស់ថ្ម តែបង ម៉ាត មិនគួរណានៅយប់ជ្រៅបែបនេះ នេះម៉ោងដប់មួយហើយ"

នាងតេរទៅរកគេតាំងពីម៉ោងប្រាំល្ងាច រហូតដល់ម៉ោងដប់មួយយប់ក៏មិនអាចទាក់ទងបាន តេរទៅខាងសណ្ឋាគារដែលជាកន្លែងរៀបចំកម្មវិធីសិក្ខាសាលា ក៏ប្រាប់ថា ម៉ាទិនេស ចេញទៅតាំងពីម៉ោងប្រាំល្ងាចម្ល៉េះ ហើយបែបនេះមិនឲ្យនាងបារម្ភពីគេម៉េចនឹងបាន។

"ឬថាលោក ម៉ាត មានគ្រោះថ្នាក់"

"ហុងស៊ីល...កុំនិយាយបែបនេះទៀត ខ្ញុំមិនស្រួលចិត្តតាំងពីព្រឹកម្ល៉េះ"

"ឬយើងតេរទៅសួរស្រីចំពុះក្រហម ក្រែងលោដឹងថាលោក ម៉ាត ទៅណា"

យ្យូលី ដកដង្ហើមធំ។



"តេរទៅក៏នាងមិនប្រាប់ដែរ បងក៏ដឹងដែរថានាងគិតតែដណ្ដើមយក បង ម៉ាត គ្រប់ដង្ហើម"

"អីចឹងយើងតេរទៅរកអ្នកជំនាញ គីម ល្អទេ ហើយប្រាប់ឲ្យគេតេរទៅសួរ បងស្រីឲ្យ"

នាងក្រមុំផ្ទាត់ម្រាមដៃយល់ស្របភ្លាម។

"មែនហើយ...ម៉េចក៏ខ្ញុំគិតមិនឃើញ អរគុណ ខ្ញុំនឹងតេរទៅគេឥឡូវនេះ"

និយាយហើយ នាងក៏ចុចទូរសព្ទទៅរក តេយ៉ុង ភ្លាម។

"អ្នកជំនាញ គីម នេះខ្ញុំ យ៉ូលី លោកគេងហើយឬនៅ?"

( នៅទេ លោកស្រីមានការអីឬអត់? )

"ខ្ញុំមានរឿងចង់ឲ្យជួយ"

ទោះព្យាយាមកាត់ចិត្តប៉ុណ្ណា ប៉ុន្តែ តេយ៉ុង ក៏នៅតែទន់ចិត្តដាក់ យ៉ូលី ដដែល។

( ប្រាប់មកខ្ញុំរីករាយជួយជានិច្ច )

"គឺ...ពេលនេះបង ម៉ាត មិនទាន់មកវិញ តាំងពីចេញទៅសិក្ខាសាលាកាលពីព្រឹកជាមួយបងស្រីរបស់លោក ទើបខ្ញុំ...ចង់សួរបងស្រីរបស់លោកថាដឹងដែរទេថាបង ម៉ាត បាត់ទៅណា?"

តេយ៉ុង ចងចិញ្ចើមភ្លាម។

( នេះលោក ម៉ាឡេសាសសូ មិនទាន់មកវិញទេឬ? )

"មែនហើយ ខ្ញុំបារម្ភណាស់"

( ខ្ញុំស្មានថាមានតែបងស្រីខ្ញុំតើដែលមិនទាន់ត្រឡប់មកវិញ )

សម្ដីរបស់ តេយ៉ុង ធ្វើឲ្យអ្នកស្ដាប់រឹងខ្លួនស្លុក។

"លោកថាម៉េច សាស្ត្រាចារ្យ គីម មិនទាន់មកវិញទេឬ?"



( បាទ )

បេះដូងរបស់នាងក្រមុំធ្លាក់ទៅនៅនឹងភ្នែកគោ ការភ័យខ្លាចក៏ធ្វើឲ្យនាងមិនហ៊ានគិតបន្ត។

"អីចឹង...ប៉ុណ្ណឹងចុះ..."

( ឈប់សិនលោកស្រី ខ្ញុំទៅរក )

"មិន មិនបាច់ទេ ខ្ញុំចូលគេងហើយ"

និយាយហើយ យ៉ូលី ក៏ចុចផ្ដាច់ទូរសព្ទភ្លាម ដែលពេលនោះទឹកភ្នែកក៏ហូរដាបថ្ពាល់ ធ្វើឲ្យ ហុងស៊ីល ព្រួយបារម្ភ។

"អ្នកនាង...កើតអី?"

"ហុងស៊ីល...ស្រីចំពុះក្រហមក៏មិនទាន់មកវិញដែរ អ្នកជំនាញ គីម ប្រាប់"

ហុងស៊ីល បើកភ្នែកធំៗ តែរហ័សដោះសាជំនួស ម៉ាទិនេស ព្រោះមិនត្រូវការឲ្យចៅហ្វាយរបស់ខ្លួនមិនសប្បាយចិត្ត។

"ប្រហែលទៅកន្លែងផ្សេងគ្នាទេដឹង"

យ៉ូលី ដើរទៅដាក់បង្អុយលើគ្រែ ទឹកភ្នែកហូរដាបថ្ពាល់។

"ទៅកន្លែងផ្សេងគ្នាយ៉ាងម៉េចទៅ ខ្ញុំថាគេច្បាស់ជាទៅជាមួយគ្នា"

នាងក្រមុំមិនទាន់ជូតទឹកភ្នែកចេញពីថ្ពាល់ស្ងួតផង ទូរសព្ទដៃក៏រោទ៍ ទើបនាងស្រវាយកមកចុចភ្លាម ព្រោះឃើញថាជាលេខរបស់ ម៉ាទិនេស ។

"បង ម៉ាត នៅឯណា ម៉េចក៏មិនព្រមទទួលទូរសព្ទអូន?"

( លោកនាយកនៅជាមួយខ្ញុំ យើងកំពុងតែសប្បាយខ្លាំង )

"នាង...គីម ជីយ៉ន!" នាងក្ដៅក្រហាយភ្លាម "នាងធ្វើស្អីបង ម៉ាត"

ជីយ៉ន សើចក្អាកក្អាយ។



( ខ្ញុំធ្វើស្អីលោកនាយកបានទៅ មានតែត្រូវលោកនាយកធ្វើ )

យូលី ឈឺផ្សៀបក្នុងចិត្ត ទឹកភ្នែកជន់បេះដូង។

"នាងនៅឯណា ប្រាប់មក គីម ជីយ៉ន !"

( មិនបាច់សួរក៏ខ្ញុំប្រាប់ដែរ ព្រោះខ្ញុំចង់ឲ្យនាងមកឃើញផ្ទាល់ភ្នែកពេលដែលខ្ញុំនិងលោកនាយកកំពុងតែសាសងគ្នា...នៅលើគ្រែ... )

យូលី ខាំធ្មេញក្រតៗ ទូរសព្ទនៅក្នុងដៃត្រូវក្តាប់ស្ទើរបែក ហើយកត់ឈ្មោះសណ្ឋាគារនិងលេខបន្ទប់តាមដែល ជីយ៉ន ប្រាប់ភ្លាម បន្ទាប់មកក៏ងាកទៅរក ហុងស៊ីល។

"ហុងស៊ីល...ទៅជាមួយខ្ញុំ"

"អ្នកនាង...ទៅណា ?"

យូលី យំអណ្តឺតអណ្តក។

"ខ្ញុំនិងទៅបកស្បែកមុខប្រុសសាវាហ្នឹងអី"

"អ្នកនាង..."

យូលី ជូតទឹកភ្នែកចោល ហើយម្នីម្នាដើរចេញពីបន្ទប់ ដោយមាន ហុងស៊ីល រត់តាម។

ជីយ៉ន បោះទូរសព្ទដៃរបស់ ម៉ាទិនេស ទៅដាក់នៅក្បាលគ្រែវិញ ហើយងាកទៅមើលអ្នកដែលកំពុងដេកលក់នៅលើគ្រែ ស្នាមញញឹមបិសាចលម្អនៅលើមុខស្រស់ស្អាតជានិច្ច។

"បើយកស្រួលៗមិនបាន ខ្ញុំត្រូវតែប្រើល្បិចបែបនេះឯង ខ្ញុំមិនព្រមឲ្យលោកបានទៅស្រីណាទេ"

នាងឡើងទៅអង្គុយលើគ្រែ អង្អែលមុខសង្ហារបស់គេដោយអារម្មណ៍



ឈ្លក់វង្វេង។

"ខ្ញុំត្រូវតែធ្វើជាម្ចាស់លោកតែម្នាក់គត់" នាងសើចគួរឲ្យខ្លាច។

សំឡេងគោះទ្វារបន្លឺឡើង ដែលធ្វើឲ្យនាងងឿងឆ្ងល់ ព្រោះមិនគិតថាលីលី មកដល់លឿនដល់ថ្នាក់នេះ ទើបម្នីម្នាចុះពីគ្រែដើរទៅបើកទ្វារ តែក៏ភ្ញាក់ផ្អើលពេលឃើញថាជាប្អូនប្រុសរបស់ខ្លួន។

"តេយ៉ុង..."

តេយ៉ុង មើលរំលងក្បាលបងស្រីចូលទៅក្នុងបន្ទប់ និងបានឃើញថានៅលើគ្រែមាន ម៉ាទិនេស ដេកនៅលើនោះ ទើបស្ទុះចូលទៅភ្លាម ទោះត្រូវបងស្រីរាំងយ៉ាងណាក៏មិនអាចស៊ូនឹងកម្លាំងគេបាន។

"ចេញទៅវិញភ្លាម គីម តេយ៉ុង"

"ម៉េចក៏បងធ្វើបែបនេះ"

"បងធ្វើស្អី!" នាងធ្វើមុខមិនដឹងខ្យល់អី តែ តេយ៉ុង មើលបងស្រីដោយកំហឹង។

"បងកុំមកធ្វើជាមិនដឹងអី ម៉េចក៏លោក ម៉ាឡេសាសសូ មកនៅទីនេះ"

គេនិយាយ ព្រមទាំងស្ទុះទៅអង្រួន ម៉ាទិនេស ខ្លាំងៗ ប៉ុន្តែគេនៅតែដេកលក់ស្កក់ស្កឹង ទើប តេយ៉ុង ងាកមកមើលមុខបងស្រីដោយការមិនពេញចិត្ត។

"កុំប្រាប់ណាថាបងដាក់ថ្នាំគេ"

ជីយ៉ន ញាក់ស្មា។

"បើមែនវាយ៉ាងម៉េច បងដាក់ថ្នាំដេកលក់ឲ្យលោកនាយក ដើម្បីនាំគេមករៀបចំឆាកបោកមីស្រីនោះ"

"កុំធ្វើបែបនេះដាច់ខាត"

"ម៉េចក៏បងធ្វើមិនបានក្នុងពេលដែលបងត្រូវការលោកនាយក" ជីយ៉ន





Scanned with CamScanner

ដើរមកចាក់ដើមទ្រូងប្អូនប្រុស "ហើយឯងក៏ត្រូវការនាងនោះមិនអីចឹង យើងនឹងបានទាំងពីរនាក់បងប្អូន"

"តែខ្ញុំមិនចូលចិត្តវិធីរបស់បង"

"ផ្លូវកាត់វាគួរតែពណ៌ប្រផេះបែបនេះហើយ ឯងស្តាប់បង គីម តេយ៉ុង បើនាងនោះវាមកឃើញប្តីរបស់វាដេកជាមួយបង វាច្បាស់ខូចចិត្ត ហើយសុំលែងលះ ក្នុងពេលដែលវាលែងលះនិងលោកនាយកទៅហើយ ឯងក៏ចូលទៅស្ទុំបេះដូងរបស់វាទៅ មិនយូរទេ វាមុខជាព្រមយកឯង"

តេយ៉ុង ឈរស្ងៀម មនសិការប្រាប់ឲ្យគេបដិសេធនិងដើរចេញពីរឿងអសីលធម៌នេះ ប៉ុន្តែចិត្តមួយទៀតដែលខ្មៅងងឹតប្រាប់ឲ្យគេ គាំទ្រទង្វើរបស់បងស្រី។

"ជឿបងចុះ គ្រប់យ៉ាងនឹងល្អប្រសើរ យើងគ្រប់គ្នានឹងរីករាយ ហើយឯងក៏មិនបាច់មកអង្គុយឈឺចិត្ត ឈឺចាប់ព្រោះតែវាមិនឃើញឯងទៀតដែរ"

"តែខ្ញុំ..."

"ឱកាសបែបនេះមានមិនច្រើនទេ ឯងមិនចង់មានសេចក្តីសុខសមបំណងនិងអ្នកដែលឯងស្រឡាញ់ទេឬយ៉ាងម៉េច"

មែនហើយគេត្រូវការ គេចង់បាន យ៉ូលី មកគ្រប់គ្រង។ បន្ទាប់ពីឈរស្ងៀមយ៉ាងយូរ ទើបគេសម្រេចចិត្តងក់ក្បាល។

"បាទ...ខ្ញុំនឹងធ្វើ"

"ឲ្យវាបានអីចឹងឡើងប្អូនសម្លាញ់"

ជីយ៉ន សើចក្អាកក្អាយដោយការពេញចិត្ត "អីចឹងឯងឆាប់ពួននៅក្នុងបន្ទប់ទៅ ព្រោះមិនយូរទេនាងនោះនឹងមកដល់ទីនេះ ហើយល្ខោនមួយឆាកធំនឹងកើតឡើង"



ទោះមានមនសិការនៅក្នុងចិត្តខ្លះ តែអំណាចនៃក្តីស្រឡាញ់ ធ្វើឲ្យគេដើរផ្លូវខុស។

"បាទ"

តេយ៉ុងដើរទៅពួននៅក្នុងបន្ទប់ទឹកជីយ៉នក៏ឈរញញឹមមានសេចក្តីសុខមិនយូរប៉ុន្មានសំឡេងគោះទ្វារបន្លឺឡើង ដែលនាងដឹងថាអ្នកណាមកដល់ ទើបដោះសម្លៀកបំពាក់ យកអាវឃ្លុំមកពាក់ ហើយដើរទៅបើកទ្វារ។

"មកលឿនផង់តែ" នាងរាក់ទាក់ យ៉ូលី។

"បង ម៉ាត នៅឯណា?" នាងក្រមុំខាំមាត់សួរ ជីយ៉ន ក៏សើចក្អាកក្អាយងាកខ្លួនចេញ ឲ្យមនុស្សស្រីពីរនាក់ដើរចូលមកក្នុងបន្ទប់។

យ៉ូលី ស្ទើរតែដួលខ្តោកតែម្តង បើគ្មានដៃរបស់ ហុងស៊ីល មកជួយទប់ពេលឃើញ ម៉ាទិនេស ដេកនៅលើគ្រែ មានភួយដណ្តប់ ដែលនាងដឹងថានៅក្នុងភួយនោះមានតែខ្លួនប្រាណនលគករបស់គេ។

ជីយ៉ន ឃើញទឹកមុខស្លេកស្លាំងនិងទឹកភ្នែករបស់មារវជ្រៀកបេះដូងរបស់ខ្លួនហើយក៏សើចក្អាកក្អាយ។

"សុំទោសផងដែលប្តីនាងដេកជាមួយខ្ញុំ តែយើងទាំងពីរត្រូវគ្នាណាស់...មើលចុះ លោកនាយកអស់កម្លាំងកំហែងដេកលក់ដូចសន្លប់ ចំណែកខ្ញុំស្ទើរតែវារចុះពីគ្រែមិនរួច"

ផាច់!!!

យ៉ូលី ងាកមកទះកំផ្លៀងអ្នកនិយាយ ធ្វើឲ្យ ជីយ៉ន ជ្រមិលរកកល់ចង់ដួល ។



"មីចង្រៃទះយើងធ្វើអី!"

"ទះឯងដែលដណ្តើមប្តីយើង!"

យ្យូលី ស្ទុះទៅរកម្ដងទៀត ដោយមាន ហុងស៊ុល ចូលមកជួយ ហើយព្រួតគ្នាទះតប់មិនប្រណី ខណៈដែល តេយ៉ុង បានឮហើយក៏ភ្ញាក់ផ្អើល ចង់មកជួយ តែធ្វើមិនបាន ទាល់តែ យ្យូលី ទះតប់ពេញចិត្តនោះឯង ទើបព្រមឈប់។

មុខរបស់ ជីយ៉ន ឡើងហើមជាំ ដោយពេលនេះអង្គុយត្បោងក្បាលជង្គង់នៅកៀនជញ្ជាំង ដោយមាន យ្យូលី ហូរទឹកភ្នែករហាមឈរច្រត់ចង្កេះសម្លឹងមុខ។

"នេះមិនទាន់សក្តិសមនឹងអ្វីដែលឯងធ្វើដាក់យើង មីចង្រៃ!" នាងស្ទុះទៅទះតប់ទៀត ប៉ុន្តែត្រូវ ហុងស៊ុល ទាញ។

"បានហើយអ្នកនាង ទះទៀតក៏ឈឺដៃទទេៗ យើងទៅវិញទៅ"

យ្យូលី ងាកទៅមើលអ្នកដែលនៅតែដេកស្លុកស្ដឹងនៅលើគ្រែដោយការឈឺចាប់។

"កុំអាល" នាងដើរទៅទះតប់អ្នកនៅលើគ្រែជាច្រើនដៃ ប៉ុន្តែគេមិនព្រមភ្ញាក់ ទើបនាងទះទាល់តែហត់ខ្លួនឯង។

"មនុស្សចង្រៃ អញ្ជើញនៅជាមួយវាទៅ ខ្ញុំនឹងលែងលះឲ្យ!"

នាងមើលគេជាលើកចុងក្រោយ ហើយរត់ចេញពីបន្ទប់នោះភ្លាមដោយការឈឺចាប់បំផុត។

ជីយ៉ន ខាំមាត់ងើបឈរ ទោះមុខមាត់ហើមជាំតែក៏ញញឹមពេញចិត្ត ខណៈដែល តេយ៉ុង រត់ចេញពីបន្ទប់ទឹក មកឃើញសភាពរបស់បងស្រីក៏អត់ភ្ញាក់ផ្អើលមិនបាន។

"បងស្រី..."

"ឯងមិនបាច់មកធ្វើមុខភ្ញាក់ផ្អើលទេ បងអូនខ"

"តែមុខរបស់បង..."

"នាងនោះមាឌតូច តែដៃធ្ងន់ផស់វា តែវាសមាមាត្រ ព្រោះចាប់ពីពេល



នេះទៅ បងនឹងបានលោកនាយកមកគ្រប់គ្រង" ជីយ៉ន សើចក្អាកក្អាយ តែក៏ត្រូវពេបមាត់ព្រោះឈឺមាត់ដែលត្រូវទះឡើងបែកឈាម។

"ខ្ញុំមិនដឹងថាអ្វីដែលធ្វើនេះវាខុសឬត្រូវ"

"ទោះខុសឬត្រូវក៏តាមតែវាទៅ ពេលនេះកែខៃអីមិនបានទេ ឯងឆាប់ទៅតាមវាទៅ វាកំពុងខូចចិត្ត ស្រួលមិនស្រួលយប់នេះអាចបានស៊ីវាក៏ថាបាន"

តេយ៉ុង មិននិយាយអី ក្រៅពីដើរចេញពីបន្ទប់ប៉ុណ្ណោះ ខណៈដែល ជីយ៉ន ញញឹមញញែមដោយការពេញចិត្ត ហើយដើរឡើងគ្រែ គ្រសុលចូលភួយជាមួយ ម៉ាទិនេស សម្ងំដេកឲ្យលក់ ទាំងឈឺមុខឈឺមាត់។

"អ្នកនាង...អ្នកនាង ចាំខ្ញុំផង..."

យ្យូលី រត់ចេញពីសណ្ឋាគារដោយការឈឺចាប់ និងប្រឹងរត់ទៅមុខដោយគ្មានគោលដៅរូបភាពនៅខាងមុខដែលឃើញក៏ស្រវាំង ដោយសារទឹកភ្នែកបិទបាំង ថែមទាំងរត់បុកអ្នកនេះអ្នកនោះ និងត្រូវស្តីឲ្យរាប់មិនអស់ ប៉ុន្តែនាងនៅតែប្រឹងរត់ ដោយនាំបេះដូងឈឺចាប់ទៅជាមួយ។

"ប្រុសសាវា ប្រុសក្បត់ចិត្ត ប្រុសចង្រៃ..."

នាងរត់ឆ្លងផ្លូវ ទើបមានសំឡេងស៊ីផ្លេ រួមទាំងសំឡេងជេរប្រទេចរបស់អ្នកបើកបរបន្លឺឡើង តែពេលនោះនាងមិនចាប់អារម្មណ៍អ្វីទាំងអស់ សូម្បីតែជីវិតខ្លួនឯង ហើយក៏រត់មកអង្គុយក្បែរជញ្ជាំង ដើម្បីបិទបាំងរាងកាយខ្លួនឯងពីមនុស្សម្នា។ នាងត្រូវការយំ ត្រូវការកម្ចាយអារម្មណ៍ទុក្ខសោក និងត្រូវការនៅម្នាក់ឯង។



សំឡេងស្រែករបស់ ហុងស៊ុល នៅតែបន្លឺងឡើងមិនឈប់ ប៉ុន្តែនាងមិនអាចដើរចេញពីកន្លែងលាក់ខ្លួនបាន។ នាងឈឺចាប់ណាស់ ឈឺចាប់ដល់ថ្នាក់



Scanned with CamScanner

មិនអាចប្រឈមមុខនឹងអ្នកណាបានទៀត បានត្រឹមតែយំអណ្ដឺតអណ្ដកស្ទើរតែដាច់ខ្យល់នៅត្រង់នោះ ហាក់ដូចបេះដូងត្រូវច្របាច់ដោយដៃបិសាច។

ហេតុអី ? ហេតុអីក៏ទៅជាបែបនេះ ហេតុអីក៏ ម៉ាទិនេស ក្បត់នាង បើមិនស្រឡាញ់នាងម៉េចក៏គេមិនប្រាប់ បើចង់មានអ្នកផ្សេង ត្រឹមប្រាប់មួយម៉ាត់ នាងរីករាយលែងលះឲ្យគេ។

"ចិត្តអាក្រក់...បង ម៉ាត ចិត្តអាក្រក់ណាស់..."

ខណៈដែលនាងកំពុងយំយែកដោយការឈឺចាប់ ហុងស៊ីល នៅតែស្រែកហៅដោយការព្រួយបារម្ភ ព្រោះរកចៅហ្វាយរបស់ខ្លួនមិនឃើញ។

"អ្នកនាង...អ្នកនាងនៅឯងណា អ្នកនាង"

"ហុងស៊ីល...ឯណាលោកស្រី អ៊ីន"

តេយ៉ុង ដែលរត់មកតាម ឃើញហើយក៏សួរនាំដោយការព្រួយបារម្ភ។

"ចេញឲ្យផុតទៅ!"

"ខ្ញុំចង់ជួយតាមរកលោកស្រី"

"កុំមកចេះ ទៅស្រែកហ៊ោអបអរនឹងបងស្រីរបស់លោកទៅ កុំមកឲ្យឃើញមុខ"

**"ខ្ញុំមិនដឹងរឿងអីទេ"**

តេយ៉ុង ស្អប់ខ្លួនឯងខ្លាំងណាស់ដែលត្រូវកុហក រអៀសចិត្តដល់ថ្នាក់មិននៅសល់សូម្បីតែកិត្តិយស។ នេះគេធ្វើត្រូវហើយមែនឬ ?

"មិនដឹងរឿងស្អី ទាំងលោកជាប្អូនប្រុសរបស់ស្រីចំពុះក្រហមនោះ ហ៊ឺ! ចេញឲ្យផុតទៅ កុំមករញ៉េរញ៉ៃនឹងអ្នកនាងរបស់ខ្ញុំទៀត!"

"ខ្ញុំធ្វើមិនបានទេ ព្រោះខ្ញុំបារម្ភពីលោកស្រី អ៊ីន"

ហុងស៊ីល ប្រុងហាមាត់បណ្ដេញម្ដងទៀត ប៉ុន្តែ យ្យូលី ដែលយំទាល់តែ



អស់ចិត្តហើយ ក៏ដើរចេញពីកន្លែងលាក់ខ្លួនក្នុងសភាពទឹកភ្នែកហូររហាម។

"អ្នកនាង..." ហុងស៊ីល រត់ទៅឱបចៅហ្វាយ "អ្នកនាងកុំធ្វើបែបនេះទៀត ខ្ញុំភ័យណាស់"

"យើងទៅបន្ទប់វិញទៅ ស្អែកនេះទៅផ្ទះវិញ"

"លោកស្រី...មិនអីទេឬ ?" តេយ៉ុង ស្ទុះទៅរក និងមើលដោយការព្រួយបារម្ភ តែ យ្យូលី គ្រវីក្បាល និងញញឹមទាំងទឹកភ្នែកដាក់។

"ខ្ញុំមិនអីទេ"

"តោះអ្នកនាង"

តេយ៉ុង តាមមើលអ្នកដែលត្រូវ ហុងស៊ីល គ្រាហ៍ចេញទៅដោយអារម្មណ៍ដឹងខុស។





Scanned with CamScanner

# ១៦

ម៉ាទិនេស ភ្ញាក់ដឹងខ្លួននៅព្រឹកថ្ងៃថ្មី។ គេងើបអង្គុយត្រវៃក្បាលខ្លាំងៗ ព្រោះធ្ងន់ក្បាល។

"ម៉េចក៏ឈឺក្បាលម្ល៉េះ"

គេលើកដៃក្ដោបក្បាល ច្របាច់ខ្លាំងៗ ហើយងាកមើលក្បែរខ្លួន ឮសំឡេងយំអណ្ដឺតអណ្ដក។

ឃើញស្រីម្នាក់អង្គុយនៅក្បែរ ឃ្លុំដោយភួយ ឈ្ងោកមុខយំ។

អ្នកណា លីលី ឬ?

"លីលី...យំធ្វើអី"

គេសួរ តែក៏ភ្ញាក់ព្រើតស្ទើរតែស្លុតតែម្ដង ពេលមនុស្សស្រីដែលយំអណ្ដឺតអណ្ដកក្បែរខ្លួនមិនមែន យ៉ូលី។

"សាស្ត្រាចារ្យ គីម!"

ម្ចាស់ឈ្មោះងើយមើលមុខដែលហើមជាំ និង ហូរហាមដោយទឹកភ្នែកមកតវ៉ាគេ។

"លោកធ្វើបាបខ្ញុំ..."

"ខ្ញុំនៀក?" អ្នកកំលោះត្រវៃក្បាល "គ្មានផ្លូវទេ ខ្ញុំមិនបានគិតស្មីទៅលើសាស្ត្រាចារ្យទេ"

"លោកនៅបដិសេធទៀតឬ ទាំងដែលយើងទាំងពីរនៅលើគ្រែតែមួយក្នុងសភាពបែបនេះ"



ម៉ាទិនេស មិនធ្លាប់ភ័យបុកពោះអីបែបនេះទេ គេស្លុតនិយាយមិនចេញ ប៉ុន្តែខណៈនោះក៏ប្រឹងរកនឹកហេតុការណ៍មុននេះ។ គេចេញពីបន្ទប់ប្រជុំ ជួប ជីយ៉ន ហើយ ជីយ៉ន ក៏សុំដោយសារឡានមកសណ្ឋាគារវិញ តែនៅតាមផ្លូវនាងប្រាប់ថា ខះ.ក នាងសុំចុះទៅទិញកាហ្វេ ដោយទិញមកផ្ញើគេមួយកែវ ហើយគេក៏ផឹកជិតអស់រលីង តែបន្ទាប់ពីនោះគេក៏ចាំអ្វីលែងបាន។

"ខ្ញុំមកទីនេះដោយរបៀបណា?"

"គឺលោកអូសខ្ញុំមក ប្រាប់ថា ចង់ដេកជាមួយខ្ញុំ ទ្រាំមិនបាន"

"មិនពិតខ្ញុំមិនធ្លាប់គិតអីទៅលើ សាស្ត្រាចារ្យ គីម"

ទឹកមុខ ជីយ៉ន ឡើងក្រមូវ តែប្រឹងលាក់អាការៈ។

"ទោះយ៉ាងណាក៏លោក ត្រូវទទួលខុសត្រូវខ្ញុំ"

អ្នកកំលោះអូសតួទចេញឲ្យឆ្ងាយពេលនាងលូនមករក។

"កុំមកជិតខ្ញុំ"

"ម៉េចក៏ធ្វើឫកស្អប់ខ្ពើមខ្ញុំ យប់មិញមិនមែនបែបនេះទេ មានតែសុំឲ្យខ្ញុំធ្វើឲ្យខ្លាំងៗ"

"ឈប់និយាយបែបនេះ ខ្ញុំមិនចង់ស្ដាប់"

នេះតើជារឿងឆ្កួតអី ហេតុអីក៏ទៅជាបែបនេះ គេមកនៅទីនេះជាមួយ ជីយ៉ន ដោយរបៀបណា?

អ្នកកំលោះគិតដោយចិត្តអន្ទះសា និងស្ត្រេសខ្លាំងមែនទែន ហើយម៉្មីម្នាចុះពីគ្រែ ស្រវាយកទូរសព្ទដៃរបស់ខ្លួនចុចទៅ យ៉ូលី។



"លីលី បងកំពុងតែទៅវិញ" ពេលនាងទទួលទូរសព្ទ គេក៏ប្រាប់ភ្លាម។

"លោកនាយក...ប្រញាប់ទៅណា?" ជីយ៉ន មានចេតនានិយាយឲ្យឮខ្លាំងៗ ឲ្យសំឡេងរបស់ខ្លួនឮចូលក្នុងទូរសព្ទ។

ម៉ាទិនេស ងាកមកសម្លឹងមុខេះ ជីយ៉ន ភ្លាមហើយដើរទៅនិយាយបន្ត នៅរានហាលបន្ទប់។

"លីលី...បងមានរឿងចង់និយាយជាមួយអូន ចាំបងមិនលើសពីដប់នាទី"

(ខ្ញុំក៏មានរឿងនិយាយជាមួយបងដែរ) សំឡេងរបស់នាងសោះកក្រោះ ដែលធ្វើឲ្យ ម៉ាទិនេស អន្ទះសា។

"លីលី ប្រហែលមិនខឹងបងមែនទេដែលមិនបានទៅវិញយប់មិញ"

(ខ្ញុំមិនខឹងទេ បន្តិចទៀតចាំជួបគ្នា) នាងក្រមុំដាក់ទូរសព្ទចុះ ខណៈដែល ម៉ាទិនេស ឈរធ្មឹងនៅត្រង់នោះ ដោយទឹកមុខតានតឹង។

"ធ្វើយ៉ាងម៉េចទៅ"

គេព្យាយាមរកដំណោះស្រាយ និងជឿជាក់ថាយប់មិញខ្លួនឯងមិនបានធ្វើស្អីដូចដែល ជីយ៉ន ប្រាប់ ដូច្នេះហើយទើបទូរសព្ទទៅរកប្អូនប្រុសភ្លាម។

"ម៉ៃ...បងមានរឿងឲ្យជួយបន្តិច"

(បាទ បងម៉ាត)

"បងចង់ពិនិត្យឈាម ចង់ដឹងថា ក្នុងខ្លួនបងមានថ្នាំអីឬអត់ ដូចជាថ្នាំដេកលក់...ឯង...អាចធ្វើបានទេ?"

(មានអីកើតឡើងឬ បងម៉ាត)

ម៉ាទិនេស រៀបរាប់ហេតុការណ៍ទាំងអស់ឲ្យប្អូនប្រុសស្តាប់ ដែលធ្វើឲ្យមេសាន់ ក្តៅក្រហាយភ្លាម។

(ស្រីសម័យនេះគួរឲ្យខ្លាចដល់ហើយ ចង់តែចាប់យកទៅបោះផុងបឹងក្រពើឲ្យអស់)

"ហើយបងធ្វើយ៉ាងម៉េចទៅពេលនេះ?"

(បងកុំបារម្ភ ចាំខ្ញុំតេរទៅរកមិត្តភក្តិដែលជាពេទ្យនៅទីនោះ ឲ្យគេពិនិត្យឲ្យ បងគ្រាន់តែទៅរកគេ ហើយពិនិត្យឈាម)

"អរគុណច្រើន ម៉ៃ"

(ខ្ញុំរីករាយជួយ ប៉ុន្តែពេលនេះ លីលី ដឹងហើយឬនៅ សង្ឃឹមថាផ្ទះមិនផ្ទុះទៅចុះ)

"បងក៏មិនច្បាស់ដែរ ប៉ុន្តែពេលបងតេរទៅ នាងនិយាយសោះកក្រោះណាស់ បងមិនដឹងទេថា នាងងរបងដែលមិនបានទៅវិញយប់មិញឬអត់ ឬថាដឹងរឿងនេះហើយ"

(ស៊ូស៊ូបងប្រុស)

"អរគុណ"

ម៉ាទិនេស ដាក់ទូរសព្ទចុះ ហើយដើរចូលបន្ទប់វិញ ដោយ ជីយ៉ន នៅតែអង្គុយលើគ្រែ។

"និយាយគ្នាយូរដល់ហើយ"

"សាស្ត្រចារ្យគ្មានសិទ្ធិរវីរវល់រឿងផ្ទាល់ខ្លួនរបស់ខ្ញុំ"

"កាលមុនមែន តែពេលនេះខ្ញុំជាប្រពន្ធរបស់លោកហើយ ដូច្នេះហើយខ្ញុំមានសិទ្ធិប្រចណ្ឌ" ម៉ាទិនេស ខាំធ្មេញ ព្យាយាមទប់កំហឹង។

"ខ្ញុំនឹងឲ្យប្រាក់តាមដែលសាស្ត្រចារ្យត្រូវការ ហើយសុំឲ្យរឿងនេះចប់"

"នេះចង់ស៊ីហើយទាត់ចោលឬ!"

"ខ្ញុំមិនទាន់ច្បាស់ទេថា បានធ្វើអីសាស្ត្រចារ្យឬអត់" ម៉ាទិនេស ខាំធ្មេញដោយការមិនពេញចិត្ត "សរុបទៅយើងនឹងទៅនិយាយគ្នានៅសេអ៊ូលម្តងទៀត"



និយាយចប់គេស្រវ៉ាយកខោអាវដើរចូលបន្ទប់ទឹកភ្លាម ដោយមាន ជីយ៉ន តាមមើលដោយការមិនពេញចិត្ត។

"គិតថាខ្ញុំបណ្ដោយឲ្យរបូតពីដៃស្រួលៗឬ គ្មានផ្លូវទេ ខ្ញុំខំចំណាយប៉ុណ្ណឹងទៅហើយ មិនព្រមឲ្យលោករបូតពីដៃជាដាច់ខាត"

**យ្យូលី ប្រឹងទប់ទឹកភ្នែកអស់ពីសមត្ថភាពពេលម៉ាទិនេស បង្ហាញខ្លួន។**

"លីលី..." អ្នកកំលោះដើរទៅរកភ្លាម ស្រវាចាប់ដៃរបស់នាង តែ យ្យូលី រលាស់ចេញ និងថយក្រោយ ដោយមាន ហុងស៊ីល ចូលមកពាំងមុខ។

"ហុងស៊ីល ចៀសចេញ"

"លោកគ្មានសិទ្ធិប៉ះពាល់អ្នកនាងរបស់ខ្ញុំទៀតទេ"

ម៉ាទិនេស ជ្រឹមភ្នែកមើលអ្នកដែលនិយាយដោយការមិនពេញចិត្ត។

"នាងនិយាយស្អី ហុងស៊ីល បងចេញសិនទៅ ចាំខ្ញុំនិយាយជាមួយគេ"

"តែ..."

"ធ្វើតាមខ្ញុំទៅ"

ពេលចៅហ្វាយត្រូវការបែបនេះ ហុងស៊ីល ក៏ព្រមដើរចេញ ទើប យ្យូលី ព្រមងើយមុខមើល ម៉ាទិនេស មើលគេទាំងទឹកភ្នែក ហើយនិយាយដោយសំឡេងញ័រ។

"ខ្ញុំនឹងលែងលះឲ្យ"

"លីលី!"

"បងត្រូវការពេលណា ប្រាប់មកថ្ងៃនេះថ្ងៃស្អែកកាន់តែល្អ"

"ម៉េចក៏អូននិយាយបែបនេះ?" ម៉ាទិនេស សួរដោយចិត្តអន្ទះសា។

"បងនឹងបានទៅនៅជាមួយសាស្ត្រាចារ្យ គីម ឆាប់ៗហ្នឹងអី"

"លីលី!"

"កុំគិតថាខ្ញុំល្ងង់ កុំគិតថាខ្ញុំមិនដឹងថាបងទៅធ្វើស្អីយប់មិញ"

ទឹកមុខរបស់ ម៉ាទិនេស ស្លេកស្លាំងហើយគេសារភាពភ្លាម។

"បងមិនដឹងទេថាវាកើតឡើងដោយរបៀបណា បងមិនដឹងទេថា ទៅទីនោះដោយរបៀបណា"

នាងក្រមុំយំទឹកភ្នែកហូរសស្រាក់។

"បងប្រាប់ថាមិនដឹង សូម្បីតែពេលដែលយកស្រីម្នាក់នោះធ្វើប្រពន្ធ?"

"បងជឿជាក់ថា បងនិងសាស្ត្រាចារ្យ គីម គ្មានអីនឹងគ្នា"

នាងក្រមុំសើចទាំងទឹកភ្នែក។

"កុំកុហកខ្ញុំ ខ្ញុំមិនមែនក្មេងបៀមដៃ មនុស្សប្រុសមនុស្សស្រីដេកស្រាតជាមួយគ្នានៅលើគ្រែ បើគ្មានស្អី វាអស្ចារ្យពេកហើយ"

"តែបងនិយាយការពិត នេះបងកំពុងតែសង្ស័យ ហើយបងកំពុងតែពិសោធ"

យ្យូលី មិនជឿសម្ដីរបស់គេ ព្រោះគេធ្វើឲ្យនាងឈឺចាប់ពេកហើយ។

"យើងនឹងលែងលះគ្នា ឲ្យឆាប់បំផុត"

"បងមិនលែង...យ៉ាងណាក៏មិនលែងដាច់ខាត" គេដើរមករក ប៉ុន្តែនាងដើរថយក្រោយមិនព្រមឲ្យគេប៉ះខ្លួន។

"កុំចូលមកជិតខ្ញុំ...ខ្ញុំខ្ពើមបង ចេញឲ្យផុតពីមុខខ្ញុំទៅ ចេញទៅ ចេញភ្លាម!"

"លីលី ម៉េចក៏មិនស្ដាប់បងអធិប្បាយ បងមិនដឹងទេថា ហេតុអីបានជាទៅដេកនៅលើគ្រែសាស្ត្រាចារ្យ គីម"

"កុំមកដោះសា កុំមកធ្វើដូចខ្លួនឯងត្រូវដាក់ថ្នាំ ហើយត្រូវអូសឡើងគ្រែ ខ្ញុំមិនជឿ"



នាងលើកដៃជូតទឹកភ្នែក ហើយដើរទៅទាញទ្វារបើក។



Scanned with CamScanner

"ខ្ញុំនឹងទៅសេអ៊ូលជាមួយអ្នកជំនាញ គីម"

"អូនត្រូវទៅវិញជាមួយបង ហាមទៅជាមួយគេដាច់ខាត" គេដើរមកស្រវាចាប់ដៃរបស់នាងតែត្រូវនាងរលាស់ចេញ និងពើងទ្រូងដាក់គេទាំងទឹកភ្នែក។

"ខ្ញុំចង់ធ្វើស្អីជាមួយអ្នកណាក៏បាន គឺធ្វើដូចដែលបងធ្វើ"

និយាយហើយនាងក៏ដើរចេញពីបន្ទប់សណ្ឋាគារភ្លាម តែ ម៉ាទិនេស ដើរតាម។

"លីលី...ស្តាប់បងសិន បងមិនបានធ្វើអីពិតមែន"

នាងក្រមុំលើកដៃជូតទឹកភ្នែកម្តងទៀត មិនចង់និយាយរកប្រុសចិត្តសាវា តែត្រូវគេស្រវាចាប់ដៃជាប់។

"លែងខ្ញុំ កុំប៉ះពាល់ខ្ញុំ"

"បងមិនលែង"

"លែងខ្ញុំ លែង!"

នាងប្រឹងម្ហូល.កដៃ ដែលពេលនោះ តេយ៉ុង ក៏ដើរមកដល់ល្មម។

"សូមលែងដៃ លោកស្រី អ៊ីន ទៅលោក ម៉ាឡេសាសសូ"

ម៉ាទិនេស ងាកទៅសម្លឹងមុខអ្នកនិយាយដោយកំហឹង។

"វាមិនមែនជារឿងរបស់លោកទេ អ្នកជំនាញ គីម"

"អ្នកជំនាញ គីម...ជួយខ្ញុំផង"

"តែលោកស្រីមិនត្រូវការនៅជាមួយលោក សូមជួយលែងនាងទៅ"

"កុំមកចេះ"

ម៉ាទិនេស មិនព្រមលែង និងអូស យ្យូលី ចូលបន្ទប់វិញ ទើប តេយ៉ុង ចូលមកពាំង ហើយដាល់គេមួយដៃ ធ្វើឲ្យគេជ្រមិលថយក្រោយ។



"ម៉ាត..."

នាងក្រមុំភ្ញាក់ ស្ទុះទៅជួយ ប៉ុន្តែពេលឃើញ ជីយ៉ន នាងក៏ភ្ញាក់ស្មារតី និងថយក្រោយវិញ។

"តោះ អ្នកជំនាញ គីម"

ម៉ាទិនេស លើកដៃជូតឈាមចេញពីគែមមាត់ ខណៈដែលតាមមើល យ្យូលី បណ្តើរ តេយ៉ុង ចេញទៅដោយកំហឹង ជីយ៉ន ញញឹមពេញចិត្ត។

"ពីរនាក់នោះសក្តិសមគ្នា បើលោកលែងលះនឹងនាងពេលណា តេយ៉ុង នឹងសុំនាងធ្វើសង្សារ"

"អ្នកណាថាខ្ញុំលែងលះ លីលី!" ម៉ាទិនេស ខាំធ្មេញនិយាយដោយសំឡេងរឹងកំព្រឹស។

"បើមិនលែងលះ យើងចង់នៅជាមួយគ្នាបីនាក់ប្តីប្រពន្ធបែបនេះឬ"

សម្តីរបស់ ជីយ៉ន ឲ្យ ម៉ាទិនេស ខឹងខ្លាំង។

"ខ្ញុំកំពុងទៅមន្ទីរពេទ្យ ទៅពិនិត្យឈាមតាមការណែនាំរបស់ប្អូនប្រុសខ្ញុំ បើក្នុងខ្លួនខ្ញុំមានសារជាតុប្លែកៗ ខ្ញុំគ្មានថ្ងៃបណ្តោយឲ្យអាអ្នកដែលបង្ករឿងនេះបានដកដង្ហើមនៅលើលោកនេះទៀតទេ"

"លោកនាយក...ទៅមន្ទីរពេទ្យឬ?" ជីយ៉ន សួរដោយសំឡេងញ័រ។

"មែន នាងក៏ត្រូវទៅដែរ សាស្ត្រាចារ្យ គីម!"

ទឹកមុខរបស់ ជីយ៉ន ស្លេកស្លាំង គ្រវីក្បាលញាប់ស្ញែក។

"ខ្ញុំ...មិនទៅទេ ខ្ញុំទៅសិនហើយ"

ជីយ៉ន លា នាងដើរចេញពីសណ្ឋាគារ ដោយនៅតាមផ្លូវប្រឹងរិះរកផ្លូវចេញឲ្យខ្លួនឯង ព្រោះបើ ម៉ាទិនេស ទៅពិនិត្យឈាម និងរកឃើញថ្នាំដេកលក់មិនខាន ហើយពេលនោះគ្រប់យ៉ាងដែលនាងធ្វើនឹងខ្ទេចខ្ទី។



នាងប្រឹងរិះរកវិធី មិនយូរប៉ុន្មានក៏នឹកឃើញ ទើបតេរទៅរកអ្នកស្គាល់គ្នាដែលនៅក្នុងតំបន់នេះ។

"សួស្តី ខ្ញុំមានរឿងឲ្យជួយ ឆាប់មករកខ្ញុំ ចាំខ្ញុំផ្ញើអាស័យដ្ឋានតាមឡាញន៍ឲ្យ"

ពេលអ្នកដែលខ្លួនតេរទៅយល់ព្រម នាងក៏ញញឹមពេញចិត្ត។

ម៉ាទិនេស រវល់តែខ្វល់ខ្វាយរឿងដែលកើតឡើង ទើបមិនបានសង្កេតថាមានឡានមួយគ្រឿងបើកតាមរហូត តាំងពីសណ្ឋាគាររហូតដល់ជិតមន្ទីរពេទ្យដែលគេត្រូវមកពិនិត្យឈាម និងទឹកនោមដើម្បីរកថ្នាំដេកលក់។

ត្រាំង!

សំឡេងរថយន្តទង្គិចគ្នាយ៉ាងខ្លាំង ធ្វើឲ្យបាត់បង់ការគ្រប់គ្រង។ ម៉ាទិនេស ស្រែកភ្ញាក់មាត់ បន្ទាប់មកឡានក៏វិលខ្វាល់ ខ្ទាត់ទៅបុកនឹងទ្រូងផ្លូវ ហួសទៅបុកដើមឈើនៅផ្លូវម្ខាងទៀត តែសំណាងល្អដែលមិនប៉ះពាល់ឡានអ្នកដទៃ។

"ហេ...ងាប់ហើយ អាញ់ប្រាប់ឲ្យឯងវ៉ាទៅឈប់ពីមុខមិនមែនឲ្យបុកវាខ្លាំងៗបែបនេះទេ តិចនាងនោះវាហែកទ្រូង" បុរសពុកមាត់ស្រម៉ូម សម្បុរទង់ដែងដែលអង្គុយនៅក្បែរអ្នកបើកស្រែកឡូឡា។

"ខ្ញុំប្រឹងទប់ចង្កូតហើយ ប៉ុន្តែទប់មិនបាន ទើបវាបុកតែម្តងទៅ" អ្នកបើកដោះសា។

"អីៗ ហើយនេះធ្វើយ៉ាងម៉េច ហ្វារេស ងាប់ឬអត់ក៏មិនដឹង"

"យើងទៅមើលវាបន្តិចទេ"

"មិនបាច់ទេ តិចប៉ូលិសដង្ហែរគ្នាមកល្មម ឆាប់បើកឡានចេញទៅ អាញ់



មិនទាន់ចង់ដេកគុកទេវ៉ើយ"

"បានៗ"

រថយន្តបង្កហេតុបើកចេញទៅភ្លាម ខណៈដែលរថយន្ត ម៉ាទិនេស ចតស្មៀមនឹងដើមឈើដែលបាក់ មនុស្សម្នាក៏នាំគ្នាមកចោមរោម សំឡេងឡានសារ៉ែនក៏បន្លឺឡើង។

"ថាម៉េច នេះឯង...បើកឡានបុកលោកនាយកឬ ?" ជីយ៉ន ភ្ញាក់ផ្អើលយ៉ាងខ្លាំង។

(បាទ តែខ្ញុំគ្មានចេតនាទេ)

"អាពួកឆ្កួត ខ្ញុំជួលឲ្យឯងទៅស្ទាក់ចាំរ៉ៃគេដើម្បីមិនឲ្យចូលមមន្ទីរពេទ្យពិនិត្យឈាម មិនមែនឲ្យទៅសម្លាប់គេ"

(គឺពួកខ្ញុំគ្មានចេតនា)

"ពួកឯង ដកក្បាលចេញទៅ ហើយមិនបាច់តេរមករកខ្ញុំទៀតទេ"

(ម៉េចនឹងបានទៅ ខ្ញុំមិនទាន់បានថ្លៃឈ្នួលផង)

ជីយ៉ន ធ្វើមុខយក្សដាក់ទូរសព្ទ។

"ធ្វើការងារភ្លាត់ស្នៀត ធ្វើឲ្យលោកនាយកគ្រោះថ្នាក់បែបនេះហើយ នៅមានមុខមកទារថ្លៃឈ្នួលទៀតឬ ដកក្បាលចេញទៅ"

(អាំ! អ្នកនាង គីម និយាយបែបនេះតិចស៊យ)

អ្នកចុងខ្សែមិនពេញចិត្ត។

"ពួកឯងដកក្បាលចេញពីខ្ញុំទៅ កុំតេរមកខ្ញុំទៀត មិនអីចឹងខ្ញុំនឹងប្តឹងប៉ូលិស"



(បើពួកខ្ញុំត្រូវចាប់ខ្លួន អ្នកនាងក៏មិនរួចខ្លួនដែរ)

ស្រីស្អាតភាំង ហើយព្រមសម្រុះសម្រួល។

"អីចឹងខ្ញុំឲ្យពាក់កណ្ដាល ព្រោះឯងធ្វើការងារភ្លាត់ស្នៀត"

(ត្រូវធ្វើតាមការព្រមព្រៀង មិនអីចឹង អ្នកនាងត្រូវត្រៀមខ្លួនឈឺសាច់ឲ្យហើយទៅ"

"អាំ..."

(ចាំខ្ញុំផ្ញើលេងគណនីឲ្យតាមឡាញន៍ អូ! ហើយឆាប់វេរមកមុនម៉ោង៨ យប់ ខ្ញុំប្រញាប់ចាយលុយ)

ពួកវាដាក់ទូរសព្ទចុះទៅហើយ បន្ទាប់មកសំឡេងផ្ញើសារតាមឡាញន៍ក៏បន្លឺឡើង ធ្វើឲ្យនាងក្ដាប់ដៃណែន តែគ្មានជម្រើស។

"អាពួកចង្រៃ!"

**ពេលមកដល់សេអ៊ូល យ៉ូលី ក៏រៀបចំឥវ៉ាន់ផ្ទាល់ខ្លួនត្រឡប់ទៅផ្ទះម្ដាយរបស់ខ្លួនភ្លាម ដោយការឈឺចាប់នៅតែមានពេញដើមទ្រូង ទឹកភ្នែកនៅតែហូរហោម។**

"អ្នកនាង...មិនអីទេ"

"ខ្ញុំទ្រាំបាន" នាងប្រាប់អ្នកមើលថែរបស់ខ្លួនទាំងទឹកភ្នែក នោះហើយដែលធ្វើឲ្យ តេយ៉ង ដែលមកជួយរៀបចំឥវ៉ាន់អត់អៀសចិត្តមិនបាន។

ហេតុអី យ៉ូលី សោកសៅម្ល៉េះ ប្រហែលមកពីនាងស្រឡាញ់ ម៉ាទិនេស ខ្លាំង នេះគេជួយមនុស្សខុសមែនទេ!

"ពេលវេលានឹងធ្វើឲ្យប្រសើរឡើងលោកស្រី អ៊ីន" យ៉ូលី មិនតប តែញញឹមដាក់គេទាំងទឹកភ្នែក។

"អរគុណច្រើនអ្នកជំនាញ គីម ដែលជួយជូនមក ហើយជួយយកខោអាវនៅផ្ទះនោះទៀត"



"ខ្ញុំរីករាយ"

"អីចឹងខ្ញុំទៅសិនហើយ ចង់ទៅសម្រាក"

"សុបិនល្អ" យ៉ូលី ប្រឹងញញឹមម្ដងទៀត ហើយបែរខ្លួនដើរចូលក្នុងផ្ទះដែលមាន ហុងស៊ីល ដើរតាម ប៉ុន្តែដើរបានតែប៉ុន្មានជំហានក៏ឈប់ដើរ ងាកមកសម្លឹងមុខ តេយ៉ង។

"ខ្ញុំនិយាយត្រង់ៗ ទោះអ្នកនាងគ្មានលោក ម៉ាត ក៏លោកមិនអាចចូលមកក្នុងបេះដូងអ្នកនាងបានដែរ ព្រោះបេះដូងរបស់អ្នកនាងខ្ញុំមានតែ លោក ម៉ាត ម្នាក់ប៉ុណ្ណោះ អ្នកនាងកើតមកដើម្បីលោក ម៉ាត តែម្នាក់គត់" អ្នកស្ដាប់ឈឺក្នុងទ្រូង ពាក្យសម្ដីចាក់បេះដូងរបស់ដៃគូសន្ទនាហាក់ដូចព្រួញមុតស្រួចបោលសម្រុកយ៉ាងខ្លាំង។

"ខ្ញុំ..."

"ខ្ញុំដឹងថាលោកកំពុងគិតអី តែខ្ញុំអះអាងបានថា លោកគ្មានផ្លូវសមបំណង ព្រោះមិនថាចំណាយពេលយូរប៉ុណ្ណាទៀត ក៏អ្នកនាងគ្មានថ្ងៃឈប់ស្រឡាញ់លោក ម៉ាត បានដែរ" ហុងស៊ីល ដកដង្ហើមធំ "ខ្ញុំខ្លាចថាអ្នកនាងគិតខ្លីទៀតផង"

បានឮហើយ តេយ៉ង បុកពោះធីបតែម្ដង។

"ប្រហែល...មិនដល់ថ្នាក់នោះទេដឹង ខ្ញុំថា..."

"លោកទៅដឹងស្អី អ្នកនាងស្រឡាញ់លោក ម៉ាត ខ្លាំងណាស់ ពេលជួបនឹងរឿងបែបនេះគឺឈឺស្ទើរស្លាប់ ខ្ញុំទៅសិនហើយ ត្រូវទៅយាមអ្នកនាងមិនឲ្យបាត់ពីភ្នែក" តេយ៉ង និយាយអីមិនចេញ តែមើល ហុងស៊ីល ដែលរត់តាម ចៅហ្វាយពេញផ្ទះដោយការភិតភ័យនិងមានអារម្មណ៍ដឹងខុស។





Scanned with CamScanner

"នេះឯង...អាត្មានិយមពេកមែនទេ គីម គេយ៉ង"

គេនិយាយរអ៊ូៗដោយអារម្មណ៍ច្របូកច្របល់ បន្ទាប់មកក៏សម្រេចចិត្តបើកឡានត្រឡប់ទៅផ្ទះវិញ។

**យ្យូលី យំយែកនៅលើគ្រែដេករបស់ខ្លួនដែលមាន ហុងស៊ុល នៅក្បែរចាំលួងលោម**

"ហេតុអីក៏បង ម៉ាត ធ្វើបែបហ្នឹងដាក់ខ្ញុំ...បងម៉ាត ចិត្តអាក្រក់ណាស់ ខ្ញុំមិនស្រឡាញ់ បងម៉ាត ទៀតទេ..."

នាងនៅតែយំមិនឈប់ រហូតដល់ទូរសព្ទដៃបន្លឺឡើង ទើបផ្អាក ឯហុងស៊ុល ក៏រត់ទៅយកទូរសព្ទដៃរបស់ចៅហ្វាយមកមើលលេខ។

"លោក ម៉ៃ"

យ្យូលី ជូតទឹកភ្នែក ដកដង្ហើមចូលឲ្យជ្រៅៗ ហៅស្មារតីខ្លួនឯងមកវិញ។

"ឲ្យមកខ្ញុំ"

ហុងស៊ុល ហុចទូរសព្ទដៃឲ្យចៅហ្វាយភ្លាម យ្យូលី ក៏ចុចទទួល។

"សួស្តីបង ម៉ៃ"

(លីលី ដឹងរឿងបង ម៉ាត ហើយឬនៅ?)

យ្យូលី ធ្វើមុខក្រមូវ ព្រោះគិតថា មេសាន់ មានន័យដល់រឿងរបស់ម៉ាទិនេស និងជីយ៉ន នៅលើគ្រែជាមួយគ្នា។

"ដឹងហើយ"

(អីចឹងឬ ខ្ញុំស្មានថាមិនទាន់ដឹង ពេលនេះ បងម៉ាត កំពុងតែត្រូវនាំឡើងឧទ្ធម្ភាគចក្រ មកមន្ទីរពេទ្យនៅទីនេះ)

នាងក្រមុំភាំង សួរដោយការងឿងឆ្ងល់។



"ហេតុអី...ឡើងឧទ្ធម្ភាគចក្រ ហើយហេតុអីត្រូវនាំ បងម៉ាត ទៅមន្ទីរពេទ្យ?"

(អា...ក្រែងប្រាប់ថាដឹងហើយនោះអី)

"ខ្ញុំស្មានថារឿងរបស់សាស្ត្រចារ្យ គីម"

(មិនមែនទេ)

សម្តីរបស់ មេសាន់ តានតឹង នោះហើយដែលធ្វើឲ្យ យ្យូលី មិនស្រួលចិត្ត។

(បងម៉ាត មានគ្រោះថ្នាក់ចរាចរណ៍ បុកដើមឈើ របួសធ្ងន់ធ្ងរ ពេលនេះមិនទាន់ដឹងខ្លួនទេ)

"បងម៉ាត...គ្រោះថ្នាក់ចរាចរណ៍!"

សម្តីរបស់នាងឮខ្សាវៗបេះដូងធ្លាក់ទៅនៅនឹងភ្នែកគោ ការព្រួយបារម្ភដែលមានចំពោះស្វាមីខ្លាំងជាងការឈឺចាប់អម្បាញ់មិញទៅទៀត។

"មិនពិត...ទេមែនទេ បងម៉ៃ លេងសើចនឹងខ្ញុំទេមែនទេ"

(ជារឿងពិត បងម៉ាត កំពុងតែទៅមន្ទីរពេទ្យដើម្បីពិនិត្យឈាម ព្រោះគាត់ជឿជាក់ថា ខ្លួនឯងមិនបានធ្វើអីស្រីម្នាក់នោះ តែមានគ្រោះថ្នាក់កើតឡើងនៅតាមផ្លូវ)

"ព្រះអើយ..." បេះដូងរបស់នាងស្ទើរតែគាំង។

(ខ្ញុំគេរប្រាប់តែប៉ុណ្ណឹង សុំទៅទាក់ទងអ្នកជំនាញខាងឧទ្ធម្ភាគចក្រសិន គួរតែមកដល់នៅកន្លះម៉ោងទៀត)

"អរគុណ បងម៉ៃ ខ្ញុំនឹងប្រញាប់ទៅ"



យ្យូលី ដាក់ទូរសព្ទចុះ មុខក៏ស្លេកស្លាំងបបូរមាត់ញ័រប៉ប៉ប់ ទើបហុងស៊ុល សួរដោយការព្រួយបារម្ភ។



Scanned with CamScanner

"អ្នកនាងកើតអី ?"

អ្នកនាងងាកទៅរកអ្នកសួរ ដែលទឹកភ្នែកហូររហាម។

"បងម៉ាត គ្រោះថ្នាក់...ពេលនេះមិនទាន់ដឹងខ្លួន"

"ព្រះជាម្ចាស់!" ហុងស៊ីល លើកដៃស្ទាបទ្រូង "អ្នកនាងធ្វើចិត្តឲ្យត្រជាក់ លោក ម៉ាត មិនអីទេ"

"ហុងស៊ីល...នាំខ្ញុំទៅរក បងម៉ាត ខ្ញុំបារម្ភពី បងម៉ាត"

"បានៗ យើងនឹងទៅឥឡូវនេះ" ហុងស៊ីល សឹងតែឱបក្រសោប យូលី ដើរចេញពីបន្ទប់តែម្តង ព្រោះចៅហ្វាយខ្សោះកម្លាំងទាំងកាយទាំងចិត្ត។

**"បងម៉ែ... បងម៉ាត នៅឯណាហើយ...យ៉ាងម៉េចដែរ ?" យូលី សួរ** ដោយសំឡេងរដាក់រដុប។

"លីលី ធ្វើចិត្តឲ្យត្រជាក់"

"ខ្ញុំធ្វើចិត្តត្រជាក់ម៉េចនឹងបាន ខ្ញុំបារម្ភពី បងម៉ាត..." នាងឡូឡា ទាំង **ទឹកភ្នែកហូររហាម ហើយងាកមើលទៅជុំវិញខ្លួន ដើម្បីរកមើលស្វាមី "ហើយ បងម៉ាត នៅឯណា បងម៉ាតនៅឯណា បងម៉ែ ?"**

មេសាន់ ដកដង្ហើមធំ ដាក់ដៃលើស្មាទាំងពីររបស់នាង។

"បងម៉ាត កំពុងតែត្រូវវះកាត់ ពេលនេះមិនទាន់ដឹងអាការៈច្បាស់លាស់"

"អ្នកនាង"

ហុងស៊ីល ស្ទុះមកគ្រាហ៍ចៅហ្វាយដែលរកកល់ចងដួលខ្លោកពេល បានឮដូច្នេះ ហើយនាំទៅអង្គុយលើកៅអីពណ៌ផ្ទៃមេឃ។

"បងម៉ាត...ត្រូវតែមិនអី" នាងយំមិនឈប់ ធ្វើឲ្យ មេសាន់ រំជួលចិត្ត។

"កុំបារម្ភអី លីលី ទីនេះមានតែពេទ្យពូកែ បងម៉ាត ត្រូវតែមិនអី ជឿខ្ញុំ



ចុះ"

នាងក្រមុំងើយមុខដែលហូរទឹកភ្នែករហាម មើល មេសាន់។

"បងម៉ែ មិនកុហកខ្ញុំទេ ?"

"ខ្ញុំមិនកុហកទេ ធ្វើចិត្តឲ្យត្រជាក់ លីលី"

នាងព្យាយាមធ្វើចិត្តឲ្យត្រជាក់ អត់ធ្មត់ឲ្យ ម៉ាទិនេស ចេញពីបន្ទប់វះកាត់ដោយសុវត្ថិភាព ហើយមួយសន្ទុះក្រោយមក ក្រុមគ្រូពេទ្យក៏ចេញពីបន្ទប់វះកាត់ ដើរមករក មេសាន់ ទើបនាងស្ទុះដើរទៅរក។

"លោក ម៉ាឡេសាសសូ មានសុវត្ថិភាពហើយ លោកប្រធាន"

នាងបានឮសំឡេងព្រួសខ្យល់ដង្ហើមចេញមកតាមមាត់របស់ មេសាន់ ដែលនាងក៏ធ្វើបែបនោះដូចគេ។

"បងម៉ាត...មានសុវត្ថិភាពហើយ..." នាងនិយាយរអ៊ូៗ ញញឹមទាំងទឹកភ្នែក។

"តែយប់នេះត្រូវរង់ចាំមើលអាការៈនៅក្នុងបន្ទប់ អាយធីយូ មួយយប់ លោកប្រធាន បើយប់នេះគ្មានអាការៈខុសពីធម្មតា ព្រឹកស្អែកអាចនាំចេញពីបន្ទប់អាយស៊ីយូបាន"

"អីចឹងជួយមើលខុសត្រូវផង បើមានការអីតេររកខ្ញុំបាន ២៤ ម៉ោង"

"បាទ លោកប្រធាន"

លោកគ្រូពេទ្យដែលជាអ្នកវះកាត់ ម៉ាទិនេស ដើរចេញទៅហើយ ទើប មេសាន់ ងាកមករកបងថ្លៃស្រីដែលឈរញញឹមទាំងទឹកភ្នែក។



"លីលី ទៅសម្រាកទៅ ស្អែកចាំមកមើល មកមើល បងម៉ាត ទៀត"

"អត់ទេ ខ្ញុំនៅជាមួយ បងម៉ាត" នាងគ្រវីក្បាល ញាប់ស្អេក។

"អ្នកនាង បន្ទប់អាយស៊ីយូ គេមិនឲ្យអ្នកក្រៅចូលទៅទេ" ហុងស៊ីល

ដាស់តឿនស្មារតីចៅហ្វាយ។

"ឲ្យខ្ញុំអង្គុយចាំនៅមុខនេះក៏បានដែរ ខ្ញុំមិនចង់ទុកបងម៉ាតចោលទេ"

"លីលី...បងម៉ាត នឹងមិនសប្បាយចិត្ត បើដឹងថា លីលី ត្រូវមកលំបាកអង្គុយទះមូសដើម្បីកំដរបែបនេះ" មេសាន់ និយាយដោយទឹកមុខប្រាកដប្រជា "ជឿខ្ញុំទៅ ត្រឡប់ទៅវិញ ហើយស្អែកចាំមកទៀត"

"តែ..."

"ជឿខ្ញុំ"

នាងក្រមុំស្រក់ទឹកភ្នែករហាម ព្រោះបារម្ភពី ម៉ាទិនេស ខ្លាំង ប៉ុន្តែមិនអាចរឹងទទឹងបាន។

"ចាំ ស្អែកខ្ញុំនឹងមកទៀត"

មេសាន់ ដកដង្ហើមធំ ធូរទ្រូងខ្សាក។

"ពូកែណាស់ ស្អែកជួបគ្នា"

"តោះអ្នកនាង ចាំស្អែកភ្ញាក់ពីព្រលឹម មកមើលលោក ម៉ាត" ហុងស៊ីល ប្រាប់ចៅហ្វាយ។

"អ៊ីចឹងទៅសិនហើយ បងម៉ៃ ជួយមើលបងម៉ាតផង"

"លីលី កុំបារម្ភ បងម៉ាត ជាបងប្រុសរបស់ខ្ញុំយ៉ាងណាក៏ខ្ញុំត្រូវតែមើលថែឲ្យបានល្អ" អ្នកកំលោះញញឹមដាក់ "ទៅផ្ទះចុះ"

"អរគុណ"

យ៉ូលី ព្រមឲ្យ ហុងស៊ីល នាំដើរចេញមកដោយនៅតាមផ្លូវនៅតែយំមិនឈប់ ទោះ ម៉ាទិនេស មានសុវត្ថិភាពហើយក៏ដោយ ប៉ុន្តែគេស្ថិតនៅក្រោមការតាមដានរបស់ពេទ្យ ដោយនាងមិនអាចចែករំលែកការឈឺចាប់ពីគេបាន។

"អ្នកនាង...ឈប់យំទៅ លោក ម៉ាត មានសុវត្ថិភាពហើយ"



"ខ្ញុំ...អាណិតបងម៉ាត"

"បើអាណិតលោក ម៉ាត អ្នកនាងត្រូវចាំមើលថែលោក ម៉ាត ឲ្យបានល្អ លោក ម៉ាត នឹងឆាប់ជា"

យ៉ូលី ងក់ក្បាល ហើយលែងមាត់លែង.កតែក្នុងចិត្តកំពុងតែបារម្ភខ្លាំង។



# ១៧

បន្ទាប់ពីដេកមិនលក់ពេញមួយយប់ ទើបព្រលឹមឡើង យ្យូលី មានសភាពស្លេកស្លក់ធ្វើឲ្យ ហុងស៊ីល ព្រួយបារម្ភ។

"អ្នកនាងអូខេទេ បើមិនអូខេ ខ្ញុំទៅមើល លោកម៉ាត ជំនួសក៏បានដែរ"

"អត់ទេ...ខ្ញុំទៅរក បងម៉ាត" នាងគ្រវីក្បាល បញ្ជាក់ពីគោលជំហររបស់ខ្លួន។

"តែមុខអ្នកនាងស្លក់ណាស់ ក្រោមភ្នែកខ្មៅដូចមនុស្សមិនបានដេកមិនបានពួនពេញមួយយប់"

"ខ្ញុំមិនអីទេ យើងឆាប់ទៅៗ តិចម៉ាក់ភ្ញាក់ឡើងឃើញយើងហើយសង្ស័យ"

ព្រោះម្ដាយមានជំងឺរ៉ាំរ៉ៃ ទើប យ្យូលី មិនប្រាប់ហេតុការណ៍ដែលកើតឡើងឲ្យគាត់ដឹង។

"ចាំ អ្នកនាង"

ពួកនាងបណ្ដើរគ្នាចេញពីផ្ទះ ឡើងឡានដែលអ្នកបើកបញ្ឆេះម៉ាស៊ីនចាំសំដៅទៅមន្ទីរពេទ្យជាបន្ទាន់។

"អ្នកនាង ដើរយឺតៗក៏បានដែរ តិចដួល" ហុងស៊ីល ប្រាប់ចៅហ្វាយរបស់ខ្លួន ដែលពេលមកដល់មន្ទីរពេទ្យ ចុះពីឡានក៏រត់ចូលមកក្នុងអគារភ្លាម។

"ខ្ញុំអន្ទះសាចង់ជួប បងម៉ាត ឆាប់ៗ"

"ហើយអ្នកនាងដឹងឬថាលោក ម៉ាត នៅបន្ទប់ណា?"



អ្នកដែលកំពុងរត់ញាប់ជើង ទៅជាទច់ដំណើរ ហើយបែរមករកហុងស៊ីល បង្ហាញឲ្យឃើញទឹកមុខអស់សង្ឃឹម។

"មិនដឹងទេ"

"អីចឹងតេរទៅរក លោកម៉ៃ សិនទេ ឬមិនអីចឹងសួរនៅកន្លែងទទួលភ្ញៀវ" ហុងស៊ីល ផ្ដល់យោបល់។

"អីចឹងចាំខ្ញុំតេរទៅរក បងម៉ៃ"

នាងទាញទូរសព្ទចុចទៅរក មេសាន់ ភ្លាម។

"បងម៉ៃ បងម៉ាត នៅបន្ទប់ណា?"

ហើយពេល មេសាន់ ប្រាប់ នាងក៏ញញឹមពព្រាយ។

"ចាំ បងម៉ៃ ខ្ញុំនឹងឡើងទៅឥឡូវនេះ"

យ្យូលី ដាក់ទូរសព្ទចុះ ហើយងាកមករក ហុងស៊ីល។

"តស់ បងម៉ាត នៅបន្ទប់សម្រាកហើយ"

"ចាំ អ្នកនាង"

ពួកនាងបណ្ដើរគ្នាចូលជណ្ដើរយន្ត មិនយូរប៉ុន្មានក៏ឡើងមកដល់គោលដៅ។ ពេលទ្វារជណ្ដើរយន្តបើក នាងក៏ម្នីម្នាដើរនាំ ហុងស៊ីល សំដៅបន្ទប់ដែល មេសាន់ ប្រាប់។

"សួស្ដី លីលី សួស្ដី ហុងស៊ីល"

"សួស្ដី បងម៉ៃ"

នាងរាក់ទាក់ មេសាន់ ពេលបើកទ្វារចូលទៅ ភ្នែកក៏សម្លឹងមើលទៅអ្នកដែលដេកស្ដូកស្ដឹងនៅលើគ្រែ ទឹកភ្នែកក៏រហូររហាម ពេលឃើញសភាពរបស់គេ។



"បងម៉ាត..." នាងស្ទុះទៅតោងគ្រែ មើលមុខសង្ហាដែលមានបង់រុំរបួស

ច្រើនកន្លែងដោយការសោកស្តាយ។

"បងម៉ាត...ឈឺខ្លាំងទេ..."

មេសាន់ ដើរមកឈរក្បែរ។

"កាលពីព្រឹកខ្ញុំនិយាយជាមួយពេទ្យអ្នកកាន់ខេសនេះហើយ បងម៉ាត មានអាការៈមិនគួរឲ្យបារម្ភទេ សំណាងល្អដែលជើងមិនរងការប៉ះទង្គិចដល់ថ្នាក់ត្រូវប៉ង់ស្មង់ មានតែឆ្អឹងខ្នងប៉ុណ្ណោះដែលប៉ះទង្គិចខ្លាំង"

យ្យូលី បើកភ្នែកធំៗ ព្រោះចាំបានថា ព្រោះតែឆ្អឹងខ្នងរបស់នាងរងការប៉ះទង្គិច ទើបធ្វើឲ្យនាងត្រូវអង្គុយលើរទេះរុញអស់រយៈពេលយូរ ទម្រាំតែជាត្រូវចំណាយពេលច្រើនឆ្នាំ។

"ហើយបែបនេះ...បងម៉ាត ដើររួចទេ ?"

"ត្រូវប្រើពេលវេលាខ្ញុំមិនច្បាស់ដែរ"ព្រោះមិនមែនជាពេទ្យឯកទេសខាងនេះ ទើប មេសាន់ មិនជឿជាក់ "តែ លីលី សប្បាយចិត្តចុះ ពេទ្យនៅទីនេះពូកែគ្រប់គ្នា បងម៉ាត ត្រូវតែជាក្នុងពេលឆាប់ៗនេះ"

"ខ្ញុំក៏សង្ឃឹមថាអីចឹងដែរ បងម៉ែ"

"អុំ ហើយនេះម៉ាក់របស់ លីលី ដឹងរឿងនេះឬអត់ ?"

នាងក្រមុំគ្រវីក្បាល។

"ខ្ញុំមិនបានប្រាប់ម៉ាក់ទេ ខ្លាចគាត់មិនសប្បាយចិត្ត អាការៈនឹងទ្រុឌទ្រោម "

"ល្អហើយដែលមិនប្រាប់ ព្រោះខ្ញុំក៏មិនបានប្រាប់ប៉ាម៉ាក់ដែរ មានតែមីក ម្នាក់ប៉ុណ្ណោះដែលដឹងថាបង ម៉ាត គ្រោះថ្នាក់ ព្រោះមិនចង់ឲ្យគ្រប់គ្នាមិនសប្បាយចិត្ត"

"បងម៉ែ ធ្វើត្រូវហើយ"

នាងនិយាយបានតែប៉ុណ្ណឹង ទ្វារបន្ទប់សម្រាករបស់ម៉ាទិនេស ក៏ត្រូវបើកដោយគ្មានការគោះ គ្មានការសុំអនុញ្ញាត តាមដោយ ជីយ៉ន ដែលដើរកែក្រោយចូលមក។

"សួស្តីអ្នកទាំងអស់គ្នា...ខ្ញុំមកសួរសុខទុក្ខលោកនាយក"

យ្យូលី ងាកមុខចេញដោយការមិនពេញចិត្ត ប៉ុន្តែ ជីយ៉ន មិនខ្វល់ នាងយកកន្ត្រកផ្លែឈើទៅដាក់លើតុ ហើយស្ទុះទៅតោងគ្រែអ្នកជំងឺ។

"ព្រះអើយ! លោកនាយករបស់ខ្ញុំ...ហេតុអីក៏សំណាងអាក្រក់បែបនេះ"

មេសាន់ ដកដង្ហើមធំ ហើយដើរមកចាប់បេះដៃ ជីយ៉ន ឲ្យចេញឆ្ងាយពីបងប្រុសរបស់ខ្លួន។

"នេះលោកចង់ធ្វើស្អី!" ជីយ៉ន ស្រែកច្រែតៗដាក់គេ។

"នាងមិនឃើញទេឬថាប្រពន្ធរបស់ បងម៉ាត ឈរឲ្យជ្រងោនៅត្រង់នេះ កុំមកធ្វើចរិតជាឆ្មាលួចស៊ីនៅមុំនេះ"

ជីយ៉ន ដៀងមើល យ្យូលី ហើយសើចចំអក។

"ហេតុអីខ្ញុំត្រូវក្រែងចិត្តលោកដុកទ័រសង្ហា ខ្ញុំក៏ជាប្រពន្ធម្នាក់របស់បងប្រុសលោកដែរ" នាងបួញមាត់បួញ-កនិយាយដោយទឹកមុខគួរឲ្យជ្រេញសម្រាប់អ្នកមើល "ប្រពន្ធមកមើលប្តីមិនបានឬ"

"បើ បងម៉ាត ចាប់អារម្មណ៍ស្រីដូចនាង ខ្ញុំថាប្រហែលជាចាប់អារម្មណ៍យូរហើយ មិនមែនមកចាប់អារម្មណ៍ពេលមានប្រពន្ធបែបនេះទេ"

មេសាន់ សើចចម្អក និងសម្លឹងមើល ជីយ៉ន តាំងពីលើដល់ក្រោមដោយការប្រមាថ។

"នាងមិនស្អាតដល់ថ្នាក់ បងម៉ាត ត្រូវយកភ្នែកមើលផង"

"នេះលោក..." ជីយ៉ន ដែលត្រូវប្រមាថនឹងមុខ ក៏ស្ទើរតែទ្រាំមិនបាន



"ចាំមើល ខ្ញុំបានចូលទៅនៅភូមិគ្រឹះនោះពេលណា លោកនឹងត្រូវខ្ញុំសងសឹក"

"ខ្ញុំថានាងគួរតែភ្ញាក់ឡើង ព្រោះនាងគ្មានថ្ងៃនោះទេ អូ៎...ខ្ញុំភ្លេចប្រាប់ ខ្ញុំយកឈាមរបស់ បងម៉ាត ទៅពិនិត្យរកសារជាតុប្លែកៗនៅក្នុងខ្លួនហើយ បើឃើញ...នាងមុខជាដឹងហើយថានឹងមានអ្វីកើតឡើង" មេសាន់ ញញឹមត្រជាក់ដាក់ ខណៈដែល ជីយ៉ន ខឹងដាច់ក្បាលដាច់កន្ទុយ។

"ចាំមើល ថាអ្នកណាឈ្នះ"

មេសាន់ គ្រវីក្បាលដោយការអាចិត្ត ហើយងាកទៅរក យ្យូលី។

"ខ្ញុំទៅធ្វើការសិនហើយ លីលី នៅម្តុំនេះយូរ អាចក្អួតបាន"

"ចាំ បងម៉ៃ"

មេសាន់ ដើរចេញទៅហើយ ដោយមាន ជីយ៉ន តាមមើលដោយការស្អប់ខ្ពើម។

"គិតឬថាខ្ញុំមិនហ៊ានស្អប់មនុស្សសង្ហាៗ"

ហុងស៊ីល ឮដូច្នេះហើយ ក៏អត់ជ្រេញមិនបាន។

"អ្នកនាង ចាំខ្ញុំទៅហៅសន្តិសុខមកឲ្យ"

"តាមមកធ្វើអី ?"

"តាមមកបណ្តេញឆ្កែចេញពីទីនេះ"

ហុងស៊ីល និយាយ និងដៀងមើល ជីយ៉ន ធ្វើឲ្យអ្នកដែលត្រូវប្រមាថថាជាឆ្កែ ខឹងសម្បាជាខ្លាំង។

"ទោះខ្ញុំជាឆ្កែ តែលោកនាយកជាប្តីរបស់ខ្ញុំ"

"ស្រីឆ្កួត និយាយមិនចេះខ្មាសមាត់"

ហុងស៊ីល ស្ទុះទៅរកបំណាងទះតប់ តែ ជីយ៉ន លើកដៃយារខ្ពស់ជាង។

"ចូលមក ចាំមើលមើល៍ អ្នកណាទះអ្នកណាបានមុន"



"ហុងស៊ីល បានហើយ កុំបន្ទាបខ្លួនឯង" យ្យូលី ហាមប្រាម មិនចង់ឲ្យមានសង្គ្រាមកើតឡើងក្នុងបន្ទប់សម្រាករបស់ស្វាមី។

"អ្នកនាងមើលចុះ វាធ្វើឫកធ្វើពា និយាយកុហកបែបនេះ"

"ខ្ញុំកុហកយ៉ាងម៉េច ឯងក៏ឃើញដូចចៅហ្វាយរបស់ឯងមិនអីចឹងថាខ្ញុំនិងលោកនាយកនៅលើគ្រែជាមួយគ្នា"

យ្យូលី ឈឺចុកក្នុងទ្រូង ទឹកភ្នែករលីងរលោងរកកល់ចង់ស្រក់ឲ្យបាន។

"ហុងស៊ីល...ខ្ញុំថាយើងនាំគ្នាទៅវិញទៅ"

"ទៅវិញយ៉ាងម៉េចអ្នកនាង ក្រែងថានៅកំដរ លោកម៉ាត នោះអី"

"ប្រពន្ធថ្មីគេមកហើយតើ" នាងគ្រមុំប្រាប់ដោយសំឡេងខ្សាវៗ ធ្វើឲ្យ ជីយ៉ន បានចិត្ត។

"អរគុណដែលយល់ អូ៎! ហើយបើលោកនាយកចេញពីមន្ទីរពេទ្យពេលណា ខ្ញុំសង្ឃឹមថានាងនឹងលែងលះឲ្យគេ ព្រោះយើងទាំងពីរចង់ចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាស្ទើរតែដាច់ខ្យល់ទៅហើយ"

"អ៊ឺក !"

ហុងស៊ីល ធ្វើឫកក្អួតចង្អោរដាក់ តែ ជីយ៉ន មិនខ្វល់ ដើរទៅចាប់ដៃម៉ាទិនេស អង្កែល។

"យើងទាំងពីរស្រឡាញ់គ្នា... សង្ឃឹមថានាងចៀសផ្លូវឲ្យពួកយើងអីន យ្យូលី"

ម្ចាស់ឈ្មោះទ្រាំលែងបាន ទើបដើរចេញពីបន្ទប់។

"អ្នកនាងចង់ទៅណា ?"



"ប្រញាប់ទៅស៊ីញ៉ៅលែងលះទេដឹង" ជីយ៉ន តាមចម្អកឡកឡឺយ ធ្វើឲ្យហុងស៊ីល អត់ខឹងមិនបាន។

"ដេកចាំទៅថាបានដូចដែលសង្ឃឹម ស្រីពស់វែក!"

ហុងស៊ុល ដេររួចហើយ ក៏រត់តាមចៅហ្វាយភ្លាម។

"ហ្គេមនេះខ្ញុំត្រូវតែឈ្នះប៉ុណ្ណោះ លោកនាយកត្រូវតែជារបស់ខ្ញុំ"

និយាយហើយ ជីយ៉ន ក៏ដើរមកឈរក្បែរគ្រែម្តងទៀត សម្លឹងមើលមុខសង្ហាដែលមានស្នាមជាំច្រើនកន្លែងដោយអារម្មណ៍ដឹងខុស។

"ខ្ញុំសុំទោសដែលធ្វើឲ្យលោកឈឺខ្លួនបែបនេះ"

**គ្រេក!**

ទ្វារត្រូវបើកម្តងទៀត ហើយ តេយ៉ុង ក៏ដើរចូលមក។

"អេ៎ តេយ៉ុង មកសួរសុខទុក្ខលោកនាយកដែរឬ?"

"បាទ"

ទឹកមុខរបស់ តេយ៉ុង ក្រមូវ ពេលដើរមកឈរក្បែរបងស្រី។

"ខ្ញុំមានរឿងចង់និយាយជាមួយបង"

"រឿងអីនិយាយត្រង់នេះក៏បាន"

អ្នកកំលោះគ្រវីក្បាលតិចៗ មើលទៅ ម៉ាទិនេស ដែលដេកស្ងួកស្ងឹង។

"ខ្ញុំមិនចង់រំខានអ្នកជំងឺ"

"មានន័យថារឿងសំខាន់មែនទេ?" ជីយ៉ន ងើបចេញពីកៅអីក្បែរគ្រែ។

"បាទ ខ្ញុំទៅចាំនៅខាងក្រៅ" និយាយហើយ គេក៏ដើរចេញទៅ ទើប **ជីយ៉ន ងាកទៅរក ម៉ាទិនេស។**

**"តិចទៀតខ្ញុំមកវិញលោកនាយក"**

និយាយហើយ នាងក៏ដើរតាមប្អូនប្រុសម្តាយទីទៃចេញពីបន្ទប់។

"ឯងមានការអីនិយាយជាមួយយើងក៏និយាយមក"

"អម្បាញ់មិញពេលមក ខ្ញុំឃើញលោកស្រី អ៊ីន"



ជីយ៉ន ញាក់ស្មាបន្តិចដោយមិនយកចិត្តទុដាក់។

"យ៉ាងម៉េច រឿងប៉ុណ្ណឹងចាំបាច់យកមកនិយាយប្រាប់បងដែរ"

"នាងយំ"

"តាមតែវាទៅ ឯងមកប្រាប់បងធ្វើអី ឬឯងចង់លួងលោម ក៏ធ្វើទៅ កុំមករញ៉េរញ៉ៃនឹងយើង"

ជីយ៉ន បែរខ្លួនដើរចូលបន្ទប់របស់ ម៉ាទិនេស វិញ តែត្រូវប្អូនប្រុសស្រវាចាប់ដៃជាប់។

"ខ្ញុំនិយាយមិនទាន់ចប់ទេ"

"ស្អីឯង!" ជីយ៉ន ងាកទៅសួរដោយការមួម៉ៅ ទើប តេយ៉ុង ព្រលែងដៃបងស្រី ហើយសម្រេចចិត្តនិយាយ។

"ខ្ញុំទ្រាំលែងបានហើយ ខ្ញុំរអៀសចិត្តខ្លាំងណាស់"

"ឯងចង់និយាយពីស្អី"

"គឺរឿងដែលបងធ្វើដាក់ លោកម៉ាឡេសាសសូ ខ្ញុំទ្រាំធ្វើជាមនុស្សអាត្មានិយមបែបនេះលែងបានហើយ"

ជីយ៉ន ញញឹម យកចង្អុលដៃចាក់ដើមទ្រូងប្អូនប្រុសខ្លាំងៗ។

"កុំល្ងង់ពេក គឺម តេយ៉ុង ឯងក៏ឃើញដែរថាផែនការរបស់បងកំពុងតែរលូន ពេលលោកនាយកដឹងខ្លួន គេនឹងលែងលះពីនាងនោះ ហើយពេលវាមានសេរីភាព ឯងចូលទៅជំនួសបានភ្លាម ហើយបែបនេះឯងមករអៀសចិត្តធ្វើស្អី ឯងគួរតែសប្បាយចិត្តដែលផែនការរបស់បងកំពុងតែធ្វើឲ្យឯងសមបំណង"

"មុននេះមែន ខ្ញុំយល់ស្របតាមបងស្រីតែពេលនេះខ្ញុំគិតឃើញហើយ ខ្ញុំមិនអាចធ្វើបាបលោកស្រី អ៊ីន បានទេ ខ្ញុំមិនចង់ឃើញនាងយំបែបហ្នឹងទៀត ខ្ញុំអាណិតនាង"





Scanned with CamScanner

"នេះកុំប្រាប់ណាំថាឯងចង់ប្រាប់ការពិតដល់វា!" ជីយ៉ន បើកភ្នែកឲ្យក្រឡោតដាក់ប្អូនប្រុស តែ តេយ៉ុង មិនឆ្លើយ គេដើរចេញ ទើបនាងដើរទៅស្រវាចាប់ដៃ។

"នែ! ឆ្លើយប្រាប់បងមកអាប្អូនចង្រៃ ឯងចង់ក្បត់បងមែនទេ"

តេយ៉ុង បេះដៃបងស្រីចេញពីដៃរបស់ខ្លួន ហើយនិយាយដោយទឹកមុខម៉ាំ។

"ខ្ញុំទៅធ្វើរឿងដែលត្រឹមត្រូវ"

"អាចង្រៃ បើឯងហ៊ាននិយាយបងនឹងសម្លាប់ឯង"

តេយ៉ុង មិនតបតនឹងបងស្រីទៀត គេសម្រេចចិត្តដើរចេញទៅ ប៉ុន្តែត្រចៀកទាំងពីរបែរជាបានឮសំឡេងគំរាមរបស់ ជីយ៉ន ដែលស្រែកតាមពីក្រោយ។

"អាប្អូនហេងស៊ុយ"

ជីយ៉ន ខឹងសម្បា ទើបទូរសព្ទទៅរកមនុស្សរបស់ខ្លួនភ្លាម។

"ខ្ញុំត្រូវការកាំភ្លើងមួយដើម ឯងរកឲ្យខ្ញុំផង"

ពេលអ្នកដែលខ្លួនគេរទៅព្រមធ្វើតាមបញ្ជាហើយ នាងក៏ចុចទូរសព្ទបិទ ហើយញញឹមគួរឲ្យខ្លាច ទឹកមុខដូចបិសាច។

"ខ្ញុំមិនព្រមឲ្យអ្នកណាមកបំផ្លាញផែនការរបស់ខ្ញុំជាដាច់ខាត សូម្បីតែឯង គឹម តេយ៉ុង"

បីថ្ងៃក្រោយមក ម៉ាទិនេស ក៏ដឹងខ្លួន ហើយពេលឃើញសភាពរបស់ខ្លួនក៏អត់សោកស្ដាយមិនបាន។ គេរកនឹកអ្វីដែលកើតឡើងមុននេះ ទើបចាំបានថាខ្លួនឯងមានគ្រោះថ្នាក់ចរាចរណ៍ សំណាងប៉ុនណាដែលមិនគ្រោះថ្នាក់ដល់



ជីវិត។

គេដកដង្ហើមធំ ហើយខំមាត់លើកដៃអង្អែលក្បាលរបស់មនុស្សម្នាក់ដែលអង្គុយក្រាបនៅលើគ្រែ ហើយទោះមិនឃើញមុខ គេដឹងច្បាស់ថាស្រីម្នាក់នោះជាអ្នកណា។

"លីលី..."

សំឡេងស្អកខ្សោះបន្លឺឡើងខ្សាវៗប៉ុណ្ណោះ ប៉ុន្តែ យូលី បែរជាឮច្បាស់ ទើបស្ទុះងើប និងពេលឃើញថា ម៉ាទិនេស ដឹងខ្លួន នាងក៏ញញឹមពព្រាយដោយការសប្បាយចិត្ត។

"បងម៉ាត...ដឹងខ្លួនហើយ..."

អ្នកកំលោះញញឹមដាក់ភរិយា។

"បងដេកលក់យូរប៉ុនណា?"

"បីថ្ងៃបីយប់ អូនខ្លាចថាបងមិនដឹងខ្លួនរហូតតើ" នាងយំ។

"បងត្រូវតែដឹងខ្លួន បងមិនព្រមស្លាប់ស្រួលៗទេ យ៉ាងណាក៏ត្រូវតែត្រឡប់មករស់នៅជាមួយអូនវិញឲ្យបាន"

បេះដូងរបស់នាងកំពុងតែរីកមាឌ និងអាចនឹងរីកណែនទ្រូង បើ ជីយ៉ន មិនបង្ហាញខ្លួន។

"លោកនាយក...ដឹងខ្លួនហើយឬ"នាងស្ទុះមកឈរក្បែរគ្រែប្រើស្មារបស់ខ្លួនកៀស យូលី ចេញឲ្យឆ្ងាយ "ខ្ញុំបារម្ភពីលោកនាយកមែនទែន"

"អរគុណ" ម៉ាទិនេស តបដោយសំឡេងសោះកក្រោះ។



"អីយ៉ា លោកនាយកកុំធ្វើជាមិនចាប់អារម្មណ៍ខ្ញុំ ភ្លេចហើយឬថាខ្ញុំក៏ជាប្រពន្ធម្នាក់របស់លោកនាយក"

"ខ្ញុំសុំអះអាងចម្លើយដដែលថាខ្ញុំមិនបានធ្វើអីសាស្ត្រចារ្យ គឹម"

"លោកនាយកនិយាយឲ្យសើចមែនទេ   មនុស្សប្រុសមនុស្សស្រីស្រាតនលតកនៅលើគ្រែជាមួយគ្នា បើគ្មានរឿងនៅលើគ្រែកើតឡើងតើគេធ្វើអី"

យ្យូលី ធ្វើមុខក្រមូវភ្លាម។

"ខ្ញុំសុំចេញទៅសិនហើយ"

"លីលី ឈប់សិន អ៊ូយ..." ម៉ាទិនេស ប្រឹងងើប ប៉ុន្តែត្រូវឈឺខ្លួនព្រោះមុខរបួស ដែលសំឡេងស្រែករបស់ស្វាមី ធ្វើឲ្យ យ្យូលី ទប់ដំណើរ ងាកមកមើលគេវិញដោយការព្រួយបារម្ភ។

"បងទើបតែដឹងខ្លួនកុំទាន់អាលកម្រើកខ្លួនពេក"

"មកពីអូនចង់ដើរចោលបង"

នាងក្រមុំដើរមករកគេវិញ។

"ខ្ញុំមិនទៅណាទេ ព្រោះយើងមិនទាន់លែងគ្នា តែបើ បងម៉ាត ជាពេលណា ខ្ញុំត្រូវការលែងលះ"

"លីលី...បងមិនលែងលះ"

"លោកនាយកលែងលះទៅ ទៅលួងវាធ្វើស្អី មានខ្ញុំទាំងមូលហើយ"

"បិទមាត់ទៅ គីម ជីយ៉ន!" ម៉ាទិនេស គ្រហឹមដាក់ ជីយ៉ន ដោយកំហឹង ហើយងាកទៅនិយាយ ជាមួយ យ្យូលី បន្ត "លីលី...ត្រូវតែជឿបង បងមិនបានធ្វើអីពិតមែន បងនឹងពិសោធឲ្យអូនឃើញ" .

នាងក្រមុំរលីងរលោងទឹកភ្នែក ខ្ទឹបបបូរមាត់។

"បងព្យាបាលខ្លួនឲ្យជាសិនទៅ   ហើយចាំយើងនិយាយរឿងនេះម្តងទៀត"

"និយាយធ្វើស្អីទៀតនាងឆាប់លែងលះទៅ អីន យ្យូលី!" ជីយ៉ន ឡូឡាដោយការមិនពេញចិត្ត។



"ប្រាប់ឲ្យបិទមាត់ គីម ជីយ៉ន កុំមកចេះដឹងរឿងក្រុមគ្រួសារខ្ញុំ!"

"ហើយខ្ញុំមិនមែនជាប្រពន្ធរបស់លោកទេឬ"

"មិនមែន!  គ្មានថ្ងៃមែន  មិនថាពេលនេះឬពេលណា!"  ម៉ាទិនេស និយាយដោយកំហឹង "ចេញពីបន្ទប់នេះ ខ្ញុំមិនចង់ឃើញមុខនាង"

"ខ្ញុំមិនទៅ ខ្ញុំជាប្រពន្ធរបស់លោក"

"ខ្ញុំនឹងហៅសន្តិសុខឲ្យមកអូស-កនាងចេញ"

"លោកនាយកចិត្តអាក្រក់ដាក់ប្រពន្ធ" ជីយ៉ន ស្រែកខ្លាំងៗ។

"ចេញទៅ!"

ជីយ៉ន មិនធ្លាប់ឃើញ ម៉ាទិនេស ខឹងដល់ថ្នាក់នេះ ទើបភ័យបុកពោះរហ័សដកថយចេញពីបន្ទប់ភ្លាម។

ម៉ាទិនេស ដកដង្ហើមចូលឲ្យជ្រៅៗ ដោយត្រូវការគ្រប់គ្រងអារម្មណ៍ ហើយនិយាយជាមួយ យ្យូលី បន្ត។

"បងជឿជាក់ថាខ្លួនឯងត្រូវដាក់ថ្នាំ"

យ្យូលី ប្រុងសួរ ប៉ុន្តែទ្វារបន្ទប់ត្រូវបើកចូលមក។

"សួស្តី លោកស្រី អីន សួស្តី លោកម៉ាឡេសាសសូ ខ្ញុំយកផ្លែឈើមកសួរសុខទុក្ខ"

តេយ៉ុង   យកកន្ត្រកផ្លែឈើទៅដាក់លើតុឲ្យអ្នកជំងឺ   ហើយសួរនាំអាការ:។

"លោកធូរហើយមែនទេ"

"អរគុណដែលខំមកសួរសុខទុក្ខ" ម៉ាទិនេស ខាំមាត់និយាយ។



"ដោយក្តីរីករាយ" តេយ៉ុង ញញឹម ហើយងាកទៅរក យ្យូលី "លោកស្រីអីន ញ៉ាំអាហារពេលព្រឹកហើយឬនៅ?"



Scanned with CamScanner

"នៅទេ កំពុងឃ្លាន អីចឹងយើងចុះទៅញ៉ាំអីទៅ" នាងក្រមុំបញ្ឈឺស្វាមី។

"អូខេ ខ្ញុំក៏មានរឿងសំខាន់ចង់ប្រាប់លោកស្រីដែរ"

"លីលី...មិននៅញ៉ាំបាយជាមួយបងទេឬ?" ម៉ាទិនេស សួរ និងមើលភរិយាដោយការអង្វរករ ប៉ុន្តែ យូលី ដែលតូចចិត្តនឹងរឿងរបស់ ជីយ៉ន ត្រូវធ្វើចិត្តរឹងដាក់គេ។

"អត់ទេ ខ្ញុំចេញទៅញ៉ាំបាយជាមួយអ្នកជំនាញ គីម ខ្ញុំទៅសិនហើយបងម៉ាត ចាំខ្ញុំប្រាប់គិលានុបដ្ឋាយិកាឲ្យមកកំដរ អូ...ចាំខ្ញុំទៅតាមសាស្ត្រាចារ្យគីម ឲ្យមកល្អជាង បងនឹងមានសេចក្តីសុខ"

"លីលី..." ម៉ាទិនេស ហៅភរិយាដោយការមិនពេញចិត្ត តែនាងមិនខ្វល់។

"តោះអ្នកជំនាញ គីម"

"បាទ"

ម៉ាទិនេស ខាំធ្មេញក្រតៗ មើលភរិយាដែលបណ្តើរ តេយ៉ុង ចេញពីបន្ទប់ដោយការប្រចណ្ឌហួងហែង។

"ងើបបានពេលណា នឹងចាប់ឋើបឲ្យរាងចាល"

អ្នកកំលោះមួម៉ៅក្តៅក្រហាយប្រឹងខាំមាត់ងើបអង្គុយផ្អែកនឹងក្បាលគ្រែ ទោះឈឺមុខរបួស តែក៏អាចធ្វើបានសម្រេច។

**តេយ៉ុង មើលមុខសោកសៅរបស់ យូលី ដោយការអៀសចិត្ត។ ទោះ**គេចង់បាននាងមកគ្រប់គ្រង ប៉ុន្តែក៏មិនចង់ឃើញនាងបៀមទុក្ខបែបនេះ។

"ហុងស៊ីល មិននៅជាមួយទេឬ?"

អ្នកដែលកំពុងតែអង្គុយក្លឹកព្រោះទុក្ខសោក ភ្ញាក់ក្រញាង ហើយសម្រប



ទឹកមុខ ប្រឹងញញឹមដាក់។

"រសៀលបន្តិចទើបមក"

ពេលឆ្លើយរួចហើយ នាងក៏អង្គុយសោកសៅបន្ត ទើប តេយ៉ុង ដកដង្ហើមធំ។

"ទោះគ្មានលោក ម៉ាឡេសាសសូ...ក៏លោកស្រីមិនមើលប្រុសផ្សេងដែរមែនទេ?"

តំណក់ទឹកភ្នែកដែលព្យាយាមទប់ ត្រូវហូរ នាងរហ័សលើកដៃជូតចោល ទើប តេយ៉ុង ហុចកន្សែងជូតមុខឲ្យ តែនាងបដិសេធមិនទទួលយក ទើបគេទុកវាវិញ។

"ខ្ញុំស្រឡាញ់ បងម៉ាត តាំងពីតូចៗម្ល៉េះ ហើយក៏មិនអាចប្តូរចិត្តទៅស្រឡាញ់អ្នកណាបានទៀតដែរ"

"ខ្ញុំ...យល់ហើយ" គេញញឹម ដោយទឹកមុខសោកសៅ និងដកដង្ហើមធំ បន្ទាប់មកក៏សម្រេចចិត្តនិយាយ "ខ្ញុំមានរឿងចង់សារភាពប្រាប់លោកស្រី"

"ចាំ?"

"ខ្ញុំ...មានរឿងសំខាន់ដែលត្រូវប្រាប់លោកស្រី"

យូលី មើលមុខគេដោយការសង្ស័យ។

"មានរឿងអីឬ មើលទៅទឹកមុខស្រ្តេសម្ល៉េះ"

"រឿងរបស់លោក ម៉ាឡេសាសសូ"

នាងក្រមុំឈ្ងោកមុខមើលតុ ជំនួសមុខរបស់ដៃគូសន្ទនា។

"កាលពិតរឿងយប់នោះ..."



"គីម តេយ៉ុង...មកនៅទីនេះឯង បងខំតាមរក"

ជីយ៉ន បង្ហាញខ្លួន និងសម្លឹងមុខប្អូនប្រុសដោយការរករឿង។

"បងតាមរកខ្ញុំធ្វើអី ?"

បងស្រីញញឹមដាក់ តែជាស្នាមញញឹមក្រជាក់។

"បងមានការនិយាយជាមួយឯង ទៅជាមួយបងបន្តិច យើងមានរឿងត្រូវនិយាយគ្នា"

"អីចឹងបងចាំខ្ញុំមួយភ្លែត ចាំខ្ញុំទៅតាម"

"មិនបាន !" ជីយ៉ន ស្រែកគំហក តែពេលដឹងខ្លួនក៏សើចបន្លប់ "មិនបានទេ បងមានរឿងសំខាន់ពិតមែន"

យ្យូលី ដកដង្ហើមធំ។

"លោកទៅចុះ កុំបារម្ភពីខ្ញុំអី តិចទៀត ហុងស៊ីល មកហើយ"

"តែខ្ញុំមិនទាន់បានប្រាប់...."

"គីមតេយ៉ុងបងប្រាប់ថាឲ្យទៅជាមួយបង"ជីយ៉នសម្លក់សម្លឹងប្អូនប្រុសហើយចាប់ទាញដៃគេឲ្យទៅជាមួយ។យ្យូលីតាមមើលពីរនាក់បងប្អូនដោយការសង្ស័យ បន្ទាប់មកក៏សម្រេចចិត្តដើរលបៗតាមពីក្រោយ។

"បងមានការអីជាមួយខ្ញុំ ?"

ពេលមកដល់កន្លែងស្ងាត់មនុស្ស តេយ៉ុង ក៏សួរបងស្រី ហើយក៏ត្រូវជីយ៉ន ទះកំផ្លៀងមួយទំហឹង។

"អាប្អូនចង្រៃ បងមានគុណចំពោះឯង តែឯងចង់ក្បត់បង គីម តេយ៉ុង !"

តេយ៉ុង មើលមុខបងស្រីដោយការដឹងកំហុស។

"ខ្ញុំសុំទោសដែលធ្វើឲ្យបងមិនពេញចិត្តតែខ្ញុំទ្រាំធ្វើខុសលែងបានហើយ ខ្ញុំទ្រាំឃើញទឹកមុខរបស់លោកស្រី អឹន បៀមទុក្ខលែងបានហើយ នាងកាន់តែឈឺចាប់ ខ្ញុំក៏ឈឺតាម...."

"អ្ហូ ! ទើបឯងចង់ធ្វើឲ្យបងឈឺជំនួសមែនទេ"



"មិនមែនអីចឹងទេ ខ្ញុំគ្រាន់តែចង់ប្រាប់ការពិត"

"បើឯងនិយាយការពិត បងនឹងចប់ ឬឯងចង់ឃើញបងខូចចិត្តបាន តែទ្រាំឃើញមីចង្រៃនោះខូចចិត្តមិនបាន"

"ខ្ញុំសុំទោស តែខ្ញុំត្រូវធ្វើរឿងត្រឹមត្រូវ"

"គីម តេយ៉ុង !"

"ខ្ញុំទៅសិនហើយបងស្រី" តេយ៉ុង បែរខ្លួនដើរចេញ តែក៏ត្រូវទប់ដំណើរពេល ជីយ៉ន ទាញកាំភ្លើងពីកាបូបស្ពាយមកភ្ជង់ក្បាលរបស់គេ។

"បើឯងនិយាយបងនឹងសម្លាប់ឯង គីម តេយ៉ុង !"

"បងស្រី..." តេយ៉ុង ភ្ញាក់ផ្អើលជាខ្លាំង ពេលឃើញបងស្រីម្តាយទីទៃតម្រង់កាំភ្លើងមករកខ្លួន "នេះបងកំពុងតែធ្វើខុស ឈប់ទៅ"

"បងមិនឈប់ ឯងនឹងហើយដែលត្រូវបិទមាត់ ហាមនិយាយដាច់ខាតថាបងដាក់ថ្នាំងងុយដេកឲ្យលោកនាយក ហើយរៀបចំឆាកនោះ"

"តែខ្ញុំត្រូវតែប្រាប់ការពិតដល់លោកស្រី អឹន"

"អីចឹងឯងត្រូវងាប់"

"បងហ៊ានសម្លាប់ខ្ញុំឬ ?"

គេសួរនាងដោយទឹកមុខឈឺចាប់។

"មែន បងហ៊ានសម្លាប់ឯង ដើម្បីឲ្យខ្លួនឯងសមបំណង"

តេយ៉ុង ខាំថ្គាមណែន រលីងរលោងទឹកភ្នែកដោយភាពអស់សង្ឃឹម។

"អីចឹងសម្លាប់ខ្ញុំទៅ ព្រោះបើខ្ញុំនៅដកដង្ហើម ខ្ញុំនឹងរកវិធីប្រាប់ការពិតដល់លោកស្រី អឹន ឲ្យទាល់តែបាន"



"គីម តេយ៉ុង !"

"អ្នកជំនាញ គីម មិនបាច់ប្រាប់អីដល់ខ្ញុំទេ ព្រោះខ្ញុំបានឮអស់ហើយ"

យ៉ូលី ដែលលួចស្ដាប់តាំងពីដើមរហូតដល់ចប់ ដើរចេញមករក។

"អ៊ីន យ៉ូលី!"

"លោកស្រី អ៊ីន" តេយ៉ុង ងាកទៅមើលនាងដោយការព្រួយបារម្ភ "ចូលទៅខាងក្នុងវិញទៅ កុំមកទីនេះ"

ប៉ុន្តែ យ៉ូលី មិនព្រមជឿ នាងដើរមកឈរទល់មុខ ជីយ៉ន។

"នាងសាហាវជាងការគិតរបស់ខ្ញុំឆ្ងាយណាស់ គីម ជីយ៉ន"

ជីយ៉ន ខាំធ្មេញក្រតៗ ព្រោះដឹងថាខ្លួនឯងភ្លាត់ស្នៀតហើយ។

"ខ្ញុំរីករាយធ្វើគ្រប់យ៉ាងដើម្បីឲ្យបានអ្វីដែលខ្ញុំត្រូវការ"

"នាងសាហាវណាស់! ខ្ញុំនឹងប្រាប់រឿងនេះដល់ បងម៉ាត ហើយនាងនឹងត្រូវ បងម៉ាត ស្អប់មួយជីវិត"

ជីយ៉ន ញញឹមចម្អក។

"ឯងគិតថាខ្ញុំបណ្ដោយឲ្យឯងមានជីវិតរស់ ទៅប្រាប់លោកនាយកអ៊ីចឹងឬ មីភ្លើ!"

**ផាច់!**

"អ៊ូយ!"

ជីយ៉ន យកដងកាំភ្លើងវ៉ៃក្បាលប្អូនប្រុសមួយទំហឹង ធ្វើឲ្យអ្នកកំលោះដួលខ្ពោក សន្លប់នៅត្រង់នោះ បន្ទាប់មកក៏ស្ទុះមកចាប់ដៃរបស់ យ៉ូលី លើកកាំភ្លើងភ្ជង់ក្បាល។

"លែងខ្ញុំ គីម ជីយ៉ន!"

"ហ៊ឹស! ឯងត្រូវតែងាប់ អ៊ីន យ៉ូលី"

"លែងខ្ញុំ"

"បងស្រី...កុំធ្វើអីលោកស្រី អ៊ីន" តេយ៉ុង ដែលមានឈាមជោកមុខ



ប្រឹងអង្វរករបងស្រីរបស់ខ្លួន តែ ជីយ៉ន មិនស្ដាប់។

"បើឯងតាមមក បងនឹងបាញ់បំបែកក្បាលនាងនេះឲ្យធ្លាយខួរ ចាំទុក! អាប្អូនទុរយស"

"អ៊ូយ! លែងខ្ញុំ គីម ជីយ៉ន" យ៉ូលី ស្រែក ពេលត្រូវអូសខ្លាំងៗ។

"បិទមាត់ ហើយដើរទៅរកឡានខ្ញុំតាមសម្រួល មិនអ៊ីចឹងខ្ញុំនឹងបាញ់បំបែកក្បាលឯងនៅត្រង់នេះ!"

"កុំ"

យ៉ូលី ភ័យខ្លាច ពេលចុងកាំភ្លើងត្រូវអូសពីកណ្ដាលខ្នងមករកចង្កេះ ដើម្បីបិទបាំងពីខ្សែភ្នែកអ្នកដទៃ។

"បើមិនចង់ងាប់ ឆាប់ដើរទៅ ឲ្យលឿនឡើង!"

យ៉ូលី បង្ខំចិត្តធ្វើតាមបញ្ជារបស់ ជីយ៉ន ដោយគ្មានជម្រើស ខណៈដែល តេយ៉ុង ប្រឹងងើបទៅតាម ប៉ុន្តែឈាមដែលហូរដាបមុខ ធ្វើឲ្យគេព្រិលភ្នែកមើលមិនច្បាស់។

"បងស្រីកុំធ្វើអីលោកស្រី អ៊ីន បងស្រី..." គេប្រឹងប្រវេប្រវា វារទៅតាម ប៉ុន្តែបានតែមួយភ្លែតប៉ុណ្ណោះ ក៏សន្លប់នៅត្រង់នោះ។





Scanned with CamScanner

# ១៨

ពេលភ្ញាក់ដឹងខ្លួនបន្ទាប់ពីសន្លប់ជិតមួយម៉ោង តេយ៉ុង ក៏ស្ទុះងើបអង្គុយ។

"អ្នកជំងឺសម្រាកសិនទៅ កុំទាន់អាលងើប" គិលានុបដ្ឋាយិកាដែលនៅកំដរ ប្រាប់គេដោយការព្រួយបារម្ភ។

"មិនបានទេ ខ្ញុំប្រញាប់ទៅ"

"អ្នកជំងឺចេញឈាមច្រើនណាស់ គិចងជឹតមុខទៀត សម្រាកសិនទៅ"

"មិនបានទេ ខ្ញុំប្រញាប់ពិតមែន អរគុណច្រើន" តេយ៉ុង មិនខ្វល់ពីការដាស់តឿនរបស់គិលានុបដ្ឋាយិកានៅក្នុងបន្ទប់សង្គ្រោះបន្ទាន់ គេស្ទុះចុះពីគ្រែរត់សំដៅជណ្តើរយន្ត ចុចទៅជាន់ដែល ម៉ាទិនេស សម្រាក។

"លោក ម៉ាឡេសាសសូ...លោកស្រី អ៊ីន មានគ្រោះថ្នាក់ហើយ"

ម៉ាទិនេស ដែលកំពុងរុញបង្គោលស៊ីរ៉ូមឈាមចេញពីបន្ទប់ទឹក មើលតេយ៉ុង ដោយទឹកមុខមិនរួសរាយ។

"លោកមករញ៉េរញ៉ៃនឹងប្រពន្ធខ្ញុំធ្វើអី ហើយក្បាលលោកត្រូវនឹងស្អី ?"

"លោកកុំអាលរករឿងខ្ញុំ ពេលនេះលោកស្រី អ៊ីន មានគ្រោះថ្នាក់"

អ្នកកំលោះពេបមាត់ដាក់ ។

"លោកត្រូវការស្អី អ្នកជំនាញ គីម !"

តេយ៉ុង គ្រវីក្បាល ធ្វើឲ្យបង់រុំរបួសក្បាលវិះតែរបូត។

"ខ្ញុំនិយាយរឿងពិត បងស្រីខ្ញុំចាប់អ្នកស្រី អ៊ីន ទៅ"



ស្នាមញញឹមឡកឡឺយនៅលើមុខសង្ហារលាយបាត់មួយរំពេច កែវភ្នែកមុតស្រួចឡើងរឹងកំព្រឹស។

"កុំមកនិយាយឆ្កួតៗបែបនេះដាក់ខ្ញុំ"

"វាមិនមែនជារឿងឆ្កួតទេ តែវាជារឿងពិត បងជីយ៉ន ចាប់លោកស្រី អ៊ីន ទៅបាត់ហើយ ចំណែកក្បាលខ្ញុំដែលបែកនេះ ព្រោះបងស្រី"

ម៉ាទិនេស ស្លុត ទឹកមុខស្លេកស្លាំង ឆ្លេឆ្លាធ្វើអ្វីមិនត្រូវភ្លាម។

"ម៉េចក៏អ៊ីចឹង ហើយពេលនេះ លីលី នៅឯណា ? "

"ខ្ញុំក៏មិនដឹងដែរ តែខ្ញុំបារម្ភពីលោកស្រី អ៊ីន ខ្លាំងណាស់ ខ្លាចបងស្រីខ្ញុំធ្វើអីហួសហេតុ គាត់មានកាំភ្លើង"

បេះដូងរបស់ ម៉ាទិនេស ធ្លាក់ទៅនៅនឹងភ្នែកគោ ភាពតានតឹងបោលសម្រុក ធ្វើឲ្យរម្ទលពោះ ទៅជាឈឺ។ គេមិនធ្លាប់មានអារម្មណ៍ភ័យខ្លាចបែបនេះទេនៅក្នុងជីវិត ខណៈនោះក៏ចុចទូរសព្ទដោយដៃញ័រទទ្រើត។

"ម៉ែ...លីលី ត្រូវសាស្រ្តាចារ្យ គីម ចាប់ខ្លួន ឯងជួយប្តឹងប៉ូលិសឲ្យបងផងឲ្យគេទៅតាមប្រពន្ធបងឲ្យបន្តិច កុំឲ្យនាងកើតអីឲ្យសោះ សុំអង្វរ"

គេអង្វរករ...អង្វរករចំពោះគ្រប់យ៉ាងនៅក្នុងលោកនេះ ដើម្បីឲ្យជួយភរិយាឲ្យមានសុវត្ថិភាព ហើយបន្ទាប់ពីនិយាយជាមួយប្អូនប្រុសចប់ គេក៏ចាប់ទាញស៊ីរ៉ូមឈាមពីដៃ។

"លោកនៅឈឺ"

"ខ្ញុំគ្រាន់តែឈឺ ប៉ុន្តែ លីលី កំពុងតែគ្រោះថ្នាក់ដល់ជីវិត ខ្ញុំត្រូវទៅជួយនាង"



"តែយើងមិនដឹងទេថាបងស្រីខ្ញុំនាំលោកស្រី អ៊ីន ទៅណា" តេយ៉ុង គិតមិនចេញ។

"ខ្ញុំនឹងតេរទៅរក ជីយ៉ន"

"តែខ្ញុំតេរទៅហើយ តែបងស្រីមិនទទួល"

"ខ្ញុំអាចប្រើជីភីអេសតាមទូរសព្ទតាម លីលី បាន លោកគ្រាន់តែបើកឡាននាំខ្ញុំទៅបានហើយ"

តេយ៉ុង ញញឹម សប្បាយចិត្ត។

"អូខេ ខ្ញុំនឹងបើកឡានជូនលោកទៅ ប៉ុន្តែលោកអូខេមែនទេ ?"

"ទោះខ្ញុំត្រូវវារទៅជួយ លីលី ក៏ខ្ញុំត្រូវតែទៅ"

តេយ៉ុង រំភើបចំពោះក្តីស្រឡាញ់ដែលពីរនាក់នេះមានចំពោះគ្នា ដោយមិនសង្ស័យអ្វីទៀត ហើយម្ទីម្នាចូលមកគ្រាហ៍ ម៉ាទិនេស។

"ប្រយ័ត្នផង"

ពួកគេគ្រាហ៍គ្នាដើរសំដៅជណ្តើរយន្ត ចុះទៅចំណតឡានជាបន្ទាន់។

**រាងតូចច្រឡឹងរបស់ យ្យូលី ត្រូវរុញមួយទំហឹងឲ្យដួលអុកគូទនៅក្នុងផ្ទះដែលត្រូវបោះបង់មួយនៅជាយក្រុង។**

"អុំយ !"

ជីយ៉ន សើចក្អាកក្អាយដោយការពេញចិត្ត ខណៈដែលមើលមុខសត្រូវបេះដូង។

"បើគ្មានឯង លោកនាយកនឹងក្លាយជារបស់ខ្ញុំតែម្នាក់"

"ទោះគ្មានខ្ញុំ ក៏ បងម៉ាត មិនស្រឡាញ់នាងដែរ ព្រោះ បងម៉ាត ស្អប់មនុស្សអាក្រក់ អុំយ..."

យ្យូលី ស្រែកថ្ងូចថ្ងូរ ពេលត្រូវទះកំផ្លៀង ធ្វើឲ្យឈាមហូរតាមចង្ហៃកមាត់។

"ខ្ញុំខំថែរក្សារបស់ខ្ញុំច្រើនឆ្នាំ សុខៗឯងក៏មកដណ្តើមយកលោកនាយក



ទៅរៀបការ ឯងសមតែងាប់ មីចោកទាប !"

"ប្រាប់ហើយតើ ទោះគ្មានខ្ញុំ ក៏ បងម៉ាត មិនស្រឡាញ់នាងដែរ ដោះលែងខ្ញុំទៅ ខ្ញុំមិនរករឿងទេ"

ជីយ៉ន សើចក្អាកក្អាយ តែកែវភ្នែកឡើងរឹងកំព្រឹស។

"ខ្ញុំធ្វើដល់ថ្នាក់នេះហើយ ឯងគិតឬថាខ្ញុំព្រមដោះលែងឯងឲ្យត្រឡប់ទៅវិញដោយសភាពល្អ មីចង្រៃ"

អ្នកស្តាប់ភ័យឡើងស្លេកមុខ។

"នាងចង់ធ្វើស្អីខ្ញុំ"

ជីយ៉ននៅតែសើចមិនឈប់បន្ទាប់មកក៏ផ្ទាត់ម្រាមដៃដែលមិនយូរប៉ុន្មានបុរសមាឌធំពីរនាក់ក៏បង្ហាញខ្លួន នោះហើយដែលធ្វើឲ្យ យ្យូលី ស្លុត រំកិលគូទថយក្រោយជាបន្ទាន់។

"នាងចង់ធ្វើស្អីខ្ញុំ គីម ជីយ៉ន"

"ហើយឯងគិតថាខ្ញុំយកមនុស្សប្រុសមកធ្វើស្អី"

"នាងប្រហែល..."

យ្យូលី និយាយមិនទាន់ចប់ផង ជីយ៉ន ក៏សើចក្អាកក្អាយ ព្រមទាំងបកស្រាយឲ្យបាត់ឆ្ងល់។

"ខ្ញុំចង់ដឹងថាបើឯងត្រូវរំលោភបូក តើលោកនាយកនៅត្រូវការឯងទៀតឬអត់"

"កុំ...កុំធ្វើបែបនេះ គីម ជីយ៉ន"

ពេលបានឃើញ យ្យូលី ភ័យខ្លាចខ្លាំង ជីយ៉ន កាន់តែពេញចិត្ត។



"ហ៎ា! ពួកឯង ចាត់ការវាម្នាក់ពីរបីតឹកទៅ លេងឲ្យហែកដល់ខាងក្នុង ចាំខ្ញុំថតក្លីបទុក ឲ្យពួកឯងទុកគំរាមវានៅពេលក្រោយ"

បុរសមាឌធំពីរនាក់នោះលើកដៃអង្អែលមាត់ ញញឹមញញែមដោយទឹកមុខគ្រេកកាម ធ្វើឲ្យអ្នកឃើញភ័យខ្លាច។

"អូខេ ពួកខ្ញុំនឹងចាត់ការឲ្យតាមតម្រូវការរបស់អ្នកនាង គីម តែស្អាតៗបែបនេះ បីបួនដងក៏មិនទាន់ឆ្អែតដែរ ត្រូវតែ១០ដង"

"ពួកឯងចង់លេងវាប៉ុន្មានសិបដងក៏បានដែរស្រេចតែចិត្ត សុំត្រឹមតែម្យ៉ាង ធ្វើឲ្យវាហែកពេទ្យមិនហ៊ានដេរ"

"ចាំចាត់ការឲ្យ"ពួកវាសើចក្អាកក្អាយ ខណៈដែលយ្យូលីភ័យឡើងស្លេកមុខ។

"កុំ កុំធ្វើអីខ្ញុំ...សុំអង្វរ..." នាងយំ ប្រឹងអូសគូទថយក្រោយ "ពួកឯងចង់បានអី ខ្ញុំនឹងរកមកឲ្យទាំងអស់ សុំត្រឹមដោះលែងខ្ញុំ កុំចាប់រំលោភខ្ញុំ..."

នាងលើកដៃសំពះពួកវា យំយែកដោយការភ័យខ្លាច។

"ពេលនេះពួកខ្ញុំចង់ចូលទៅក្នុងខ្លួននាងជាងស្រីស្អាត ចង់ដឹងថាដេកជាមួយទេពធីតាហើយវាឲ្យអារម្មណ៍រំភើបបែបណា"

អាម្នាក់ដែលជាលោកបងសើចក្អាកក្អាយ ដើរទៅរក ហើយឱនចាប់ទាញក-ជើងរបស់នាងកន្ត្រាក់ អូសមកជិត។

"អំាៗ...កុំ...លែងខ្ញុំ"

យ្យូលី ទាំងទទាក់ ទាំងរើបម្រះ ប៉ុន្តែក-ជើងមិនអាចរបូតពីដៃស្មោកគ្រោករបស់ប្រុសថោកទាបបាន។ នាងអង្វរករ ប៉ុន្តែពួកវាបែរជាសើចក្អាកក្អាយ។

"លែងខ្ញុំ កុំធ្វើអីខ្ញុំ...លែង..."

"ចាត់ការវាឲ្យធ្ងន់ទៅ ឆាប់ឡើង ខ្ញុំនឹងបានថតក្លីប"

ជីយ៉ន សើចក្អាកក្អាយ មើលមារប្រែកបេះដូងដែលកំពុងតែធ្លាក់ទៅក្នុងនរកដោយផ្ទាល់ភ្នែក ដោយការពេញចិត្ត។



"យ៉ាងណាក៏ថ្ងៃនេះឯងត្រូវតែក្លាយជាប្រពន្ធរបស់អាពីរនាក់នេះ អ៊ិន យ្យូលី"

"ឈប់ភ្លាម គីម ជីយ៉ន!"

សំឡេងរឹងកំព្រឹសរបស់ ម៉ាទិនេស បន្លឺឡើងនៅមាត់ទ្វារ ជីយ៉ន ក៏ងាកខ្ទាប់ទៅមើល ហើយក៏ស្លុត ពេលឃើញគេដែលពាក់ឯកសណ្ឋានមន្ទីរពេទ្យឈរនៅត្រង់នោះជាមួយប្អូនប្រុសម្ដាយទីទៃដែលមានបង់រុំក្បាល។

"លោកនាយក!"

"ខ្ញុំមិនគិតទេថានាងធ្វើបែបនេះ គីម ជីយ៉ន!"

"បងម៉ាត ជួយខ្ញុំផង..." យ្យូលី ញញឹមដោយការសប្បាយចិត្ត ពេលឃើញ ម៉ាទិនេស ប៉ុន្តែពេលគេដើរទៅរកនាង ជីយ៉ន ក៏លើកកាំភ្លើងភ្ជង់។

"កុំចូលមកលោកនាយក ឯងដែរ គីម តេយ៉ុង មិនអីចឹងខ្ញុំនឹងបាញ់ផ្លាយពោះវៀន"

"បងស្រីឈប់ទៅ កុំធ្វើឲ្យរឿងកាន់តែធ្ងន់ធ្ងរជាងនេះ"តេយ៉ុង ដាស់តឿនបងស្រីរបស់ខ្លួន ប៉ុន្តែ ជីយ៉ន មិនស្ដាប់។

"ឯងមិនបាច់មកចេះដឹងរឿងរបស់យើងទេ អាប្អូនទុរយស!"

"ដាក់កាំភ្លើងចុះទៅ គីម ជីយ៉ន ខ្ញុំសន្យាថាមិនរករឿងនាងបើនាងព្រមចប់នៅពេលនេះ"

"មិនបាន ខ្ញុំមិនព្រមចប់ ខ្ញុំមិនព្រមឲ្យមីចង្រៃនេះយកលោកពីខ្ញុំបានទេ លោកត្រូវតែធ្វើជារបស់ខ្ញុំ..."

"ខ្ញុំមិនធ្លាប់ស្រឡាញ់នាង ក្នុងភ្នែករបស់ខ្ញុំនាងគ្រាន់តែជាមិត្តរួមការងារ ជាកូនចៅម្នាក់ប៉ុណ្ណោះ ខ្ញុំមិនធ្លាប់មើលនាងក្នុងផ្លូវស្នេហា"



បានឮហើយ ជីយ៉ន ក៏ក្ដៅស្លឹកត្រចៀក ការខឹងសម្បា ធ្វើឲ្យនាងទៅជា

ឡប់សតិ ទើបសើចក្អាកក្អាយ មិនខុសពីមនុស្សឆ្កួត ខណៈដែលដៃនៅតែកាន់កាំភ្លើងភ្ជង់ ម៉ាទិនេស។

"អាមនុស្សចិត្តអាក្រក់! ម៉េចក៏លោកធ្វើបែបនេះដាក់ខ្ញុំ ខ្ញុំលួចស្រឡាញ់លោកយូរហើយ តែលោកបែរជាមិនចាប់អារម្មណ៍ខ្ញុំ"

"ខ្ញុំសុំទោស...តែយើងអាចធ្វើជាមិត្តនឹងគ្នាបាន"

"មិនបាន! ខ្ញុំមិនត្រូវការធ្វើជាមិត្តរបស់លោក ខ្ញុំត្រូវការធ្វើជាប្រពន្ធរបស់លោក យល់ទេលោកនាយក!"

ជីយ៉ន ខាំធ្មេញក្រតៗនិយាយ ហើយងាកទៅបញ្ជាមនុស្សរបស់ខ្លួន ឲ្យចាត់ការ យ្យូលី។

"ចាត់ការវាទៅ រំលោភវាឲ្យប្ដីវាមើលទៅ" ជីយ៉ន សើចក្អាកក្អាយ មិនខុសពីមនុស្សឆ្កួត។

"កុំ បើនាងធ្វើអី លីលី ខ្ញុំនឹងសម្លាប់នាង គីម ជីយ៉ន!"

"កុំបងស្រី...ខ្ញុំសុំអង្វរ"

"អីយ៉ា មានតែមនុស្សបារម្ភ តែគួរឲ្យស្ដាយដែលនាងនេះវាកំពុងតែមានប្ដីពីរនាក់ទៀតហើយ ចាត់ការទៅពួកឯង ឆាប់ឡើង លេងវាឲ្យហែករហុយទៅ"

"កុំ ជីយ៉ន!" ម៉ាទិនេស ខិតទៅរក ហើយឆ្លៀតពេលដែល ជីយ៉ន ភ្លេចខ្លួន គ្រវាសកាំភ្លើងឲ្យរបូតពីដៃនាង។

"អ៊ំា!"

"អ្នកជំនាញ គីម ចាប់បងស្រីរបស់លោកឲ្យជាប់" ម៉ាទិនេស ងាកទៅបញ្ជា តេយ៉ុង។

"បាទ លោក" តេយ៉ុង ស្ទុះទៅចាប់បងស្រីរបស់ខ្លួន។



"លែងយើងអាចង្រៃ យើងជាបងស្រីឯង លែងយើង"

"ខ្ញុំសុំទោស តែខ្ញុំមិនអាចឲ្យបងធ្វើខុសជាងនេះបានទេ"

តេយ៉ុង ចាប់បងស្រីរបស់ខ្លួនជាប់ ខណៈដែល ម៉ាទិនេស ស្ទុះទៅជួយភរិយារបស់ខ្លួន។

"ពួកឯងលែងប្រពន្ធរបស់អញ!"

ពីរនាក់នោះងាកមករក ម៉ាទិនេស ហើយការតស៊ូក៏កើតឡើង។ បើពេលធម្មតា អ្នកកំលោះអាចទប់ទល់នឹងអាពីរនាក់នេះបានស្រួល ប៉ុន្តែពេលនេះគេមានរបួសជាប់ខ្លួន ទើបតស៊ូមិនបានយូរប៉ុន្មាន ក៏ត្រូវពួកវាលេងឡើងដួលស្ដាប។

"បងម៉ាត...កុំធ្វើអី បងម៉ាត" យ្យូលី ស្ទុះទៅឱបរាងកាយទ្រុឌទ្រោមរបស់ស្វាមីណែនដៃ យំយែកអាណិតគេ "បងម៉ាត...ខ្ញុំសុំទោស បងម៉ាត..."

តេយ៉ុង ឃើញបែបនេះហើយ ទើបព្រលែងបងស្រីរបស់ខ្លួន ស្ទុះទៅជួយ ប៉ុន្តែដោយសារគេរបួសក្បាល ទើបមិនអាចតស៊ូនឹងពួកនោះបាន លទ្ធផលក៏ត្រូវដេកស្ដាបម្នាក់ទៀត ទើប ជីយ៉ន ដើរមកមើល ហើយសើចចម្អក។

"យ៉ាងណាក៏ថ្ងៃនេះលោកត្រូវតែឃើញប្រពន្ធរបស់លោកត្រូវប្រុសផ្សេងរំលោភដដែល លោកនាយក"

"លែង បងម៉ាត និងអ្នកជំនាញ គីម ទៅ នាងចង់ធ្វើស្អីខ្ញុំក៏អញ្ជើញ"

យ្យូលី ងើយមើលមុខ ជីយ៉ន ដោយកំហឹង។

"ឯងមិនបាច់បារម្ភទេ ខ្ញុំមិនសម្លាប់មនុស្សប្រុសដែលខ្ញុំស្រឡាញ់ទេ តែឯងវិញ អាចងាប់ ព្រោះត្រូវអាពីរនាក់នេះរំលោភក៏ថាបាន មីភ្លើ"



"កុំធ្វើអី លីលី...ហាមប៉ះពាល់ លីលី..." ម៉ាទិនេស ប្រឹងនិយាយ ទើបជីយ៉ន ងាកមលមើលមុខ និងសើចចម្អក។



Scanned with CamScanner

"នៅឲ្យស្ងៀម ចាំមើលកុនក្ដៅសាច់ល្អជាងលោកនាយក ហេ៎! ពួកឯងចាត់ការបន្ត"

"ទទួលបញ្ជា"

"កុំ...កុំ...កុំប៉ះពាល់ខ្ញុំ" យ្យូលី ប្រឹងជួយខ្លួនឯង។

"កុំធ្វើអី លីលី កុំធ្វើ...លីលី..." ម៉ាទិនេស ស្រែកខ្លាំងៗ ស្ទើរតែដាច់ខ្យល់ទៅហើយ។

"សុំអង្វរបងស្រី ឈប់ទៅ...សុំអង្វរ"

តេយ៉ុង ក៏ជួយហាមប្រាម ប៉ុន្តែមិនអាចបញ្ឈប់ទង្វើអាក្រក់របស់បងស្រីខ្លួនបាន។ ជីយ៉ន មិនខ្វល់ពីសំឡេងស្រែកអង្វរកររបស់អ្នកណា នាងលើកខ្សែសព្វដៃចុចចុចថតត្លីប។

"លើកដៃឡើង យើងជាប៉ូលិស!"

"វីវរហើយឯង ប៉ូលិសម៉ោ"

អាពីរនាក់នោះភ័យ បញ្ឈរភ្នែក ស្ទុះថយឲ្យឆ្ងាយពី យ្យូលី ខណៈដែល ជីយ៉ន ក៏ភ័យដែរ ទើបរត់ទៅរើសយកកាំភ្លើង ហើយស្ទុះទៅចាប់បោចសក់ យ្យូលី ឲ្យងើបឈរ។

"ឯងមកណេះ ទៅជាមួយយើង"

"មិនទៅ លែងខ្ញុំ"

យ្យូលី ប្រឹងរើបម្រះ ប៉ុន្តែត្រូវ ជីយ៉ន សង្កត់កាណុងកាំភ្លើងនឹងក្បាល ទើបបង្ខំចិត្តនៅស្ងៀម។

"ដាក់អាវុធចុះ នាងរត់មិនរួចទេ" ម៉ាទិនេស ដាស់តឿន។

"ទោសធ្ងន់នឹងទៅជាស្រាលបងស្រី ដាក់អាវុធចុះទៅ"

"មិនដាក់...យើងមិនព្រមជាប់គុក ឯងមកជាមួយយើង"



"អ៊ូយ!"

យ្យូលី ត្រូវអូសចេញទៅឆ្ងាយ ខណៈដែល ម៉ាទិនេស ប្រឹងប្រវេប្រវា វារទៅតាម។

"លីលី..."

"កុំមកតាមដាច់ខាត មិនអីចឹងខ្ញុំនឹងបាញ់បំបែកក្បាលមីចង្រៃនេះ"

"បងម៉ាត..." យ្យូលី ហូរទឹកភ្នែករហាម មើលស្វាមីដែលប្រឹងវារមករកខ្លួន អាណិតគេឡើងខ្លោចចិត្តទៅហើយ។

"ពួកឯងចាំទុក បើយើងមិនបាន អ្នកណាក៏មិនបានដូចគ្នា"

ជីយ៉ន សើចក្អាកក្អាយ ហើយងាកទៅកាន់បក្ខពួក។

"ពួកឯងមកតាមយើងឲ្យឆាប់ឡើង"

"អត់ទេ ខ្ញុំមិនចង់ជាប់គុក"

និយាយហើយ អាពីរនាក់នោះក៏លើកដៃដើរទៅរកប៉ូលិស ព្រមទាំងស្រែកប្រាប់ថាព្រមចុះចាញ់ ទើប ជីយ៉ន ខាំធ្មេញក្រតៗដោយកំហឹង ពេលនៅសល់តែខ្លួនមួយ។

"អាពួកថ្លើមតូច!"

យ្យូលី ឆ្លៀតពេលដែល ជីយ៉ន់ កំពុងតែអស់សង្ឃឹមនឹងទង្វើរបស់បក្ខពួក ក៏គ្រវែងខ្លួនទាល់តែរបូត ហើយរត់ទៅរក ម៉ាទិនេស ដែលពេលនោះ ជីយ៉ន ក៏បង្វែរកាណុងកាំភ្លើងមករក ហើយកេះកៃភ្លាម ទើប តេយ៉ុង ហក់មកក្រសោប យ្យូលី ទើបគ្រាប់កាំភ្លើងហោះមកទម្លុះខ្នងរបស់គេ។

"អ៊ូយ!"



"តេយ៉ុង..." ជីយ៉ន ភ្ញាក់ផ្អើលជាខ្លាំង ពេលឃើញប្អូនប្រុសដួលខ្ពោកឈាមហូរស្រោចខ្នង ខណៈដែលប៉ូលិសក៏សម្រុកចូលមក ព្រមទាំងចាប់នាង

ដាក់ខ្មោះជាបន្ទាន់។

"តេយ៉ុង...បងសុំទោស...តេយ៉ុង...."

ពេលនេះ ជីយ៉ន ដូចមនុស្សឡប់សតិទៅហើយ គិតតែគ្រវីក្បាល ទឹកភ្នែកហូរសស្រាក់ ខណៈដែល យ៉ូលី ក្រសោប តេយ៉ុង ដាក់លើភ្លៅ ដោយមាន ម៉ាទិនេស រារមករក។

"លោកប៉ូលិសមានជនរងគ្រោះ ហៅឡានពេទ្យ"

"ខ្ញុំ...សុំទោសជំនួសបងស្រីខ្ញុំផង"

"អ្នកជំនាញ គីម...មិនបាច់និយាយទេ អរគុណដែលជួយខ្ញុំ អរគុណមែនទែន" នាងក្រមុំអរគុណគេដោយចិត្តស្មោះ ខណៈដែល តេយ៉ុង ក៏បិទភ្នែកយឺតៗ ហើយសន្លប់មុនពេលរថយន្តសង្គ្រោះបន្ទាន់មកដល់។

"អ្នកជំនាញ គីម... អ្នកជំនាញ គីម"

"គេគ្រាន់តែសន្លប់ប៉ុណ្ណោះ តិចទៀតឡានពេទ្យមកហើយ លីលី"

នាងក្រមុំយំ ផ្តួលខ្លួនទៅពិតនឹងរាងកាយរបស់ស្វាមីដោយអារម្មណ៍ទុក្ខសោក។

នាងចង់ឲ្យហេតុការណ៍ដែលកើតឡើងនៅថ្ងៃនេះគ្រាន់តែជាយល់សប្តិ ...យល់សប្តិដែលមិនធ្លាប់កើតឡើង។



# សុភមង្គលស្នេហ៍

**ជប់ថ្ងៃក្រោយមក រឿងមិនល្អទាំងឡាយក៏ត្រូវបញ្ចប់ ជីយ៉ន និងគូកន** ត្រូវចាប់ដាក់គុក ចំណែក តេយ៉ុង ព្យាបាលខ្លួនជាសះស្បើយ អាចត្រឡប់ទៅធ្វើការនៅមន្ទីរពេទ្យ ម៉ាឡេសាសសូ វិញបាន ឯ យ៉ូលី និង ម៉ាទិនេស ក៏អាចរួមរស់ជាមួយគ្នា តែ...

"បង ម៉ាត ថ្ងៃនេះមានណាត់ធ្វើកាយចលនា"

យ៉ូលី ដាក់បង្គុយចោងហោងនៅចំពោះមុខស្វាមី។

"ហើយហាមរឹងទទឹង ទើបឆាប់បានដើរដូចអូនហ្នឹងអី បង ម៉ាត"

"បងប្រហែលគ្មានសង្ឃឹមទេ"

"កុំនិយាយបែបនេះ ថ្ងៃនេះអូនអញ្ជើញអ្នកជំនាញកាយចលនា ដែលពូកែបំផុតមកជួយធ្វើកាយចលនាឲ្យបង"

ម៉ាទិនេស គ្រវីក្បាលតិចៗ។

"បងប្រហែលដើរលែងបានហើយ អូនកុំលំបាកដើម្បីបងទៀត"

"បង ម៉ាត កុំរឹងមើល៍ ដឹងទេថាអូនបារម្ភខ្លាំងប៉ុនណា"

"អូនបារម្ភពីមនុស្សពិការដូចបងធ្វើអី" គេដាក់ដៃលើកង់រទេះ ហើយបង្វិលចេញទៅ តែ យ៉ូលី ដើរតាម មកពាំងមុខ។

"បង ម៉ាត កំពុងប្រមាថទឹកចិត្តរបស់អូន" នាងមើលគេទាំងទឹកភ្នែករលីងរលោង។



"បងគ្រាន់តែមិនចង់ឲ្យអូនមកខាតពេលនឹងប្តីពិការបែបនេះ"

នាងបណ្តោយឲ្យទឹកភ្នែកហូរដាបថ្ពាល់ ដាក់បង្អុយលើកែងជើងនៅចំពោះមុខគេម្តងទៀត ហើយស្រវាចាប់ដៃរបស់គេមកក្តោប។

"ដែលបងក្លាយជាបែបនេះ ព្រោះជួយអូន អូនម៉េចនឹងទុកបងចោលបានទៅ"

"ប៉ុណ្ណឹងឬ ?"

នាងក្រមុំនៅស្ងៀមមួយវិនាទី ខ្ទឹបមាត់ដោយកំពុងសម្រេចចិត្ត ហើយនិយាយដោយសំឡេងខ្សាវៗ។

"និង...ព្រោះ...ព្រោះអូនស្រឡាញ់បង"

អ្នកកំលោះលួចញញឹមសប្បាយចិត្ត តែពេលនាងងើយមកមើលមុខ គេក៏ធ្វើមុខមាំបន្លប់ភ្លាម។"

"ស្រឡាញ់ ព្រោះអាណិតដែលបងពិការមែនទេ ?"

"មិនមែនទេ"នាងគ្រវីក្បាលតិចៗថ្ពាល់ក្រហមទៅៗ"អូនលួចស្រឡាញ់បង ម៉ាត យូរហើយ"

"មែនក៏អី ?" គេជ្រឹមភ្នែកមើលដោយខ្សែភ្នែកលាក់កំណួច ទើប យ៉ូលី ងក់ក្បាល។

"ចាំអូនស្រឡាញ់បង ម៉ាត តាំងពីតូចម្ល៉េះ តែបង ម៉ាត មិនធ្លាប់ស្រឡាញ់អូន"

អ្នកកំលោះទាញភរិយាឲ្យងើបឈរ ហើយទាញឲ្យអង្គុយលើភ្លៅខ្លួនឯងដែលធ្វើឲ្យ យ៉ូលី ស្រែកភ្លាត់មាត់។

"បង ម៉ាត...បងឈឺជើង"

"ទោះឈឺ តែបងចង់ឱបអូនជាង"

"មិនបានទេ អូនមិនចង់ធ្វើឲ្យបងឈឺ"



"បងមិនឈឺទេ"

"ច្បាស់ហើយ ?" នាងមើលមុខស្វាមី ដោយចិត្តខ្វល់ខ្វាយ។

"ច្បាស់ហើយ" គេញញឹម "ប្រាប់បងម្តងទៀតមើល៍ថាស្រឡាញ់បង"

"គឺ...អូនប្រាប់រួចហើយតើ"

ពេលនិយាយហើយ នាងគេចភ្នែកពីគេភ្លាម។

ម៉ាទិនេស ញញឹមញញែម លូកដៃមកភ្ញើយចង្ការបស់ភរិយា និងបង្ខាប់ឲ្យនាងប្រសព្វភ្នែកជាមួយ។

"អូននិយាយតិចៗពេក ត្រចៀកបងមិនល្អ ទើបស្តាប់មិនច្បាស់"

"ហ៊ឹស ! បង ម៉ាត ផ្តេសផ្តាសហើយ"

"បើអូនមិនប្រាប់ថាស្រឡាញ់បងម្តងទៀត បងមិនព្រមធ្វើកាយចលនា"

ពេលស្វាមីគំរាមបែបនេះ និងដោយសារស្រឡាញ់គេ ទើបនាងនិយាយម្តងទៀត។

"ខ្ញិនហើយនៅផ្តាច់ការទៀត"

"ព្រមនិយាយឬអត់" គេសួរខ្សឹបៗ។

"ស្រឡាញ់ ស្រឡាញ់ខ្លាំង ពេញចិត្តហើយនៅ"

ម៉ាទិនេស លាក់ស្នាមញញឹមនៃសេចក្តីសុខ ខណៈនោះក៏ឱបភរិយាណែនដៃ។

"ហើយចង់ដឹងទេថាបងស្រឡាញ់អូនពេលណា"

នាងជ្រួញច្រមុះដាក់អ្នកសួរ។

"មិនចង់ដឹងទេ ព្រោះបង ម៉ាត មិនបានស្រឡាញ់អូនផង"

"ក្មេងល្ងង់ បើមិនស្រឡាញ់ តើព្រមរៀបការជាមួយធ្វើអី"

នាងមើលមុខគេ សម្លឹងកែវភ្នែកមុតស្រួចដោយការសង្ស័យ។





Scanned with CamScanner

"ព្រោះបងជំទាស់បញ្ជារបស់ម៉ាក់មិនបាន"

អ្នកកំលោះគ្រវីក្បាលតិចៗ កែវភ្នែកមានពន្លឺស្រទន់។

"ឃើញបងមិះៗបែបនេះ បងកេះឆ្នាំងបាយឆ្លុះ បើមិនចូលចិត្ត គឺបងមិនខ្វល់ តែបើរបស់ណាពេញចិត្ត បងនឹងទទួលយកភ្លាម"

"បងចង់មានន័យថា..."

"ព្រោះពេញចិត្តអូនតាំងពីយូរហើយ ទើបបងព្រមរៀបការជាមួយអូន"

នាងក្រមុំធ្វើមាត់មួបៗ បន្ទាប់មកក៏គ្រវីក្បាល ប្រាប់ថាមិនជឿ។

"បង ម៉ាត កុំកុហក តើមានប្រុសណាចូលចិត្តស្រីពិការទៅ"

"បងនេះអី និងមិនត្រឹមតែចូលចិត្តទេ ស្រឡាញ់តែម្តង"

"បង ម៉ាត..."

"ជឿបងឬអត់?"

"អឺ..."

នាងនៅតែនិយាយមិនចេញ ព្រោះតែងតែគិតថា ម៉ាទិនេស មិនបានស្រឡាញ់ខ្លួន ដែលព្រមរៀបការជាមួយ ព្រោះត្រូវចាស់ទុំបង្ខំ។

"បងស្រឡាញ់ លីលី"

"បង ម៉ាត មិនបាច់និយាយទេ"

"បងស្រឡាញ់ លីលី"

អ្នកកំលោះនៅតែនិយាយ និងកាន់តែខ្លាំងៗទៅ។

"ស៊ូច...បង ម៉ាត...បានហើយ ខ្មាសគេ"

"បងស្រឡាញ់ លីលី...បំផុតនៅក្នុងលោក!"

"អូខេ អូនជឿហើយ"

គេផ្អៀង.កមើលដោយការចម្អកចំអន់។



"ជឿថាអី ប្រាប់បងបន្តិចម៉ោមើល៍"

"គឺ..."

"គឺអី?"

"គឺជឿថាបង ម៉ាត ស្រឡាញ់អូន"

អ្នកកំលោះសើចក្អាកក្អាយ និងថើបថ្ពាល់ភរិយាខ្សឹតៗ។

"ពេលជឿ ជឿស្រួលៗដល់ហើយ"

"អូនក៏មិនចង់ជឿដែរ តែពេលគិតដល់កាលដែលបងព្រមឈឺខ្លួន ដើម្បីជួយអូន ក៏ធ្វើឲ្យអូនដឹងថា បើមិនស្រឡាញ់...ប្រហែលធ្វើបែបហ្នឹងមិនបាន..."

ម៉ាទិនេស លើកដៃអង្អែលក្បាលភរិយា និងមើលនាងដោយខ្សែភ្នែកនៃក្តីស្រឡាញ់។

"ការពិតអូនគួរតែដឹងតាំងពីយូរហើយ ថាបងស្រឡាញ់អូន"

"ដឹងដោយរបៀបណា បើបងមិនបានប្រាប់ផង" នាងធ្វើសំឡេងក្ងួរដាក់ជាការតវ៉ា។

"បើអូនរៀនសង្កេតរឿងតូចតាចដែលបងធ្វើអូននឹងដឹងតាំងពីយូរថាបងស្រឡាញ់អូនខ្លាំងប៉ុនណា"

"ដូចជាស្អីដែរ?" នាងផ្អៀង.កទៅសួរ កែវភ្នែកថ្លាយង់មានពន្លឺផ្លេកៗ។

"ដូចជាការប្រចណ្ឌហួងហែងរបស់បងដែលមានចំពោះអូនហ្នឹងអី"

នាងក្រមុំអស់សំណើច រកនឹកដល់រឿងកន្លងមក ទើបឃើញថាដូចដែលគេនិយាយមែន។ បើនាងសង្កេតឲ្យស្រួលបួល នឹងឃើញថា ម៉ាទិនេស បង្ហាញឲ្យឃើញថាមិនពេញចិត្តពេលដែលនាងស្និទ្ធស្នាលនឹង តេយ៉ុង។



នាងជ្រប់មុខនឹងស្មារបស់ស្វាមី ដាក់ដៃលើដើមទ្រូងធំទូលាយ ទើបដឹងថាបេះដូងរបស់គេលោតញាប់ប៉ុនណា។

"បេះដូងបង ម៉ាត...ជារបស់អូនហើយ ហាមទាមទារដាច់ខាត មិនអីចឹង អូននឹងរុងយកវាបោះចូលទន្លេ"

"ទទួលបញ្ញាទាន គ្មានថ្ងៃទាមទារដាច់ខាត ទោះអូនក្រាញននៀលថា នឹងប្រគល់ឲ្យវិញយ៉ាងណាក៏ដោយ"

យ្យូលី សើចក្អាកក្អាយ។

"អូនគ្មានថ្ងៃឲ្យវិញទេ អូននឹងប្រចាច់ អូននឹងញក់ញីបែបនេះមួយជីវិត"

កំលោះក្រមុំសើចដាក់គ្នាឲ្យកក្អិចយ៉ាងមានសេចក្ដីសុខ រហូតដល់បាន ឮសំឡេងក្អកគ្រហែម ទើបងាកទៅមើល។

"អេ៎! អ្នកជំនាញ គីម...ម៉ោយូរហើយឬ"

យ្យូលី ម្នីម្នាចុះពីភ្លៅរបស់ស្វាមី។

"ទើបតែមកដល់" តេយ៉ុង តបដោយទឹកមុខញញឹម។

"កុំប្រាប់ណា ថាអ្នកជំនាញថ្មីដែលដាប់ដែលអូនប្រាប់..." ម៉ាទិនេស ចងចិញ្ចើម មើលភរិយា។

"ចាំ អ្នកជំនាញ គីម"

អ្នកកំលោះអស់សំណើច។

"មិនឃើញអីត្រូវប្រៀកពេលវេលាអ្នកជំនាញ គីម ទេ លីលី"

"មិនអីទេ ខ្ញុំរីករាយបម្រើលោក ម៉ាឡេសាសសូ" តេយ៉ុង និយាយដោយ ការពេញចិត្ត ទើប យ្យូលី ងាកទៅនិយាយជាមួយ។

"តាមសម្រួលចុះអ្នកជំនាញ គីម អ្ហ៎! បើបង ម៉ាត រឹង អាចរើបាន ខ្ញុំ អនុញ្ញាត"

"ខ្ញុំមិនហ៊ានទេ"

"អ្ហ៊ំហ៊ំ នេះបងធ្វើកាយចលនា មិនមែនរៀនសរសេរអក្សរផ្ចង់" ម៉ាទិនេស



និយាយរអ៊ូៗ ទើបនាងក្រមុំញញឹម ដើរមករកស្វាមី។

"យកចិត្តទុកដាក់ធ្វើ បង ម៉ាត នឹងបានរត់ដេញចាប់អូនឆាប់ៗ"

ពេលស្វាមីងក់ក្បាលតិចៗដាក់ ទើប យ្យូលី ឰរទ្រូង ងាកទៅរក តេយ៉ុង។

"ពឹងពាក់ផង"

"ដោយក្ដីរីករាយ"

"អីចឹងខ្ញុំទៅសិនហើយ"

នាងដើរចេញទៅ ទើប តេយ៉ុង ដើរមកឈរទល់មុខអ្នកជំងឺរបស់ខ្លួន។

"មិនគួរឲ្យជឿថា គ្រាន់តែត្រូវអាពួកនោះជាក់កណ្ដាលខ្នងបីបួនដើងក៏ ធ្វើឲ្យលោកដើរមិនបាន"

ម៉ាទិនេស អើតមើលទាល់តែជឿជាក់ថាភរិយាដើរចេញបាត់ហើយ ទើប និយាយជាមួយអ្នកជំនាញ។

"អ្នកណាថាខ្ញុំដើរមិនបាន"

"អេ៎!" តេយ៉ុង បើកភ្នែកធំៗដោយការភ្ញាក់ផ្អើល។

"ស៊ូច! ស្ងាត់ស្ងៀមអ្នកជំនាញ គីម ខ្ញុំគ្រាន់តែចង់ម៉ិកម៉ូក់ដាក់ លីលី ប៉ុណ្ណោះ"

អ្នកជំនាញអស់សំណើច ហើយគ្រវីក្បាលតិចៗ។

"មិនគួរឲ្យជឿថាលោកស្រី អ៊ីន ត្រូវសងសឹកបែបនេះ"

"ឆ្កួត ខ្ញុំមិនបានសងសឹក លីលី ទេ គ្រាន់តែចង់ឲ្យនាងមើលថែតើ"

តេយ៉ុង ប្រើពេលយូរគួរសមទម្រាំតែឈប់សើចបាន។



"ហើយសរុបទៅខ្ញុំត្រូវជួយទេ?"

"ជួយតិចតួច កុំឲ្យ លីលី សង្ស័យ"

"បាទ តាមចិត្តលោកចុះ ខ្ញុំចាត់ចែងឲ្យបានគ្រប់យ៉ាង"

កំលោះទាំងពីរសើចដាក់គ្នា ដោយមិនដឹងទេថា យ្យូលី ដែលលួចមើលតាមបង្អួចមានការសង្ស័យ។

"ពីរនាក់នោះសើចរឿងអី មើលទៅដូចមានអាថ៌កំបាំង"

·

**ការសង្ស័យរបស់ យ្យូលី កាន់តែកើនឡើង ពេល ហុងស៊ុល និយាយ** ឲ្យស្ដាប់ថាឃើញ ម៉ាទិនេស ដើបដើរ តែពេលនាងសួរគេ គេបែរជាបដិសេធថា ហុងស៊ុល ព្រិលភ្នែក ដូច្នេះហើយទើបនាងត្រូវរកវិធីពិសោធដោយខ្លួនឯងដើម្បីចាប់ឲ្យបាននឹងកន្លែង។

"លីលី...ឡើងម៉ោដេកជាមួយបងម៉ោ" ម៉ាទិនេស ទះពូកក្បែរខ្លួន និងបក់ដៃហៅភរិយាជាទីស្រឡាញ់។

យ្យូលី លាក់ការសង្ស័យទុកក្នុងចិត្ត ខណៈដែលដើរទៅដាក់បង្អួយនៅតែមគ្រែ ហើយឱនថើបថ្ពាល់គ្រើមថ្នមៗ។

"អូនចង់ទៅដេកនៅបន្ទប់សៀវភៅ ចង់ដេកអានប្រលោមលោក បងទៅជាមួយអូនទេ ?"

អ្នកកំលោះគ្រវីក្បាលតិចៗ។

"តែបងចង់ដេកឱបអូន ម៉ោះ ភ្លៀងធ្លាក់បែបនេះដេកឱបគ្នាល្អជាង"

យ្យូលី គ្រវីក្បាល និងដើបឈរ។

"បើបងមិនទៅ អូនទៅម្នាក់ឯងក៏បាន"

"ឈប់សិន លីលី"

អ្នកដែលបែរខ្នងដាក់លួចញញឹម ហើយប្ដូរទឹកមុខភ្លាមពេលងាកមកប្រឈមមុខនឹងស្វាមី។



"ចាំ បងសម្លាញ់"

ពេលពុតរិយាឆ្លើយដោយសំឡេងពីរោះ ម៉ាទិនេស ក៏ទន់ល្អកភ្លាម។

"បងទៅកំដរ លីលី ក៏បាន"

"អរគុណ អីចឹងអូនយករទេះម៉ោឲ្យ"

នាងក្រមុំដើរទៅយករទេះមកឲ្យ ហើយគ្រាហ៍គេឲ្យឡើងមកអង្គុយដោយការប្រុងប្រយ័ត្ន។

"អរគុណ"

យ្យូលី ញញឹមស្រស់ ដើរមកឈរក្រោយខ្នងអ្នកអង្គុយលើរទេះ។

"ប្លែកណាស់បង ម៉ាត បន្ទាប់ពីឧបទ្ទវហេតុបងនៅដើរបានសោះ តែពេលត្រូវអាពួកនោះវ៉ៃមិនប៉ុន្មានដៃប៉ុន្មានជើង បងបែរជាដើរមិនបាន"

"វាតន្ត្រំខ្នងបងហ្នឹងណ៎ា ទើបបង...ទៅជាបែបនេះ"

"បែបមែនទេដឹង"

នាងសង្ស័យជាខ្លាំង ហើយថ្ងៃនេះតាំងចិត្តហើយថាត្រូវតែដឹងឲ្យបានថាស្វាមីដើរបាន ឬពិការមែន។

"លីលី ចង់អានសៀវភៅអី ?"

"អូនចង់អានប្រលោមលោក ឲ្យ ហុងស៊ុល ទិញឲ្យកាលពីថ្ងៃមុន"

នាងនាំស្វាមីចេញពីបន្ទប់ដេកសំដៅបន្ទប់សៀវភៅ។

"មិនដែលដឹងសោះថាប្រពន្ធបងញៀនប្រលោមលោក"

"អូនចូលចិត្តអានប្រលោមលោកតាំងពីតូចៗ ជាពិសេសពេលដែលអូនដើរមិនរួចគឺអផ្សុកណាស់ បានប្រលោមលោកនេះហើយកំដរ"



នាងរុញស្វាមីមកឈប់ត្រង់សាឡុងក្បែរបង្អួច។

"បងនៅត្រង់នេះហើយ អូនសុំដើររើសសៀវភៅសិន"



Scanned with CamScanner

"ឲ្យបងទៅផង"

"កុំអី ផ្លូវចង្អៀត បងអង្គុយចាំអូនត្រង់នេះហើយ"

នាងញញឹមដាក់ស្វាមី ហើយដើរចូលតាមប្រឡោះជាន់ដាក់សៀវភៅ ខណៈដែល ម៉ាទិនេស ចង់ទៅជួយមែនទែន។

"យកដល់ទេ លីលី ?"

"មិនដល់ទេបង ម៉ាត តែចាំអូនយកកៅអីដាក់ឡើង"

"លីលី ប្រយ័ត្នផង តិចធ្លាក់" គេបារម្ភ ទើបបង្វិលរទេះទៅជិត។

"មិនធ្លាក់ទេ" នាងលួចញញឹម ហើយអូសកៅអីមកដាក់ឡើង។

"លីលី បងថាទៅតាមគេម៉ោជួយល្អជាង តិចធ្លាក់បាក់ដៃបាក់ជើង"

"មិនល្អឬ យើងនឹងអង្គុយរទេះរុញដូចគ្នា"

"ឆ្កួតទេអី ហើយបែបហ្នឹងបងម៉ិកម៉ូក់ដាក់អ្នកណា" គេស្តីឲ្យ "ចុះម៉ោបងសុំអង្វរ"

"មិនអីទេ អូនយកដល់..." នាងប្រឹងចំទើតជើង ឈោងយកសៀវភៅដែលចង់បានឲ្យបាន កៅអីក៏រអិលទៅរអិលមក មើលទៅគួរឲ្យខ្លាច ធ្វើឲ្យស្វាមីរមួលពោះចង់ដាច់ពោះវៀនទៅហើយ។

"លីលី...តិចធ្លាក់..."

"អាំៗៗ"

និយាយមិនទាន់ផុតពីមាត់ផង រាងកាយរបស់ភរិយាក៏ធ្លាក់ពីកៅអី ទើប ម៉ាទិនេស ហក់ទៅក្រសោបបានទាន់វេលា។

"លីលី...មិនអីទេ ?"

អ្នកកំលោះបីភរិយាទៅដាក់លើសាឡុង និងសួរនាំដោយការបារម្ភ។

"ភ័យទេ ?"



នាងក្រមុំផ្អៀង.កមើលស្វាមី ហើយឱនមើលជើងរបស់គេ នោះហើយដែលធ្វើឲ្យ ម៉ាទិនេស ដឹងខ្លួន ទើបសើចហេះៗ។

"អឺ បង..."

"បង ម៉ាត...មនុស្សកំហូច! នេះនែ៎! នេះនែ៎!"

នាងគក់ទ្រូងធំទូលាយខ្លាំងៗដោយកំហឹង ធ្វើឲ្យ ម៉ាទិនេស ទ្រាំឈឺមិនបាន ទើបចាប់ក្រសោបដៃទាំងពីររបស់នាង។

"បងសុំទោស"

"មិនបាច់សុំទោសទេ ធ្វើឲ្យអូនបារម្ភសឹងស្លាប់ តាមពិតកុហកតើ"

"បងសុំទោស បងគ្រាន់តែចង់ឲ្យអូនមើលថៃ"

យុ្យលី ខាំមាត់ សម្លក់សម្លឹងគេ។

"អ្នកជំនាញ តឹម ក៏ម្នាក់ទៀតដែរ ជួយបិទបាំង ចាំមើល ជួបមុខពេលណា នឹងស្តីឲ្យឲ្យស្លឹកមុខ"

"លីលី បងខុសម្នាក់ឯង កុំបន្ទោសអ្នកដទៃ បើចង់ខឹង ខឹងបងទៅ បងព្រមទទួលខុស"

នាងក្រមុំងាកមកសម្លក់គេថ្មែ។

"មិនបាច់ធ្វើខ្លួនជាមនុស្សល្អទេ បងត្រូវអូនដាក់ទោស"

"ប្រពន្ធសម្លាញ់ ប្តីសុំទោស ចាប់ពីពេលនេះទៅមិនហ៊ានបោកប្រពន្ធសំណព្វចិត្តទៀតទេ"

"អត់ទេ មិនលើកលែងទោសឲ្យទេ"

នាងងើបដើរចេញ តែត្រូវស្វាមីចាប់ដៃជាប់។

"លីលី បងសុំទោស...កុំខឹងបងអី"

"ខឹង ខឹងខ្លាំងទៀតផង ព្រលែងដៃអូន"



"តើបងត្រូវធ្វើយ៉ាងណា ទើបអូនបាត់ខឹង" អ្នកកំលោះតាមមើលភរិយាដោយការអង្វរករ "ឲ្យបងថើបជប់ជងហើយបាត់ខឹង អូខេទេ?"

នាងក្រមុំជ្រួញច្រមុះដាក់គេដោយការជិនឆ្អន់។

"អត់! គ្មានផ្លូវបាត់ខឹងទេ នែ៎! លែងអូន"

"អត់ទេ អត់លែង"

និយាយហើយ ស្វាមីរូបសង្ហា និងត្រេកកាមចាប់ភរិយារុញទៅពិតនឹងជញ្ជាំងបន្ទប់។

"ត្រូវប្រើវិធីនេះទេដឹង ទើប លីលី ឈប់ខឹងបង"

"នេះបងចង់ធ្វើអី" នាងភិតភ័យ ពេលត្រូវគេធ្វើបែបនេះ "កុំបង ម៉ាត នេះបន្ទប់សៀវភៅ"

"គ្មានអ្នកណាចូលម៉ោទេ...នៅស្ងៀមៗ អូនសម្លាញ់"

ម៉ាទិនេស មិនបើកឱកាសឲ្យនាងបានបដិសេធទៀត ដោយការឱនទៅថើបបិទមាត់ភ្លាម ដែលដំបូងនាងបិទមាត់ តែពេលត្រូវដាស់អារម្មណ៍ក៏បង្អើបមាត់ទទួលយកអណ្ដាតក្ដៅដែលជ្រែកចូលមក។

"អឺ...អ៊ំា..."

ក្រមុំកំលោះឱបរឹតគ្នាណែនដៃ ចុងអណ្ដាតក៏រឹតរួតគ្នា។

"អ៊ុំ...លីលី..."

អ្នកកំលោះម្ទីម្ទាទាញរូតខោទម្លាក់ និងទាញអ្វីម៉្យាងចេញមក ចំណែកយ្យូលី ក៏ទាញខោក្នុងទម្លាក់ជាបន្ទាន់ បន្ទាប់មកនាងក៏បែរមុខទៅរកជញ្ជាំងដោយដឹងតួនាទី ហើយអ៊ែនត្រគាកទៅទទួលភាពមហិមារបស់ស្វាមីដោយការពេញចិត្ត។

"អ៊ុំ...ប្រពន្ធសម្លាញ់...ក្ដៅគគុកណាស់"



អ្នកកំលោះគ្រហឹមដោយការពេញចិត្ត និងជ្រែកភាពមហិមាចូលទៅភ្លាម ដែលធ្វើឲ្យនាងភ្ញាក់ក្រញាង តែបន្ទាប់មកក៏គ្រវែងត្រគាកតបត។

"អ៊ំា...អ៊ំា...បង ម៉ាត..."

អ្នកកំលោះគ្រវែងត្រគាកដោយចង្វាក់ក្ដៅគគុក ខណៈដែលដៃក៏លូកទៅច្របាច់ដើមទ្រូងណែនក្បំ ម្រាមដៃក៏ជួយត្រដុស។

"អ៊ុំ...តឹងណាស់ លីលី..."

"បង ម៉ាត...ខ្លាំងៗ...អ៊ំា...ខ្លាំងទៀត...អ៊ំា..."

ម៉ាទិនេស ពេញចិត្តជាខ្លាំងនឹងភាពក្ដៅគគុករបស់ភរិយា។ គេជ្រែកភាពមហិមាចូលទៅម្ដងហើយម្ដងទៀត គ្រវែងត្រគាកញាប់ស្អេកដោយការស្រេកឃ្លាន។

"អ៊ុំ...លីលី...អ៊ុំ...បងទ្រាំលែងបានហើយ"

រាងកាយទាំងពីររមួលចូលគ្នាដោយចង្វាក់ក្ដៅគគុក និងផ្ទះម្ដងហើយម្ដងទៀតរាប់មិនអស់។ អ្នកកំលោះចាប់រាងតូចច្រឡឹងរបស់ភរិយាឲ្យបែរមុខមករក ហើយចាប់ជើងម្ខាងឲ្យកៀវចង្កេះមាំមួន ហើយជ្រែកភាពមហិមាចូលទៅម្ដងទៀត ខ្លាំងៗតែម្ដង។

"អ៊ំា...អ៊ំា...អ៊ំា..."

គេយោកត្រគាកខ្លាំងៗ ខណៈនោះក៏បឺតជញ្ជក់បបូរមាត់ក្រពុំដែរ។ គេយោកដោយចង្វាក់ដែលដឹងតែពីរនាក់ ហើយមិនយូរប៉ុន្មានក៏ដឹកដៃគ្នាទៅដល់វិមានអាកាស។ សំឡេងគ្រហឹមព្យួរញួយបន្ទប់ ទឹកដមក្ដៅគគុកត្រូវព្រួសចូលប្រកជ្រៅ ភាពទន់ជ្រាយនៅតែរឹតរួតខ្លាំង។

"អ៊ុំ...លីលី...គួរឲ្យស្រឡាញ់ណាស់..."



រាងកាយទាំងពីរឱបរឹតគ្នាណែនដៃ ដោយភាពមហិមានៅតែសម្ងំក្នុង

រាងកាយរបស់នាង។

"បាត់ខឹងបងហើយនៅ?"

រាងកាយរបស់នាងក្រមុំក្រហមសព្វសាច់ ប្រឹងងាកមុខចេញពីខ្សែភ្នែក មុតស្រួច តែត្រូវគេទាញមកវិញ។

"បងស្រឡាញ់ លីលី ខ្លាំង បើអ្វីដែលបានធ្វើហើយ ធ្វើឲ្យអូនមិនពេញចិត្ត បងសុំទោស តែដោយភាពស្មោះត្រង់ បេះដូងបងមានតែអូនម្នាក់"

យ្យូលី រលីងរលោងទឹកភ្នែក មើលឃើញក្ដីស្រឡាញ់ ការព្រួយបារម្ភក្នុងខ្សែភ្នែករបស់ស្វាមីបានច្បាស់។

"អូន...មិនខឹងបងទេ អូនស្រឡាញ់បង"

"សំណព្វចិត្តបង..." គេដោះលែងភាពមហិមាឲ្យមានសេរីភាព ហើយបើបបួរមាត់ក្រពុំ"យើងចូលបន្ទប់យើងទៅបងនៅមានក្ដីស្រឡាញ់ច្រើនទៀតដែលចង់បង្ហាញឲ្យអូនឃើញ"

និយាយហើយ ម៉ាទិនេស ក៏ឱនរើសខោក្នុងដែលនាងរលាស់ចោលមកស្លៀកឲ្យវិញដោយកាយវិការថ្នាក់ថ្នម។

"បង ម៉ាត...អូនស្លៀកខ្លួនឯងបាន"

"បងធ្វើឲ្យអូនដោះវា" គេគ្រវីក្បាល "បងក៏ត្រូវស្លៀកឲ្យ"

មុខសង្ហាមានស្នាមញញឹមពព្រាយលម្អ។

"បងបីទៅបន្ទប់"

"អូនដើរខ្លួនឯងបាន"

នាងក្រមុំអៀនឡើងរមួលខ្លួន ចំហាយក្ដៅដែលគេបន្សល់ទុកឲ្យនៅតែក្ដៅគគុកនៅកន្លែងអាថ៌កំបាំង។

"តែបងចង់បី លីលី ហ្នឹងណា៎"



គេលើកបីរាងតូចស្ដើង ដើរសំដៅបន្ទប់ដេក ខណៈនោះ ហុងស៊ីល ដើរមកឃើញល្មម ក៏អត់ភ្ញាក់ផ្អើលមិនបាន។

"លោក ម៉ាត ដើរបានហើយឬ?"

"អ្ហឹម ទើបតែដើរបានអម្បាញ់មិញ" ម៉ាទិនេស ឆ្លើយ ហើយចេញបញ្ជា "បើមានអ្នកណារកខ្ញុំ ឬ លីលី ប្រាប់ឲ្យត្រឡប់ទៅវិញទៅ ព្រោះពួកខ្ញុំមិនចេញពីបន្ទប់ទាល់តែដល់ល្ងាច"

"បង ម៉ាត និយាយស្អីបែបនេះ"

យ្យូលី អៀនឡើងក្រហមមុខ ចំណែក ហុងស៊ីល ញញឹមសប្បាយចិត្តអបអរចៅហ្វាយទាំងពីរដែលមានសេចក្ដីសុខ។

"ចាំ ខ្ញុំនឹងមិនឲ្យអ្នកណាឡើងទៅរំខានទេ"

"ល្អណាស់ ហុងស៊ីល ចាំខ្ញុំឲ្យប្រូណើស"

"សូមឲ្យមានសេចក្ដីសុខ អ្នកនាង" ហុងស៊ីល អត់មិនបាននឹងបង្អាប់ចៅហ្វាយស្រី។

"ហុងស៊ីល និយាយស្អីក៏មិនដឹង ខ្ញុំខ្មាស"

អ្នកមើលថែជំនិតរបស់នាងក្រមុំសើចខឹកៗ។

"អីចឹងខ្ញុំទៅសិនហើយ អញ្ជើញតាមសម្រួលចុះ"

និយាយហើយ ហុងស៊ីល ក៏ដើរចេញទៅ ទើប យ្យូលី ងើយមុខមើលស្វាមី ហើយក៏អត់មិនបាននឹងតវ៉ាគេដោយការអឹមអៀន។

"បង ម៉ាត ហុងស៊ីល ចំអន់អូនហើយ ឃើញទេ"

ម៉ាទិនេស ញញឹម ខណៈដែលដើរសំដៅបន្ទប់ដេក។ គេបើកទ្វារ ហើយប្រើជើងបិទ បន្ទាប់មកក៏នាំរាងតូចស្ដើងទៅដាក់លើគ្រែ ដោយខ្លួនឯងតាមទៅដេកក្បែរ។



"គឺយើងជាប្ដីប្រពន្ធនឹងគ្នាហ្នឹងណា៎ រឿងបែបនេះវាធម្មតាៗ មិនឃើញមានអីត្រូវខ្មាស"

"គឺអូនមុខមិនក្រាស់ដូចបងហ្នឹងណា៎"

អ្នកកំលោះងើយមុខអស់សំណើច។

"បើជារឿងនេះជាមួយ លីលី បងព្រមមុខក្រាស់ សុំត្រឹមបាននៅជាមួយអូន...ប៉ុណ្ណឹងគ្រប់គ្រាន់ហើយ"

"កុំសម្ដីផ្អែម នេះអូនមិនទាន់ភ្លេចរឿងដែលបងធ្វើពុតជាដើរមិនបានទេ"

"អីចឹងបងឲ្យអូនដាក់ទោស ល្អទេ"

"អ៎ា...បងចង់ធ្វើអី ?"

នាងស្រែកភ្ញាក់មាត់ ពេលត្រូវទាញឲ្យមកអង្គុយច្រកកៀវលើរាងកាយមាំមួន។

"គឺ...ឲ្យអូនដាក់ទោសបងហ្នឹងអី"

"បង ម៉ាត លាមក"

"ឬមិនចូលចិត្ត ?" គេសួរដោយការបេះបួយ កែវភ្នែកមុតស្រួចពោរពេញដោយការប្រាថ្នា។

"ចូលចិត្ត"

អ្នកកំលោះអស់សំណើចបែបត្រេកកាម។

"អីចឹង...គ្រប់គ្រងបង"

នាងងក់ក្បាលយល់ព្រមដោយការអឹមអៀន ហើយដោះសម្លៀកបំពាក់ខ្លួនឯងដោយដៃញ័រទទ្រើត បន្ទាប់មកក៏ហើបខ្លួនឲ្យខ្ពស់ និងគ្រប់គ្រងគេបន្តិចម្ដងៗ ទាល់តែបានគ្រប់គ្រងទាំងអស់។



"អ្ហ៎...លីលី..."

ម៉ាទិនេស បិទភ្នែកគ្រហឹម ខណៈនោះក៏អែនត្រគាកមកទទួលយកចង្វាក់នៃការគ្រប់គ្រងរបស់ភរិយាម្ដងហើយម្ដងទៀត។ ការដង្ហោយរកផ្នែករាងកាយបញ្ហាឲ្យគេងើបក្បាលមកហាមាត់លេបផ្លែឈើរី ដែលកំពុងតែយោលយោកនៅចំពោះមុខ។ គេបឺតជញ្ជក់ខ្លាំងៗ ធ្វើឲ្យម្ចាស់វាស្រែកដោយការស្រៀវស្រើបនិងយោកកាន់តែខ្លាំងទៅៗ។

"អ៎ា...អ៎ា...បង ម៉ាត...អ៎ា..."

ឃ្យូលី ខ្ទាំដើមទ្រូងធំទូលាយ ស្រែកហៅឈ្មោះគេម្ដងហើយម្ដងទៀត ហើយនាំគេហោះហើរទៅដល់ឋានសួគ៌នៅក្នុងពេលដ៏ឆាប់រហ័ស។ ម៉ាទិនេសផ្ទុះមិនខុសពីនាង ខ្លួនប្រាណបំភាយចំហាយនៃសេចក្ដីសុខ ដង្ហើមដង្ហក់ខ្លាំងបេះដូងលោតញាប់។ គេទាញរាងតូចស្ដើងជោកដោយញើសមកដេកក្បែរ និងថើបថ្ពាសរបស់នាងដោយក្ដីស្រឡាញ់។

"បងស្រឡាញ់ លីលី...ស្រឡាញ់ខ្លាំងមែនទែន"

នាងក្រមុំមើលគេដោយទឹកភ្នែករលីងរលោង បេះដូងរីកមាឌមិនខុសពីផ្កាលីលីក្រពុំត្រូវប្រោះព្រំដោយទឹកភ្លៀង។

"ហើយហាមឈប់ស្រឡាញ់អូន"

"បងនឹងស្រឡាញ់អូនមួយជីវិត...លីលី សំណព្វចិត្តបង ម៉ាត"

ឃ្យូលី ឱបរឹតគេណែនដៃ។

"អូនក៏ស្រឡាញ់បង ស្រឡាញ់ឡើងឈឺពេញបេះដូងទៅហើយ អរគុណដែលស្រឡាញ់អូន"

"បងសន្យាថានឹងមើលថែជីវិតដ៏ស្រស់ស្អាតរបស់ លីលី ឲ្យល្អបំផុត លីលី ជាទេពធីតារបស់បង"



និយាយហើយ ម៉ាទិនេស ក៏ឱនថើបបបូរមាត់ក្រពុំដែលបង្កើបចាំរបស់ភរិយាម្ដងទៀត ប្រាប់ថាស្រឡាញ់ដោយភាសាកាយដ៏ទន់ភ្លន់។ មិនថាជីវិតនៅថ្ងៃខាងមុខ ត្រូវជួបនឹងអ្វីខ្លះ សុំត្រឹមមាន ឃ្យូលី នៅក្បែរ ប៉ុណ្ណឹងជីវិតរបស់គេក៏មានសេចក្ដីសុខទៅហើយ។

"បងស្រឡាញ់អូន...លីលី"

( ចប់ )

សប្ដាហ៍ក្រោយជួបអ្នកប្រុសទី២ ដែលជាឈុតចុងក្រោយទាំងអស់គ្នាណា!

Scanned with CamScanner